# ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២១

## ៦ខែឆ្នាំនេះ ពលរដ្ឋកម្ពុជាដែលរងគ្រោះបញ្ហាជួញដូរមនុស្ស ជាង២ពាន់នាក់ ត្រូវបានសង្គ្រោះពីបរទេស

http://freshnewsasia.com/ 2021-08-31 02:14pm

**(ភ្នំពេញ)៖** លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) បានថ្លែងថា ៦ខែ ឆ្នាំ២០២១នេះ ពលរដ្ឋកម្ពុជាដែលរងគ្រោះលើបញ្ហាជួញដូរមនុស្ស ចំនួន ២៣១៧នាក់ ត្រូវបានស្ថានតំណាងផ្លូវការកម្ពុជានៅបរទេសជួយសង្គ្រោះ និងត្រូវបញ្ជូនមកមាតុប្រទេសវិញ។ មន្ត្រីជាន់ខ្ពស់ក្រសួងមហាផ្ទៃ ថ្លែងបែបនេះ នៅក្នុងកិច្ចសម្ភាសជាមួយអង្គភាពព័ត៌មាន Fresh News ពាក់ព័ន្ធនឹងវឌ្ឍនភាពនៃកិច្ចខិតខំប្រឹងប្រែង ក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើជួយដូរមនុស្ស របស់រាជរដ្ឋាភិបាលកម្ពុជា។ លោកស្រី ជូ ប៊ុនអេង បានបញ្ជាក់យ៉ាងដូច្នេះថា៖ **«ក្នុងចំណោមមនុស្សរងគ្រោះទាំងអស់នោះ មានស្ត្រី ៩៧២នាក់ ដែលមានមកពី ៨ប្រទេស គឺចិន ម៉ាឡេស៊ី សិង្ហបុរី ថៃ ឥណ្ឌូនេស៊ី វៀតណាម ឡាវ និងឥណ្ឌា។ ក្នុងនោះ មកពីថៃច្រើនជាងគេ ដែលភាគច្រើនពាក់ព័ន្ធទៅនឹងការងារខុសច្បាប់»**។

បើតាមលោកស្រី ជូ ប៊ុនអេង, នៅឆ្នាំ២០២០ វិញ គឺប្រជាពលកម្ពុជារងគ្រោះ ១៩៧៤នាក់ ពាក់ព័ន្ធនឹងការងារខុសច្បាប់ ត្រូវបានស្ថានតំណាងផ្លូវការកម្ពុជានៅបរទេសជួយសង្គ្រោះ និងបញ្ជូនមកមាតុប្រទេសវិញ។មន្ត្រីជំនាញបានបញ្ជាក់ទៀតថា ពាក់ព័ន្ធនឹងការងារបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើកេងប្រវ័ញ្ច គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានចំនួន ១៩៨ករណី កើនឡើង ១៣៥ករណី បើធៀបនឹងរយៈពេលដូចគ្នា នៅឆ្នាំ២០២០ ដែលមានត្រឹមតែ ៦៣ករណី។ លោកស្រី ជូ ប៊ុនអេង បានបន្តថា ក្នុងការបង្ក្រាបទាំង ១៩៨ករណី គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស ឃាត់ខ្លួនជនសង្ស័យបាន ២៩១នាក់ និងសង្គ្រោះជនរងគ្រោះបាន ៧២១នាក់ ក្នុងនោះករណីជួញដូរមនុស្សបែបកម្លាំងពលកម្ម ១៣៩ករណី ដែលឃាត់ខ្លួនបានជនសង្ស័យ ២៣១នាក់ និងការធ្វើអាជីវកម្មផ្លូវភេទ ៥៩ករណី ដែលឃាត់ខ្លួនជនសង្ស័យបាន ៦០នាក់។

លោកស្រីកត់សម្គាល់ថា ករណីជួញដូរមនុស្សបែបកម្លាំងពលកម្ម ទាំង ១៣៩ករណី ភាគច្រើនក៏ជាការនាំចេញដោយខុសច្បាប់សម្រាប់ឆ្លងដែន ដែលមានរហូតដល់ទៅ ១២១ករណី ឃាត់បានជនសង្ស័យ ១៩៨នាក់។ នៅមានប្រភេទនៃការជួញដូរមនុស្ស និងកេងវ័ញ្ច ច្រើនទៀត ប៉ុន្តែចំណុចដែលលើកឡើងនេះ ជាករណីធំៗ និងទូទៅ។ ចំពោះការបង្ក្រាបបានច្រើនបែបនេះ ត្រូវបានលោកស្រី ជូ ប៊ុនអេង ពន្យល់ថា មកពីដៃគូពាក់ព័ន្ធសហការគ្នាបានល្អ។ រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំរបស់សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា ប្តេជ្ញាសហការជាមួយ ដៃគូរពាក់ព័ន្ធទាំងអស់ ទាំងថ្នាក់ប្រទេស និងកម្រិតតំបន់ លុបបំបាត់រាល់ទម្រង់នៃ អំពើជួញដូរមនុស្ស និងអំពើកេងប្រវ័ញ្ច ដើម្បីលើកស្ទួយការគោរពសិទ្ធិ សេចក្តីថ្លៃថ្នូរ និងយុត្តិធម៌សង្គមមនុស្សជាតិ៕

## ក្រសួងការងារ ប្រកាសប្រាប់ពលរដ្ឋឱ្យប្រុងប្រយ័ត្នខ្ពស់ ចំពោះរាល់ការផ្សព្វផ្សាយជ្រើសរើស និងបញ្ជូនពលករខ្មែរទៅធ្វើការនៅប្រទេសអូស្ត្រាលី ដោយទីភ្នាក់ងារជ្រើសរើស ឬអង្គភាពណាមួយ

http://freshnewsasia.com/ 2021-08-30 06:55pm

**(ភ្នំពេញ)៖** ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២១នេះ បានប្រកាសប្រាប់ប្រជាពលរដ្ឋខ្មែរ ឱ្យប្រុងប្រយ័ត្នខ្ពស់ ចំពោះរាល់ការផ្សព្វផ្សាយជ្រើសរើស និងបញ្ជូនពលករខ្មែរទៅធ្វើការនៅប្រទេសអូស្ត្រាលី ដោយទីភ្នាក់ងារជ្រើសរើស ឬអង្គភាពណាមួយ។ ក្រសួងអះអាងថា ថ្មីៗនេះ រដ្ឋាភិបាល អូស្ត្រា

លី បានប្រកាសអំពីការបង្កើតទិដ្ឋាការកសិកម្មអូស្ត្រាលី (Australian Agriculture Visa) ដើម្បីឆ្លើយតបទៅនឹងកង្វះខាតកម្លាំងពលកម្មក្នុងវិស័យកសិកម្មនៅប្រទេសអូស្ត្រាលី។ បច្ចុប្បន្ននេះរដ្ឋាភិបាលអូស្ត្រាលីបាននឹងកំពុងពិភាក្សាទ្វេភាគីអំពីការផ្តល់ទិដ្ឋាការកសិកម្មអូស្ត្រាលី ជាមួយបណ្តាប្រទេសជាដៃគូនានា រួមទាំងកម្ពុជាផងដែរ។

ក្រសួងការងារបានបញ្ជាក់ថា ចាប់ពីឆ្នាំ២០១៧មក ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានទំនាក់ទំនងជាមួយរដ្ឋាភិបាលអូស្ត្រាលី ទាំងកម្រិតរដ្ឋ និង រដ្ឋាភិបាលសហព័ន្ធ ដោយក្រសួងបានផ្ញើជូនរដ្ឋមន្ត្រីក្រសួងមុខរបរ ក្រសួងកិច្ចការនារី និងជារដ្ឋមន្ត្រីទទួលបន្ទុកជួយនាយករដ្ឋមន្ត្រីលើវិស័យសេវាសាធារណៈអូស្ត្រាលី តាមរយៈលិខិតលេខ 029/17M.L.V.T ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៧ ជាពិសេសបានពិភាក្សាការងារនេះជាមួយស្ថានឯកអគ្គរដ្ឋទូតអូស្ត្រាលីប្រចាំកម្ពុជា និងសមាគមកសិកម្ម និងសហគ្រាស ធុនតូចអូស្ត្រាលីជាបន្តបន្ទាប់ផងដែរ។ ក្នុងដំណើរការចរចានេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងស្ថានឯកអគ្គរាជទូតនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំប្រទេសអូស្ត្រាលីផងដែរ។ ដូច្នេះ ក្នុងដំណាក់កាលដែលរដ្ឋាភិបាលអូស្ត្រាលីពុំទាន់សម្រេចថា នឹងផ្តល់ទិដ្ឋាការនេះជូនកម្ពុជានៅឡើយ សូមសាធារណជនមានការប្រុងប្រយ័ត្នខ្ពស់ ចំពោះរាល់ការផ្សព្វផ្សាយអំពីការជ្រើសរើស និងបញ្ជូនពលករខ្មែរទៅធ្វើការនៅប្រទេសអូស្ត្រាលី ដោយទីភ្នាក់ងារជ្រើសរើស ឬអង្គភាពណាមួយ។

ឆ្លៀតឱកាសនេះ ក្រសួងសូមបញ្ជាក់ថា អនុក្រឹត្យលេខ១៩០ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងលើការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេសតាមរយៈទីភ្នាក់ងារជ្រើសរើសឯកជន បានកំណត់ថាពលករសំដៅដល់ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលស្ថិតនៅគ្រប់ដំណាក់កាលទេសន្តរប្រវេសន៍ការងារ ចាប់ពីពេលចុះកិច្ចសន្យាសេវារកការងារឱ្យធ្វើជាមួយទីភ្នាក់ងារជ្រើសរើស រហូតដល់ពេលធ្វើមាតុភូមិនិវត្តន៍។ ទន្ទឹមនឹងនេះ ក៏រាប់បញ្ចូលប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលទៅធ្វើកម្មសិក្សាផង និងធ្វើការងារផងនៅបរទេស ហើយមាន កិច្ចសន្យាត្រឹមត្រូវ ដែលទទួលស្គាល់ដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ជាមួយគ្នានេះ អនុក្រឹត្យក៏បានចែងថា «ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាក្រសួងមានសមត្ថកិច្ចក្នុងការគ្រប់គ្រងលើការបញ្ជូនពលករខ្មែរទៅ ធ្វើការនៅបរទេស ដោយធ្វើកិច្ចសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ»។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នឹងបន្តសហការជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្នុងការចរចាជាមួយរដ្ឋាភិបាលអូស្ត្រាលី ដើម្បីឱ្យមានការទទួលយកពលករទេសន្តរប្រវេសន៍ពីកម្ពុជា ក្រោមទិដ្ឋាការកសិកម្មអូស្ត្រាលី។ ក្រសួងនឹងជម្រាបជូនព័ត៌មានបន្ថែមអំពីលក្ខខណ្ឌ និងនីតិវិធីលម្អិត បន្ទាប់ពីបានពិភាក្សាជាមួយរដ្ឋាភិបាលនៃប្រទេសអូស្ត្រាលីរួចរាល់៕

## មន្ត្រីជំនាញ៖ រយៈពេល៦ខែដើមឆ្នាំនេះ ករណីជួញដូរមនុស្សនៅកម្ពុជាកើនឡើង៣ដង

https://khmer.voanews.com/ 27 សីហា 2021លាស់ លីបលីប

ភ្នំពេញ៖ មន្ត្រីជំនាញ នៃក្រសួងមហាផ្ទៃបានឲ្យដឹងថា ករណីជួញដូរមនុស្សក្នុងរយៈពេល៦ខែ ដើមឆ្នាំ២០២១នេះ បានកើនឡើង៣ដង បើធៀបនឹងរយៈពេលដូចគ្នានៃឆ្នាំ២០២០ ដែលនេះបង្ហាញថា ប្រជាពលរដ្ឋបានចំណាកស្រុកច្រើន ដោយសារជួបប្រទះបញ្ហាសេដ្ឋកិច្ចក្នុងវិបត្តិជំងឺកូវីដ១៩។

អ្នកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានថ្លែងប្រាប់វីអូអេនៅថ្ងៃសុក្រនេះថា ករណីនៃការជួញដូរមនុស្សក្នុងរយៈពេល ៦ខែដើមឆ្នាំ២០២១ កើនឡើង៣ដង ដោយសារតែប្រជាជននៅតែចាញ់បោកល្បិចរបស់មេខ្យល់ក្នុងការបញ្ចុះបញ្ចូលទៅរកការងារធ្វើ ឬរៀបការជាមួយជនបរទេស ដោយខុសច្បាប់ជាដើម។ អ្នកស្រីថ្លែងថា៖ «៦ខែដើមឆ្នាំ គឺករណី

ដែលយើងបង្ក្រាបករណីដែលជួញដូរ គឺមានរហូតដល់ទៅ១៩៣ករណី ហើយបើប្រៀបធៀបទៅឆ្នាំមុនមានតែ៦៨ករណី។ អញ្ចឹងមានន័យថា វាខុសគ្នាឆ្ងាយ គឺវាកើនឡើង៣ដង»។ អ្នកស្រី ជូ ប៊ុនអេង បានបញ្ជាក់ទៀតថា ការចាញ់បោកមេខ្យល់ គឺដោយសារតែប្រជាពលរដ្ឋខ្វះការយល់ដឹង មានបញ្ហាផ្នែកសេដ្ឋកិច្ច ជាមួយនឹងការសម្រេចចិត្តទាំងប្រថុយប្រថានរបស់ពួកគេ។ អ្នកស្រីបន្តថា ដំណាក់កាលនេះ ភាពប្រឈមរបស់ប្រជាពលរដ្ឋ មិនមែនត្រឹមតែចាញ់បោកមេខ្យល់យកទៅលក់ ឬទៅជួញដូរនោះទេ ប៉ុន្តែអាចរងហានិភ័យ ពាក់ព័ន្ធការឆ្លងជំងឺកូវីដ១៩ ជាពិសេសដាក់បន្ទុកបន្ថែមដល់គ្រួសារថែមទៀតផង។ អ្នកស្រីបន្តថា៖ «ប្រជាពលរដ្ឋមួយចំនួនធំ ត្រូវបានប្រជាពលរដ្ឋមួយចំនួន ហៅថាកាត់បន្ថយផ្នែកសេដ្ឋកិច្ចរបស់ពួកគាត់ ធ្វើឲ្យពួកគាត់ហ្នឹង កំពុងគិតថា បើមានឱកាសគាត់នឹងសម្រេចចិត្តថាធ្វើអ្វី។ ដល់ពេលជនជួញដូរមនុស្ស គឺធម្មតា គាត់មានល្បិចកល ហើយគាត់អូសទាញដោយយកការភូតភរពីរឿងផលប្រយោជន៍ ដើម្បីឲ្យអ្នកខ្វះការយល់ដឹងទៅតាម»។ អ្នកស្រីបន្ថែមថា៖ «អញ្ចឹងវាមានភាពប្រឈមធំជាងមុនសម្រាប់ពលករ ឬមួយអ្នកដែលសម្រេចចិត្តចេញទៅ[ចំណាកស្រុក]...បរទេសក្នុងពេលនេះ ដែលហៅថា ជាឱកាសរបស់មេខ្យល់ផង ហើយក៏វាពាក់ព័ន្ធនឹង[ការ]ទទួលវិញនូវផលវិបាក ដែលគាត់ត្រឡប់មកវិញ ទាំងមិនបានការងារ ទាំងនាំយកមេរោគមក ហើយដាក់បន្ទុកបន្ថែមទៅលើគ្រួសារថែមទៀត»។

អ្នកស្រី មាស សាអ៊ីម អនុប្រធានផ្នែកស្ត្រី និងកុមារនៃសមាគមអាដហុក ដែលធ្វើការលើការជួយពលរដ្ឋខ្មែរដែលចាញ់បោកគេនៅបរទេស មានប្រសាសន៍ថារដ្ឋាភិបាលត្រូវតែផ្តល់ការទំនុកបម្រុង និងបង្កើតឱកាសការងារទៅដល់ប្រជាពលរដ្ឋ ដើម្បីអាចឲ្យពលរដ្ឋប្រកបរបរចិញ្ចឹមជីវិតបានសមរម្យ ហើយនេះជាវិធីសាស្ត្រដែលមានប្រសិទ្ធភាពក្នុងការទប់ស្កាត់ និងការបង្ក្រាបការជួញដូរមនុស្ស។ អ្នកស្រីបានថ្លែងថា៖ «ទីមួយ ត្រូវមានការងារសមស្រប ហើយត្រូវមានទីផ្សារការងារ ហើយមានប្រព័ន្ធធារាសាស្ត្រ មានការផ្គត់ផ្គង់ពូជស្រូវ ដើម្បីឲ្យពួកគាត់[ប្រជាពលរដ្ឋ] ឲ្យបានពេញលេញ និងសមស្របទៅនឹងលទ្ធភាព សមត្ថភាពរបស់ពួកគាត់។ ទីពីរទាក់ទងការជួយសង្គ្រោះ ហើយនឹងអន្តរាគមន៍ក្រោយពេលជួយមកវិញហ្នឹង គឺត្រូវមើលថ្លឹងថ្លែងផ្តល់សេវាពេញលេញ ក្នុងនោះដែរមានទាំងសេវាសុខភាពផ្លូវកាយ ផ្លូវចិត្ត ទាំងសេវាផ្នែកច្បាប់ បានន័យថា ស្វែងរកយុត្តិធម៌ ការទាមទារសំណងកុំឲ្យចំណាយរយៈពេលយូរ យឺតយ៉ាវសម្រាប់ពួកគាត់។ អញ្ចឹងនីតិវិធីហ្នឹង ត្រូវពង្រឹង និងពន្លឿនផងដែរ»។

កាលពីថ្ងៃព្រហស្បតិ៍ មន្ត្រីក្រសួងការបរទេសកម្ពុជាបានឲ្យដឹងថា ស្ត្រីខ្មែរចំនួន១២នាក់ ត្រូវបានជួយសង្គ្រោះពីការជួញដូរក្នុងប្រទេសចិន។ អ្នកនាំពាក្យក្រសួងការបរទេសកម្ពុជា លោក កុយ គួង បានបង្ហោះសារនៅក្នុងប្រព័ន្ធតេឡេក្រាម(Telegram) ជាការផ្តល់ដំណឹងដល់អ្នកសារព័ត៌មានថា ស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំទីក្រុងធុងឈីង ប្រទេសចិន បានជូនដំណឹងមកថា ស្ថានអគ្គកុងស៊ុល បានសហការជាមួយអាជ្ញាធរចិន ជួយសង្គ្រោះស្ត្រីខ្មែរចំនួន១២នាក់ ដែលរងគ្រោះដោយការជួញដូរ។ លោកបន្ថែមថា ពួកគេនឹងវិលត្រឡប់ទៅកម្ពុជាវិញ ដែលគ្រោងមកដល់នៅថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០២១ វេលាម៉ោង៣:៣០នាទីល្ងាច តាមជើងយន្តហោះ។ ទោះជាយ៉ាងណាលោក កុយ គួង មិនបានបញ្ជាក់ថា ស្ត្រីខ្មែរទាំង១២នាក់នោះ រងគ្រោះ ដោយការជួញដូរប្រភេទណានោះទេ។ លោក កុយ គួង ប្រាប់វីអូអេនៅថ្ងៃសុក្រនេះថា លោកមិនទាន់មានព័ត៌មានលម្អិតអំពីស្ត្រីទាំង១២នាក់នោះទេ។ ប៉ុន្តែលោកបញ្ជាក់ថា រយៈពេល៦ខែដើមឆ្នាំ២០២១នេះ គឺចាប់ពីខែមករាដល់ខែមិថុនា ស្ត្រីខ្មែរដែលត្រូវបានជួយសង្គ្រោះពីប្រទេសចិនសរុបចំនួន២៣០នាក់។

កាលពីឆ្នាំ២០១៩ ប្រទេសកម្ពុជាបានកត់ត្រាថា ស្ត្រីខ្មែរ១១១នាក់ បានវិលត្រឡប់ពីប្រទេសចិនមកកម្ពុជាវិញ ដោយពួកគេអះអាងថា ត្រូវបានបង្ខំឲ្យរៀបការជាមួយជនជាតិចិន។ របាយការណ៍របស់ទីភ្នាក់ងារអង្គការសហប្រជាជាតិឈ្មោះ UN-ACT ដែលផ្សាយកាលពីឆ្នាំ ២០១៦ បានលើកឡើងថា ស្ត្រីខ្មែរទៅប្រទេសចិនដោយសារចាញ់បោកមេខ្យល់ ដែលសន្យាបោកប្រាស់ថា ពួកគេនឹងទទួលបានការងារមានប្រាក់ខែច្រើន។ របាយការណ៍បន្ត

ថា ស្ត្រីខ្មែរមួយចំនួនក៏បានយល់ព្រមរៀបការ ប៉ុន្តែពួកគេត្រូវបានប្រាប់ព័ត៌មានខុសដោយថា ពួកគេនឹងមានជីវភាពល្អពេលរៀបការជាមួយស្វាមីចិន ប៉ុន្តែការពិត ពួកគេបានធ្លាក់ជាជនរងគ្រោះវិញ ដោយរៀបការជាមួយបុរសជនជាតិចិន ដែលក្រីក្រនៅតាមជនបទ។ របាយការណ៍ឲ្យដឹងទៀតថា បុរសជនជាតិចិនបានឲ្យប្រាក់ទៅមេខ្យល់ពី១ម៉ឺន ទៅ២ ម៉ឺនដុល្លារ ដើម្បីឲ្យទាក់ទងស្ត្រីខ្មែររៀបការជាមួយខ្លួន។

កាលពីចុងខែមិថុនា ក្រសួងការបរទេសសហរដ្ឋអាមេរិក បានចេញរបាយការណ៍ស្តីពីការជួញដូរមនុស្ស ដោយបានបង្ហាញថា ប្រទេសកម្ពុជាស្ថិតនៅក្នុងលំដាប់ថ្នាក់ទីពីរក្នុងបញ្ជីប្រឆាំងការជួញដូរមនុស្សសម្រាប់ឆ្នាំ២០១៧ ដែលមិនមានអ្វីប្រែប្រួលប្រសើរជាងឆ្នាំមុននោះទេ។ របាយការណ៍នោះបានឲ្យដឹងថា កម្ពុជាបានបន្តស្ថិតនៅក្នុងលំដាប់ថ្នាក់ទីពីរក្រោមការឃ្លាំមើល ដោយសារតែរដ្ឋាភិបាលកម្ពុជាមិនបានបំពេញតាមនិយាមអប្បបរិមាក្នុងការលុបបំបាត់ការជួញដូរមនុស្សទេ ដូចជាការមិនស៊ើបអង្កេត ឬយកមកកាត់ទោសក្រុមមន្ត្រីដែលពាក់ព័ន្ធនឹងបទល្មើសជាដើម។ របាយការណ៍របស់ក្រសួងការបរទេសអាមេរិកស្តីពីការប្រឆាំងការជួញដូរមនុស្ស បានផ្តល់អនុសាសន៍មួយចំនួនដល់រដ្ឋាភិបាលកម្ពុជាក្នុងការជួយជនរងគ្រោះ ក៏ដូចជាបង្កើនសេវាដែលមានស្រាប់សម្រាប់ជួយជនរងគ្រោះដែលជាបុរស។ អនុសាសន៍សំខាន់ៗនោះរួមមាន អាជ្ញាធរកម្ពុជាត្រូវតែកាត់ទោសជនដែលប្រព្រឹត្តបទល្មើសទាំងឡាយពាក់ព័ន្ធការជួញដូរមនុស្ស ហើយផ្តល់អំណាចដល់ការប្រើប្រាស់បច្ចេកទេសស៊ើបអង្កេតដោយសម្ងាត់ក្នុងការអនុវត្តន៍ច្បាប់ប្រឆាំងការជួញដូរ និងការបង្កើតនីតិវិធីជាប្រព័ន្ធ ហើយបែងចែកធនធាន ដើម្បីជួយពលរដ្ឋកម្ពុជារងគ្រោះ តាមបេសកកម្មការទូតនៅបរទេស និងក្នុងប្រទេសទាំងឡាយណា ដែលមិនមានតំណាងការទូតកម្ពុជានៅទីនោះ៕

## លោក សិទ្ធិ ឡោះ : កម្លាំងនគរបាល ទាំងអស់ត្រូវពង្រឹងកិច្ចការពារសន្តិសុខសង្គម និង ទប់ស្កាត់បទល្មើសឆ្លងដែន ខុសច្បាប់

https://dap-news.com/ BySS107 Posted on August 30, 2021

បន្ទាយមានជ័យ : នៅព្រឹកថ្ងៃទី ៣០ ខែសីហាឆ្នាំ ២០២១ នេះនៅ ស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ បានបើកកិច្ចប្រជុំបូកសរុបលទ្ធផលការងាររយៈពេល ៨ ខែ ឆ្នាំ២០២១ និងដាក់ចេញនូវផែនការយុទ្ធសាស្ត្រទិសដៅបន្ត ក្រោមអធិបតីភាព លោកឧត្តមសេនីយ៍ទោ សិទ្ធិ ឡោះ ស្នងការ នៃស្នងការដ្ឋាននគរបាលខេត្ត និងមានការចូលរួមពី លោក លោកស្រី ឧត្តមសេនីយ៍ វរៈសេនីយ៍ ស្នងការរង លោកអធិការក្រុង ស្រុក ទាំង ៩ និងលោកមេបញ្ជាការវរៈសេនាតូចនគរបាលការពារព្រំដែនគោក ទាំង ៤ វរៈ ៩១១-៨៩១- ៨០៧- ៨១៥ ផងដែរ ។

ថ្លែងក្នុងឱកាសនោះ លោកឧត្តមសេនីយ៍ទោសិទ្ធិ ឡោះ មានប្រសាសន៍បូកសរុប និងវាយតម្លៃលទ្ធផលការងាររយៈពេល ៨ ខែកន្លងមក ក៏បានលើកសរសើរដល់គ្រប់អង្គភាពទាំងអស់ដែលបានខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្តដើម្បីបំពេញការងាររបស់ខ្លួនបានជោគជ័យ ជាបន្តបន្ទាប់។ ចំពោះកិច្ចការមួយចំនួនដែលបំពេញហើយតែមិនទាន់បានល្អនិងមិនទាន់ពេលវេលា លោកក៏បានផ្តល់អនុសាសន៍កែតម្រូវ ចែករំលែកបទពិសោធន៍ដើម្បីស្តាបនាផងដែរ។ លោកឧត្តមសេនីយ៍ទោ សិទ្ធិ ឡោះ ក៏បានដាក់ចេញនូវផែនការយុទ្ធសាស្ត្រទិសដៅបន្តកម្លាំងនគរបាលគ្រប់ផ្នែកពាក់ព័ន្ធទាំងអស់ត្រូវពង្រឹងនិងអនុវត្ត តួនាទី ភារកិច្ច របស់ខ្លួនឲ្យបានល្អ។ ពិសេសគឺ១-ត្រូវពង្រឹងការងារភូមិឃុំមានសុវត្ថិភាព ២-ទប់ស្កាត់បទល្មើសឆ្លងដែនខុសច្បាប់ ៣-ទប់ស្កាត់បទល្មើសជួញដូរផ្លូវភេទលើស្ត្រីនិងកុមារ ៤-បង្ក្រាបរាល់ល្មើសជួញដូរគ្រឿងញៀន ៥-បង្ក្រាបរាល់ក្មេងទំនើងនឹងក្រុមម៉ូតូស៊ីម៉ាំងប្រែន ៦-ទប់ស្កាត់ការធ្វើបដិវត្តន៍និងការប្រឆាំងរបស់ក្រុមឧទ្ទាមក្រៅច្បាប់ ៧-ត្រូវធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរជូនពលរដ្ឋឲ្យបានទាន់ពេលវេលា ៨-ត្រូវគ្រប់គ្រងអោយបានរាល់ចំណូលស្រុក និងចំណាកស្រុក តាមមូលដ្ឋានដើម្បីទប់ស្កាត់ការរីករាលតត្បាតនៃជំងឺកូវីដ១៩៕

# នារីខ្មែរវ័យ២៦ឆ្នាំម្នាក់ ត្រូវមេខ្យល់ឆបោកយកទៅលក់នៅចិន បានអាជ្ញាធរកម្ពុជា ជួយសង្គ្រោះបានវិញ

https://kbn.news/ August 31, 2021

**រាជធានីភ្នំពេញ ៖** កាលពីថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២១ គណនីហ្វេសប៊ុកឈ្មោះ Bros Bee បានសរសេរសារផ្ញើចូលក្នុងគេហទំព័រហ្វេសប៊ុករបស់សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដោយមានខ្លឹមសារថា ″ ថ្ងៃនេះក្មួយមានទុក្ខជាទម្ងន់ បងស្រីក្មួយគេយកទៅធ្វើការនៅប្រទេសចិន សូមសម្តេចជួយផង ឥឡូវបងស្រីរបស់ខ្ញុំគាត់រត់ចូលប៉ុស្តិ៍ប៉ូលីសហើយ ខ្ញុំរស់នៅភូមិអង្គញ ឃុំសំរោង ស្រុកសូទ្រនិគម ខេត្តសៀមរាប។ បងស្រីរបស់ខ្ញុំឈ្មោះ អ៊ិត ឈូក ត្រូវបានគេយកទៅធ្វើការនៅប្រទេសចិន ប៉ុន្តែឥឡូវត្រូវបានគេយកទៅលក់វិញ សូមសម្តេច មេត្តាជួយបងស្រីខ្ញុំផង ឥឡូវថ្ងៃទី១០ ខែសីហា នេះ បងស្រីរបស់ខ្ញុំត្រូវបានរត់ចូលប៉ុស្តិ៍ប៉ូលិសហើយ សូមសម្តេចក្រឡាហោម ស ខេង ជួយបងស្រីខ្ញុំផង ពួកខ្ញុំជាកូនកំព្រាអត់មានម្តាយឪពុកទេ គាត់បានស្លាប់អស់ហើយ សូមសម្តេចជួយកូនផង ឥឡូវខ្ញុំបារម្ភ ខ្ញុំអត់ដឹងធ្វើម៉េចទេ បងស្រីរបស់ខ្ញុំត្រូវគេដកយកអីវ៉ាន់អស់ហើយ ខ្ញុំទាក់ទងបងស្រីអត់បានទេ សូមសម្តេចជួយផង! ″ ។

ក្រោយពីទទួលបានសារខាងលើ ក្រុមការងាររបស់សម្តេចក្រឡាហោម ស ខេង ដកស្រង់ធ្វើចំណាត់ការដាក់ជូនអគ្គស្នងការដ្ឋាននគរបាលជាតិ ដើម្បីធ្វើការស្រាវជ្រាវ និងអន្តរាគមន៍ដោះស្រាយ។ ដោយមានការឯកភាពពីឯកឧត្តម ឧត្តមសេនីយ៍ឯក ឆាយ គឹមខឿន អគ្គស្នងការរងនគរបាលជាតិ ក្រុមការងារប្រតិកម្មរហ័សអគ្គស្នងការដ្ឋាននគរបាលជាតិ បានធ្វើចំណាត់ការបញ្ជូនករណីនេះទៅនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ដើម្បីជាសមត្ថកិច្ច។ ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២១ ឯកឧត្តម ឧត្តមសេនីយ៍ឯក ជីវ ផល្លី ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានបញ្ជាក់ឲ្យដឹងថា បន្ទាប់ពីទទួលបានព័ត៌មាននេះ មន្ត្រីជំនាញនាយកដ្ឋានបានធ្វើការស្រាវជ្រាវ ស៊ើបអង្កេតអង្គហេតុ និងរកឃើញទីតាំង(Location) គឺស្ថិតនៅចំណុច 9VWJ+XR ស្រុកសុងស៊ីខោនទី ក្រុងណាភីង ខេត្តហ្វូជៀន ប្រទេសចិន ដែលជនរងគ្រោះស្នាក់នៅ និងបានផ្ញើទីតាំងនេះទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដើម្បីបញ្ជូនទៅស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំប្រទេសចិន សហការជាមួយអាជ្ញាធរចិន ដើម្បីជួយអន្តរាគមន៍ និងសង្គ្រោះជនរងគ្រោះ។

ជាលទ្ធផល ស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំទីក្រុងក្វាងចូវ សហការជាមួយអាជ្ញាធរចិន បានជួយសង្គ្រោះជនរងគ្រោះឈ្មោះ អ៊ិត ឈូក ភេទស្រី កើតនៅថ្ងៃទី២ ខែកក្កដា ឆ្នាំ១៩៩១ ជនជាតិខ្មែរ ទីកន្លែងកំណើតភូមិត្រពាំងរំដេង ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ ។ ស្ថានអគ្គកុងស៊ុលបានស្នើសុំចេញលិខិតធ្វើដំណើរបណ្តោះអាសន្នពីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដើម្បីអនុញ្ញាតឱ្យជនរងគ្រោះបានត្រឡប់មកកម្ពុជាវិញ។

ឯកឧត្តម ឧត្តមសេនីយ៍ឯក ជីវ ផល្លី បានបញ្ជាក់បន្ថែមថា ជាទិសដៅ នាយកដ្ឋាននឹងបន្តសហការជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដើម្បីសម្របសម្រួលឱ្យជនរងគ្រោះត្រឡប់មកកម្ពុជាវិញ ហើយនៅពេលមកដល់កម្ពុជាត្រូវអនុវត្តវិធានការរបស់ក្រសួងសុខាភិបាល ធ្វើចត្តាឡីស័ក ហើយបន្ទាប់ពីអនុវត្តវិធានរួច ជំនាញនាយកដ្ឋាននឹងបន្តសម្ភាសន៍ជនរងគ្រោះដើម្បីស្វែងរកព័ត៌មានបន្ថែមទៀត និងមានចំណាត់ការបន្ត។ ក្នុងនាម ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការនគរបាលជាតិ ឯកឧត្តម ឧត្តមសេនីយ៍ឯក ជីវ ផល្លី ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំនៅទីក្រុងក្វាងចូវ ក៏ដូចជាអាជ្ញាធរចិន ដែលតែងតែសហការឆ្លើយតបគ្រប់សំណូមពររបស់អគ្គស្នងការដ្ឋាននគរបាលជាតិ ៕

## ក្រសួងការងារ កំពុងចរចា ជាមួយអូស្ត្រាលី ឲ្យទទួលយក ពលករទេសន្តរប្រវេសន៍ ពីកម្ពុជា

https://www.kampucheathmey.com/ ថ្ងៃអង្គារ ៣១ សីហា ២០២១ដោយ sopheak khoun

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នឹងសហការ ជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ធ្វើការចរចាជាមួយរដ្ឋាភិបាលអូស្ត្រាលី ដើម្បីឲ្យទទួលយកពលករទេសន្តរប្រវេសន៍ពីកម្ពុជា ក្រោមទិដ្ឋាការកសិកម្មអូស្ត្រាលី។ ក្រសួងនឹងផ្តល់ជូនព័ត៌មានបន្ថែម អំពីលក្ខខណ្ឌ និងនីតិវិធីលម្អិត បន្ទាប់ពីបានពិភាក្សាជាមួយរដ្ឋាភិបាល នៃប្រទេសអូស្ត្រាលីរួចរាល់។

លោកបណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានមានប្រសាសន៍ថា ស្ថិតក្នុងដំណាក់កាល កំពុងចរចានេះ ប្រជាពលរដ្ឋត្រូវ ប្រុងប្រយ័ត្នខ្ពស់ ចំពោះរាល់ការផ្សព្វផ្សាយជ្រើសរើស និងបញ្ជូនពលករខ្មែរ ទៅធ្វើការនៅប្រទេសអូស្ត្រាលី ដោយទីភ្នាក់ងារជ្រើសរើស ឬអង្គភាពណាមួយ ពីព្រោះរដ្ឋាភិបាលអូស្ត្រាលី ពុំទាន់សម្រេចថា នឹងផ្តល់ទិដ្ឋាការ កសិកម្មអូស្ត្រាលីជូនកម្ពុជា នៅឡើយទេ។ តាមរយៈសេចក្តីជូនដំណឹងរបស់ក្រសួងការងារ លោករដ្ឋមន្ត្រីបានបន្តថា ថ្មីៗនេះ រដ្ឋាភិបាលអូស្ត្រាលី បានប្រកាស អំពីការបង្កើតទិដ្ឋាការកសិកម្មអូស្ត្រាលី ដើម្បីឆ្លើយតបទៅនឹង កង្វះខាតកម្លាំងពលកម្ម ក្នុងវិស័យកសិកម្ម នៅប្រទេសអូស្ត្រាលី។ បច្ចុប្បន្ននេះ រដ្ឋាភិបាលអូស្ត្រាលី បាននឹងកំពុង ពិភាក្សាទ្វេភាគី អំពីការផ្តល់ទិដ្ឋាការ កសិកម្មអូស្ត្រាលី ជាមួយបណ្តាប្រទេស ជាដៃគូនានា រួមទាំងកម្ពុជាផងដែរ។ លោករដ្ឋមន្ត្រី បានបន្តទៀតថា ចាប់ពីឆ្នាំ២០១៧មក ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានទំនាក់ទំនង ជាមួយរដ្ឋាភិបាលអូស្ត្រាលី ទាំងកម្រិតរដ្ឋ និងរដ្ឋាភិបាលសហព័ន្ធ ដោយក្រសួងបានផ្ញើជូន រដ្ឋមន្ត្រីក្រសួងមុខរបរ ក្រសួងកិច្ចការនាវី និងជារដ្ឋមន្ត្រី ទទួលបន្ទុក ជួយនាយករដ្ឋមន្ត្រីលើវិស័យ សេវាសាធារណៈអូស្ត្រាលី តាមរយៈលិខិតចុះថ្ងៃទី៩ ខែមករា ឆ្នាំ២០១៧ ជាពិសេសបានពិភាក្សាការងារនេះ ជាមួយស្ថានឯកអគ្គរដ្ឋទូត អូស្ត្រាលីប្រចាំកម្ពុជា និងសមាគមកសិកម្ម និងសហគ្រាស ធុនតូចអូស្ត្រាលីជាបន្តបន្ទាប់ផងដែរ។

លោក រដ្ឋមន្ត្រីបានបន្ថែមថា «ដូច្នេះ ក្នុងដំណាក់កាល ដែលរដ្ឋាភិបាលអូស្ត្រាលី ពុំទាន់សម្រេចថា នឹងផ្តល់ទិដ្ឋាការនេះ ជូនកម្ពុជានៅឡើយ សូមសាធារណជន មានការប្រុងប្រយ័ត្នខ្ពស់ ចំពោះរាល់ការផ្សព្វផ្សាយ អំពីការជ្រើសរើស និងបញ្ជូនពលករខ្មែរ ទៅធ្វើការនៅប្រទេសអូស្ត្រាលី ដោយទីភ្នាក់ងារជ្រើសរើស ឬអង្គភាពណាមួយ»។ គួរបញ្ជាក់ថា យោងតាមអនុក្រឹត្យលេខ១៩០ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១១ ស្តីពី ការគ្រប់គ្រងលើការបញ្ជូនពលករខ្មែរ ទៅធ្វើការនៅបរទេស តាមរយៈទីភ្នាក់ងារ ជ្រើសរើសឯកជន បានកំណត់ថា ពលករសំដៅ ដល់ប្រជាពលរដ្ឋខ្មែរ ទាំងពីរភេទ ដែលស្ថិតនៅគ្រប់ដំណាក់កាល ទេសន្តរប្រវេសន៍ការងារ ចាប់ពីពេលចុះកិច្ចសន្យាសេវា រកការងារឲ្យធ្វើ ជាមួយទីភ្នាក់ងារជ្រើសរើស រហូតដល់ពេលធ្វើមាតុភូមិនិវត្តន៍។ ទន្ទឹមនឹងនេះ ក៏រាប់បញ្ចូលប្រជាពលរដ្ឋខ្មែរ ទាំងពីរភេទ ដែលទៅធ្វើកម្មសិក្សាផង និងធ្វើការងារផងនៅបរទេស ហើយមានកិច្ចសន្យាត្រឹមត្រូវ ដែលទទួលស្គាល់ ដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ជាមួយគ្នានេះ អនុក្រឹត្យ ក៏បានចែងថា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាក្រសួងមានសមត្ថកិច្ច ក្នុងការគ្រប់គ្រង លើការបញ្ជូនពលករខ្មែរទៅ ធ្វើការនៅបរទេស ដោយធ្វើកិច្ចសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ៕ អត្ថបទ៖ សំអឿន

## កម្លាំងនគរបាល សហការជាមួយកម្លាំងយោធា ទទួលប្រជាពលរដ្ឋកម្ពុជា ពីយោធាប្រទេសថៃ

http://cambodiapolice.com/policekh/ 9:22 am 30 សីហា 2021

ខេត្តបាត់ដំបង ៖ ដោយអនុវត្តតាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំ ស្តីពីការ ការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យ

ពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញ ចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា_ថៃ លោកវរសេនីយ៍ឯក ពៅ ថារ៉ុធ ស្នងការរងទទួលការងារវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ នៅថ្ងៃអាទិត្យ ៦រោច ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី ២៩ ខែសីហា ឆ្នាំ២០២១ កម្លាំងនគរបាលប៉ុស្តិ៍ព្រំដែនចក្រីនៃវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ ដឹកនាំដោយលោកអនុសេនីយ៍ឯក ស៊ិម-កុសល (នាយរងប៉ុស្តិ៍)សហការជាមួយកម្លាំងយោធាកងអនុសេនាធំទី២,វរសេនាតូចលេខ១ ដឹកនាំដោយលោកវរសេនីយ៍ត្រី ណាន- វន្នី(មេបញ្ជាការកងអនុសេនាធំ) បានចេញទៅទទួលប្រជាពលរដ្ឋ ចំនួន០២នាក់,ស្រី០១នាក់ ក្នុងនោះក្មេងប្រុស០ ១នាក់ ពីយោធាថៃកងអនុសេនាធំលេខ១១១៣,វរសេនាធំលេខ១៣ ត្រង់ចំណុចនិយាមកា 0213666- 1482174 ភូមិសាស្រ្ត ភូមិខៅធង់យែប ឃុំខ្លូងហាត ស្រុកខ្លូងហាត ខេត្តស្រះកែវ ទល់មុខប៉ុស្តិ៍ព្រំដែនចក្រីភូមិសាស្រ្ត ភូមិកោះតូច ឃុំសំពៅលូន ស្រុកសំពៅលូន ខេត្តបាត់ដំបង។ ក្រោយពីសាកសួរ កត់ឈ្មោះរួចកម្លាំងយើងបានប្រគល់បងប្អូនជូនក្រុមគ្រូពេទ្យដើម្បីបញ្ជូនទៅកាន់មណ្ឌលចត្តាឡីស័កអនុវិទ្យាល័យកូនភ្នំ៣២ ពិនិត្យសុខភាពនិងធ្វើតេស្តរហ័សនៅទីនោះ ។

## កម្លាំងវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧សហការទទួលពលករខ្មែរត្រឡប់មកពីថៃចំនួន៣នាក់ បញ្ជូនទៅមណ្ឌលចត្តាឡីស័កអនុវិទ្យាល័យកូនភ្នំ៣២

http://cambodiapolice.com/policekh/ 9:10 am 28 សីហា 2021

ខេត្តបាត់ដំបង ៖ ដោយអនុវត្តតាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំ ស្តីពីការ ការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញ ចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ លោកវរសេនីយ៍ឯក ពៅ ថារ៉ុធ ស្នងការរងទទួលការងារវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ នៅថ្ងៃសុក្រ ៤ រោច ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី ២៧ ខែសីហា ឆ្នាំ២០២១ កម្លាំងនគរបាលប៉ុស្តិ៍ព្រំដែនចក្រីនៃវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ ដឹកនាំដោយលោកអនុសេនីយ៍ឯក ស៊ឹម កុសល នាយរងប៉ុស្តិ៍ សហការជាមួយកម្លាំងយោធាកងអនុសេនាធំទី២, វរសេនាតូចលេខ១ ដឹកនាំដោយលោកវរសេនីយ៍ត្រី ណាន វន្នី មេបញ្ជាការកងអនុសេនាធំ បានទៅទទួលប្រជាពលរដ្ឋវិលត្រឡប់មកពីប្រទេសថៃ មកកម្ពុជាវិញចំនួន០៣នាក់,ស្រី០១នាក់ ក្នុងនោះក្មេងប្រុស០១នាក់ ពីយោធាថៃកងអនុសេនាធំលេខ១១១៣ នៃកងវរសេនាធំលេខ១៣ ត្រង់ចំណុចនិយាមកា0213666-1482174 ភូមិសាស្រ្ត ភូមិខៅធង់យែប ឃុំខ្លូងហាត ស្រុកខ្លូងហាត ខេត្តស្រះកែវ ទល់មុខប៉ុស្តិ៍ព្រំដែនចក្រីភូមិសាស្រ្ត ភូមិកោះតូច ឃុំសំពៅលូន ស្រុកសំពៅលូន ខេត្តបាត់ដំបង ។ ក្រោយពីសាកសួរ កត់ឈ្មោះរួច កម្លាំងយើងបានប្រគល់ជូនក្រុមគ្រូពេទ្យ បន្ទាប់មកក្រុមគ្រូពេទ្យបានបញ្ជូនទៅកាន់

# ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២១

## លោកជំទាវ ជូ ប៊ុនអេង បញ្ជាក់ថា ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើកេងប្រវ័ញ្ច បានច្រើន ដោយសារដៃគូពាក់ព័ន្ធសហការល្អ

https://cen.com.kh/ Posted ByPen Srey NeatSeptember 1, 2021

ភ្នំពេញ៖មន្ត្រីជាន់ខ្ពស់ក្រសួងមហាផ្ទៃទទួលបន្ទុកកិច្ចការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ) បានថ្លែងឲ្យដឹង នាថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២១ ថា ក្នុងចំណោមមនុស្សរងគ្រោះខកខ្លួន ឬចាញ់បោកមេខ្យល់នាំទៅក្រៅប្រទេស ក្នុងចំនួន ២៣១៧នាក់ មានស្ត្រី ៩៧២នាក់ មកពី ៨ប្រទេស គឺចិន ម៉ាឡេស៊ី សិង្ហបុរី ថៃ ឥណ្ឌូនេស៊ី វៀតណាម ឡាវ និងឥណ្ឌា, ក្នុងនោះ មកពីថៃច្រើនជាងគេ ដែលភាគច្រើនពាក់ព័ន្ធទៅនឹងការងារខុសច្បាប់ ហើយត្រូវបានស្ថានទូតកម្ពុជា នៅបណ្តាប្រទេសទាំងនោះជួយសង្គ្រោះពួកគេទាន់ពេលវេលា។

លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង នឹងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) បានឲ្យដឹងបែបនេះ ខណៈផ្តល់បទសម្ភាសន៍ ដល់ក្រុមអ្នកសារព័ត៌មាន នាថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២១ ពាក់ព័ន្ធនឹងវឌ្ឍនភាពនៃកិច្ចខិតខំប្រឹងប្រែង ក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើជួយដូរមនុស្ស របស់រាជរដ្ឋាភិបាលកម្ពុជា, ដោយលោកជំទាវ បានបញ្ជាក់ថា ក្នុងរយៈពេល ៦ខែ ឆ្នាំ២០២១ នេះ ពលរដ្ឋកម្ពុជា ដែលរងគ្រោះដោយសារការជួញដូរមនុស្ស ចំនួន ២៣១៧នាក់ ត្រូវបានស្ថានតំណាងផ្លូវការកម្ពុជា នៅបរទេសជួយសង្គ្រោះ និងសម្រួលដល់ការបញ្ជូនពួកគេមកកាន់មាតុប្រទេសវិញ។លោកជំទាវ ជូ ប៊ុនអេង បានបង្ហាញថា កាលពីឆ្នាំ២០២០ឯណោះវិញ គឺប្រជាពលកម្ពុជា រងគ្រោះ ១៥៧៤នាក់ ពាក់ព័ន្ធនឹងការងារខុសច្បាប់ ត្រូវបានស្ថានតំណាងផ្លូវការកម្ពុជានៅបរទេសជួយសង្គ្រោះ និងបញ្ជូនមកមាតុប្រទេសវិញ។ ពាក់ព័ន្ធនឹងការងារបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើកេងប្រវ័ញ្ចនេះទៀតសោត គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បង្ក្រាបបានចំនួន ១៩៨ករណី កើនឡើង ១៣៥ករណី បើធៀបនឹងរយៈពេលដូចគ្នា នៅឆ្នាំ២០១៩ ដែលមានត្រឹមតែ ៦៣ករណី។

ក្នុងការបង្ក្រាបទាំង ១៩៨ករណី គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស ឃាត់ខ្លួនជនសង្ស័យបាន ២៩១នាក់ និងសង្គ្រោះជនរងគ្រោះបាន ៧២១នាក់ ក្នុងនោះ ករណីជួញដូរមនុស្សបែបកម្លាំងពលកម្ម ១៣៩ករណី ឃាត់ខ្លួនបានជនសង្ស័យ ២៣១នាក់ និងការធ្វើអាជីវកម្មផ្លូវភេទ ៥៩ករណី ឃាត់ខ្លួនជនសង្ស័យបាន ៦០នាក់។ ការបង្ក្រាបបានច្រើនបែបនេះ គឺមកពីដៃគូពាក់ព័ន្ធសហការគ្នាបានល្អ, ហើយថា រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំរបស់សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជា ប្តេជ្ញាសហការជាមួយ ដៃគូពាក់ព័ន្ធទាំងអស់ ទាំងថ្នាក់ប្រទេស និងកម្រិតតំបន់ ធ្វើយ៉ាងណាលុបបំបាត់រាល់ទម្រង់នៃ អំពើជួញដូរមនុស្ស និងអំពើកេងប្រវ័ញ្ចឲ្យធ្លាក់នៅកម្រិតទាបបំផុតដើម្បីសុខដុមរមនាក្នុហសង្គម៕ រក្សាសិទ្ធិដោយ ៖ ពិសិដ្ឋ CEN

## ថៃសន្យាផ្តល់ភាពស្របច្បាប់ និងចាក់វ៉ាក់សាំងកូវីដ-១៩ ឲ្យពលករក្រោយការដាក់ញត្តិទៅក្រសួងការងារ»

https://www.rfa.org/khmer/news/ ដោយ មួង ណារ៉េត2021-08-31

តំណាងពលករអះអាងថា ក្រសួងការងារថៃបានសន្យាយល់ព្រមផ្តល់ភាពស្របច្បាប់ និងចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ (Covid-19) ឲ្យពលករទាំងអស់។ ការលើកឡើងនេះ ក្រោយពេលដែលក្រុមពលករខ្មែរជាង ៥០នាក់ បាននាំគ្នាដាក់ញត្តិទៅក្រសួងការងារ កាលពីថ្ងៃទី៣០ ខែសីហា។ អ្នកឃ្លាំមើលសិទ្ធិពលកររំពឹងថាក្រោយ

ការចាក់វ៉ាក់សាំងរួច ពលករនឹងឆាប់ទទួលបានការងារធ្វើវិញ។ ស្ថានភាពពលករធ្វើការនៅប្រទេសថៃនៅតែមិនទាន់មានភាពប្រសើរដោយភាគច្រើនមិនទទួលបានអត្ថប្រយោជន៍ពីក្រសួងការងារថៃ និងមិនទាន់បានចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ នៅឡើយទេ។

ប្រធានមូលនិធិពលករខ្មែរប្រចាំនៅប្រទេសថៃលោក ស៊ុន សីហា ឲ្យដឹងនៅថ្ងៃទី៣១ ខែសីហាថា តំណាងពលករប្រហែល ៥០នាក់បានជួបជុំគ្នា នៅថ្ងៃទី៣០ ខែសីហា និងបានយកញត្តិដាក់ជូនក្រសួងការងារថៃ ដើម្បីសុំឲ្យមានការគិតគូរដល់ពលករកំពុងជួបទុក្ខលំបាកក្នុងការដ្ឋានសំណង់ និងនៅតាមបន្ទប់ជួល។ លោកបន្តថា ក្រុមពលករបានថ្លែងសារពីទុក្ខកង្វល់ជាច្រើននៅមុខក្រសួងការងារថៃ ពិសេសគឺការទាមទារឲ្យអាជ្ញាធរថៃកុំរើសអើងពលករ និងត្រូវផ្ដល់សេវាសុខាភិបាលឲ្យបានស្មើភាពគ្នា ដោយមិនត្រូវទុកពលករខ្មែរដែលឆ្លងជំងឺកូវីដ-១៩ ចោលនោះទេ។ ប៉ូលិសថៃមិនបានរារាំង មិនបង្កភាពរញ៉េរញ៉ៃ រុញច្រាន រំខាន ឬធ្វើទុក្ខបុកម្នេញដល់ការដាក់ញត្តិរបស់ពលករឡើយ។ ក្រោយពីបានថ្លែងសារចប់រួចរាល់ ក្រុមពលករបានដាក់ញត្តិទៅក្រសួងការងារថៃ ហើយអាជ្ញាធរថៃក៏បានហៅតំណាងពលករចូលជួប និងសន្យាអន្តរាគមន៍ជួយពលករឲ្យអស់ពីលទ្ធភាព៖ «ស្នើឲ្យពិនិត្យមើលទៅលើការដ្ឋានសំណង់មួយចំនួន ដែលពួកគាត់ស្នាក់នៅមិនសមសម្រាប់មនុស្សនៅហើយអនាម័យហ្នឹងវាអត់ល្អ។ មុជទឹកអាងនៅកណ្ដាលវាលរួមគ្នា មួយរយ ឬពីរយនាក់រួមគ្នាអ៊ីចឹងទៅ ហើយការប្រើបង្គន់ហ្នឹង គឺបង្គន់សង់ពីបាំងស័ង្កសីដែលគ្មានអនាម័យ ហើយបង្គន់បី បួន ប្រាំ ប្រើមនុស្សបី បួនរយនាក់ ហើយគ្មានអនាម័យ ដែលងាយស្រួលឆ្លងជំងឺកូវីដ១៩ ទៅដល់ពលករយើង»។

លោក ស៊ុន សីហា បន្ថែមទៀតថា បន្ទាប់ពីទទួលបានការសន្យានេះហើយ ពលករមានភាពកក់ក្ដៅជាងមុន និងខិតខំបន្តទ្រាំរស់នៅរង់ចាំធ្វើការបន្តទៀត នៅក្នុងប្រទេសថៃ។ ទោះជាយ៉ាងណា តំណាងពលកររូបនេះឲ្យដឹងថា ពួកគាត់គ្មានបំណងដាក់ញត្តិទៅស្ថានទូតខ្មែរប្រចាំនៅប្រទេសថៃទេ ដោយសារមិនមានភាពជឿជាក់ថា មន្ត្រីនៃស្ថានទូតអាចជួយពលករបាន។ កាលពីចុងខែមិថុនា ក្រុមមូលនិធិពលករខ្មែរធ្លាប់បានដាក់ញត្តិទៅរដ្ឋសភាថៃ និងគណៈរដ្ឋមន្ត្រីថៃម្ដងហើយ ដើម្បីស្នើសុំឲ្យមានដំណោះស្រាយជុំវិញបញ្ហាប្រឈមនៃវិបត្តិជំងឺកូវីដ-១៩។ កាលនោះក្រុមពលករបានស្នើសុំឲ្យរដ្ឋាភិបាលថៃ យកចិត្តទុកដាក់ជួយផ្គត់ផ្គង់ម្ហូបអាហារ និងសេវាព្យាបាលជំងឺកូវីដ១៩ ដល់ពលករឲ្យបានសមរម្យ។

ជុំវិញបញ្ហានេះ វិទ្យុអាស៊ីសេរីមិនអាចសុំការបញ្ជាក់ពីឯកអគ្គរាជទូតកម្ពុជាប្រចាំនៅប្រទេសថៃលោក អ៊ូក សោភ័ណ្ឌ និងអ្នកនាំពាក្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិលោក កុយ គួង បានទេ នៅថ្ងៃទី៣១ ខែសីហា។ តែយ៉ាងណាលោក កុយ គួង បានប្រាប់សារព័ត៌មានវីអូឌី (VOD) ថា មន្ត្រីស្ថានទូតតែងតែយកអំណោយចែកឲ្យពលករកំពុងជួបការលំបាកទីទ័លខ្លាំង និងទាក់ទងទៅអាជ្ញាធរមូលដ្ឋានរបស់ថៃ ដើម្បីស្នើសុំឲ្យយកចិត្តទុកដាក់ជួយដោះស្រាយបញ្ហានានារបស់ពលករ។

អ្នកឃ្លាំមើលសិទ្ធិពលករទទួលស្គាល់ថា ស្ថានទូតខ្មែរ និងអាជ្ញាធរថៃ បានយកចិត្តទុកដាក់ខ្លះដល់ពលករខ្មែរមែន នៅមួយរយៈពេលចុងក្រោយនេះ តែនៅតិចតួច និងមិនទាន់គ្រប់គ្រាន់តម្រូវការជាមូលដ្ឋានរបស់ពលករនៅឡើយ។ មន្ត្រីសិទ្ធិការងារនៃមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារនិងសិទ្ធិមនុស្ស (Central) ប្រចាំប្រទេសថៃលោក លឹង សុផុន លើកទឹកចិត្តឲ្យមន្ត្រីស្ថានទូតខ្មែរ ធ្វើសកម្មភាពជួយពលករឲ្យបានច្រើនជាងនេះ និងជួយឧបត្ថម្ភស្បៀងអាហារឲ្យបានច្រើនបន្តិច ដើម្បីលើកទឹកចិត្តដល់ពលករខ្មែរ ដែលកុំឲ្យធ្វើដំណើរទាំងប្រថុយវិលត្រឡប់ទៅកម្ពុជាវិញ។ លោកយល់ថា ប្រសិនបើមន្ត្រីស្ថានទូតខ្មែរមានភាពសកម្មខ្លាំង ដោយចែកអំណោយដល់ពលករ និងរកវ៉ាក់សាំងចាក់ឲ្យពលករតាំងពីដំបូង នោះពលករនឹងមិនសម្រុកទៅស្រុកវិញច្រើនទេ ហើយបញ្ហាប្រឈមរបស់ពលករក៏សូវធ្ងន់ធ្ងរខ្លាំងដូចបច្ចុប្បន្នដែរ៖ «ខ្ញុំគិតថា បងប្អូនពលករខ្មែរ ប្រហែលជាមិនត្រឡប់ទៅខ្មែរច្រើនអ៊ីចឹងទេ

បើសិនជាគាត់ (ស្ថានទូត) មានវិធានការណាមួយដើម្បីទប់ស្កាត់រឿងហ្នឹង។ កន្លងមកបងប្អូន ដែលឆ្លងកូវីដហើយ ដែលគាត់មិនដឹងថា គាត់ជាពីកូវីដហើយ គាត់ទៅចាក់វ៉ាក់សាំងនៅកន្លែងណា ឬមួយគាត់ ដែលកំពុងតែឆ្លងកូវីដហ្នឹងមិនដឹងទៅព្យាបាលនៅកន្លែងណា គឺគាត់តែងតែព្រួយបារម្ភ។ គាត់តែងតែសង្ឃឹមថា ត្រឡប់ទៅខ្មែរហើយ បានចាក់វ៉ាក់សាំង»។

របាយការណ៍របស់អគ្គនាយកដ្ឋានអន្តោប្រវេសន្តបង្ហាញថា គិតចាប់ពីខែធ្នូ ឆ្នាំ២០២០ ដល់ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២១ មានពលករ បានវិលត្រឡប់ពីប្រទេសថៃ ជាងបួនម៉ឺន (៤៤.០០០) នាក់ ចូលមកកម្ពុជា។ រយៈពេលប៉ុន្មានថ្ងៃចុងក្រោយនេះ ចំនួនអ្នកឆ្លងជំងឺកូវីដ១៩ នៅប្រទេសថៃបានថយចុះ ពីជាង ២ម៉ឺន (២០.០០០) នាក់ ក្នុងមួយថ្ងៃមកនៅជាង ១ម៉ឺន ៤៣ាន់ (១៤.០០០) នាក់។ ទោះយ៉ាងណាក្តី រដ្ឋាភិបាលថៃនៅតែបន្តវិធានការទប់ស្កាត់ការឆ្លងជំងឺកូវីដ១៩ ដដែល ប៉ុន្តែបានបន្ធូរបន្ថយវិធានការតឹងរ៉ឹងនៅតំបន់មួយចំនួន ដោយបើកឱ្យមនុស្សអាចធ្វើដំណើរឆ្លងខេត្តបាន ចាប់ពីថ្ងៃទី១ ខែកញ្ញាតទៅ៕

## ស្ថានឯកអគ្គរាជទូតកម្ពុជា អំពាវនាវឱ្យពលរដ្ឋប្រុងប្រយ័ត្នចំពោះការជ្រើសរើសពលករខ្មែរទៅធ្វើការនៅអូស្ត្រាលី

https://www.postkhmer.com/ ម៉ុំ គន្ធា | Publication date 01 September 2021 | 17:57 ICT

**ភ្នំពេញៈ** ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំអូស្ត្រាលី បានអំពាវនាវឱ្យពលរដ្ឋខ្មែរប្រុងប្រយ័ត្នចំពោះរាល់ការផ្សព្វផ្សាយពីការជ្រើសរើស និងការបញ្ជូនពលករខ្មែរមកធ្វើការនៅអូស្ត្រាលីដោយទីភ្នាក់ងារជ្រើសរើស បុគ្គល ឬអង្គភាពណាមួយ ដោយសាររដ្ឋាភិបាលអូស្ត្រាលីមិនទាន់ជ្រើសរើសពលករខ្មែរមកធ្វើការនៅទីនោះក្រោមគម្រោងទិដ្ឋាការ "កសិកម្ម" ថ្មីនៅឡើយទេ។

ការអំពាវនាវនេះធ្វើឡើងតាមរយៈសេចក្តីជូនដំណឹងរបស់ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំអូស្ត្រាលីនៅថ្ងៃទី១ ខែកញ្ញានេះ បន្ទាប់ពីមានសារព័ត៌មាន បណ្តាញសង្គម ក្រុមហ៊ុនឯកជន និងបុគ្គលមួយចំនួន បានដើរបំផុសបំផុលផ្តល់ពត៌មានពុំច្បាស់លាស់ ឬបំភ្លៃការពិតក្នុងចេតនាបោកប្រាស់ជ្រើសរើសពលករខ្មែរមកធ្វើការនៅប្រទេសអូស្ត្រាលី(Australia)ក្រោមគម្រោងទិដ្ឋាការ"កសិកម្ម"ថ្មី(Australian Agriculture Visa)របស់ប្រទេសអូស្ត្រាលី។ ស្ថានទូតបានបញ្ជាក់ថា បច្ចុប្បន្នរដ្ឋាភិបាលអូស្ត្រាលី (ក្រសួងការបរទេស មហាផ្ទៃ និងក្រសួងកសិកម្មអូស្ត្រាលី) កំពុងពិភាក្សានៅឡើយលើការរៀបចំគម្រោងទិដ្ឋាការកសិកម្មថ្មី ជាមួយនឹងការកំណត់លក្ខខណ្ឌផ្សេងៗក្នុងការទទួលបានទិដ្ឋាការនេះ។ ប្រភពដដែលបានបន្តថា គម្រោងទិដ្ឋាការកសិកម្មថ្មីនេះនឹងផ្តល់ឱកាសដល់ពលរដ្ឋប្រទេសមួយចំនួននៅក្នុងតំបន់អាស៊ីអាចមកធ្វើការនៅប្រទេសអូស្ត្រាលីលើវិស័យកសិកម្ម រួមទាំងឧស្សាហកម្មកែច្នៃសាច់ផងដែរ (Agriculture sector including meat processing) ជាមួយនឹងការផ្តល់ឱកាសអាចស្នើសុំសិទ្ធិរស់នៅអចិន្ត្រៃយ៍ក្នុងករណីពលករនោះបំពេញបានតាមលក្ខខណ្ឌនិងមានតម្រូវការជាក់ស្តែងពីរដ្ឋាភិបាលអូស្ត្រាលី។

ស្ថានទូតកម្ពុជាប្រចាំអូស្ត្រាលីបានបន្ថែមថាៈ «តាមគម្រោងទិដ្ឋាការថ្មីនេះនឹងពិភាក្សាចប់សព្វគ្រប់នៅចុងខែកញ្ញា ឆ្នាំ ២០២១ ខាងមុខ។ជាមួយគ្នានេះរដ្ឋាភិបាលអូស្ត្រាលីនឹងពិភាក្សាចរចាទ្វេភាគីជាមួយប្រទេសដៃគូមួយចំនួនក្នុងតំបន់លើគម្រោងទិដ្ឋាការថ្មី»។ ក្រោមគោលការណ៍របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការស្វែងរកទីផ្សារការងារជូនពលករខ្មែរកន្លងមក ស្ថានទូតបានខិតខំស្វះស្វែងរកទីផ្សារការងារជូនបងប្អូនខ្មែរទាំងនៅប្រទេសអូស្ត្រាលី ក៏ដូចជា ប្រទេសនូវែលសេឡង់ តាមរយៈការជួបពិភាក្សាជាមួយថ្នាក់ដឹកនាំរបស់រដ្ឋាភិបាល ប្រទេសនីមួយៗជាបន្តបន្ទាប់។ ស្ថានទូតដដែលនេះ បានបន្ថែមថា ចំពោះគម្រោងទិដ្ឋាការកសិកម្មថ្មីនេះក្រោមការណែនាំដ៏ខ្ពង់ខ្ពស់ពីថ្នាក់ដឹកនាំក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងកិច្ចសហការគាំទ្រពីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈកម្ពុជា ស្ថានទូតបានត្រៀមខ្លួនជាស្រេចក្នុងការបន្តជួបចរចារកទីផ្សារការងារជូនពលរដ្ឋខ្មែរជាមួយរដ្ឋាភិបា

លអូស្ត្រាលី។ ស្ថានទូតសូមបញ្ជាក់ជាថ្មីថា «មកទល់ពេលនេះគម្រោងទិដ្ឋាការកសិកម្មនេះកំពុងស្ថិតក្នុងដំណាក់កាលរៀបចំនៅឡើយ ហើយរដ្ឋាភិបាលអូស្ត្រាលីនៅពុំទាន់សម្រេចថានឹងផ្តល់ទិដ្ឋាការប្រភេទនេះជូនកម្ពុជា ឬប្រទេសណាមួយនៅឡើយទេ។ ហេតុនេះស្ថានទូតស្នើបងប្អូនប្រុងប្រយ័ត្នខ្ពស់ចំពោះរាល់ការផ្សព្វផ្សាយព័ត៌មានពីការជ្រើសរើសនិងការបញ្ជូនពលករខ្មែរមកធ្វើការនៅប្រទេសអូស្ត្រាលី ដោយទីភ្នាក់ងារជ្រើសរើស បុគ្គល ឬអង្គភាពណាមួយ»។ ព័ត៌មានផ្លូវការជុំវិញវឌ្ឍនភាពគម្រោងទិដ្ឋាការកសិកម្មថ្មីនេះអាចតាមដានលើគេហទំព័រផ្លូវការរបស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិកម្ពុជា ស្ថានទូតកម្ពុជាប្រចាំប្រទេសអូស្ត្រាលី (https:// www.embassyofcambodia.ogr.au) ឬក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈកម្ពុជា៕

## ពលរដ្ឋ២នាក់ត្រូវអាជ្ញាធរថៃដោះលែងឱ្យមានសេរីភាពឡើងវិញ

https://kohsantepheapdaily.com.kh/ ឧត្តរមានជ័យ០១ ខែ កញ្ញា ឆ្នាំ ២០២១ ម៉ោង ០៩:៤០

ខេត្តឧត្តរមានជ័យ ៖ ប្រជាពលរដ្ឋចំនួន២នាក់ ត្រូវបានក្រុមអាជ្ញាធរថៃដោះលែងឱ្យមានសេរីភាពឡើងវិញកាលពីថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២១ និងនាំយកមកប្រគល់ឱ្យក្រុមអាជ្ញាធរកម្ពុជា តាមច្រកទ្វារអន្តរជាតិជាំ ស្ថិតក្នុងភូមិជាំ ឃុំត្រពាំងប្រីយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ ពលរដ្ឋទាំង២នាក់ដែលត្រូវអាជ្ញាធរថៃដោះលែងឱ្យមានសេរីភាពខាងលើ ក្នុងនោះម្នាក់ឈ្មោះប៊ុន រ៉ា ភេទប្រុស អាយុ៣៨ឆ្នាំ រស់នៅភូមិអូរស្វាយ ឃុំអូរស្វាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ត្រូវទាហានថៃចាប់ខ្លួនកាលពីថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៧ ពីបទឆ្លងដែនកាប់ឈើគ្រញូងខុសច្បាប់ចូលតាមច្រកអូស្វាយ និងម្នាក់ទៀតឈ្មោះរ៉ន ដើម ភេទប្រុស អាយុ៥៧ឆ្នាំ រស់នៅភូមិស្រែជ្រៅ ឃុំល្វើក ស្រុកឈូក ខេត្តកំពត ត្រូវទាហានចាប់ខ្លួនកាលពីថ្ងៃទី១៦ ខែកម្ភៈ ឆ្នាំ២០១៨ ពីបទឆ្លងដែនកាប់ឈើក្រញូងខុសច្បាប់ ចូលតាមច្រកទឹកជប់ ។ អ្នកទាំង២បានជាប់ពន្ធនាគារនៅស្រុកខាន់ថាឡាក់ ខេត្តស៊ីសាកេត ប្រទេសថៃ ។

ក្រុមការងារកម្ពុជាបម្រើការងារនៅច្រកជាំបានឱ្យដឹងថា បន្ទាប់ពីបានទទួលប្រជាពលរដ្ឋខ្មែរ២នាក់ពីក្រុមអាជ្ញាធរថៃសមត្ថកិច្ចបានធ្វើការណែនាំនិងធ្វើកិច្ចសន្យាបញ្ឈប់ឆ្លងដែនខុសច្បាប់បន្តទៀត ខណៈនេះប្រគល់ទៅឱ្យលោកគ្រូពេទ្យផ្នែកចត្តាឡីស័កប្រចាំច្រកអន្តរជាតិជាំធ្វើតេស្តយកសំណាក ជាលទ្ធផលរកឃើញ អវិជ្ជមាន និងបញ្ជូនទៅធ្វើចត្តាឡីស័កនៅសាលាបឋមសិក្សាទួលថ្មី ៕

## អ្នកនាំពាក្យការបរទេស៖ កម្ពុជាបន្តសម្រួលបញ្ជូនពលរដ្ឋខ្មែរនៅថៃ ១៤នាក់ ត្រឡប់មកមាតុប្រទេសវិញ

http://freshnewsasia.com/ 2021-09-01 04:02pm

**(ភ្នំពេញ)៖** ស្ថានអគ្គកុងស៊ុលកម្ពុជានៅខេត្តស្រះកែវ ប្រទេសថៃ នៅថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២១នេះ បានបន្តសហការជាមួយអាជ្ញាធរថៃ ជួយសម្រួលបញ្ជូនពលរដ្ឋខ្មែរចំនួន ១២នាក់ និងកុមារ ២នាក់ទៀត ត្រឡប់មកកម្ពុជាវិញ ដោយសុវត្ថិភាព តាមច្រកអន្តរជាតិខ្លងលឹក-ប៉ោយប៉ែត។ លោក កុយ គួង អ្នកនាំពាក្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានបន្តថា ប្រជាពលរដ្ឋទាំង ១២នាក់ ត្រូវបានប្រគល់ជូនសមត្ថកិច្ចកម្ពុជាចាត់ការតាមនិតិវិធីសុខាភិបាលបន្ត៕

## មេខ្យល់នាំមនុស្សឆ្លងដែនប៉ុនប៉ងចូលទៅប្រទេសថៃ ដោយខុសច្បាប់ចំនួន០១នាក់ត្រូវបានឃាត់ខ្លួនអនុវត្តតាមច្បាប់

http://cambodiapolice.com/policekh/ 11:56 am 1 កញ្ញា 2021

**បាត់ដំបង៖** កម្លាំងអធិការដ្ឋាននគរបាលស្រុកកំរៀង បានធ្វើការស្រាវជ្រាវបង្ក្រាបមុខសញ្ញានាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែនទៅប្រទេសថៃ ១លើក ឃាត់ខ្លួនមេខ្យល់១នាក់ និងទប់ស្កាត់ពលរដ្ឋបំរុងឆ្លងដែនខុសច្បាប់ចំនួន ០៦នាក់ ស្រី ០៣នាក់ ត្រង់ចំនុចក្រុមទី៦ ភូមិអូរដាលើ ឃុំបឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបង នៅថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២១ វេលាម៉ោង១១និង៣០នាទី។

លោកវរសេនីយ៍ទោ វេ គឹមចត់ អធិការនគរបាលស្រុកកំរៀង បានអោយដឹងថា ដោយអនុវត្តតាមយោបល់ដឹកនាំរបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនៃស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង លើការងារបង្ក្រាបមេខ្យល់និងទប់ស្កាត់ពលករឆ្លងដែនខុសច្បាប់ កម្លាំងអធិការដ្ឋាននគរបាលស្រុកកំរៀង សហការណ៍ជាមួយកម្លាំងនគរបាលវរសេនាតូចការពារព្រំដែនគោកលេខ៨១៩ ដែលមានលោកវរសេនីយ៍ឯក ម៉ង់ ស៊ី ជាមេបញ្ជាការបានធ្វើការបង្ក្រាបករណីនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែនបានមួយករណីក្នុងបទល្មើសជាក់ស្តែង។ ក្នុងនោះបានឃាត់ខ្លួនជនសង្ស័យបានចំនួន០១នាក់ ដោយមានប្រជាពលរដ្ឋដែលសន្និដ្ឋានថាជាពលករនិងកូនចៅរបស់គាត់ជាជនរងគ្រោះក្នុងអំពើនាំចេញនេះចំនួន ០៦នាក់ ស្រីចំនួន០១៣នាក់ អនីតិជនចំនួន ០១នាក់ ស្រី០១នាក់។ មេខ្យល់មានឈ្មោះ ធឿង សូវៀត ហៅ ហ៊ុប ភេទប្រុស អាយុ ៣២ឆ្នាំ មុខរបរ កម្មករ ស្នាក់នៅភូមិអូរដាលើ ឃុំបឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបង។ ឆ្លងតាមការស្តាប់ចម្លើយរបស់ឈ្មោះ ធឿង សូវៀត ហៅ ហ៊ុប មានបានសារភាពថា ខ្លួនបាននាំពលករទាំង០៦នាក់ខាងលើលួចឆ្លងដែនចេញទៅប្រទេសថៃដោយស៊ីឈ្នួលឲ្យឈ្មោះ លីន ភេទស្រី រស់នៅក្នុងផ្សារថៃ (បានឡែម) ប្រទេសថៃ មិនដែលបានជួបមុខគ្នាដោយយកថ្លៃឈ្នួលក្នុងម្នាក់ចំនួន ១០ម៉ឺនរៀល ហើយកន្លងមកខ្លួនក៏បានធ្លាប់នាំពលករលួចឆ្លងដែនចេញទៅថៃឲ្យឈ្មោះ លីន ភេទស្រី ចំនួន២លើកមកហើយ។ នាពេលនេះ ជនសង្ស័យជាមេខ្យល់ខាងលើត្រូវបានសមត្ថកិច្ចនគរបាលស្រុកកសាងសំណុំរឿងបញ្ជូនមកការិយាល័យជំនាញអនុវត្តតាមច្បាប់ រីឯប្រជាពលរដ្ឋរងគ្រោះបានអប់រំណែនាំឱ្យវិលទៅលំនៅដ្ឋានវិញ៕ មណ្ឌលចត្តាឡីស័កអនុវិទ្យាល័យកូនភ្នំ៣២ ដើម្បីពិនិត្យសុខភាពនិងធ្វើតេស្តរហ័សនៅទីនោះ ៕

# ថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០២១

## ពលករខ្មែរ ធ្វើដំណើរចូលមកស្រុក តាមច្រកព្រំដែនអន្តរជាតិអូរស្មាច់ ថយចុះ

https://kohsantepheapdaily.com.kh/ ឧត្តរមានជ័យ០២ ខែ កញ្ញា ឆ្នាំ ២០២១ ម៉ោង ០០:៣៣

ខេត្តឧត្តរមានជ័យ៖ ពលករខ្មែរ ដែលធ្វើចំណាកស្រុក ទៅរកការងារធ្វើ នៅក្នុងប្រទេសថៃ វិលត្រឡប់មកស្រុកកំណើត ចូលតាមច្រកព្រំដែនអន្តរជាតិអូរស្មាច់ ស្ថិតក្នុងភូមិអូរស្មាច់ សង្កាត់អូរស្មាច់ ក្រុងសំរោង បានថយចុះជាងសព្វដង។

លោក សមុទ្រ សុនី គ្រូពេទ្យផ្នែកធ្វើចត្តាឡីស័ក ប្រចាំច្រកទ្វារអន្តរជាតិអូរស្មាច់ បានឱ្យដឹងថា ពលករខ្មែរដែលធ្វើដំណើរចូលតាមច្រកទ្វារអន្តរជាតិអូរស្មាច់ កន្លងទៅ មិនក្រោមពី ៤០០នាក់ ទៅ ៥០០នាក់នោះទេ ខណៈនោះ គ្រូពេទ្យចត្តាឡីស័ក យកសំណាកពិនិត្យរកឃើញមេរោគ COVID ១៩ ជាង ១០០នាក់ តែក្នុងរយៈពេលក្នុងមួយអាទិត្យនេះ ពលករចូលតាមច្រកនេះ មានត្រឹមតែ ៩០ ទៅ ១០០នាក់ ហើយយកសំណាក រកឃើញ COVID19 ចាប់ពី ៨ ទៅ ១០នាក់ផងដែរ។

លោក ប៉ែន កុសល្យ អភិបាលខេត្តឧត្តរមានជ័យ បានដឹកនាំក្រុមការងារចុះសាកសួរសុខទុក្ខពលករខ្មែរ និងបានណែនាំដល់ពលករ បើពលករយើងមិនទាន់បានចាក់វ៉ាក់សាំងទេ គឺក្រុមអាជ្ញាធរកំណត់ចាក់វ៉ាក់សាំង ប្រភេទ ចនសុន ជាថ្នាំវ៉ាក់សាំងកូវីដ១៩ ផលិតនៅប្រទេសអាមេរិក។ ដោយឡែក ពលករណា ដែលគ្រូពេទ្យ ពិនិត្យរកឃើញមានវិជ្ជមាន COVID19 ត្រូវសម្រាកព្យាបាលនៅក្នុងមណ្ឌលព្យាបាលជា ទើបវិលទៅស្រុកកំណើតវិញ ជៀសវាងឆ្លងដល់បងប្អូន និងឪពុកម្តាយ៕ ឱម សារឿន

## កម្លាំងវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ ទទួលពលករខ្មែរម្នាក់ពីយោធាថៃ បញ្ជូនទៅមណ្ឌលចត្តាឡីស័កអនុវិទ្យាល័យកូនភ្នំ៣២

http://cambodiapolice.com/policekh/ 6:58 pm 1 កញ្ញា 2021

ខេត្តបាត់ដំបង ៖ នៅថ្ងៃពុធ ៩រោច ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២១ ដោយអនុវត្តតាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំ ស្តីពីការ ការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញ ចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ លោកវរសេនីយ៍ឯក ពៅ ថារុធ ស្នងការរងទទួលការងារវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ បានចាត់កម្លាំងប៉ុស្តិ៍ព្រំដែន សហការជាមួយកម្លាំងយោធា ចេញល្បាតតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ក្នុងភូមិសាស្ត្រប៉ុស្តិ៍គ្រប់គ្រង និងទៅទទួលប្រជាពលរដ្ឋដែលកងអនុសេនាធំលេខ១១១៣(ថៃ)ប្រគល់មកអោយក្នុងភូមិសាស្រ្ត ភូមិខាវធង់ឃែប ឃុំខ្លងហាត ស្រុកខ្លងហាត ខេត្តស្រះកែវ ទល់មុខប៉ុស្តិ៍ព្រំដែនចក្រី ស្ថិតក្នុងភូមិកោះតូច ឃុំសំពៅលូន ស្រុកសំពៅលូន ខេត្តបាត់ដំបង ចំនួន០១នាក់(ស្រី) ។ បន្ទាប់ពីសាកសួរ,កត់ឈ្មោះ និងអប់រំណែនាំរួច កម្លាំងយើងបានប្រគល់បងប្អូនឲ្យទៅក្រុមគ្រូពេទ្យ ដើម្បីទទួលយកទៅកាន់មណ្ឌលចត្តាឡីស័កអនុវិទ្យាល័យកូនភ្នំ៣២ ៕

## ឃាត់ខ្លួនពលករខ្មែរ ៧នាក់ ដែលកំពុងចាកចេញពីផ្សាររុងគ្លឿ ប៉ុនប៉ងលបឆ្លងដែនតាមច្រករបៀងចូលមកកម្ពុជា

https://www.kampucheathmey.com/ ថ្ងៃព្រហស្បតិ៍ ២ កញ្ញា ២០២១ដោយ Sorn Phanith

ពលករខ្មែរចំនួន ៧នាក់ ត្រូវបានកម្លាំងឈុតខ្មៅថៃ សហការជាមួយតម្រួតព្រំដែនលេខ១២ ធ្វើការឃាត់ខ្លួន ខណៈពួកគេកំពុងធ្វើដំណើរឆ្លងផ្លូវ ឆ្ពោះទៅរកខ្សែបន្ទាត់ព្រំដែនថៃ-កម្ពុជា។ ការឃាត់ខ្លួននេះ គឺកាលពីថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២១ វេលាម៉ោង៦និង៣០នាទីល្ងាច ដោយកម្លាំងការពារព្រំដែនថៃ ដែលកំពុងល្បាតតាមខ្សែបន្ទាត់ព្រំដែនត្រង់ចំណុច បានដុងងូ ក្នុងភូមិដុងងូ ឃុំប៉ារ៉ៃ ស្រុកអារញ្ញប្រាថេត ខេត្តស្រះកែវ ខណៈដែលពលករខ្មែរទាំង៧នាក់ កំពុងធ្វើដំណើរឆ្ពោះទៅកាន់ខ្សែបន្ទាត់ព្រំដែន ដែលក្នុងនោះមានប្រុស៤នាក់ ស្រី២នាក់ និងក្មេងប្រុស១នាក់។ នៅពេលកម្លាំងត្រួតពិនិត្យ ដោយបានសាកសួរដោយពួកគេបានសារភាពថា ពួកគេបានមកធ្វើការនៅក្នុងផ្សាររុងគ្លឿលឿយូរហើយ លុះពេលកូវីដផ្ទុះខ្លាំងក៏អស់ការងារធ្វើដោយសារតែផ្សារ ត្រូវបានអាជ្ញាធរថៃបិទជាបណ្តោះអាសន្ន ទើបសម្រេចថានឹងវិលត្រឡប់ទៅប្រទេសខ្លួនវិញ ដោយធ្វើដំណើរតាមច្រករបៀង ដើម្បីឆាប់បានដល់ផ្ទះ ព្រោះមិនចង់ឲ្យអាជ្ញាធរកម្ពុជាឃុំខ្លួន១៤ថ្ងៃ ដើម្បីធ្វើចត្តាឡីស័ក។ បច្ចុប្បន្នពលករខ្មែរទាំង៧នាក់ ត្រូវបានសមត្ថកិច្ចថៃ ពិនិត្យសុខភាពព្រមទាំងបានបញ្ជូនឲ្យទៅសមត្ថកិច្ចកម្ពុជាតាមច្រកអូរបីជាន់ ក្នុងស្រុកគោកខ្យង ដើម្បីធ្វើចត្តាឡីស័កនៅលើទឹកដីកម្ពុជា ៕ **អត្ថបទ៖ សោ និយមរ័ត្ន**

## អគ្គកុងស៊ុលកម្ពុជា សហការជាមួយអង្គការ LPN នាំយកនូវស្បៀងអាហារចែកជូនពលករខ្មែរ៦១គ្រួសារ ដែលកំពុងស្នាក់នៅជិតផ្សាររោងក្លឿ

https://www.kampucheathmey.com/ ថ្ងៃព្រហស្បតិ៍ ២ កញ្ញា ២០២១ដោយ Kang Tola

លោក កុយ គួង រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងកាបរទេស និងសហប្រតិបត្តិការអន្តរជាតិកម្ពុជា បានឲ្យដឹងថា តាមការអំពាវនាវរបស់បងប្អូនពលករខ្មែរ ក្រុមការងាររបស់ស្ថានអគ្គកុងស៊ុល បានសហការជាមួយអង្គការការពារសិទ្ធិពលករ (Labour Protection Network -LPN) នៅថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២១ នេះ បានចុះសួរសុខទុក្ខបងប្អូនពលករខ្មែរចំនួន៦១គ្រួសារ ដែលកំពុងស្នាក់នៅសហគមន៍២០០បន្ទប់ (ស្ថិតនៅតំបន់ជិតផ្សាររោងក្លឿ) ស្រុកអារញ្ញប្រាថេត ខេត្តសាកែវ។ បើតាមលោក កុយ គួង ខណៈពេលចុះសួរសុខទុក្ខបងប្អូនពលករខ្មែរនោះ ក្រុមការងារក៏បាននាំយកនូវស្បៀងអាហារ មានដូចជា អង្ករ ត្រីខកំប៉ុង ពងមាន់ ទឹកត្រី ទឹកស៊ីអ៊ីវ ត្រីប្រឡាក់គ្រៀម មើមផៃថៅ ផ្លែននោង ទឹកដោះគោ ទឹកសុទ្ធ ម៉ាស់ ថ្នាំពេទ្យសំរាប់កុមារ ទឹកអាកុលលាងដៃ និងសម្ភារៈប្រើប្រាស់មួយចំនួនទៀត សម្រាប់ចែកជូនពួកគាត់ ដើម្បីជួយសម្រាលទុក្ខលំបាករបស់ពួកគាត់ ដែលកំពុងទទួលរងផលប៉ះពាល់ដោយសារការរីករាលដាលជំងឺកូវីដ-១៩ផងដែរ។ *ដោយ ៖ កោះកែវ*

## ទូតកម្ពុជាអន្តរាគមន៍ បញ្ជូនពលករខ្មែរនៅថៃ ១៤នាក់ និងកុមារម្នាក់ មកមាតុប្រទេសវិញ

http://www.freshnewsasia.com/ 2021-09-02 05:20pm

**(ភ្នំពេញ)៖** ស្ថានអគ្គកុងស៊ុលប្រចាំខេត្តសាកែវ ប្រទេសថៃ នៅថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២១ បានបន្តអន្តរាគមន៍សហការជាមួយអាជ្ញាធរថៃ សម្របសម្រួលបញ្ជូនពលករខ្មែរចំនួន ១៤នាក់ និងកុមារម្នាក់ទៀត ឲ្យវិលត្រឡប់ទៅកម្ពុជាវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិខ្លងលឹក-ប៉ោយប៉ែត។

លោក កុយ គួង រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានបញ្ជាក់ទៀតថា ស្ថានអគ្គកុងស៊ុលកម្ពុជានៅខេត្តស្រះកែវ ប្រទេសថៃ នៅថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២១ ក៏បានសហការជាមួយអាជ្ញាធរថៃ ជួយសម្រួលបញ្ជូនពលរដ្ឋខ្មែរចំនួន ១២នាក់ និងកុមារ ២នាក់ ត្រឡប់មកកម្ពុជាវិញ ដោយសុវត្ថិភាព តាមច្រកអន្តរជាតិខ្លងលឹក-ប៉ោយប៉ែតផងដែរ។ បើតាមមន្ត្រីជាន់ខ្ពស់ក្រសួងការបរទេស, ប្រជាពលរដ្ឋទាំងអស់ ត្រូវបានប្រគល់ជូនសមត្ថកិច្ចកម្ពុជា ចាត់ការតាមនិតិវិធីសុខាភិបាលបន្ត៕

## កម្ពុជាប្ដេជ្ញាការពារសិទ្ធិ និងប្រយោជន៍ពលករ ក្នុងវិស័យនេសាទនិងកែច្នៃអាហារសមុទ្រក្នុងតំបន់

https://thmeythmey.com/ 02, Sep 2021 , 9:29 pm ដោយ: អ៊ូ សុខមាន (OU Sokmean)

ភ្នំពេញ៖ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានដាក់ឱ្យដំណើរការគម្រោងកម្មវិធីសិទ្ធិពលករនេសាទនៅអាស៊ីអាគ្នេយ៍ ជាមួយស្ថាប័នពាក់ព័ន្ធនៅកម្ពុជា និងឯកភាពតាមផែនការសកម្មភាព។ កម្ពុជាបានតាំងចិត្តខ្ពស់ក្នុងការ ការពារសិទ្ធិ និងប្រយោជន៍ពលករដែលចំណាកស្រុកទៅបរទេសដែលធ្វើការក្នុងវិស័យនេសាទនិងកែច្នៃអាហារសមុទ្រ។ គម្រោងកម្មវិធីសិទ្ធិពលករនេសាទនៅអាស៊ីអាគ្នេយ៍( Ship to Shore Rights South East Asia Programme) ចាប់អនុវត្តពីថ្ងៃទី២កញ្ញា ឆ្នាំ២០២១ រហូតដល់ឆ្នាំ២០២៤។ នេះបើយោងតាមសេចក្តីប្រកាសព័ត៌មានរបស់អង្គការពលកម្មអន្តរជាតិ(ILO) ដោយបានបញ្ជាក់ថា គម្រោងនេះ គឺមានការចូលរួមគ្រប់ភាគីពាក់ព័ន្ធ មកពីតំណាងរាជរដ្ឋាភិបាល និយោជក សហជីព និងអង្គការសង្គមស៊ីវិល បានពិភាក្សាអំពីគម្រោងកម្មវិធីថ្មី ដែលបង្ហាញពីឆន្ទៈរួមគ្នា លើកម្ពស់ការធ្វើទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព និងស្របច្បាប់ ដើម្បីទទួលបានការងារសមរម្យក្នុងវិស័យនេសាទ និងកែច្នៃអាហារសមុទ្រនៅប្រទេសកម្ពុជា និងតំបន់អាស៊ីអាគ្នេយ៍។

រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ លោក ហ៊ូ វុឌ្ឍី បាននិយាយថា គ្រប់ភាគីពាក់ព័ន្ធបានពិនិត្យឡើងវិញអំពីសិទ្ធិពលករនេសាទ ក៏ដូចជាតួនាទីរបស់ភាគីពាក់ព័ន្ធនៅកម្ពុជា ក្នុងការការពារ និងលើកកម្ពស់សិទ្ធិពលករ ក្នុងវិស័យនេសាទ និងកែច្នៃអាហារសមុទ្រ ។ បើតាមលោក វុឌ្ឍី គ្រប់ភាគីពាក់ព័ន្ធ នឹងស្វែងយល់ពីសកម្មភាពនានាជាអាទិភាព សម្រាប់អន្តរាគមន៍រយៈពេលមធ្យមនិងរយៈពេលវែង ដែលស្ថិតក្នុងកិច្ចការពារនិងលើកកម្ពស់សិទ្ធិពលករ ។ ជាពិសេសបង្កើតគណៈកម្មការប្រឹក្សាកម្មវិធីថ្នាក់ជាតិមួយ ដែលមានសមាសភាពគ្រប់គ្រាន់ និងពេញលេញ សម្រាប់ដឹកនាំនិងតម្រង់ទិសការងារនៃកម្មវិធីថ្មីមួយនេះ ឱ្យទទួលបានជោគជ័យតាមការគ្រោងទុក។ គម្រោងនៃកម្មវិធីនេះ គឺស្ថិតនៅក្រោមជំនួយបច្ចេកទេសនៃអង្គការអន្តរជាតិខាងការងារ(ILO) អង្គការទេសន្តរប្រវេសន៍អន្តរជាតិ(IOM), កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) និងជំនួយខាងហិរញ្ញវត្ថុពីសហភាពអឺរ៉ុប(EU)។ នេះបើតាមរដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

លោក ប្រាយអាន ហ្សូណោរី ដែលជាទីប្រឹក្សា និងជាប្រធានកិច្ចសហប្រតិបត្តិការ ប្រតិភូនៃសហភាពអឺរ៉ុបប្រចាំនៅកម្ពុជា បានលើកឡើងថា គម្រោងកម្មវិធីសិទ្ធិពលករនេសាទអាស៊ីអាគ្នេយ៍នេះ នឹងដោះស្រាយបញ្ហាប្រឈមសំខាន់ៗ របស់ពលករទេសន្តរប្រវេសន៍ទាំងបុរសនិងស្ត្រី ដែលត្រូវការគាំពារកាន់តែខ្លាំងថែមទៀត ក្នុងអំឡុងពេលនៃការរីករាលដាលជំងឺកូវីដ-១៩នៅកម្ពុជា និងនៅអាស៊ីអាគ្នេយ៍។ លោក ប្រាយអាន ហ្សូណោរី ដូច្នេះ៖ «ដើម្បីធ្វើឱ្យប្រាកដ ថាមានការធ្វើទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាពនិងស្របច្បាប់ គឺតម្រូវឱ្យមានការសម្របសម្រួលពីថ្នាក់តំបន់ ហេតុដូចនេះ សហភាពអឺរុបនឹងបន្តលើកកម្ពស់ភាពជាដៃគូជាមួយរាជរដ្ឋាភិបាលកម្ពុជា អង្គការសហប្រជាជាតិ និងដៃគូអភិវឌ្ឍពាក់ព័ន្ធ»។

លោក បេនចាមីន ហាកឃីន មន្ត្រីបច្ចេកទេសសម្រាប់កម្មវិធីសិទ្ធិពលករនេសាទនៅអាស៊ីអាគ្នេយ៍ បាននិយាយថា៖ «យើងទទួលស្គាល់ថា ការងារក្នុងវិស័យនេះមានសារៈសំខាន់ សម្រាប់ពលករទេសន្តរប្រវេសន៍ ព្រោះដោយយោងតាមបទពិសោធន៍កន្លងមក ដែលមានការរំលោភសិទ្ធិធ្ងន់ធ្ងរក្នុងអំឡុងពេលជ្រើសរើស និងពេលបំពេញការងារ»។ គម្រោងកម្មវិធីសិទ្ធិពលករអាស៊ីអាគ្នេយ៍ បានចាប់ផ្តើមឆ្លើយតបចំពោះតម្រូវការចាំបាច់របស់ពលករទេសន្តរប្រវេសន៍ តាមរយៈការតាមដានពីឥទ្ធិពលនៃការរាតត្បាតជំងឺកូវីដ-១៩ ចំពោះពលករទេសន្តរប្រវេសន៍កម្ពុជាដែលធ្វើការនៅប្រទេសថៃ។ ជាពិសេសពលករដែលធ្វើការក្នុងវិស័យ នេសាទ និងកែច្នៃអាហារសមុទ្រ។ នេះបើតាមសេចក្តីប្រកាសព័ត៌មានខាងលើដដែល៕

## រដ្ឋាភិបាលកំពុងយកចិត្តទុកដាក់បណ្តុះបណ្តាលជំនាញ និងបង្កើតការងារក្នុងស្រុក ដើម្បីកាត់បន្ថយការធ្វើចំណាកស្រុក ខណៈជំងឺកូវីដនៅតែបន្តឆ្លងទូទាំងពិភពលោក

https://www.postkhmer.com/ ឡាយ សាមាន | Publication date 03 September 2021 | 09:09 ICT

**បន្ទាយមានជ័យៈ** ការជំពាក់បំណុលគេ ការធ្វើស្រែចម្ការមិនសូវបានផល និងទីផ្សារការងារក្នុងស្រុកទទួលបានប្រាក់កម្រៃទាប គឺជាដើមហេតុចម្បង ដែលជាកត្តាជំរុញឱ្យពលរដ្ឋខ្មែរ នៅតែបន្តប្រថុយប្រថាន ធ្វើចំណាកស្រុក ទៅស្វែងរកការងារធ្វើនៅប្រទេសថៃ បើទោះបីជាមានការបិទច្រកព្រំដែនដោយសារតែប្រទេសថៃ កំពុងមានការផ្ទុះឆ្លងរាលដាលជំងឺកូវីដ ១៩ យ៉ាងខ្លាំងយ៉ាងណាក៏ដោយ។

មន្ត្រីជំនាញបានលើកឡើងថា បច្ចុប្បន្នរាជរដ្ឋាភិបាលកំពុងយកចិត្តទុកដាក់បណ្តុះបណ្តាលជំនាញ និងបង្កើតការងារក្នុងស្រុកឱ្យបានកាន់តែច្រើន ប្រយោជន៍ដើម្បីកាត់បន្ថយការធ្វើចំណាកស្រុកដែលប្រឈមនឹងគ្រោះថ្នាក់។ រីឯអាជ្ញាធរនៅខេត្តជាប់ព្រំដែនថៃចាត់ទុកបញ្ហាពលករ ដែលវិលត្រឡប់មកពីប្រទេសថៃ គឺជាបន្ទុកដ៏ធ្ងន់ធ្ងរសម្រាប់រាជរដ្ឋាភិបាល ខណៈដែលពួកគេមួយចំនួនមានឆ្លងជំងឺកូវីដ ១៩ និងប្រមាណជា ១០ ភាគរយទៀត បាក់កម្លាំង ដោយសារតែពួកគេប្រើប្រាស់គ្រឿងញៀន នៅពេលពួកគេធ្វើការនៅក្នុងប្រទេសថៃ។

អ្នកស្រី សើម សើរ នៅស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យដែលបានធ្វើចំណាកស្រុកទៅប្រទេសថៃអស់រយៈពេលប្រមាណ ៥ ឆ្នាំមកហើយ ហើយទើបតែវិលត្រឡប់មកវិញដោយសារតែនៅថៃមានផ្ទុះឆ្លងកូវីដបានថ្លែងថា ទោះដឹងថានៅប្រទេសគេមិនស្រួលដូចនៅស្រុកកំណើត ប៉ុន្តែយ៉ាងហោចណាស់អ្នកស្រីអាចរកប្រាក់បានច្រើន និងសន្សំលុយបានខ្លះ។ អ្នកស្រីថា៖ «ខ្ញុំធ្វើការសំណង់នៅថៃ ៥ ឆ្នាំហើយ ធ្វើការផ្នែកសំណង់ លើកឥដ្ឋ ១ ខែរកបានប្រាក់កម្រៃ ៨ ពាន់បាត បើថែមម៉ោងពីម៉ោង ៦ ល្ងាច ដល់ម៉ោង ១០ យប់ តែបើអត់ថែមម៉ោងបានប្រហែល ៥ ពាន់បាត»។ អ្នកស្រីបានបញ្ជាក់ពីមូលហេតុដែលអ្នកស្រីបានចាកចេញពីស្រុកកំណើតយ៉ាងដូច្នេះថា៖«ខ្ញុំមានដីផ្ទះ និងដីស្រែតិចតួច ខ្ញុំនៅស្រុកធ្វើស្រែអត់បានផលទេ ដោយសារភ្លៀងច្រើនពេកហើយឆ្នាំខ្លះក៏រាំងស្ងួតគ្មានទឹក។ ធ្វើស្រែហូបមិនគ្រប់ទេ រកព្រឹកខ្វះល្ងាច រកល្ងាចខ្វះព្រឹក។ នៅស្រុកខ្ញុំ ប្រជាជនគាត់មានតែធ្វើស្រែ ក្រៅពីធ្វើស្រែរកអីមិនសូវបានទេ»។ កាលពីមុនអ្នកស្រី សើរ បានទៅធ្វើការជាកម្មករសំណង់នៅប្រទេសថៃជាមួយប្តី តែដោយសារប្តីមានជំងឺប្រចាំកាយ ឥឡូវអ្នកស្រីត្រូវទៅធ្វើការនៅថៃតែ ២ នាក់កូនប្រុសអាយុ ២១ ឆ្នាំ។ អ្នកស្រីនិយាយថា បើស្ថានភាពនៅប្រទេសថៃរាងធូរស្រាល អ្នកស្រីនឹងនាំកូនវិលត្រឡប់ទៅថៃវិញហើយ ពីព្រោះនៅស្រុកខ្មែរអត់មានការងារធ្វើ មានតែធ្វើស្រែចម្ការ ហើយមិនសូវបានផលទៀត។ អ្នកស្រីឱ្យដឹងថា ដំបូងឡើយ អ្នកស្រីមិនចេះនិយាយភាសាថៃទេ ប៉ុន្តែក្រោយពីធ្វើការនៅទីនោះមួយរយៈក្រោយមក អ្នកស្រីអាចនិយាយភាសាថៃបានគួរសម។

លោក ឆាយ វីត អាយុ ៣៩ ឆ្នាំ និងប្រពន្ធដែលបានធ្វើការនៅថៃរយៈពេល ៣ ឆ្នាំមកហើយនោះបានថ្លែងថា៖ «ខ្ញុំត្រឡប់មកដល់ខ្មែរវិញបាន ២ ខែហើយនៅពេលកូវីដស្ងប់ស្ងាត់ ហើយបើគេនៅបើកច្រកព្រំដែនធម្មតា ខ្ញុំនឹងត្រឡប់ទៅថៃវិញហើយ។ ខ្ញុំធ្វើការផ្នែកសំណង់ ១ ខែរកបាន ១ ម៉ឺនបាត ថ្លៃទឹក ភ្លើងថៅកែចេញ តែថ្លៃជួលផ្ទះយើងចេញ»។ ប្រពន្ធលោក វីត ក៏ធ្វើការសំណង់ជាមួយគ្នាផងដែរ ប៉ុន្តែ ១ ខែគាត់រកបានប្រាក់តែ ៦ ពាន់បាតទេ ដោយសារតែគាត់ជាអ្នកលើកឥដ្ឋ។ លោក វីត ថ្លែងថា៖ «ខ្ញុំនៅខេត្តបន្ទាយមានជ័យ ខ្ញុំនៅស្រុកអត់មានស្រែ អត់មានចម្ការធ្វើទេ។ អ៊ីចឹងនៅស្រុករកលុយមិនសូវបាន ដោយសារខ្ញុំអត់ដែលទៅធ្វើការនៅស្រុកគេ អ៊ីចឹងចង់ទៅធ្វើនៅប្រទេសគេ ព្រោះនៅស្រុកយើងអត់មានការងារធ្វើដដែល»។ លោករៀបរាប់បញ្ហាប្រឈមមួយចំនួន អំឡុងពេលធ្វើការនៅប្រទេសថៃ ពោលគឺបើប៉ះចំថៅកែចិត្តល្អមិនអីទេ តែបើប៉ះចំថៅកែចិត្តអាក្រក់ ពេលខ្លះអត់បើកលុយឱ្យក៏មានដែរ។ លោក វីត ដែលមានកូនម្នាក់ទុកឱ្យម្តាយជួយមើលថែបានថ្លែងថា៖ «ពេលប្រពន្ធឆ្លងទន្លេ គាត់មកសម្រាលនៅស្រុក ពេលសម្រាលហើយ ទុកកូនឱ្យយាយមើលថែ ហើយខ្ញុំធ្វើការនៅថៃផ្ញើលុយមកបណ្តើរ។ បើនៅថៃធ្វើការសល់ប្រាក់ហើយមានលទ្ធភាពសង់ផ្ទះនៅស្រុកបាន។ បើមានលទ្ធភាព ខ្ញុំឈប់ទៅធ្វើនៅថៃហើយ ព្រោះធ្វើការនៅថៃក៏ពិបាកដែរ តែចេះតែទ្រាំទៅ»។

លោក សេក សុខុម ប្រធានមន្ទីរព័ត៌មានខេត្តបន្ទាយមានជ័យបានថ្លែងថា ជាទូទៅការរកការងារធ្វើ គឺគេទៅនៅកន្លែងណាដែលមានប្រាក់កម្រៃបានខ្ពស់មិនថាពលករខ្មែរ មីយ៉ាន់ម៉ា ឬពលករប្រទេសណានោះទេ។ លោកថា៖ «និយាយជារួមប្រទេសថៃ គេកំពុងអភិវឌ្ឍ គ្រប់ការដ្ឋាន សំណង់ រោងចក្រដំណើរការល្អអ៊ីចឹងតម្លៃពលកម្មបើនៅខ្មែរ ១ ថ្ងៃគាត់រកបានពី ៣ ម៉ឺនរៀល ទៅ ៤ ម៉ឺនរៀល ប៉ុន្តែគេទៅថៃអាចលក់កម្លាំងពលកម្មបានពី ៥ ម៉ឺនទៅ ៨ ម៉ឺនរៀល ក្នុង ១ ថ្ងៃ»។ សម្រាប់នៅខេត្តបន្ទាយមានជ័យ ពលរដ្ឋប្រកបរបរកសិកម្ម និងចម្ការតិចតួច ខណៈពលរដ្ឋជាង ៨០ ភាគរយជាកសិករ។ ប៉ុន្តែពលរដ្ឋមួយចំនួនបានលក់ដី លក់ស្រែ លក់ស្រូវ ហើយធ្វើចំណាកស្រុកទៅប្រទេសថៃ។ លោក សុខុម ថា៖ «សម្រាប់ខេត្តបន្ទាយមានជ័យ អ្នកដែលមានលទ្ធភាពស៊ូរស់នៅបាន គឺគាត់ទៅធ្វើការនៅរោងចក្រ ក្នុងខេត្តមាន ៨ រោងចក្រ មានរោងចក្រកាត់ដេរ រោងចក្រអេឡិកត្រូនិក និងរោងចក្រកែច្នៃផ្សេងទៀត។ ប៉ុន្តែពួកគាត់គិតថា បើធ្វើការនៅក្នុងស្រុក គាត់បានចំណូលមកតិច ហើយត្រូវចាយអស់ តែបើគាត់ទៅស្រុកគេ គាត់រកបានច្រើនគួរសម ចេះសន្សំ ចាយត្បិតត្បៀតគាត់សល់លុយ»។

យ៉ាងណាក៏ដោយលោកថា រាជរដ្ឋាភិបាលកម្ពុជាតាមរយៈអភិបាលខេត្តបន្ទាយមានជ័យបានកំពុងបន្តធ្វើការអភិវឌ្ឍផ្នែកធារាសាស្ត្រ ផ្តល់ពូជស្រូវ ដំណាំដល់កសិករ ដែលកំពុងជួបការលំបាក និងតែងតែផ្តល់អំណោយដល់ជនទីទ័លក្រ។ អ្វីដែលជាបញ្ហាចំពោះមុខនាពេលនេះ នៅពេលពលករសម្រុកមកពីថៃវិញ គឺជាបន្ទុករបស់រដ្ឋាភិបាលមួយកម្រិតទៀត ដែលត្រូវចំណាយទៅលើការដឹកជញ្ជូនពលករ ការព្យាបាល ការធ្វើចត្តាឡីស័ក និងការផ្តល់បាយទឹក ១ ថ្ងៃ ៣ ទៅ ៤ ដងជូនពួកគាត់។ លោកថា៖ «សម្រាប់បច្ចុប្បន្ន រដ្ឋាភិបាលកម្ពុជាទទួលបន្ទុកធ្ងន់លើពលករដែលត្រឡប់មកពីថៃវិញជិត ៧ ពាន់នាក់ ដែលត្រូវចំណាយលើថ្លៃការស្នាក់នៅ ថ្លៃបាយទឹក ដឹកជញ្ជូនកម្លាំង»។ លោកលើកឡើងថា៖ «ពលករដែលត្រឡប់មកវិញខ្លះមានវិបត្តិទៀត ពេលគាត់មានកម្លាំងទៅធ្វើពលកម្មនៅប្រទេសគេ នៅពេលបាក់កម្លាំងក៏ត្រឡប់មកវិញ ជាប់ញៀនថ្នាំ រិជ្ជមានកូវីដ ១៩។ នេះជាបន្ទុកធ្ងន់របស់រដ្ឋាភិបាល។ ពលករមកវិញស្ទើរ ១០ ភាគរយជាប់ពាក់ព័ន្ធគ្រឿងញៀន អ៊ីចឹងបាននៅខេត្តបន្ទាយមានជ័យ មានមជ្ឈមណ្ឌលបន្សាបគ្រឿងញៀន»។

ពាក់ព័ន្ធការបង្កើតទីផ្សារការងារក្នុងស្រុក អ្នកនាំពាក្យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ លោក ហេង សួរ បានប្រាប់ភ្នំពេញប៉ុស្តិ៍ថា ក្នុងឆ្នាំ ២០២០ ទីភ្នាក់ងារជាតិមុខរបរ និងការងារ និងក្រសួងការងារបានប្រមូល និងផ្សព្វផ្សាយកម្លាំងពលកម្មសរុបចំនួន ១៩០ ១២៧ កន្លែង ចែកជាវិស័យកសិកម្មចំនួន ១ ២៧៩ កន្លែង វិស័យឧស្សាហកម្មចំនួន ១០២ ៦០៩ កន្លែង និងវិស័យសេវាកម្មចំនួន ៨៦ ២៣៩ កន្លែង។ លោកបន្តថា នាពេលបច្ចុប្បន្ននេះ កម្ពុជាមានតម្រូវការកម្លាំងពលកម្មសរុបចំនួន ២២ ៩៥៤ កន្លែង ចែកជា វិស័យកសិកម្មចំនួន ៦០០ កន្លែង វិស័យឧស្សាហកម្មចំនួន ២១ ១៦៤ កន្លែង និងវិស័យសេវាកម្មចំនួន ១ ១៩០ កន្លែង។ លោកគូសបញ្ជាក់ថា៖ «ជាការពិតណាស់ការខិតខំបង្កើតការងារនៅក្នុងស្រុករបស់រាជរដ្ឋាភិបាលពិតជាបានស្រូបយកកម្លាំងពលកម្មជាច្រើនចូលក្នុងទីផ្សារការងារ ដែលអត្រាអ្នកមានការងារធ្វើរហូតដល់ ៩៩,៣ ភាគរយ ចំណែកការខិតខំបើកច្រកទីផ្សារការងារនៅក្រៅប្រទេសគឺជាការផ្តល់នូវជម្រើសបន្ថែមទៀតជូនប្រជាពលរដ្ឋ។ ទន្ទឹមនឹងនេះពលករទៅធ្វើការនៅក្រៅប្រទេសក៏បានរួមចំណែកយ៉ាងធំដល់កំណើនសេដ្ឋកិច្ចជាតិ តាមរយៈបញ្ញើបងប្អូនពលករដែលក្នុង ១ ឆ្នាំៗ ប្រមាណជាង ២ ប៊ីលានដុល្លារផងដែរ។ លោក ហេង សួរ ឱ្យដឹងថា បច្ចុប្បន្នពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃមានចំនួន ១ ២២០ ១៩៧ នាក់ (ស្រី ៤៨៩ ៧១៣ នាក់)។ លោកបានឱ្យដឹងទៀតថា ក្រៅពីការបង្កើតឱកាសការងារក្នុងស្រុក ក្រសួងក៏បានបើកវគ្គបណ្តុះបណ្តាលមុខជំនាញ រួមមានសំណង់ស៊ីវិល អគ្គិសនី អេឡិចត្រូនិក បរិក្ខារត្រជាក់ មេកានិក យន្តសាស្ត្ររថយន្ត កម្មន្តសាល ធុរកិច្ច/ICT សហគ្រិនភាព ទេសចរណ៍ និងជំនាញវិជ្ជាជីវៈជាច្រើនទៀត។

លោក មឿន តុលា នាយកប្រតិបត្តិមជ្ឈមណ្ឌលសម្ព័នភាពការងារ និងសិទ្ធិមនុស្ស (Central) មើលឃើញថា នាពេលបច្ចុប្បន្ន ពលករដែលមកកម្ពុជាវិញមានច្រើន ដោយសារនៅថៃមានការបិទខ្ទប់ច្រើន និងមិនមានកន្លែងព្យាបាលគ្រប់គ្រាន់សម្រាប់អ្នកជំងឺកូវីដនោះទេ។ ប៉ុន្តែពលករខ្មែរដែលសម្រេចត្រឡប់ទៅថៃវិញមានការថយចុះច្រើន។ លោកថា៖ «មូលហេតុដែលពលករខ្មែរគាត់ធ្វើការសម្រេចចិត្តត្រឡប់ទៅថៃវិញទោះក្នុងអំឡុងពេលកូវីដ ១៩ គឺដោយសារកត្តាជំរុញក្នុងស្រុក គឺគាត់អត់មានការងារធ្វើ អត់មានមុខរបរដោយសារយើងក៏ផ្ទុះកូវីដដែរ ហើយបំណុលដែលគាត់ជំពាក់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឬធនាគារ គាត់នៅតែសងគេ ខ្លាចគេរឹបអូសផ្ទះ អ៊ីចឹងគាត់នៅតែប្រថុយទៅប្រទេសថៃ»។ លោកបន្តទៀតថា ក្នុងអំឡុងកូវីដក៏មានជនខិលខូចមួយចំនួនឆ្លៀតឱកាសទៅបញ្ចុះបញ្ចូលពលរដ្ឋខ្មែរឱ្យទៅថៃ។ លោកសូមអំពាវនាវដល់ពលរដ្ឋថា «យើងគួរពិចារណាឱ្យបានជិតដល់ ព្រោះថៃមានការផ្ទុះកូវីដខ្លាំង អ៊ីចឹងគាត់ទៅមិនប្រាកដថា បានការងារធ្វើ ឬមានមុខរបរនៅថៃទេ។ តែផ្ទុយទៅវិញគាត់អាចនឹងឆ្លងជំងឺកូវីដ ១៩ ហើយអាចអាជ្ញាធរគេបោះបង់គាត់ចោលដែរ»។

លោកបន្តថា ការដែលពលករខ្មែរនៅតែបន្តធ្វើចំណាកស្រុកទៅថៃ ដោយសារទីផ្សារការងារក្នុងស្រុកនៅតែចង្អៀតនៅឡើយ។ ពលករភាគច្រើនដែលទៅធ្វើការនៅថៃ គាត់ចាប់យកវិស័យកសិកម្មដោយទៅធ្វើការនៅតាមចម្ការកៅស៊ូ ចម្ការអំពៅហើយអ្នកខ្លះធ្វើការសំណង់។ ពួកគាត់ទាំងនោះជាអតីតកម្មករក្នុងស្រុក និងជាអតីតកសិករ ។ «អ៊ីចឹងគាត់ធ្វើកសិកម្មក្នុងស្រុកចំណូលពីផលកសិកម្មរបស់គាត់អត់រួចដើមព្រោះគាត់ទិញជី ជួលគោយន្ត ទិញប្រេង។ ប៉ុន្តែនៅពេលលក់ទៅអត់បានចំណេញ ផ្ទុយទៅវិញគាត់ជំពាក់បំណុលគេ។ ត្រង់នេះហើយទោះបីជាមានកូរ៉ៃដែក៏គាត់ត្រូវតែទៅថៃ ដើម្បីយកលុយមកដោះបំណុលគេ»។ លោក តុលា បន្តថា មានខ្លះទៀតគាត់មិនជំពាក់បំណុលគេទេ ប៉ុន្តែគាត់គិតថា ទៅស្រុកគេរកកម្រៃបានច្រើន សន្សំលុយធ្វើផ្ទះទិញដី។ ប៉ុន្តែភាគច្រើនដែលលោកបានជួប និងធ្វើការសម្ភាស ពួកគាត់ទៅរកការងារធ្វើនៅថៃ គឺដោយសារជំពាក់បំណុលគេ។ ក្នុងនាមសង្គមស៊ីវិលលោកមានមតិថា៖ «រឿងនេះបើសិនជាចង់ដោះស្រាយ ទាល់តែរដ្ឋយើងព្យាយាមធ្វើកំណែទម្រង់វិស័យកសិកម្មឱ្យបានស៊ីជម្រៅ មានន័យថា កុំបំប្លែងកសិករយើងឱ្យទៅជាពលករ ឬកម្មករ។ ឧទាហរណ៍សព្វថ្ងៃយើងនាំចេញពណ៌លឿងទៅចិន អ៊ីចឹងរដ្ឋគួរជួយផ្តល់ដីឱ្យបានគ្រប់គ្រាន់ដល់កសិករជាលក្ខណៈគ្រួសារ ផ្តល់វគ្គបណ្តុះបណ្តាលជំនាញ និងគ្រាប់ពូជ បន្ទាប់មកសម្របសម្រួលជាមួយគាត់ក្នុងការទិញផលិតផលគាត់ បើធ្វើបែបនេះកសិករគាត់មិនប្រថុយប្រថានទៅស្រុកគេទេ ព្រោះគាត់ទៅប្រទេសគេធ្វើកសិកម្មដដែល»។

ទន្ទឹមនេះដែរក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទបានយកចិត្តទុកដាក់ខ្ពស់ដល់ការពង្រឹងសមត្ថភាពប្រជាកសិករ និងអ្នកពាក់ព័ន្ធនានាលើការគ្រប់គ្រងដី និងសារជាតុចិញ្ចឹមក្នុងផលិតកម្មដំណាំកសិកម្ម ដោយបានរៀបចំឯកសារសម្រាប់ធ្វើការបណ្តុះបណ្តាលស្តីពី " វិធានការចម្រុះគ្រប់គ្រងដី និងសារជាតុចិញ្ចឹមរបស់ដីក្នុងផលិតកម្មដំណាំបន្លែសុវត្ថិភាព" ផងដែរ។ ក្រោយពីនេះមន្ត្រីជំនាញបានធ្វើដំណើរចុះមូលដ្ឋាននៅទូទាំងប្រទេសដើម្បីបណ្តុះបណ្តាលក៏ដូចជាផ្តល់បច្ចេកទេសនៃការចិញ្ចឹម មាន់ ទា ជ្រូក គោ កង្កែប និងត្រីជាដើម ដើម្បីឱ្យពលរដ្ឋទទួលបានចំណូលបន្ថែមក្នុងគ្រួសារនិងកាត់បន្ថយការធ្វើចំណាកស្រុក។ រដ្ឋមន្ត្រីក្រសួងកសិកម្មលោក វេង សាខុន ថ្លែងថា ក្នុងទិសដៅជំរុញផលិតភាព អនុវិស័យដំណាំឱ្យកាន់តែរីកចម្រើនទាំងបរិមាណ និងគុណភាព ការបញ្ចូលយន្តូបនីយកម្មទៅក្នុងផលិតកម្មកសិកម្ម គឺជាភារកិច្ចអាទិភាពមួយ ដែលក្រសួងកសិកម្មជំរុញការធ្វើទំនើបកម្មកសិកម្មកម្ពុជា។ លោកថា៖ «យើងបាន និងកំពុងគិតគូរ យកចិត្តទុកដាក់ ធ្វើយ៉ាងណាលើកកម្ពស់ប្រសិទ្ធភាពសេដ្ឋកិច្ច ចំណេញពេល កាត់បន្ថយពលកម្ម ជំរុញល្បឿនផលិតកម្មកសិកម្ម តាមរយៈការប្រើប្រាស់គ្រឿងយន្តកសិកម្ម...»៕

# ថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២១

## កម្ពុជាបន្តអន្តរាគមន៍ បញ្ជូនពលករខ្មែរនៅថៃ ៧នាក់ ត្រឡប់មកមាតុប្រទេសវិញ

http://freshnewsasia.com/ 2021-09-03 05:53pm

**(ភ្នំពេញ)៖** ស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំខេត្តស្រះកែវ ប្រទេសថៃ នៅថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០២១ បានបន្តអន្តរាគមន៍ជួយសម្រួលបញ្ជូនពលករខ្មែរ ចំនួន ០៧នាក់ ដែលបានមកពីខេត្តនានា នៃប្រទេសថៃ ឲ្យវិលត្រឡប់មកកម្ពុជាវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិខ្លងលឹក-ប៉ោយប៉ែត។ លោក កុយ គួង រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានបញ្ជាក់ទៀតថា ប្រជាពលរដ្ឋទាំងអស់ ត្រូវបានប្រគល់ជូនសមត្ថកិច្ចកម្ពុជា ចាត់ការតាមនិតិវិធីសុខាភិបាលបន្ត៕

## ស្ថានអគ្គកុងស៊ុលកម្ពុជានៅស្រះកែវ យកស្បៀងអាហារចែកជូន ពលករខ្មែរចំនួន៦៦ គ្រួសារ ដែលកំពុងជួបការលំបាក

https://www.kampucheathmey.com/ ថ្ងៃសុក្រ ៣ កញ្ញា ២០២១ដោយ Kang Tola

លោក កុយ គួង រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិកម្ពុជា បានឲ្យដឹងនារសៀលនេះថា នៅថ្ងៃទី០៣ កញ្ញា ២០២១ នេះដែរ ក្រុមការងាររបស់ស្ថានអគ្គកុងស៊ុលកម្ពុជា ប្រចាំខេត្តស្រះកែវ ប្រទេសថៃ បានសហការជាមួយលោកអភិបាលស្រុកប៉ាកណាម អាជ្ញាធរពាក់ព័ន្ធថៃ និងអង្គការការពារសិទ្ធិពលករ (Labour Protection Network -LPN) ចុះសួរសុខទុក្ខបងប្អូនពលករខ្មែរចំនួន ៦៦គ្រួសារ ដែលកំពុងស្នាក់នៅ និងធ្វើការស្រុកប៉ាកណាម ខេត្តចន្ទថាក់បុរី។ បើតាមលោក កុយ គួង នៅក្នុងឱកាសនោះ ក៏បាននាំយកនូវស្បៀងអាហារ មានដូចជា អង្ករ ត្រីខកំប៉ុង ពងមាន់ ទឹកត្រី ទឹកស៊ីអ៊ីវ ត្រីប្រឡាក់គ្រៀម មើមផែថៅ ផ្លែននោង ទឹកដោះគោ ទឹកសុទ្ធ ម៉ាស់ ថ្នាំពេទ្យសំរាប់កុមារ ទឹកអាកុលលាងដៃ និងសម្ភារៈប្រើប្រាស់មួយចំនួនទៀត សម្រាប់ចែកជូន ដើម្បីជួយសម្រាលទុក្ខលំបាករបស់ពួកគាត់ ដែលកំពុងទទួល រងផលប៉ះពាល់ដោយសារការរីករាលដាលជំងឺកូវីដ-១៩ ផងដែរ។ បន្ថែមពីនេះ ដើម្បីសុវត្ថិភាពសុខភាពបងប្អូនពលករខាងលើ ក្រុមការងារបានក្រើនរំលឹក អោយពួកគាត់មានការយកចិត្តទុកដាក់ថែទាំសុខភាពជាប្រចាំក្នុងតំណាក់កាលបរិបទជំងឺកូវីដនេះ ជាពិសេសអំពីវិធានការ ៣កុំ និង ៣ការពារ។ *ដោយ ៖ កោះកែវ*

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិបាវិត ទទួលពលរដ្ឋខ្មែរ ០៣នាក់ ពីវៀតណាម

https://swiftnewsdaily.com/ SWIFT NEWS ថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០២១

(ស្វាយរៀង)៖ នៅថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០២១ ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិបាវិត បានសហការជាមួយស្ថាប័នចត្តាឡីស័ក និងសម្របសម្រួលជាមួយស្ថានអគ្គកុងស៊ុលកម្ពុជា ប្រចាំទីក្រុងហូជីមិញ ធ្វើការទទួលពលរដ្ឋខ្មែរចំនួន ០៣នាក់ ស្រី ០២នាក់ ដែលបានអនុវត្តទោសរួចរាល់ ពីប្រទេសវៀតណាម។ ដោយអនុវត្តតាមសេចក្ដីណែនាំ របស់អនុគណៈកម្មការគ្រប់គ្រងច្រកទ្វារចេញ-ចូលប្រទេស និងការធ្វើចត្តាឡីស័ក ក្រុមការងារបានធ្វើតេស្តរហ័ស ជាលទ្ធផល (អវិជ្ជមាន) និងបន្តធ្វើចត្តាឡីស័កពលរដ្ឋខ្មែរខាងលើ នៅផ្ទះសំណាក់ ប៉ាងសំអុល ស្ថិតនៅភូមិបាវិតលើ សង្កាត់បាវិត ក្រុងបាវិត ខេត្តស្វាយរៀង តាមវិធានការណ៍របស់អនុគណៈកម្មការ៕

## ពលករខ្មែរ ៤៨ នាក់ លបឆ្លងដែនខុសច្បាប់ ពីខេត្តប៉ៃលិនទៅខេត្តច័ន្ទបុរីដើម្បីបេះផ្លែមៀន ត្រូវទាហានឈុតខ្មៅថៃ ចាប់ខ្លួន

https://www.kampucheathmey.com/ ថ្ងៃសៅរ៍ ៤ កញ្ញា ២០២១ដោយ Kang Tola

ពលករខ្មែរចំនួន ៤៨ នាក់ ត្រូវបានក្រុមទាហានឈុតខ្មៅថៃ ចាប់ខ្លួន ខណៈដែលពួកគេលបឆ្លងដែនដោយខុសច្បាប់ ចូលទឹកដីថៃ ដើម្បីធ្វើជាកម្មករបេះផ្លែមៀននៅក្នុងខេត្តច័ន្ទបុរី។ ការឃាត់ខ្លួននេះបានធ្វើឡើងកាលពីវេលាម៉ោង៤ទៀបភ្លឺ ថ្ងៃទី ៤ ខែកញ្ញា ឆ្នាំ២០២១ ត្រង់ចំណុចភូមិ៤ ក្នុងឃុំខ្លងយៃ ស្រុកពោងណាំរ៉ន ខេត្តច័ន្ទបុរី ប្រទេសថៃ។ នៅមុនពេលឃាត់ខ្លួនគឺមានពលករខ្មែរចំនួន ៤៨នាក់ បានលបឆ្លងព្រំដែនចូលទៅក្នុងទឹកដីថៃ ដោយបាននាំគ្នាដើរកាត់តាមចំការ ស្របពេលដែលកម្លាំងទាហានឈុតខ្មៅថៃ កំពុងល្បាតក៏បានស្ទាក់ចាប់ ក្នុងនោះប្រុស ១៨ ស្រី ២៣ នាក់ និងក្មេងតូចៗ ៧ នាក់។ ក្រោយការចាប់ខ្លួនពលករខ្មែរបានសារភាពថា ពួកគេមកពីខេត្តប៉ៃលិន ដោយចូល តាមច្រករបៀងកាត់ព្រៃ ដើម្បីទៅធ្វើការនៅក្នុងចំការមៀន ក្នុងខេត្តច័ន្ទបុរី ដោយក្នុងម្នាក់ៗត្រូវចំណាយឲ្យមេខ្យល់ ៥.០០០ បាត តែក៏ត្រូវឃាត់ខ្លួនតែម្តង។ ក្រោយពេលឃាត់ខ្លួន ក្រុមយោធាថៃបានសង្កេត

ឃើញថា ពួកគេគ្មានច្បាប់អនុញ្ញាតត្រឹមត្រូវឡើយ ទើបត្រួតពិនិត្យសុខភាពពួកគេទាំងអស់ និងបានបញ្ជូនទៅឲ្យភាគីកម្ពុជាវិញ ដើម្បីធ្វើចត្តាឡីស័ក ៕ *អត្ថបទ ៖ សោ និយមវ័ត្ថ*

## សមត្ថកិច្ចឃាត់ខ្លួនមេខ្យល់៣នាក់ បំរ៉ុងនាំពលករឆ្លងដែនខុសច្បាប់ទៅប្រទេសថៃ

http://cambodiapolice.com/policekh/ 2:26 pm 4 កញ្ញា 2021

បាត់ដំបង ៖ អនុវត្តតាមយោបល់ដឹកនាំរបស់លោក ឧត្តមសេនីយ៍ទោ សាត គឹម សាន ស្នងការនៃស្នងការដ្ឋាននគរបាល ខេត្តបាត់ដំបង និងដោយមានការសម្របសម្រួលនីតិវិធីពីឯកឧត្តម កែវ សុជាតិ ព្រះរាជអាជ្ញាអមសាលាដំបូងខេត្ត លោកវរសេនីយ៍ទោ វេ គឹម ចត់ អធិការនគរបាលស្រុកកំរៀង ដឹកនាំកម្លាំង សហការជាមួយកម្លាំងនគរបាលវរសេនាតូចការពារព្រំដែនគោកលេខ៨១៩ ដែលមានលោកវរសេនីយ៍ឯក ម៉ង់ ស៊ី ជាមេបញ្ជាការបង្ក្រាបករណីនាំយកចេញឆ្លងដែនដោយមិនស្របច្បាប់ ក្នុងបទល្មើសជាក់ស្តែង កាលពីថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០២១ វេលាម៉ោង១០និង៥៥នាទី។

មេខ្យល់ទាំង០៣នាក់(ប្រុស)នោះរួមមាន ៖ ១-ឈ្មោះ កិល យាំង ភេទប្រុស អាយុ ៣១ឆ្នាំ , ២-ឈ្មោះ គឹម សុខហេង ហៅ ផែប ភេទប្រុស អាយុ២៩ឆ្នាំ និង ៣-ឈ្មោះ ឡាំ ភារុណ ភេទប្រុស អាយុ ៤៣ឆ្នាំ អ្នកទាំងបីរស់នៅក្នុងឃុំពេជ្រចិន្តា ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង និងមធ្យោបាយរថយន្ត០១គ្រឿង ម៉ាក NISSAN (នីសាន់) ពណ៌សំបកឪឡឹក ពាក់ស្លាកលេខ ភព-0250 និងទប់ស្កាត់ពលករបំរ៉ុងឆ្លងដែនចំនួន ០៧នាក់ ស្រីចំនួន ០២នាក់ អនីតិជន ០៥នាក់ ស្រីចំនួន ០១នាក់។ បច្ចុប្បន្ន មេខ្យល់ទាំង០៣នាក់និងរថយន្ត សមត្ថកិច្ចនគរបាលស្រុកកសាងសំណុំរឿងបញ្ជូ ន មកការិយាល័យជំនាញ ដើម្បីអនុវត្តតាមច្បាប់ រីឯប្រជាពលរដ្ឋរងគ្រោះបានអប់រំណែនាំឱ្យវិលទៅលំនៅដ្ឋានវិញ៕

## លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ពង្រឹងនិងដាក់ពង្រាយកម្លាំងប្រចាំការតាមគោលដៅតូចៗចំនួន៥០ ដើម្បី ការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ

http://cambodiapolice.com/policekh/ 5:14 pm 4 កញ្ញា 2021

ខេត្តបាត់ដំបង ៖ នៅថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០២១ លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ បានចាត់កម្លាំងប៉ុស្តិ៍ព្រំដែនទាំង៦ ចំណុះឲ្យវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ សហការជាមួយកម្លាំងយោធា ចេញល្បាតតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា_ថៃ ក្នុងភូមិ សាស្រ្តប៉ុស្តិ៍គ្រប់គ្រង និងដាក់ពង្រាយកម្លាំងប្រចាំការតាមគោលដៅតូចៗចំនួន៥០គោលដៅ ដើម្បីទប់ស្កាត់ប្រជាពលរដ្ឋចេញចូលផងដែរ ។ ការដាក់ពង្រាយកម្លាំងនេះទៀតសោត ដោយអនុវត្តតាមបទបញ្ជាលោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ស្តីពីការ ការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា_ថៃ និងមានការណែនាំរបស់លោកវរសេនីយ៍ឯក ពៅ ថាវុធ ស្នងការរងទទួលការងារវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ ៕

# ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២១

## លោក សៅ សារ៉ាត់ អ្នកតំណាងរាស្ត្រមណ្ឌលប៉ៃលិន បានសួរសុខទុក្ខកងកម្លាំងតាមព្រំដែន និងជំរុញឲ្យកម្លាំងប្រចាំការ នៅតំបន់ព្រំដែនកម្ពុជា-ថៃ ត្រូវតែទប់ស្កាត់តាមដានពលករខ្មែរ ដែលឆ្លងដែនទៅប្រទេសថៃ ខុសច្បាប់

http://nokorwatnews.com/ 06/09/2021

**ខេត្តប៉ៃលិន៖** នៅព្រឹកថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២១ លោក សៅ សារ៉ាត់ អ្នកតំណាងរាស្ត្រមណ្ឌលប៉ៃលិន បានអញ្ជើញចុះជួបសំណេះ សំណាលសាកសួរសុខទុក្ខ និងបាននាំយកគ្រឿង ឧបភោគបរិភោគ ទៅឧបត្ថម្ភដល់កងកម្លាំងចម្រុះ ដែលកំពុងបំពេញបេសកកម្ម ការពារតាមគោលដៅ ខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ក្នុងការបង្ការ នឹងទប់ស្កាត់ការចម្លងរីករាលដាលនៃជំងឺកូវីដ-១៩ ចូលក្នុងសហគមន៍។ ការចុះជួបសំណេះសំណាល សាកសួរសុខទុក្ខនោះ ដោយមានការអញ្ជើញចូលរួមពីលោក សេង សុគន្ធ ស្នងការនគរបាលខេត្តប៉ៃលិន ,លោក ទី សុខា មេបញ្ជាការទិសទី៣ប៉ៃលិន ព្រមទាំងក្រុមការងារជាច្រើនរូបទៀត។ ក្នុងឱកាសនេះដែរ លោក សៅ សារ៉ាត់ អ្នកតំណាងរាស្ត្រមណ្ឌលប៉ៃលិន បានមានប្រសាសន៍ពាំនាំនូវការផ្ដាំផ្ញើសាកសួរសុខទុក្ខពីលោក អភិបាលខេត្តប៉ៃលិន ដោយខិតខំប្រឹងប្រែងឲ្យបានខ្ពស់ ក្នុងការទប់ស្កាត់ពលករឆ្លងដែនខុសច្បាប់ ទៅកាន់ប្រទេសថៃ ហើយការពង្រឹងសមត្ថកិច្ចតាមព្រំដែន គឺជាការអនុវត្តតាមការណែនាំរបស់រាជរដ្ឋាភិបាល ឱ្យបណ្ដាខេត្តដែលមានព្រំដែន ជាប់នឹងប្រទេសជិតខាង ត្រូវមានការយកចិត្តទុកដាក់ឱ្យបានខ្ពស់ នូវការរីករាលដាលជំងឺឆ្លងកូវីដ-១៩ ជាពិសេសព្រំដែនកម្ពុជា-ថៃ ដែលមានហានិភ័យខ្ពស់ ចំពោះពលករខ្មែរចំណាកស្រុក។

លោក សៅ សារ៉ាត់ អ្នកតំណាងរាស្ត្រមណ្ឌលប៉ៃលិន ក៏បានជំរុញដល់កម្លាំងចម្រុះទាំងអស់ ត្រូវធ្វើយ៉ាងណាខិតខំតាមដានរាល់សភាពការណ៍ នៃការឆ្លងដែនរបស់ពលករខ្មែរ និងត្រូវប្រចាំការ ២៤ម៉ោង តាមគោលដៅដែលខ្លួនទទួលខុសត្រូវ ក្រែងមានពលករលួចឆ្លងដែន ដោយខុសច្បាប់ទៅកាន់ប្រទេសថៃ ។ ជាមួយគ្នានេះសូមសមត្ថកិច្ច ដែលប្រចាំការ តាមគោលដៅ សូមកុំមានការពាក់ព័ន្ធនិងពួកប្រព្រឹត្តល្មើស ដែលនាំឲ្យអន្តរាយដល់ខ្លួនយើង និងគ្រួសារយើងផងដែរ។ នៅក្នុងឱកាសនោះ លោក សៅ សារ៉ាត់ អ្នកតំណាងរាស្ត្រមណ្ឌលប៉ៃលិន បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះកងកម្លាំងចម្រុះ ដែលកំពុងឈរជើងការពារនៅតាមបន្ទាត់ព្រំដែន និងនៅតាមគោលដៅទាំងអស់ ដែលបានខិតខំបំពេញការងារទាំងកំលាំងកាយទាំងកំលាំងចិត្ត ប្រកបដោយការទទួលខុសត្រូវខ្ពស់ ក្នុងការរួមគ្នាប្រយុទ្ធប្រឆាំង និងទប់ស្កាត់ការចម្លងរីករាលដាលជំងឺកូវីដ-១៩ ជាពិសេសលើកទឹកចិត្តដល់ក្រុមគ្រូពេទ្យជំនាញទាំងអស់ ដែលកំពុងបំពេញបេសកកម្មដ៏ថ្លៃថ្លានេះ សម្រាប់ប្រទេសជាតិ។ សូមបញ្ជាក់ថា៖ អំណោយដែលលោក សៅ សារ៉ាត់ អ្នកតំណាងរាស្ត្រមណ្ឌលប៉ៃលិន យកទៅឧបត្ថម្ភជូនដល់កងកម្លាំង ដែលកំពុងប្រចាំការ តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ដោយក្នុង ១គោលដៅៗ ទទួលបានរួមមាន៖ អង្ករ ៥០គីឡូក្រាម, មី៥កេស, ទឹកស៊ីអ៊ីវ២យួរ,ទឹកសុទ្ធ២០យួរ,ទឹកSTING ២កេស និងថវិកាមួយចំនួនផងដែរ៕

## អភិបាលខេត្តឧត្តរមានជ័យ ចុះពិនិត្យ វឌ្ឍនភាពមណ្ឌលចត្តាឡីស័កនៅស្រុកអន្លង់វែង ដើម្បីត្រៀមដាក់បងប្អូនពលករដែលចំណាកស្រុកពីប្រទេសថៃ ចូលមកកម្ពុជា តាមច្រកទ្វារព្រំដែនអូរស្មាច់

http://nokorwatnews.com/ 06/09/2021

ខេត្តឧត្តរមានជ័យ៖ លោក ប៉ែន កុសល្យ អភិបាល នៃគណៈអភិបាលខេត្តឧត្តរមានជ័យ និងជាប្រធានគណៈកម្មការប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ខេត្តឧត្តរមានជ័យ ដឹកនាំក្រុមកាងារចុះពិនិត្យ វឌ្ឍនភាពមណ្ឌលចត្តាឡីស័កមួយកន្លែងដែលស្ថិតនៅក្នុងស្រុកអន្លង់វែង ដើម្បីត្រៀមដាក់បងប្អូនពលករដែលចំណាកស្រុកពីប្រទេសថៃចូលមកប្រទេសកម្ពុជា តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់។ នេះបើតាមការបញ្ជាក់ពីហ្វេសប៊ុកផ្លូវការរបស់រដ្ឋបាលខេត្តឧត្តរមានជ័យ នៅយប់ថ្ងៃសៅរ៍ ១២រោច ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥ ត្រូវនឹង ថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០២១។ សូមបញ្ជាក់ផងដែរថា មណ្ឌលចត្តាឡីស័កនេះអាចទុកពលករបានរហូតទៅដល់ ២.៥០០ នាក់ ឬ ២.៥០០ គ្រែ។

ដោយឡែកនៅថ្ងៃដដែលនេះ លោកអភិបាលខេត្តឧត្តរមានជ័យ ក៏បានដឹកនាំក្រុមការងារចុះពិនិត្យមើលស្ថានភាពទឹកនៅទំនប់អាង០៥ និងបានបន្តដំណើរចុះពិនិត្យមើលរមណីយដ្ឋានអូរទឹកខៀវ ដែលមានទីតាំងស្ថិតនៅក្នុងស្រុកត្រពាំងប្រាសាទ និងបានចេញដំណើរមករមណីយដ្ឋានក្បាលទន្សោងផងដែរ។ គួរបញ្ជាក់ថា ចុះពិនិត្យមើលស្ថានភាពទឹកនៅទំនប់អាង០៥ និងបានបន្តដំណើរចុះពិនិត្យមើលរមណីយដ្ឋានអូរទឹកខៀវ ដែលមានទីតាំងស្ថិតនៅក្នុងស្រុកត្រពាំងប្រាសាទនេះ គឺដើម្បីរៀបចំហេដ្ឋារចនាសម្ព័ន្ធ និងលើកកម្ពស់សោភ័ណភាព ក្នុងការទាក់ទាញភ្ញៀវទេសចរជាតិ និងអន្តរជាតិចូលមកកម្សាន្តនៅលើទឹកដីជាយដែន មួយនេះឱ្យបានច្រើនកុះករក្រោយពេលស្ថានភាពកូវីដ-១៩ បានស្ងប់ស្ងាត់ទៅវិញ៕

## ម្នាក់ៗចំណាយ៥ពាន់បាតឱ្យមេខ្យល់នាំចូលដីថៃ ទៅធ្វើជាកម្មករបេះផ្លែមៀន

https://kohsantepheapdaily.com.kh/ ប៉ៃលិន ០៦ ខែ កញ្ញា ឆ្នាំ ២០២១ ម៉ោង ០៨:៤៦

ខេត្តប៉ៃលិន ៖ ដោយសារជឿតាមការអូសទាញរបស់មេខ្យល់ ពលករខ្មែរម្នាក់ៗបានសម្រេចចិត្តបង់ប្រាក់ឱ្យទៅមេខ្យល់ ទើបពលករខ្មែរចំនួន៤៨នាក់ ត្រូវបានគេនាំឆ្លងដែនដោយខុសច្បាប់ តាមច្រករបៀងខេត្តប៉ៃលិន ហើយត្រូវបានក្រុមទាហានឈុតខ្មៅថៃ ធ្វើការចាប់ឃាត់ខ្លួន ខណៈដែលពួកគេចូលទៅក្នុងទឹកដីថៃ ដើម្បីធ្វើជាកម្មករបេះផ្លែមៀន (ហៅតាង៉ែន) នៅក្នុងទឹកដីខេត្តចាន់បុរី ប្រទេសថៃ ។ ហេតុការណ៍ឃាត់ខ្លួនពលករខ្មែរខុសច្បាប់នេះ បានធ្វើឡើងកាលពីវេលាម៉ោង៤ទៀបភ្លឺថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០២១ នៅចំណុចភូមិ៤ ឃុំខ្លុងយ៉ៃ ស្រុកពោងណាំរ៉ន ខេត្តចាន់បុរី ប្រទេសថៃ ។ ប្រភពព័ត៌មានបានឱ្យដឹងថា ពលករខ្មែរចំនួន៤៨នាក់ បាននាំគ្នាលួចឆ្លងព្រំដែនចូលទៅក្នុងទឹកដីថៃ ដោយលួចដើរកាត់តាមចំការដំណាំ។ ស្របពេលដែលកម្លាំងទាហានឈុតខ្មៅថៃ កំពុងចុះល្បាតតាមព្រំដែនក៏ស្ទាក់ចាប់ឃាត់ខ្លួនបានទាំងដុលតែម្តង ដោយក្នុងនោះពលករទាំង៤៨នាក់ មានប្រុសចំនួន១៨នាក់ និងស្ត្រី២៣នាក់ ព្រមទាំងក្មេងតូចៗចំនួន៧នាក់ផងដែរ ។

ប្រភពបានបន្តទៀតថា ក្រោយពេលទាហានថៃចាប់ឃាត់ខ្លួនពលករខ្មែរទាំងនោះបានសារភាពថា ពួកគេពិតជាបានលួចចូលតាមទឹកដីខេត្តប៉ៃលិន ដោយលួចចូលតាមច្រករបៀងដើរកាត់ព្រៃ ដើម្បីទៅធ្វើការនៅក្នុងចំការមៀនឱ្យជនជាតិថៃក្នុងខេត្តចាន់បុរីដោយមេខ្យល់បានទារប្រាក់ពីពួកគេ ក្នុងម្នាក់ៗចំនួន៥.០០០បាត(ប្រាក់ថៃ)។ បន្ទាប់ពីមេខ្យល់បាននាំពួកគេឆ្លងដែនចូលទៅក្នុងទឹកដីថៃរួច បានគេចខ្លួនបាត់ស្រមោល ចំណែកពួកគេត្រូវបាន

ទាហានថៃឃាត់ខ្លួនតែម្តង ។ ក្រោយពេលឃាត់ខ្លួន ក្រុមយោធាថៃបានសង្កេតឃើញថា ពួកគេគ្មានលិខិតច្បាប់អនុញ្ញាតត្រឹមត្រូវឡើយ ទើបតម្រូវត្រួតពិនិត្យសុខភាពទាំងអស់ដោយធ្វើតេស្តរកមេរោគកូវីដ-១៩ និងបានរៀបចំបញ្ជូនមកឱ្យភាគីកម្ពុជាវិញ ដើម្បីធ្វើចត្តាឡីស័កបន្តនៅក្នុងខេត្តប៉ៃលិន ។

ពាក់ព័ន្ធទៅនឹងបញ្ហានេះ លោកវរសេនីយ៍ទោ សួន ដាលីន ប្រធានក្រុមការងារទំនាក់ទំនងព្រំដែនកម្ពុជា-ថៃ ប្រចាំការនៅច្រកទ្វារអន្តរជាតិព្រំ បានប្រាប់ក្រុមអ្នកសារព័ត៌មានយើងឱ្យដឹងថា ខាងលោកមិនទាន់បានទទួលដំណឹងនេះនៅឡើយទេ ហើយខាងលោកនឹងទាក់ទងទៅខាងភាគីថៃ ដើម្បីសួរនាំបន្ថែមឲ្យដឹងច្បាស់ រួចទទួលយកពលករឆ្លងដែនខុសច្បាប់ទាំងនោះត្រឡប់មកប្រទេសកម្ពុជាវិញ ៕

## កម្ពុជាបន្តអន្តរាគមន៍បញ្ជូនពលករខ្លួននៅថៃ ២៣នាក់ ឱ្យបានត្រលប់មកមាតុប្រទេសវិញ

http://freshnewsasia.com/ 2021-09-06 03:54pm

**(ភ្នំពេញ)៖** ស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំខេត្តសាកែវ ប្រទេសថៃ នៅថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២១ បានបន្តអន្តរាគមន៍សម្របសម្រួលបញ្ជូនពលករខ្មែរ ចំនួន ២៣នាក់ នៅតំបន់នានាក្នុងប្រទេសថៃ ឲ្យបានវិលត្រលប់មកប្រទេសកម្ពុជាវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិខ្លងលឹក-ប៉ោយប៉ែត។ លោក កុយ គួង រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានបញ្ជាក់ថា ពលករទាំងអស់ ត្រូវបានប្រគល់ជូនអាជ្ញាធរកម្ពុជា ដើម្បីដំណើការតាមនីតិវិធីសុខាភិបាល៕

## ឯកអគ្គរាជទូតកម្ពុជានៅថៃ ចុះសួរសុខទុក្ខ និងយកអំណោយ ចែកជូនពលករខ្មែរ ជួបការលំបាកខ្លាំង ដោយសារការរាតត្បាតជំងឺកូវីដ១៩ នៅខេត្តរ៉ះយ៉ង

https://cen.com.kh/ Posted ByPen Srey NeatSeptember 6, 2021

ភ្នំពេញ ៖ អ្នកនាំពាក្យក្រសួងការបរទេសកម្ពុជា ឯកឧត្តម កុយ គួង បានឲ្យដឹងថា ថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២១ ឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសថៃ និងក្រុមការងារស្ថានទូត បានសួរសុខទុក្ខ និងយកអំណោយរួមមាន អង្ករ ត្រីខ បន្លែស្រស់ សាច់ស្រស់ និងគ្រឿងឧបភោគបរិភោគផ្សេងៗ ចុះចែកដល់បងប្អូនពលករខ្មែរចំនួន ៨០គ្រួសារ ដែលជួបការលំបាកខ្លាំងដោយសារការរាតត្បាតជំងឺកូវីដ១៩ នៅឃុំថាងក្វៀន ស្រុកក្លែង ខេត្តរ៉ះយ៉ង ដោយមានការអញ្ជើញចូលរួមពីឯកឧត្តមអភិបាលខេត្តរ៉ះយ៉ង មន្ទីរការងារ មន្ទីរអន្តោប្រវេសន៍ លោកអភិបាលស្រុក ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាឃុំ និងអាជ្ញាធរពាក់ព័ន្ធ។ ឯកឧត្តមបន្តថា ក្នុងឱកាសនោះ ឯកអគ្គរាជទូតបានជួបប្រជុំការងារជាមួយឯកឧត្តមអភិបាលខេត្ត និងបានថ្លែងអំណរគុណ និងស្នើឲ្យឯកឧត្តមអភិបាលខេត្ត និងអាជ្ញាធរពាក់ព័ន្ធ បន្តជួយមើលថែ ធ្វើតេស្ត ព្យាបាល និងចាក់វ៉ាក់សាំងដល់បងប្អូនពលរដ្ឋខ្មែរឲ្យបានទាន់ពេលវេលា។

ជាការឆ្លើយតប ឯកឧត្តមអភិបាល ខេត្ត មានប្រសាសន៍ថា ពលរដ្ឋខ្មែរ ដែលកំពុងរស់នៅ និងធ្វើការច្រើនម៉ឺននាក់ ។ ឯកឧត្តមអភិបាលខេត្ត បានជម្រាបបន្ថែម អំពីវិធានការក្នុងការទប់ស្កាត់ជំងឺកូវីដ១៩ របស់ ខេត្តរ៉ះយ៉ង ថា ប្រសិនបើ មានពលករកម្ពុជា កំពុងបម្រើការងារឆ្លងកូវីដក្នុង រោងចក្រ /សហគ្រាស ត្រូវទទួលការព្យាបាល ត្រឹមត្រូវ ។ ចំពោះគំនិតផ្តួចផ្តើមថ្មី "Bubble & Seal Procedure" បើអ្នកវិជ្ជមានកូវីដ១៩ យកទៅរក្សាព្យាបាលនៅក្នុងរោងចក្រតែម្តង ដល់ពេលជាសះស្បើយត្រឡប់ទៅធ្វើការដូចដើម និងទទួលការចាក់វ៉ាក់សាំង ចំណែកអ្នកអវិជ្ជមានធ្វើការធម្មតា ។ សូមកុំភ័យខ្លាច កុំរត់គេចខ្លួន គំនិតផ្តួចផ្តើមនេះបានទទួលការគាំទ្រពីម្ចាស់រោងចក្រ /សហគ្រាសយ៉ាងពេញទំហឹង៕ រក្សាសិទ្ធិដោយ ៖ ចេស្តារ

# ឯកអគ្គរាជទូតកម្ពុជា ស្នើឲ្យអាជ្ញាធរថៃ ជួយព្យាបាល និងចាក់វ៉ាក់សាំងដល់បងប្អូនពលរដ្ឋខ្មែរឲ្យបានទាន់ពេល

https://www.kampucheathmey.com/ ថ្ងៃចន្ទ ៦ កញ្ញា ២០២១ដោយ Kang Tola

ការស្នើរបស់ឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសថៃនេះ បានធ្វើឡើងនៅក្នុងកិច្ចប្រជុំជាមួយអភិបាលខេត្ត ខេត្តរ៉ះយ៉ង ខណៈលោកដឹកនាំក្រុមការងារ នាំយកអំណោយចែកជូនបងប្អូនពលករខ្មែរចំនួន៨០ គ្រួសារ ដែលជួបការលំបាកខ្លាំង ដោយសារការរាតត្បាតជំងឺកូវីដ១៩ នេះបើតាមការបញ្ជាក់ពីអ្នកនាំពាក្យ។

លោក កុយ គួង អ្នកនាំពាក្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិកម្ពុជាបានឲ្យដឹងនារសៀលនេះថា ឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសថៃ និងក្រុមការងារស្ថានទូត នៅថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២១ នេះ បានសួរសុខទុក្ខ និងយកអំណោយ ចុះចែកដល់បងប្អូនពលករខ្មែរចំនួន ៨០គ្រួសារ ដែលជួបការលំបាកខ្លាំងដោយសារការរាតត្បាតជំងឺកូវីដ១៩ នៅឃុំថាងក្វៀន ស្រុកក្លែង ខេត្តរ៉ះយ៉ង ដែលឱកាសនោះ ក៏មានការចូលរួមពីអភិបាលខេត្តរ៉ះយ៉ង មន្ទីរការងារ មន្ទីរអន្តោប្រវេសន៍ លោកអភិបាលស្រុក ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាឃុំ និងអាជ្ញាធរពាក់ព័ន្ធ របស់ថៃផងដែរ។ បើតាមលោក កុយ គួង នៅក្នុងឱកាសនោះ ក្រោយពីសំណេះសំណាល និងចែកអំណោយ ឯកអគ្គរាជទូតបានជួបប្រជុំការងារជាមួយលោកអភិបាលខេត្ត ដែលក្នុងនោះលោកបានថ្លែងអំណរគុណដល់ភាគីថៃ និងស្នើឲ្យលោកអភិបាលខេត្ត និងអាជ្ញាធរពាក់ព័ន្ធ បន្តជួយមើលថៃ ធ្វើតេស្ត ព្យាបាល និងចាក់វ៉ាក់សាំងដល់បងប្អូនពលរដ្ឋខ្មែរឲ្យបានទាន់ពេលវេលា។

ជាការឆ្លើយតប លោកអភិបាលខេត្តរ៉ះយ៉ង បានបញ្ជាក់ថា នៅខេត្តរ៉ះយ៉ង មានពលរដ្ឋខ្មែរកំពុងរស់នៅ និងធ្វើការច្រើនម៉ឺននាក់ ហើយក្នុងនោះ លោកអភិបាលខេត្តបានជម្រាបបន្ថែមអំពីវិធានការក្នុងការទប់ស្កាត់ជំងឺកូវីដ១៩ របស់ខេត្តរ៉ះយ៉ងថា ប្រសិនបើមានពលករកម្ពុជាកំពុងបម្រើការងារឆ្លងកូវីដ នៅក្នុងរោងចក្រ សហគ្រាស ត្រូវទទួលការព្យាបាលត្រឹមត្រូវ។ លោកអះអាងថា បើមានអ្នកជំងឺមានកូវីដ១៩ គឺយកទៅរក្សាព្យាបាលនៅក្នុងរោងចក្រតែម្តង ហើយនៅពេលជាសះស្បើយ គឺត្រឡប់ទៅធ្វើការដូចដើម និងទទួលការចាក់វ៉ាក់សាំង ចំណែកអ្នកអវិជ្ជមានធ្វើការធម្មតា នេះបើតាមគំនិតផ្តួចផ្តើមថ្មី "Bubble & Seal Procedure" ។ ជាមួយគ្នានោះ លោកបានផ្តែផ្តាំពលករខ្មែរកុំឲ្យភ័យខ្លាច កុំរត់គេចខ្លួន ហើយគំនិតផ្តួចផ្តើម(Bubble & Seal Procedure) នេះ បានទទួលការគាំទ្រពីម្ចាស់រោងចក្រ សហគ្រាស យ៉ាងពេញទំហឹង។

សូមបញ្ជាក់ថា នៅថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២១ ស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំខេត្តសាកែវ ក៏បានអន្តរាគមន៍សម្របសម្រួលបញ្ជូនពលករខ្មែរចំនួន២៣នាក់ ដែលមកពីតំបន់នានា ក្នុងប្រទេសថៃ ឲ្យវិលត្រឡប់មកកម្ពុជាវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិខ្លងលឹក-ប៉ោយប៉ែត ដោយប្រគល់ជូនអាជ្ញាធរកម្ពុជា ដើម្បីដំណើរការតាមនីតិវិធីសុខាភិបាលផងដែរ៕ *ដោយ ៖ កោះកែវ*

# ពលករខ្មែរ ១៦នាក់ ចំណាយលុយឱ្យមេខ្យល់ ឆ្លងដែនខុសច្បាប់ ត្រូវទាហានថៃចាប់បាន

https://www.kampucheathmey.com ថ្ងៃអង្គារ ៧ កញ្ញា ២០២១ដោយ KC Virak

ខេត្តបាត់ដំបង៖ ពលករខ្មែរចំនួន ១៦ នាក់ ត្រូវបានក្រុមទាហានឈុតពិសេសរបស់ថៃចាប់ខ្លួន ខណៈដែលពួកគេលបឆ្លងដែន ដោយបានចំណាយក្នុងម្នាក់ៗចាប់ពី ៤,៥០០ បាត ដល់ ៩,០០០ បាត ដើម្បីចូលទឹកដីថៃរកការងារធ្វើដោយខុសច្បាប់។ ការឃាត់ខ្លួននេះបានធ្វើឡើងត្រង់ចំណុចភ្នំកូនដំរី ក្នុងភូមិ១៤ ឃុំតាប្រាក់យ៉ា ស្រុកតាប្រាក់យ៉ា ខេត្តស្រះកែវ ប្រទេសថៃ កាលពីព្រឹកថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២១ វេលាម៉ោង ៩ ព្រឹក។ នៅមុនពេលឃាត់ខ្លួន គឺមានពលករខ្មែរចំនួន១៦ នាក់ បានលបឆ្លងព្រំដែនចូលទៅក្នុងទឹកដីថៃ ដោយបាននាំគ្នាដើរកាត់

តាមចម្ការ ស្របពេលដែលកម្លាំងទាហានឈុតពិសេសថៃ សហការជាមួយកម្លាំងតម្រួតព្រំដែន កំពុងល្បាតក៏បានស្ទាក់ចាប់ ក្នុងនោះមានប្រុស ០៩នាក់ និង ស្រី ០៧នាក់។

ក្រោយការចាប់ ខ្លួនពលករខ្មែរបានសារភាពថា ពួកគេមកពីខេត្តបន្ទាយមានជ័យ ដោយបានប្រមូលផ្តុំគ្នានៅក្នុងឃុំល្មៀត ស្រុកថ្មពួក ដោយមានមេខ្យល់នាំផ្លូវ និងត្រូវចំណាយម្នាក់ៗ ចាប់ពី ៤,៥០០ បាត ទៅ ៩,០០០ បាត និងត្រូវដើរកាត់ចម្ការដើម្បីឡើងទៅលើផ្លូវជាតិលេខ ៣០៨៥ ត្រង់ចំណុច បានណាងង៉ាម ចំណែកលុយកាក់គឺបានប្រគល់ទៅឱ្យមេខ្យល់តាំងពីនៅដីខ្មែរម្ល៉េះ ដែលក្នុងគោលដៅទៅធ្វើការនៅ ក្រុងបាងកក ០៨ នាក់ ខេត្តប៉ាធុំថានី ០៣ នាក់ ខេត្តសមុទ្រប្រាកាន ០១ នាក់ ខេត្តនគររាជសីមា ០៣ នាក់ និង ខេត្តរ៉ាក់យ៉ង ០១ នាក់។ ក្រោយពេលឃាត់ខ្លួន ក្រុមយោធាថៃបានត្រួតពិនិត្យសុខភាពពួកគេទាំងអស់ និងបានបញ្ជូនទៅឱ្យអធិការដ្ឋានតម្រួតស្រុកតាប្រាក់យ៉ា ដើម្បីអនុវត្តតាមនីតិវិធី៕ អត្ថបទ៖ សោ និយមវត្ថ

## ថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២១

### ពលករឆ្លងដែនមកពីថៃកំណើនអ្នកឆ្លងកូវីដ-១៩ មានការថយចុះច្រើនជាងអ្នកឆ្លងក្នុងសហគមន៍

https://news.btv.com.kh/ 09/07/2021 10:09 AM

ឧត្តរមានជ័យ ៖ ចំនួនលំហូរពលករឆ្លងដែនមកពីថៃ តាមច្រកទ្វារព្រំដែនអូរស្មាច់ នៃខេត្តឧត្តរមានជ័យ មានការថយចុះច្រើនក្នុងមួយថ្ងៃមានត្រឹមតែ ១០០ជាងតែប៉ុណ្ណោះ ខណៈកំណើនអ្នកឆ្លងជំងឺកូវីដ-១៩ គឺមានការថយចុះច្រើនជាងចំនួនអ្នកឆ្លងក្នុងសហគមន៍ នាពេលបច្ចុប្បន្ននេះ។

លោកវេជ្ជបណ្ឌិត ឃ្លោក ហួត ប្រធានមន្ទីរសុខាភិបាលខេត្តឧត្តរមានជ័យ បានឲ្យដឹងថា បច្ចុប្បន្នស្ថានភាពចំពោះពលករឆ្លងដែនមកពីថៃ ដែលចូលមកករណីឆ្លងជំងឺកូវីដ-១៩មានការថយចុះច្រើន ក្នុងរយៈពេលដើមខែកញ្ញានេះ ដោយសារតែយើងអាចគ្រប់គ្រងស្ថានភាពលើចំនួនពលករចូលមកបាន ក៏ប៉ុន្តែចំពោះករណីឆ្លងក្នុងសហគមន៍វិញនោះហាក់បីមានការហក់ឡើងខ្ពស់បន្តិចនៅក្នុងភូមិស្រុកអន្លង់វែង នឹងស្រុកត្រពាំងប្រាសាទ។ លោក បានបន្តថា ដោយសារតែស្ថានភាពសហគមន៍យើងពិបាកក្នុងការគ្រប់គ្រង ចំពោះអ្នកធ្វើដំណើរដែលជាបញ្ហាមួយបណ្តាលឲ្យមានការឆ្លងច្រើនលឿនជាងពលករឆ្លងដែនមកពីថៃ នៅតាមបណ្តាស្រុកផ្សេងៗ ដោយក្នុងមួយថ្ងៃក្រុមគ្រូពេទ្យចុះស្រាវជ្រាវពិនិត្យរកឃើញមុខសញ្ញាអ្នកផ្ទុកវិរុសកូវីដ-១៩ មានមិនក្រោមពី១០០នាក់ ប៉ុន្តែពុំមានការឆ្លងប្រភេទជំងឺកូវីដបំប្លែងខ្លួនថ្មីប្រភេទ (delta) នោះទេ។

ជាមួយគ្នានោះដែរតាមការប្រកាសព័ត៌មានរបស់រដ្ឋបាលខេត្តឧត្តរមានជ័យ គិតត្រឹមវេលាម៉ោង ៧:៣០នាទីយប់ថ្ងៃទី៦កញ្ញា ឆ្នាំ២០២១ម្សិលមិញនេះ ចំនួនពលករឆ្លងដែនចូលមកមានចំនួន១១០នាក់ ស្រី៤២នាក់ រកឃើញវិជ្ជមានជំងឺកូវីដ-១៩ ចំនួន៦នាក់ ស្រី២នាក់ ។ ក្នុងនោះករណីឆ្លងសហគមន៍មានចំនួន ៦៤នាក់ករណីឆ្លងសរុបមានចំនួន៧០នាក់ និងជាសះស្បើយថ្មី៦០នាក់ អ្នកឆ្លងជំងឺកូវីដ-១៩ សរុបក្នុងខេត្តឧត្តរមានជ័យ កើនឡើងដល់ចំនួន ៧.១៤១ ករណី ក្នុងចំណោមនោះ ករណីអ្នកឆ្លងជំងឺបំប្លែងខ្លួនថ្មីប្រភេទ (delta) មានចំនួន២២៥ ករណី នឹង ៥.៧៧១ ករណីនាំចូលពីក្រៅ ៕ អត្ថបត្ត ៖ សារិទ្ធ

# ពលករខ្មែរជាង ១ ម៉ឺននាក់ វិលចូលស្រុកតាមច្រកព្រំដែនកម្ពុជា-ថៃនៃខេត្តឧត្តរមានជ័យ និងបន្ទាយមានជ័យ

https://m.postkhmer.com/ ឡាយ សាមាន07 September 2021 | 10:18 ICT

**ឧត្តរមានជ័យ/ប.មានជ័យៈ** ពលករខ្មែរជាង ១០០០០ នាក់ បានវិលត្រឡប់ចូលស្រុកកំណើតវិញតាមច្រកព្រំដែនកម្ពុជា-ថៃ នៃខេត្តឧត្តរមានជ័យ និងខេត្តបន្ទាយមានជ័យ គិតត្រឹមរយៈពេលជាង ២០ ថ្ងៃ បន្ទាប់ពីរាជរដ្ឋាភិបាលអនុញ្ញាតឱ្យបើកច្រកព្រំដែនឡើងវិញចាប់ពីថ្ងៃទី ១៣ ខែសីហា ដល់ថ្ងៃទី ៥ ខែ កញ្ញា ឆ្នាំ ២០២១។ ខេត្តឧត្តរមានជ័យ និងខេត្តបន្ទាយមានជ័យ គឺជាច្រកព្រំដែនកម្ពុជា-ថៃ ដែលមានពលករវិលត្រឡប់មកច្រើនជាងគេ ដោយគិតជាមធ្យមភាគក្នុង ១ ថ្ងៃ ពលករមកតាមខេត្តនេះមិនក្រោមពី ១០០ នាក់ទេ ពោលគឺ ចន្លោះពី ២០០ ទៅ ៣០០ នាក់ក្នុង ១ ខេត្ត។

អ្នកនាំពាក្យសាលាខេត្តឧត្តរមានជ័យ លោក ផល លឹម ប្រាប់ភ្នំពេញប៉ុស្តិ៍ នាថ្ងៃទី ៦ កញ្ញា ថា ពលករខ្មែរដែលធ្វើចំណាកស្រុកទៅធ្វើការនៅប្រទេសថៃនៅតែបន្តវិលចូលស្រុកកំណើតវិញមិនថមថយនោះទេ។ បើផ្អែកតាមរបាយការណ៍ដែលទទួលបានពីមន្ទីរសុខាភិបាលខេត្ត គឺក្នុង ១- ថ្ងៃមានពលករប្រមាណ ២០០ នាក់ ដែលបានវិលត្រឡប់តាមច្រកព្រំដែនខេត្តឧត្តរមានជ័យ។ លោកថ្លែងថា៖ «គិតចាប់ពីថ្ងៃបើកច្រកព្រំដែនឡើងវិញ ពោលចាប់ពីថ្ងៃទី ១៣ ខែសីហា ដល់ថ្ងៃទី ៥ ខែកញ្ញា ឆ្នាំ ២០២១ ពលករ ខ្មែរត្រឡប់ពីថៃវិញមានចំនួន ៦ ៤២៨ នាក់ ក្នុងនោះវិជ្ជមានកូវីដ ១៩ ចំនួន ៧៤០ នាក់»។ ទោះយ៉ាងណា លោកបញ្ជាក់ថា ពលករទាំងនោះសុទ្ធតែមកតាមច្រកព្រំដែនស្របច្បាប់ ដោយពុំសូវមានពលករមកតាមច្រករបៀងខុសច្បាប់នោះទេ។

លោកថាអាជ្ញាធរខេត្តបានរឹតបន្តឹង ច្រកព្រំដែនរបៀងទៅមក។ លោកប្រាប់ថា៖ «កាលពីថ្ងៃទី ៤ ខែកញ្ញានេះ លោកអភិបាលខេត្ត ប៉ែន កុសល្យ លោកបានចុះដើរមើលតាមច្រករបៀង និងបានណែនាំដល់កម្លាំងទាហានដែលបានដាក់ពង្រាយយាមកាមនៅទីនោះឱ្យខិតខំបំពេញការងារ ហើយបើសិនណាជាមានច្រករបៀងណាមានពលករលួច [ចេញ-ចូល] ទាហាននោះនឹងត្រូវវង់ពិន័យ ឬដកស័ក្តិ»។ លោកទទួលស្គាល់ថា នៅមុនកូវីដ ១៩ មកដល់ នៅតាមច្រករបៀងមានពលករលួចឆ្លងដែនខុសច្បាប់ច្រើន ប៉ុន្តែបន្ទាប់ពីអាជ្ញាធរខេត្ត បានដាក់វិធានការរឹតបន្តឹងច្រកព្រំដែនឡើងវិញ ពុំសូវមានពលករលួចឆ្លងដែនខុសច្បាប់នោះទេ។ លោកបញ្ជាក់ថា៖ «កាលពីមុនមានច្រើនដែរ តែឥឡូវអត់សូវមានពលករលួចឆ្លងដែនខុសច្បាប់ទៅថៃទេ បើមានក៏តិចដែរ ដូចកាលពីថ្ងៃទី ៣ ខែកញ្ញា ឆ្នាំ ២០២១ កម្លាំងទាហានថៃបានចាប់បញ្ជូនពលករខ្មែរម្នាក់ (ប្រុស) ដែលឆ្លងដែនចូលទឹកដី ថៃខុសច្បាប់ ហើយបច្ចុប្បន្ននាំគាត់ទៅធ្វើចត្តាឡីស័ក»។

ទន្ទឹមនឹងនេះ ប្រធានមន្ទីរព័ត៌មានខេត្តបន្ទាយមានជ័យ លោក សេក សុខុម ឱ្យដឹងថា ពលករខ្មែរ ដែលចូលតាមច្រកព្រំដែននៃខេត្តរបស់ខ្លួនមានជាង ៧ ០០០ នាក់។ លោកថា តាមការសង្កេតឃើញថា ពលករនឹងបន្តសម្រុកវិលចូលស្រុកកាន់តែច្រើនស្របពេលថៃជួបវិបត្តិកូវីដ ១៩។ លោកថ្លែងថា៖ «ចំនួនពលករ ដែលវិលចូលកម្ពុជាវិញនឹងបន្តកើនឡើងមិនថយទេ។ ព្រោះបើគិត ពីថ្ងៃបើកច្រកព្រំដែនវិញ ពលករមានជាង ៧ ០០០ នាក់ ហើយមកតាមខេត្តយើង ព្រោះការដ្ឋានមួយចំនួន និងក្រុមហ៊ុននៅថៃត្រូវបានបិទទ្វារ។ អ៊ីចឹងពលករបង្ខំចិត្តត្រឡប់កម្ពុជាវិញ»។ បើតាមលោកប្រធានមន្ទីរ មូលហេតុ ដែលនាំឱ្យពលករខ្មែរបន្តវិលត្រឡប់ចូលស្រុកកំណើត គឺដើម្បីជួបជុំជាមួយគ្រួសារ នាឱកាសបុណ្យភ្ជុំបិណ្ឌខាងមុខនេះ ហើយក៏ដើម្បីជួយធ្វើស្រែចម្ការ នៅរដូវវស្សាផងដែរ។

ភ្នំពេញប៉ុស្តិ៍មិនទាន់អាចរកតួលេខនៃចំនួនពលករ ដែលវិលត្រឡប់មកតាមបណ្ដាខេត្តជាប់ព្រំដែនកម្ពុជា-ថៃបាននៅឡើយទេ រីឯមន្ត្រីនាំពាក្យសាលាខេត្តប្រាប់ថា ពុំទាន់មានតួលេខក្នុងដៃនៅឡើយ។

នាយកប្រតិបត្តិមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (Central) លោក មឿន តុលា បានថ្លែងថា បញ្ហាចម្បងដែលជំរុញឱ្យពលករខ្មែរសម្រុកមកស្រុកកំណើតវិញយ៉ាងគំហុកនេះ ដោយសារនៅប្រទេសថៃមានការឆ្លងរាលដាលនៃជំងឺកូវីដ ១៩ កាន់តែខ្លាំង។ ហេតុនេះហើយនាំឱ្យរដ្ឋាភិបាលថៃសម្រេចបិទការដ្ឋានសំណង់ផ្សេងៗទាំងក្នុងក្រុង និងជាយក្រុង និងបិទទីតាំងមួយចំនួន ធ្វើឱ្យប៉ះពាល់ដល់ពលករខ្មែរដែលកំពុងបម្រើការងារក្នុងវិស័យនេះ។ លោក តុលា បាន ថ្លែងថា៖ «យើងដឹងហើយនៅប្រទេសថៃ ចំនួនពលករ ដែលទទួលបាន [ការ] ចាក់វ៉ាក់សាំងការពារជំងឺកូវីដ ១៩ បានចំនួនតិចនៅឡើយ។ ជាពិសេសពលករខ្មែរយើងដែលមានឯកសារត្រឹមត្រូវទទួលបាន [ការ] ចាក់វ៉ាក់សាំងតិចណាស់។ ដូច្នេះនៅពេលផ្ទុះកូវីដ ១៩ ជាពិសេសមេរោគបំប្លែងថ្មីដែលតា ធ្វើឱ្យមានការចលាចលខ្លាំង ជាពិសេសវិស័យការងារទើបធ្វើឱ្យពលករខ្មែរវិលចូលស្រុកវិញ»៕

## បន្ទាយមានជ័យមានអ្នកថ្មី ១០៩នាក់ ជាករណីនាំចូលទាំងអស់

https://www.khmertimeskh.com/ ខ្មែរថាមស៍ September 7, 2021

រដ្ឋបាលខេត្តបន្ទាយមានជ័យបានរាយការណ៍ពីការរកឃើញករណីឆ្លងថ្មីចំនួន ១០៩ករណី។ ករណីឆ្លងប្រចាំថ្ងៃដ៏ច្រើនសន្ធឹកសន្ធាប់នៅតែបន្តមាន នៅក្នុងខេត្តបន្ទាយមានជ័យ ពីព្រោះព្រំដែននៅក្នុងខេត្តនេះនៅតែបន្តជាច្រកចូលសំខាន់នៅកម្ពុជា។ ករណីឆ្លងថ្មីទាំងអស់ដែលរដ្ឋបាលខេត្តបានរាយការណ៍ គឺជាពលករខ្មែរដែលទើបត្រឡប់មកពីប្រទេសថៃ ហើយបច្ចុប្បន្នកំពុងសម្រាកព្យាបាលនៅមណ្ឌលចត្តាឡីស័កខេត្ត។ ករណីនាំចូលបន្តកើនឡើង បើទោះបីជាចំនួនមនុស្សដែលចូលមកប្រទេសថៃធ្លាក់ចុះក៏ដោយ។ ខេត្តបន្ទាយមានជ័យក៏បានរាយការណ៍ពីការផ្ទុះឡើងក្នុងសហគមន៍ នៅឃុំគោក ដែលមានករណីឆ្លងក្នុងសហគមន៍ចំនួន ៧០ករណី ក្នុងរយៈពេលបីថ្ងៃ នៅក្នុងភូមិចំនួនបីផងដែរ។ ទន្ទឹមនឹងនេះ ករណីឆ្លងក្នុងសហគមន៍ហាក់ដូចជាកើនឡើងនៅក្នុងខេត្តជាប់ព្រំដែនជាមួយនឹងការផ្ទុះឡើងនូវជំងឺកូវីដ-១៩ នៅក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ ចំនួនករណីឆ្លងក្នុងសហគមន៍នៅក្នុងក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ បានបញ្ឈប់ការបើកដំណើរការនូវផ្សារឡើងវិញ ខណៈករណីឆ្លងវីរុសបំប្លែងខ្លួនថ្មីបន្តផ្ទុះឡើង។ ខេត្តបន្ទាយមានជ័យមានករណីឆ្លងវីរុសបំប្លែងខ្លួនថ្មីសរុបចំនួន ៥២៦ ករណី ដែលជាតួលេខខ្ពស់បំផុតបន្ទាប់ពីទីក្រុងភ្នំពេញ៕

## ឧត្តរមានជ័យ មានពលករ ត្រឡប់ពីថៃ រង្វង់១០០នាក់ ក្នុងមួយថ្ងៃ ខណៈរកឃើញកូវីដ ចន្លោះពី១០ ទៅ២០នាក់

https://www.kampucheathmey.com/ ថ្ងៃអង្គារ ៧ កញ្ញា ២០២១ដោយ sopheak khoun

អាជ្ញាធរខេត្តឧត្តរមានជ័យ បានឲ្យដឹងថា ចាប់ពីដើមខែកញ្ញានេះមក មានពលករត្រឡប់មកពីប្រទេសថៃចូលមកមូលដ្ឋានខេត្តឧត្តរមានជ័យ មានចំនួនក្នុងរង្វង់១០០នាក់ប៉ុណ្ណោះ ក្នុងមួយថ្ងៃ ដែលខុសគ្នាច្រើន នៅពេលមានការបើកព្រំដែនភ្លាមៗ ដោយថ្ងៃខ្លះមានពលករត្រឡប់មកវិញ ក្នុងរង្វង់៣០០នាក់ឯណោះ ក្នុងមួយថ្ងៃ។

លោក ឌី រ៉ាដូ អភិបាលរង និងជាអ្នកនាំពាក្យ រដ្ឋបាលខេត្តឧត្តរមានជ័យ មានប្រសាសន៍ប្រាប់អ្នកសារព័ត៌មានកម្ពុជាថ្មី នៅថ្ងៃទី៧ ខែកញ្ញានេះថា ការវិលត្រឡប់របស់ពលករខ្មែរ មកពីប្រទេសថៃ មានការថយចុះច្រើនចាប់ពីដើមខែកញ្ញាមក ដោយក្នុងមួយថ្ងៃ មានក្នុងរង្វង់១០០នាក់ ហើយក្នុងចំណោមនោះ រកឃើញវិជ្ជមានកូវីដ-១៩ ក្នុងរង្វង់ពី១០ ទៅ២០នាក់ប៉ុណ្ណោះ។ លោក ឌី រ៉ាដូ មានប្រសាសន៍បន្តថា «ជាការកត់សម្គាល់នេះ យើងឃើញថា បើយើងប្រៀបធៀប ពីពេល យើងទើបនឹងបើកព្រំដែនថ្មីៗ ឃើញថា សន្ទុះពលករនៅពេលនេះ គឺថា ថយច្រើន យើងពិនិត្យមើលតួលេខ ដើមខែ៩នេះ គឺថា ក្នុងរង្វង់១០០នាក់ទេ ជាង១០០នាក់អញ្ចឹងទេ...តាមការពិនិត្យ

មើលរបាយការណ៍ ឃើញថា ការពិនិត្យលើពលករ ពាក់ព័ន្ធនឹងកូវីដ-១៩ហ្នឹង ឃើញថា មានចំនួនមិនច្រើនទេ ក្នុងរង្វង់១០ ទៅ ២០នាក់ទេ បើយើងប្រៀបពីមុន គឺច្រើន ៣០០នាក់ រកឃើញ១០០ជាង»។ អភិបាលរង ខេត្តឧត្តរមានជ័យ បានមានប្រសាសន៍ឲ្យដឹងបន្តថា គិតមកដល់ពេលនេះ ខេត្តឧត្តរមានជ័យ បានរកឃើញអ្នកវិជ្ជមានកូវីដ-១៩ ជាង៧ពាន់នាក់ និងជាសះស្បើយជាង៣ពាន់ ៤នាក់។ ចំពោះប្រជា ពលរដ្ឋ ក៏ដូចជាពលករ ដែលកំពុងធ្វើចត្តាឡីស័ក នៅក្នុងខេត្តឧត្តរមានជ័យ មានចំនួនជិត ៣ពាន់នាក់។

ឆ្លើយតបនឹងការលើកឡើង អំពីការធ្វើចត្តាឡីស័ក រយៈពេលយូរថ្ងៃនោះ ត្រូវបានលោក ឌី រ៉ាដូ អ្នកនាំពាក្យរដ្ឋបាលខេត្តឧត្តរមានជ័យ បញ្ជាក់ថា តាមគោលការណ៍ គឺត្រូវធ្វើចត្តាឡីស័ករយៈពេល២១ថ្ងៃ ហើយប្រសិន បើបុគ្គលនោះ រកឃើញវិជ្ជមានកូវីដ-១៩ នឹងត្រូវចាប់ផ្តើមរាប់ថ្ងៃទី១ឡើងវិញ។ លោកមានប្រសាសន៍ថា «ជាការគោលការណ៍ របស់ក្រសួងសុខាភិបាល គឺថា ពាក់ព័ន្ធនឹងបងប្អូនពលករ ដែលវិលត្រឡប់មកពីប្រទេសថៃវិញ គឺតម្រូវឲ្យធ្វើចត្តាឡីស័កហ្នឹង រយៈពេល២១ថ្ងៃ ជាគោលការណ៍ណា ប៉ុន្តែករណីឧទាហរណ៍ថា ដល់ថ្ងៃទី៧ គាត់ត្រូវយកសំណាកតេស្ត បើសិនជាពិនិត្យឃើញថា គាត់មានវិជ្ជមាន ជំងឺកូវីដ-១៩ គឺយើងត្រូវបន្តទៀត យើងរាប់ពីថ្ងៃទី១ឡើងវិញ រហូតដល់២១ថ្ងៃ»។ អ្នកនាំពាក្យ រដ្ឋបាលខេត្តឧត្តរមានជ័យ បានគូសបញ្ជាក់ថា គិតមកដល់ពេលនេះ អាជ្ញាធរខេត្តឧត្តរមានជ័យ អាចគ្រប់គ្រង លើស្ថានការណ៍ នៃការឆ្លងរាលដាល ជំងឺកូវីដ-១៩បានហើយ មិនមានការឆ្លងធ្ងន់ធ្ងរ ដូចមុនទៀតទេ៕ អត្ថបទ៖ ឃួន សុភ័ក្រ

## ពលរដ្ឋខ្មែរ១៦នាក់ត្រូវចាប់ខ្លួន ក្រោយត្រូវមេខ្យល់នាំដើរកាត់ព្រៃឆ្លងដែន

https://kohsantepheapdaily.com.kh/ បន្ទាយមានជ័យ០៧ ខែ កញ្ញា ឆ្នាំ ២០២១ ម៉ោង ១៤:៤១

ខេត្តបន្ទាយមានជ័យ ៖ ពលករខ្មែរយ៉ាងតិច១៦នាក់ ត្រូវបានកម្លាំងទាហាន និងតម្រួតព្រំដែនថៃធ្វើការចាប់ខ្លួនក្នុងឃុំ និងស្រុកតាប្រាយ៉ា ខេត្តស្រះកែវ ជាប់ព្រំដែនកម្ពុជា ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ កាលពីព្រឹកថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០២១ ក្រោយពួកគេចាញ់បោកមេខ្យល់នាំដើរកាត់ព្រៃចូលទឹកដីថៃបម្រុងទៅរកការងារធ្វើ។ ពលករទាំងនេះមិនត្រូវបានគេប្រាប់ឲ្យស្គាល់អត្តសញ្ញាណនោះទេ ដោយមានប្រុស៩នាក់ និងស្រី៧នាក់ មកពីខេត្តបន្ទាយមានជ័យ នេះបើយោងតាមការចុះផ្សាយលើគេហទំព័រថៃមួយ។ ប្រភពព័ត៌មានបានឱ្យដឹងបន្តថា ក្រោយឃាត់ខ្លួនពលករទាំងនេះ ប្រាប់សមត្ថកិច្ចថៃថា ពួកគេបានចេញពីកម្ពុជា តាមច្រករបៀងមួយ ដោយមេខ្យល់នាំដើរកាត់ព្រៃ និងវាលស្រែ លុះចូលដល់ដីថៃក្នុងភូមិណាង៉ាម និងកំពុងរង់ចាំឡើងរថយន្តឆ្ពោះទៅកាន់គោលដៅខេត្តចំនួន៥ ដើម្បីរកការងារធ្វើ ស្រាប់តែត្រូវសមត្ថកិច្ចចាប់ខ្លួនតែម្តង។ ពួកគេ បានប្រាប់បន្តថា គេបានចំណាយប្រាក់ឲ្យមេខ្យល់រួចហើយ ដោយអ្នកខ្លះអស់៤៥០០បាត និងអ្នកខ្លះទៀតចំណាយលើសនេះ តាមគោលដៅដែលត្រូវទៅឆ្ងាយ ឬជិត។ ក្រោយឃាត់ខ្លួន ពលករទាំងនេះ ត្រូវសមត្ថកិច្ចចម្រុះថៃដំណើរការត្រួតពិនិត្យសុខភាពតាមវិធានការរបស់ក្រសួងសុខាភិបាលរបស់គេ មុនពេលប្រគល់ជូនសមត្ថកិច្ចជំនាញចាត់ការបន្ត។

គួរបញ្ជាក់ថា មួយរយៈចុងក្រោយនេះ ប្រទេសថៃកំពុងជួបបញ្ហាធ្ងន់ធ្ងររឿងជំងឺកូវីដ១៩ ដោយមួយថ្ងៃៗមានអ្នកឆ្លង និងស្លា.ប់ជាច្រើននាក់។ ហើយពលករមិនតិចទេ បានសម្រុកវិលត្រឡប់ពីប្រទេសថៃមកមាតុប្រទេសវិញតាមខេត្តជាប់ព្រំដែន។ ម្យ៉ាងភាគីទាំង២ កម្ពុជា-ថៃក៏បានរឹតបណ្តឹងតាមបន្ទាត់ព្រំដែនផងដែរ ចុះហេតុអ្វីពលករទាំង១៦នាក់ខាងលើនៅតែប្រថុយប្រថានឆ្លងដែនខុសច្បាប់បែបនេះ? ទីបំផុតប្រាក់ក៏បង់ ថង់ក៏ជាប់ ពោលគឺប្រាក់ក៏អស់មិនបានដល់គោលដៅ ហើយត្រូវសមត្ថកិច្ចថៃចាប់ខ្លួនទៀត៕

## មេខ្យល់២នាក់ ត្រូវឃាត់ខ្លួន ខណៈធ្វើនលឹងច្បាប់នាំពលករឆ្លងដែនខុសច្បាប់

https://www.kampucheathmey.com/ ថ្ងៃអង្គារ ៧ កញ្ញា ២០២១ដោយ Sorn Phanith

សមត្ថកិច្ចឈរជើងតាមបន្ទាត់ព្រំដែន បានឃាត់មេខ្យល់២នាក់ ដែលបម្រុងនាំពលករច្រើននាក់ ឆ្លងដែនខុសច្បាប់ទៅប្រទេសថៃ ដើម្បីកសាងសំណុំរឿងបន្តតាមនីតិវិធីផ្លូវច្បាប់។

លោកវរសេនីយ៍ឯក ហេង បារាំង អធិការនគរបាលស្រុកភ្នំព្រឹក បានឲ្យដឹងថា ការបង្ក្រាបឃាត់ខ្លួនជនសង្ស័យជាមេខ្យល់ទាំង២នាក់ ក្នុងចំណោមពលករជាច្រើននាក់នេះ ធ្វើឡើងចំនួន២ទីតាំងផ្សេងគ្នា កាលពីថ្ងៃទី០៥ និងថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២១ ដោយករណីទី១កម្លាំងផ្នែកជំនាញ បានចុះស្រាវជ្រាវរហូតកំណត់មុខសញ្ញាឃាត់ខ្លួនពលករខ្មែរ បានចំនួន៩នាក់ ខណៈដែលពួកគេប្រុងឆ្លងដែនចូលប្រទេសថៃ នៅត្រង់ចំណុចច្រកទ្វារព្រំដែនអូររំដួល ក្នុងភូមិអូរថ្មីយុ ឃុំពេជ្រចិន្តា និងករណីទី២ឃាត់ខ្លួន បានបុរសមេខ្យល់ចំនួន២នាក់ទៀត នៅត្រង់ចំណុចរង្វង់មូល ក្នុងភូមិភ្នំតូចឃុំពេជ្រចិន្តា ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ដែលអ្នកទាំង២នាក់ជាអ្នកនាំពលករទាំង៩នាក់ ចូលទៅប្រទេសថៃ។

ប្រតិបត្តិបង្ក្រាបខាងលើនេះ នគរបាលស្រុកភ្នំព្រឹកឃាត់ខ្លួនបានអ្នកពាក់ព័ន្ធសរុបចំនួន១១នាក់ ប្រុសចំនួន៣ ស្ត្រី០៥នាក់ រួមទាំងក្មេងចំនួន០៣នាក់ ផងដែរ។ ប្រភពនគរបាលដដែលបានបញ្ជាក់ថា បុរសជាមេខ្យល់ទាំង០២នាក់ ត្រូវបានផ្នែកជំនាញរៀបចំបែបបទបញ្ជូនមកកាន់ការិយាល័យជំនាញ ដើម្បីអនុវត្តបន្តតាមផ្លូវច្បាប់៕

## តុលាការឧទ្ធរណ៍ ជម្រះបណ្ដឹង ជនជាប់ចោទ០២ នាក់ ប្ដីប្រពន្ធ ជាប់ពាក់ព័ន្ធនឹងករណីបើកហាងលក់សាច់អាំង តែបន្លប់សេវាភេទ !!!!

https://cen.com.kh/ Posted ByPen Srey NeatSeptember 7, 2021

ភ្នំពេញ ៖ តុលាការឧទ្ធរណ៍ភ្នំពេញ កាលពីព្រឹកថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ២០២១ បានបើកសវនាការជំនុំជម្រះ លើបណ្ដឹងឧទ្ធរណ៍ របស់ជនជាប់ចោទ ០២ នាក់ ប្ដីប្រពន្ធ ដែលត្រូវបានតុលាការថ្នាក់ក្រោម កាត់ទោសដាក់ពន្ធនាគារកំណត់ ម្នាក់ៗ ០៧ឆ្នាំ ជាប់ពាក់ព័ន្ធនឹងបទល្មើស សញ្ជារកម្ម មានស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ ប្រព្រឹត្តិកាលពីអំឡុងឆ្នាំ ២០២០។

លោកស៊ិន វិសាល ប្រធានចៅក្រមប្រឹក្សាជំនុំជម្រះ នៃ សាលាឧទ្ធរណ៍ភ្នំពេញ បានឲ្យដឹងថា ជនជាប់ចោទប្ដីប្រពន្ធ ០២ នាក់ខាងលើ មានឈ្មោះ សឹក សុភាពភេទប្រុស អាយុ ៤១ឆ្នាំ និង ប្រពន្ធ ឈ្មោះ កប សុផាតអាយុ ៣៨ ឆ្នាំ។ ជនជាប់ចោទទាំង ០២ ត្រូវបានសមត្ថកិច្ចឃាត់ខ្លួនកាលពី ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២០ នៅត្រង់ក្នុងចំណុចហាងរបស់ពួកគេ ដែលមានទីតាំងស្ថិតក្នុង សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។ ពួកគេត្រូវបានតុលាការរាជធានីភ្នំពេញ កាលពីខែសីហាឆ្នាំ ២០២០ កាត់ទោសដាក់ពន្ធនាគា ក្នុងម្នាក់ៗ កំណត់ ០៧ ឆ្នាំ តែពួកគេបានប្តឹងខ្មាស់មកកាន់សាលាឧទ្ធរណ៍។

នាពេលសវនាការ ជនជាប់ចោទទាំង០២នាក់ ប្ដីប្រពន្ធ បានឆ្លើយបដិសេធចំពោះបទចោទប្រកាន់ខាងលើ និង និយាយថា ពួកគេមិនប្រព្រឹត្តអ្វី ដូចការចោទប្រកាន់នោះទេ។ ពួកគេនិយាយទៀតថា ពួកគាត់ក៏មិនបានដឹង ឬយកលុយពីក្មេងស្រីៗ ដែលធ្វើការជាមួយខ្លួន ឬទទួលបានកុំមីស្យុង លុយកាក់ពីពួកនាងៗនោះ ដែរ។ ពួកគេ បានសុំឲ្យតុលាការឧទ្ធរណ៍ មេត្តាលើកការចោទប្រកាន់ និងសម្រេចដោះលែងខ្លួន ឲ្យមានសេរីភាពវិញ ដើម្បីធាប់បានវិលត្រឡប់ទៅមើលថែទាំ កូនតូចៗដែលកំពុងតែកំព្រាមេបាវិញ។ សំណុំរឿងក្ដីនេះ សាលាឧទ្ធរណ៍នឹងប្រកាសសាលដីកា នៅថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០២១ វេលាម៉ោង ៨ ព្រឹក៕ រក្សាសិទ្ធិដោយ ៖ ចន្ទា ភា

## ពលករនៅតាមព្រំដែនកម្ពុជា-ថៃ ៨៧៩នាក់ត្រូវបានដឹកទៅដល់បណ្តាខេត្តគោលដៅក្នុងថ្ងៃនេះ

https://swiftnewsdaily.com/ SWIFT NEWS ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២១

(ភ្នំពេញ)៖ នៅថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០២១នេះ កងពលតូចដឹកជញ្ជូនលេខ៩០ នៃកងទ័ពជើងគោក បានប្រើរថយន្តកងទ័ពដឹកជញ្ជូនពលករចំណាកស្រុកនៅតាមព្រំដែនកម្ពុជា-ថៃ មកដាក់នៅតាមបណ្តាខេត្តនានា បានចំនួន៨៧៩នាក់ ដែលស្មើនិង១០៤ជើង។ អនុវត្តតាមបទបញ្ជាដ៏ខ្ពង់ខ្ពស់ ឧត្តមសេនីយ៍ឯក ហ៊ុន ម៉ាណែត អគ្គមេបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ មេបញ្ជាការកងទ័ពជើងគោក ក្នុងនោះកងពលតូចដឹកជញ្ជូនលេខ៩០ ដែលដឹកនាំដោយ ឧត្តមសេនីយ៍ទោ ឈរ សុខ នាយសេនាធិការរងកងទ័ពជើងគោក មេបញ្ជាការ កងពលតូចដឹកជញ្ជូនលេខ៩០ និងកងកម្លាំងជំនាញដឹកជញ្ជូន ដែលបានចាត់តាំងក្នុងបេសកកម្មនេះ នៅបន្តអនុវត្តយ៉ាងយកចិត្តទុកដាក់ និងប្រកបដោយការទទួលខុសត្រូវខ្ពស់ ក្នុងការដឹកពលករខ្មែរ ទៅដាក់នៅតាមបណ្តាគោលដៅដែលបានកំណត់ ទាន់ពេលវេលា និងប្រកបដោយសុវត្ថិភាព។

សូមជម្រាបបថា កងពលតូចដឹកជញ្ជូនលេខ៩០ កងទ័ពជើងគោក ជាអង្គភាពជំនាញដឹកជញ្ជូនសម្ភារៈកម្លាំងទ័ព ធានាបម្រើប្រយុទ្ធ បច្ចុប្បន្នកំពុងទទួលបទបញ្ជាដឹកពលករចំណាកស្រុកនៅតាមព្រំដែនកម្ពុជា-ថៃ មកដាក់នៅតាមបណ្តាខេត្តនានា ដែលជាវិធានការមួយរបស់រដ្ឋាភិបាល ក្នុងការទប់ស្កាត់ការឆ្លងរីករាលដាលជំងឺកូវីដ-១៩ ចូលសហគមន៍ តាមរយៈពលករចំណាកស្រុកទាំងនោះ៕ ដោយៈអោម ចែតច័ន្ទណារ៉ា

# ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២១

## ឧត្តរមានជ័យៈពលករខ្មែរជិត១០ម៉ឺននាក់វិលចូលស្រុកកំណើតតាមច្រកអន្តរជាតិពីរ

https://www.rasmeinews.com/ 7 September, 2021

*ដោយៈអូរស្មាច់/ឧត្តរមានជ័យៈ នៅថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០២១ លោក ប៉ែន កុសល្យ អភិបាលខេត្តឧត្តរមានជ័យ បានមានប្រសាសន៍ថា គិតចាប់ពីថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២០ ដល់ថ្ងៃទី៦ ខែកញ្ញា ឆ្នាំ០២១មានប្រជាពលពលរដ្ឋ និងពលករខ្មែរដែលបានឆ្លងដែនពីប្រទេសថៃ ចូលតាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ (ក្រុងសំរោង) និងច្រកទ្វារព្រំដែនអន្តរជាតិជាំសាង៉ាំ (ស្រុកអន្លង់វែង) ដែលអាជ្ញាធរថៃអនុញ្ញាតឱ្យចេញ មានចំនួន៩៨.៤៧២នាក់ (ស្រី ៤៤.០៦៩នាក់)ហើយរដ្ឋបាលខេត្តនេះបានប្រើប្រាស់មណ្ឌលចត្តាឡីស័កចំនួន២០ទីតាំង, មណ្ឌលព្យាបាលចំនួន១៣ទីតាំង។*

ថ្លែងក្នុងកិច្ចប្រជុំគណៈកម្មការប្រយុទ្ធប្រឆាំងជំងឺកូវីដ១៩ ខេត្តឧត្តរមានជ័យ តាមប្រព័ន្ធវីដេអូលោកអភិបាលខេត្ត បានបន្តថា ក្រុមគ្រូពេទ្យក្នុងខេត្តនេះក៏បានរកឃើញករណីកូវីដ១៩ សរុបចំនួន៧.១៤១នាក់។ ក្នុងនោះមានករណីនាំចូលចំនួន ៥.៧៧១នាក់ និងករណីសហគមន៍ចំនួន១.៣៧០នាក់, បានសម្រាកព្យាបាលចំនួន៤.៩៥៧នាក់,ជាសះស្បើយ ចំនួន៣.៤៦០នាក់,ស្លាប់១៤នាក់ និងកំពុងសម្រាក ព្យាបាលបច្ចុប្បន្នចំនួន១.៤៨៣នាក់។ លោកអភិបាលខេត្តបញ្ជាក់ថា សម្រាប់ការងារចាក់វ៉ាក់សាំងមានប្រជាពលរដ្ឋសរុបប្រមាណចំនួន១៩៣.០១៣នាក់ ទទួលការចាក់វ៉ាក់សាំងបង្ការការពារជំងឺកូវីដ-១៩ បានជាងចំនួន១៦ម៉ឺននាក់ស្មើជាង៨០ភាគរយមកដល់ពេល នេះ៕សរន

## កងកម្លាំងប៉ូវ៉ាផា បានចាប់ឃាត់ខ្លួនពលរដ្ឋខ្មែរលួចឆ្លងដែនចូលប្រទេសថៃ ដោយខុសច្បាប់ចំនួន 4នាក់

https://www.facebook.com/Khmer.Channel.kh/ 08/09/2021

ថ្ងៃទី07 ខែកញ្ញា ឆ្នាំ2021កងកម្លាំងប៉ូវ៉ាផា បានចាប់ឃាត់ខ្លួនពលរដ្ឋខ្មែរលួចឆ្លងដែនចូលប្រទេសថៃដោយខុសច្បាប់ចំនួន 4នាក់(ប្រុស3នាក់-ស្រី1នាក់) នៅបរិវេណក្រុមទី8 ភូមិខៅឱន ឃុំខ្លងហាត ស្រុកខ្លងហាត ខេត្តស្រះកែវ។ បន្ទាប់ពីអាជ្ញាធរធ្វើការសាកសួរពលរដ្ឋទាំងអស់ធ្វើដំណើរមកពីខេត្តបាត់ដំបង ដើម្បីចូលទៅធ្វើការនៅប៉ែកខាងក្នុងប្រទេសថៃ បន្ទាប់មក ត្រូវអាជ្ញាធរបញ្ជូនទៅចាត់វិធានការបន្តតាមផ្លូវច្បាប់។

## ១សប្ដាហ៍ដើមខែកញ្ញា ពលករខ្មែរមកពីថៃ ចូលតាមច្រកខេត្តបាត់ដំបង មានជាង៤00នាក់ រកឃើញវិជ្ជមានកូវីដ១៩ ជាង២0នាក់

https://news.btv.com.kh/ 09/08/2021 10:09 AM

បាត់ដំបង៖ ក្នុងរយៈពេល១សប្ដាហ៍ ដើមខែកញ្ញា ឆ្នាំ ២០២១នេះ ពលករខ្មែរវិលត្រឡប់មកពីប្រទេសថៃចូលតាមច្រកព្រំដែននានា ក្នុងភូមិសាស្ត្រខេត្តបាត់ដំបង មានចំនួន៤១០នាក់ ក្នុងនោះ បានរកឃើញវិជ្ជមានជំងឺកូវីដ១៩ ចំនួន២៦នាក់ផងដែរ។

លោក សឿម ប៊ុនរិទ្ធិ អភិបាលរងខេត្ត និងជាអ្នកនាំពាក្យរដ្ឋបាលខេត្តបាត់ដំបង បានថ្លែងថា ពលករខ្មែរទាំងអស់ដែលវិលត្រឡប់មកពីប្រទេសថៃវិញ តាមច្រកខេត្តបាត់ដំបង ត្រូវបាន ក្រុមគ្រូពេទ្យ យកសំណាក និងធ្វើតេស្តរហ័សនៅចំណុចព្រំដែន ក្នុងករណីមានលទ្ធផលវិជ្ជមាន ក្រុមការងារនឹងរៀបចំដាក់ព្យាបាលក្នុងមណ្ឌលនៅតាមព្រំដែន.។ ចំណែកអ្នកអវិជ្ជមាន នឹងបញ្ជូនពួកគាត់ទៅធ្វើចត្តាឡីស័កក្នុងមណ្ឌលនានាតាមបណ្ដោយព្រំដែនចំនួន១៤ថ្ងៃ រួចផ្ទេរបន្តមកធ្វើចត្តាឡីស័កនៅជិតទីរួមខេត្ត ចំនួន៧ថ្ងៃបន្ថែមទៀត មុននឹងធ្វើការដឹកជញ្ជូនពួកគាត់ទៅកាន់បណ្ដាស្រុក ឬខេត្តកំណើតរៀងៗខ្លួន ។

គួរកត់សម្គាល់ថា ទោះបីជាមានពលករខ្មែរវិលត្រឡប់មកពីប្រទេសថៃវិញជាបន្តបន្ទាប់ ប៉ុន្តែស្របពេលជាមួយគ្នានេះ ជារឿយៗក៏មានមេខ្យល់មួយចំនួននៅបន្តលួចនាំពលរដ្ឋខ្មែរឆ្លងដែនចូលទៅធ្វើការដោយខុសច្បាប់នៅក្នុងប្រទេសថៃ ខណៈមេខ្យល់ទាំងនោះត្រូវបានកម្លាំងសមត្ថកិច្ចឈរជើងប្រចាំការនៅតាមបន្ទាត់ព្រំដែន ធ្វើការបង្ក្រាប និងអនុវត្តន៍ទៅតាមនីតិវិធីច្បាប់ ចំណែកពលរដ្ឋត្រូវបានធ្វើការ អប់រំណែនាំ និងបញ្ជូនត្រឡប់ទៅស្រុកកំណើតរៀងៗខ្លួនវិញ។

ពលករដែលកំពុងធ្វើចត្តាឡីស័កនៅតាមមណ្ឌលនានា ក្នុងខេត្តបាត់ដំបងភាគច្រើនជាពលករដែលត្រូវបានផ្ទេរមកពីបណ្ដាខេត្តផ្សេងៗ ជាពិសេសខេត្តឧត្តរមានជ័យ និងបន្ទាយមានជ័យជាដើម ខណៈមណ្ឌលស្ទើរទាំងអស់មានសភាពធូរស្រាល មិនចង្អៀតណែននោះទេ ហើយមណ្ឌលខ្លះទៀតនៅទំនេរទៀតផង។ អត្រាឆ្លងជំងឺកូវីដ១៩ថ្មីក្នុងខេត្តបាត់ដំបង នាប៉ុន្មានថ្ងៃចុងក្រោយនេះ មានចំនួនកើនឡើងបន្តិចវិញ ប៉ុន្តែស្ថិតក្នុងសភាពមួយធូរស្រាលមិនគួរឲ្យព្រួយបារម្ភនោះទេ។ រហូតមកដល់ពេលនេះ ខេត្តបាត់ដំបង បានរកឃើញអ្នកឆ្លងជំងឺកូវីដ១៩ សរុបចំនួន៦ ៣០៦នាក់ ក្នុងនោះបានព្យាបាលជាសះស្បើយចំនួន ៥ ២២១នាក់ កំពុងសម្រាកព្យាបាល៩៩៨នាក់ និងស្លាប់ចំនួន៨៧នាក់៕

# សាលាឧទ្ធរណ៍តម្កល់ទោស ស្ត្រីជាប់ចោទម្នាក់ ដាក់គុក ០៧ ឆ្នាំ ជាប់ពាក់ព័ន្ធនឹងការជួញដូរ ស្ត្រីខ្មែរ១៥នាក់ ទៅរៀបការប្តីនៅចិន !!

https://cen.com.kh/ Posted ByPen Srey NeatSeptember 8, 2021

ភ្នំពេញ ៖ សាលាឧទ្ធរណ៍ភ្នំពេញ កាលពីព្រឹកថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ២០២១ បានបើកសវនាការ ប្រកាសសាលដីការ លើបណ្តឹងឧទ្ធរណ៍ របស់ស្ត្រីជាប់ចោទម្នាក់ ដែលត្រូវបានតុលាការរាជធានីភ្នំពេញ កាត់ទោសដាក់ពន្ធនាគារ ០៧ ឆ្នាំ ជាប់ពាក់ព័ន្ធបទល្មើស« ការនាំចេញដោយមិនស្របច្បាប់ ដោយមានគោលដៅ» ប្រព្រឹត្តនៅក្នុងរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ ២០១៧ ដល់ ២០១៨ ។ សាលាឧទ្ធរណ៍ភ្នំពេញ បានសម្រេចតម្កល់សាលក្រមរបស់ តុលាការរាជធានីភ្នំពេញ រក្សាទុកជាបានការដដែល តែប្រកាសបើកផ្លូវឲ្យជនជាប់ ប្តឹងសារទុក្ខ ទៅកាន់តុលាការកំពូល តាមនីតិវិធីច្បាប់។

លោកជំទាវ គឹម ដានី ជាប្រធានចៅក្រមប្រឹក្សាជំនុំជម្រះ នៃសាលាឧទ្ធរណ៍ភ្នំពេញ បានថ្លែងដឹងនៅក្នុងសវនាការថា ជនជាប់ចោទមានឈ្មោះ ស៊ុ សុគន្ធា ភេទ ស្រី អាយុ ៣៧ ឆ្នាំ ។ ជនជាប់ចោទ ត្រូវបានសាលាដំបូងរាជធានីភ្នំពេញ សម្រេចផ្តន្ទាទោស ដាក់ពន្ធនាគារកំណត់ ០៧ ឆ្នាំ អំឡុង ២០១៩ និង បង្គាប់ឲ្យសងជម្ងឺចិត្តដល់ជនរងគ្រោះ ម្នាក់ៗ ចំនួន ២០ លានរៀល ពីបទ« ការនាំចេញដោយមិនស្របច្បាប់ដោយមានគោលដៅ » តាមបញ្ញត្តិមាត្រា ១០ នៃ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ។ តែជនជាប់ចោទ បានប្តឹងជំទាស់មកសាលាឧទ្ធរណ៍ដើម្បីសុំបន្ធូរបន្ថយទោស។

ជនជាប់ចោទឈ្មោះ ស៊ុ សុគន្ធា ត្រូវបាន សមត្ថកិច្ចចាប់ឃាត់ខ្លួន និង បញ្ជូនទៅតុលាការសម្រាប់ចោទប្រកាន់ និងត្រូវបានសម្រេចឃុំខ្លួន នៅអំឡុងឆ្នាំ ២០១៩ ជាប់ពាក់ព័ន្ធនឹងការជ្រើសរើសស្ត្រី ជនជាតិខ្មែរ ចំនួន១៥នាក់ អោយទៅប្រទេសចិន ដើម្បីរៀបការប្តីចិន ព្រោះមានលុយច្រើន តែពេលទៅជនរងគ្រោះ បានទៅដល់ប្រទេសចិន ពួកគេត្រូវបានគេលក់ដូរ ពីបុរសចិនមួយទៅបុរសចិនមួយ ដូចសត្វធាតុ ដើម្បីគ្រាន់តែបំពេញការសប្បាយផ្លូវភេទ និង កាមគុណរបស់ពួកប្រុសៗចិន អស់រយៈពេលជាច្រើនឆ្នាំ នៅក្នុងប្រទេសចិន។ ជនជាប់ចោទឈ្មោះ ស៊ុ សុគន្ធា ក្រោយមកត្រូវបានចាប់ឃាត់ខ្លួន នៅក្នុងអំឡុងឆ្នាំ ២០១៩ តាមបណ្តឹងនារីរងគ្រោះ បន្ទាប់ពីពួកគេត្រូវមន្ត្រីស្ថានទូតខ្មែរ ប្រចាំនៅចិនសហការជាមួយសមត្ថកិច្ចនគរបាលចិន ជួយសង្គ្រោះ និង បានបញ្ជូនពួកគេវិលត្រឡប់ មកកាន់ប្រទេសកម្ពុជាវិញ នៅក្នុងឆ្នាំ ២០១៩។

នាពេលសវនាការ ជនជាប់ចោទ ឈ្មោះស៊ុ សុគន្ធា បានឆ្លើយបដិសេធចំពោះ ការចោទប្រកាបន់ខាងលើ និង និយាយថា ខ្លួនមិនបានប្រព្រឹត្តិ អំពើដូចការចោទប្រកាន់ទេ។ ទោះជាយ៉ាងណាក្តី ជនជាប់ចោទ ឈ្មោះស៊ុ សុគន្ធា បានទទួលស្គាល់ថា ខ្លួនពិតបានជួយ សម្រួល និង ជួយបកប្រែ ជាភាសាចិនអោយពួកកគេ អោយបុរសចិនម្នាក់(គេចខ្លួន) ដែលជា អ្នកជ្រើសរើស ជនរងគ្រោះ ទៅរៀបការប្តីនៅចិនតែ ប៉ុណ្ណោះ។រក្សាសិទ្ធិ ដោយ ៖ចន្ទា ភា

# ក្រសួងកិច្ចការនារីជ្រើសរើស យកខេត្តសៀមរាប ជាខេត្តគំរូ ទប់ស្កាត់អំពើហិង្សា

https://swiftnewsdaily.com/ SWIFT NEWS ថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២១

(សៀមរាប)៖ រដ្ឋបាលខេត្តសៀមរាប បានបើកកិច្ចប្រជុំផ្សព្វផ្សាយសមាសភាព ក្រុមការងារឆ្លើយតប ជាពហុវិស័យ ចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ ក្នុងនោះ ក្រសួងកិច្ចការនារីជ្រើសរើស យកខេត្តសៀមរាប ជាខេត្តគំរូ ទប់ស្កាត់អំពើហង្សា។ នេះបើយោងតាមមន្ទីរព័ត៌មាន ខេត្តសៀមរាប។ រដ្ឋបាលខេត្តសៀមរាប បានបើកកិច្ចប្រជុំផ្សព្វផ្សាយសមាសភាពក្រុមការងារឆ្លើយតបជាពហុវិស័យ ចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ តាមប្រពន្ធ័វីដេអូបញ្ជូនរូបភាព និងសំឡេង កម្មវិធី ZOOM ក្រោមអធិបតីភាពលោកជំទាវ ស៊ិន ណម សមាជិកក្រុមប្រឹក្សាខេត្ត និង

ជាប្រធានកិត្តិយសក្រុមការងារឆ្លើយតបជាពហុវិស័យ ចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រខេត្តសៀមរាប , លោកស្រីយូ សុភា អភិបាលរងខេត្ត និងជាប្រធានក្រុមការងារឆ្លើយតបជាពហុវិស័យ ចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រខេត្តសៀមរាប និង ប្រតិភូតំណាងក្រសួងកិច្ចការនារី។

លោកស្រី យូ សុភា អភិបាលរងខេត្តសៀមរាប មានប្រសាសន៍ថា គោលបំណងសំខាន់នៃកិច្ចប្រជុំនេះ គឺដើម្បីរៀបចំជាផែនការសកម្មភាពសម្រាប់អនុវត្តប្រកបដោយប្រសិទ្ធភាព សម្រាប់ការទប់ស្កាត់អំពើហិង្សាទាក់ទងនឹងយេនឌ័រនេះ ព្រោះថា ខេត្តសៀមរាប ជាខេត្តដែលនាំមុខគេក្នុងវិស័យទេសចរណ៍ ដូច្នេះការរំលោភបំពានពាក់ព័ន្ធនឹងយេនឌ័រនេះក៏កើតមានដែរ ដែលការណ៍នេះ យើងត្រូវតែរួមគ្នាដើម្បីទប់ស្កាត់ឲ្យមានភាពល្អប្រសើរ ។ លោកស្រី យូ សុភា មានប្រសាសន៍បន្ថែមថា កន្លងមកខេត្តសៀមរាប ត្រូវបានក្រសួងកិច្ចការនារីជ្រើសរើសជាខេត្តគំរូ នៅក្នុងការទប់ស្កាត់អំពើហង្សាពាក់ព័ន្ធនឹងយេនឌ័រនេះ ដូច្នេះដើម្បីរក្សាបាននូវកិត្តិនាមនេះ តាមរយៈនៃកិច្ចប្រជុំនេះ សូមឲ្យគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ត្រូវរួមគ្នាទប់ស្កាត់អំពើហិង្សាដែលពាក់ព័ន្ធនឹងយេនឌ័រ គ្រប់ទម្រង់ដូចជាអំពើហិង្សាក្នុងគ្រួសារ , ការរំលោភផ្លូវភេទ និងការជួញដូរស្ត្រី និងកុមារជាដើម ជាពិសេសនៅតាមបណ្ដាក្រុងស្រុកទាំង១២របស់ខេត្ត ត្រូវរៀបចំឲ្យមានក្រុមការងារនេះ ដើម្បីបង្កើនប្រសិទ្ធភាពការងារ៕

## ១ថ្ងៃពលករខ្មែរត្រឡប់ពីថៃក្នុងភូមិសាស្ត្រខេត្តបន្ទាយមានជ័យមាន៣២៥នាក់ និងរកឃើញវិជ្ជមានកូវីដ១៨នាក់

https://kohsantepheapdaily.com.kh/ បន្ទាយមានជ័យ០៨ ខែ កញ្ញា ឆ្នាំ ២០២១ ម៉ោង ១៥:៥៨

បន្ទាយមានជ័យ ៖ ពលករខ្មែរដែលត្រឡប់ពីប្រទេសថៃចូលមកកម្ពុជាក្នុងភូមិសាស្ត្រខេត្តបន្ទាយមានជ័យព្រឹត្តិការ២០ កុម្ភៈ ២០២១ មានចំនួន៦៤,៣៦៤នាក់ ។ ដោយយោងតាមរបាយការណ៍រដ្ឋបាលសាលាខេត្តបន្ទាយមានជ័យ នៅថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២១ រយៈពេល១ថ្ងៃ មានពលករខ្មែរដែលត្រឡប់ពីប្រទេសថៃ ចូលកម្ពុជាវិញ តាមច្រក២ ក្នុងភូមិសាស្ត្រខេត្តបន្ទាយមានជ័យ មានច្រកអូរបីជាន់ ស្រុកអូរជ្រៅ ច្រកបឹងត្រកួន ស្រុកថ្មពួកមានចំនួន៣២៥នាក់ ស្រី១៤៥នាក់ រកឃើញអ្នកវិជ្ជមានកូវីដ១៩ មានចំនួន១៨នាក់ ស្រី១០នាក់ ។

ព្រឹត្តិការណ៍ ២០ កុម្ភៈ ២០២១ ពលករខ្មែរដែលត្រឡប់ពីប្រទេសថៃចូលមកកម្ពុជា វិញមានចំនួន៦៤,៣៦៤នាក់ ស្រី២៨.៨១៥នាក់ និងពលករខ្មែរដែលបានពិនិត្យសុខភាពយកសំណាកមានចំនួន៥៥.៧២៤នាក់ ស្រី២៤.៤៥៣នាក់ ពលករខ្មែរដែលត្រូវបានបញ្ជូនចេញទៅតាមមូលដ្ឋានខ្លួន មានចំនួន៥៩.៤៥៩នាក់ ស្រី២៦.៦៩០នាក់ និងពលករខ្មែរដែលត្រូវបានធ្វើចត្តាឡីស័កមានចំនួន៤៣.០៨៨នាក់ ស្រី២០.៣៧៧នាក់ និងកំពុងធ្វើចត្តាឡីស័ក និងព្យាបាលកូវីដ១៩ មានចំនួន៥.១៨៣នាក់ ស្រី២.២៥៤នាក់ ៕

## ទូតអូស្ត្រាលីប្រចាំកម្ពុជា ប្រាប់ពលរដ្ឋខ្មែរឲ្យប្រយ័ត្នចាញ់បោក គម្រោងទិដ្ឋាការកសិកម្មអូស្ត្រាលី ខណៈកម្ពុជា-អូស្ត្រាលី មិនទាន់មានទិដ្ឋាការនេះនៅឡើយទេ

http://freshnewsasia.com/ 2021-09-08 03:41pm

**(ភ្នំពេញ)៖** ស្ថានទូតអូស្ត្រាលីប្រចាំកម្ពុជា បានបញ្ជាក់ឱ្យដឹងថា បច្ចុប្បន្ននេះមិនទាន់មានការរៀបចំទិដ្ឋាការកសិកម្មទ្វេភាគីរវាងអូស្ត្រាលី និងកម្ពុជានៅឡើយទេ។ ជាមួយគ្នានេះស្ថានទូតបានសំណូមពរឱ្យប្រជាជនកម្ពុជា ប្រុងប្រយ័ត្នចំពោះក្រុមហ៊ុនណាដែលអះអាងថា គេអាចរៀបចំទិដ្ឋាការកសិកម្មសម្រាប់អូស្ត្រាលីបាននាបច្ចុប្បន្ននេះ។ នេះបើយោងតាមសេចក្តីប្រកាសព័ត៌មាន របស់ស្ថានទូតអូស្ត្រាលីប្រចាំកម្ពុជា ពីបច្ចុប្បន្នភាពស្តីអំពីគម្រោងទិដ្ឋាការកសិកម្មអូស្ត្រាលី ដែលFresh News ទទួលបាន នៅរសៀលថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២១នេះ។

នៅក្នុងសេចក្តីប្រកាសព័ត៌មាននេះបានឱ្យដឹងទៀតថា កាលពីថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២១ រដ្ឋាភិបាលអូស្ត្រាលីបានប្រកាសបង្កើតគម្រោងទិដ្ឋាការកសិកម្មអូស្ត្រាលីថ្មី។ ស្ថានទូតនឹងធ្វើការចរចាជាមួយដៃគូទ្វេភាគី អំពីការរៀបចំនានាសម្រាប់ទិដ្ឋាការនេះ ដោយចាប់ផ្តើមពីបណ្តាប្រទេសមួយចំនួន មុននឹងពង្រីកទៅបណ្តាប្រទេសជាច្រើន ទៅថ្ងៃមុខ។

ព័ត៌មានលំអិតអំពីរបៀបដាក់ពាក្យសុំ និងតម្រូវការដើម្បីទទួលបានទិដ្ឋាការ នឹងធ្វើឡើងតាមរយៈដំណើរការកម្មវិធី ដោយមានការពិគ្រោះយោបល់ជាមួយវិស័យ កសិកម្មអូស្ត្រាលី។ ក្រសួងកិច្ចការបរទេសនិងពាណិជ្ជកម្មអូស្ត្រាលី ជាអ្នកគ្រប់គ្រងលើទិដ្ឋាការនេះ។ ក្រសួងមហាផ្ទៃ និងក្រសួងកសិកម្មទឹក និងបរិស្ថាន នឹងផ្តល់ការ គាំទ្រផ្នែកប្រតិបត្តិការ ដើម្បីធានាសុចរិតភាពទិដ្ឋាការ ព្រមទាំងដើម្បីបំពេញតម្រូវការវិស័យកសិកម្ម និងវិស័យឧស្សាហកម្មបឋម។ ស្តង់ដារអេប្បបរមាដើម្បីការពារកម្មករពីការកេងប្រវ័ញ្ចជាការសំខាន់ ហើយនឹងត្រូវយកគំរូតាមកម្មវិធីចល័តពលកម្មប៉ាស៊ីហ្វិក ដែលទទួលបានជោគជ័យរបស់អូស្ត្រាលី។ នៅពេលការរៀបចំទិដ្ឋាការត្រូវបានបញ្ចប់ នឹងមានច្បាប់តឹងរ៉ឹងដើម្បីការពារកម្មករ។ រដ្ឋាភិបាលប្តេជ្ញាធានាថា កម្មករទាំងអស់មានឱកាសចូលរួមចំណែក ជាវិជ្ជមានដល់សេដ្ឋកិច្ចអូស្ត្រាលី ដោយមិនមានអារម្មណ៍ភ័យខ្លាចពីការកេងប្រវ័ញ្ច៕

## ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២១

## បញ្ជូនសំណុំរឿងមេខ្យល់នាំពលករឆ្លងដែនទៅតុលាការ តែមិនទាន់បញ្ជូនជនសង្ស័យ ព្រោះមានឆ្លងកូវីដ

https://www.postkhmer.com/ អោម ប៊ុនធឿន | Publication date 08 September 2021 | 16:49 ICT

**បាត់ដំបង:** នគរបាលខេត្តបាត់ដំបងនៅរសៀលថ្ងៃទី ៨ ខែកញ្ញានេះ បានបញ្ជូនសំណុំរឿងមេខ្យល់ ២ នាក់ទៅតុលាការ បន្ទាប់ពីសមត្ថកិច្ចនគរបាលស្រុកភ្នំព្រឹកចាប់បញ្ជូនទៅស្នងការដ្ឋានកាលពីថ្ងៃទី ៦ ខែកញ្ញា ពាក់ព័ន្ធករណីនាំពលរដ្ឋខ្មែរចំនួន ១១ នាក់ បម្រុងឆ្លងដែនទៅថៃដោយខុសច្បាប់ ក៏ប៉ុន្តែមិនទាន់បញ្ជូនជនសង្ស័យទេ ដោយសារមានករណីឆ្លងកូវីដ ១៩។

លោកស្រី រស់ ជីវី ស្នងការរងទទួលផែនការងារនគរបាលប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ខេត្តថ្លែងនៅថ្ងៃទី៨ ខែកញ្ញាថា បុរសជាមេខ្យល់ ២ នាក់ ពាក់ព័ន្ធករណីនាំមនុស្សឆ្លងដែនខុសច្បាប់ ត្រូវបានសមត្ថកិច្ចនគរបាលខេត្តបាត់ដំបង បញ្ជូនសំណុំរឿងពួកគេទៅកាន់តុលាការហើយនៅរសៀលថ្ងៃទី ៨ ខែកញ្ញានេះ។ លោកស្រីបន្តថា ការបញ្ជូនសំណុំរឿងដោយមិនបញ្ជូនខ្លួនជនសង្ស័យទៅនេះ គឺដើម្បីការពារកុំឲ្យមានហានិភ័យជំងឺកូវីដ ១៩ កើតឡើងនៅក្នុងស្ថាប័នតុលាការព្រោះមេខ្យល់ទាំង ២ នាក់នោះមានម្នាក់ឆ្លងជំងឺកូវីដ ១៩ និងបានយកទៅព្យាបាលកាលពីល្ងាចថ្ងៃទី៧ ខែកញ្ញា។ រីឯម្នាក់ទៀតកំពុងដាក់ឲ្យនៅដាច់ដោយឡែកនៅស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង។ លោស្រីបញ្ជាក់ថា៖ «យើងយកសំណុំរឿងហ្នឹងទៅឆ្លងតុលាការសិន ពេលបានដីកាឃុំបានអីហើយ ទើបយើងយកគាត់ទៅឃុំ ព្រោះគាត់មានបញ្ហាប្រឈមយើងអត់អាចយកគាត់ទៅដាក់នៅតុលាការដូចអ្នកដទៃបានទេ» ។

លោក ហេង បារាំង អធិការនគរបាលស្រុកភ្នំព្រឹកបានថ្លែងនៅថ្ងៃទី ៨ ខែកញ្ញាថា សមត្ថកិច្ចលោកបានឃាត់ខ្លួនជនសង្ស័យជាមេខ្យល់ទាំង២នាក់ នៅចំណុចរង្វង់មូលផ្លូវបែកជា ៤ ស្ថិតក្នុងភូមិភ្នំតូច ឃុំពេជ្រចិន្តា ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង កាលពីថ្ងៃទី ៦ ខែកញ្ញា បន្ទាប់ពីសមត្ថកិច្ចឃាត់បានពលរដ្ឋ ១១ នាក់ យកមកសួរនាំកាលពីថ្ងៃទី ៥ ខែកញ្ញា នៅចំណុច ច្រកទ្វារព្រំដែនអូរវែ្ជល ក្នុងភូមិ អូរថ្មី ឃុំពេជ្រចិន្តា ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ។ លោកថ្លែងថា៖ «ក្រោយពីកម្លាំងយើងបានសួរនាំប្រជាពលរដ្ឋដែលយើងបានឃាត់ហ្នឹងក៏ឈានដល់ការកំណត់អត្តសញ្ញាណ ហើយស្រាវជ្រាវចាប់ខ្លួនមេខ្យល់ទាំង ២ នាក់បានតែម្តង» ។ លោក បារាំង បានបញ្ជាក់ថា ពលរដ្ឋទាំង

ចំនួន ១១ នាក់ នោះមានស្រី ៧ នាក់ក្នុងនោះមានក្មេងតូច ៣ នាក់ (ស្រី ២ នាក់)។ ក្រោយសាកសួររួចសមត្ថកិច្ចបានអប់រំណែនាំកុំឲ្យចាញ់បោកមេខ្យល់ទៀតនៅពេលក្រោយ និងបានអនុញ្ញាតឲ្យត្រឡប់ទៅផ្ទះវិញរៀងៗខ្លួន។ បើតាមលោក បារាំង ជនសង្ស័យជាមេខ្យល់ ទាំង ២ នាក់ មាន ឈ្មោះ ឈួម រ៉ា (ហៅ ឆេះ) ភេទប្រុស អាយុ ៤០ ឆ្នាំ មានលំនៅក្នុងភូមិ អូរថ្មី ឃុំពេជ្រចិន្តា ស្រុកពេជ្រចិន្តាខេត្តបាត់ដំបង និងម្នាក់ទៀត ឈ្មោះ យ៉ង អ៊ីមហៅ មូល ភេទប្រុស អាយុ ៣៥ ឆ្នាំ មានលំនៅក្នុងភូមិ អូរអន្លក់ឃុំតាសែនស្រុកកំរៀង ខេត្តបាត់ដំបង៕

## ស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ និងនគរបាលសហព័ន្ធអូស្ត្រាលី រួមគ្នាទប់ស្កាត់បង្ក្រាបបទល្មើស

https://cen.com.kh/ Posted ByPen Srey NeatSeptember 10, 2021

បន្ទាយមានជ័យ ៖ លោក ឧត្តមសេនីយ៍ទោ សិទ្ធិ ឡោះ ស្នងការនគរបាលខេត្តបន្ទាយមានជ័យ បានចាត់ឱ្យ លោកឧត្តមសេនីយ៍ត្រី រ៉ែម វីរៈ ស្នងការរងផែនការងារសេនាធិការ ដឹកនាំលោក-លោកស្រីឧត្តមសេនីយ៍ វរសេនីយ៍ស្នងការរង ចូលរួមសំណេះសំណាលសម្តែងការគួរសមជាមួយលោក Anthony Maguire នាយនគរបាលជាន់ខ្ពស់ នៃនគរបាលសហព័ន្ធអូស្ត្រាលីប្រចាំស្ថានទូតអូស្ត្រាលី តាមប្រព័ន្ធវីឌីអូ ZOOM នៅស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ។

លោកឧត្តមសេនីយ៍ត្រី រ៉ែម វីរៈ បានមានប្រសាសន៍ថា កិច្ចប្រជុំថ្ងៃនេះ គឺជដែកពិភាក្សាលើកិច្ចសហប្រតិបត្តិការការងាររក្សាសន្តិសុខសណ្តាប់ធ្នាប់សង្គម, ការបង្ក្រាបបទល្មើសឧក្រិដ្ឋជនឆ្លងដែន, បទល្មើសគ្រឿងញៀន, បទល្មើសជួញដូរមនុស្ស, បទល្មើសពលករឆ្លងដែនខុសច្បាប់, ការគ្រប់គ្រងលើពលរដ្ឋចំណូលស្រុក-ចំណាកស្រុកតាមមូលដ្ឋាន, ការផ្តល់ថ្នាំវ៉ាក់សាំងដល់ប្រជាពលរដ្ឋ និងការប្រយុទ្ធប្រឆាំងជំងឺកូវីត-១៩។

លោក Anthony Maguire នាយនគរបាលជាន់ខ្ពស់ នៃនគរបាលសហព័ន្ធអូស្ត្រាលីប្រចាំស្ថានទូតអូស្ត្រាលី បានសំណូមពរមកថ្នាក់ដឹកនាំនគរបាលខេត្តបន្ទាយមានជ័យ ជួយសម្រួលលើកិច្ចសហប្រតិបត្តិការល្អ ក្នុងការទប់ស្កាត់បង្ក្រាបបទល្មើសផ្សេងៗ៕ រក្សាសិទ្ធិដោយៈបញ្ញាស័ក្តិ

## បញ្ជូនបក្សពួកមេខ្យល់ដែលនាំពលករឆ្លងដែនខុសច្បាប់ទៅតុលាការ

https://kohsantepheapdaily.com.kh/ ប៉ៃលិន១០ ខែ កញ្ញា ឆ្នាំ ២០២១ ម៉ោង ០៩:៤៤

ខេត្តប៉ៃលិន ៖ រហូតដល់ថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២១ កម្លាំងជំនាញផ្នែកនគរបាលយុត្តិធម៌ នៃអធិការដ្ឋាននគរបាលស្រុកសាលាក្រៅ បាននាំខ្លួនជនត្រូវចោទម្នាក់ ទៅកាន់ពន្ធនាគារខេត្តប៉ៃលិនហើយ តាមដីកាបង្គាប់ឲ្យឃុំខ្លួនរបស់លោកចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តប៉ៃលិន ដែលជាប់ទោសពីបទ (នាំចេញដោយមិនស្របច្បាប់សម្រាប់ឆ្លងដែន និងប្រើប្រាស់សារជាតុញៀនដោយខុសច្បាប់) ។ ប្រភពព័ត៌មានពីនគរបាលបានឱ្យដឹងថា ៖ ជនសង្ស័យរូបនេះ បានលួចនាំពលករខុសច្បាប់ជិត៥០នាក់ចេញពីខេត្តប៉ៃលិន ទៅធ្វើការជាពលករបេះផ្លែមៀនប៉ៃលិន ហៅតាង៉ែន នៅខេត្តចាន់បូរី ប្រទេសថៃ ។

សូមបញ្ជាក់ថា ៖ កាលពីវេលាម៉ោង០២ និង៣៥នាទីរសៀល ថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០២១ សមត្ថកិច្ចនគរបាលបានធ្វើការឃាត់ខ្លួនបក្សពួករបស់មេខ្យល់ម្នាក់ឈ្មោះ សុខ ប៊ុនថាន់ ភេទប្រុស អាយុ៤០ឆ្នាំ មុខរបរមិនពិតប្រាកដ ជនជាតិខ្មែរ មានទីលំនៅក្នុងភូមិផ្សារព្រំជើង ឃុំស្ទឹងកាច់ ស្រុកសាលាក្រៅ ខេត្តប៉ៃលិន ដែលបាននាំប្រជាពលរដ្ឋឆ្លងដែនដោយខុសច្បាប់ចំនួន៤៧នាក់ ក្នុងនោះ ស្រី២៧នាក់ ក្មេង០៨នាក់ ទៅអធិការដ្ឋាននគរបាលស្រុកសាលាក្រៅ ដើម្បីចាត់ការបន្តតាមនីតិវិធី និងយោងតាមការចង្អុលបង្ហាញផ្ទាល់របស់លោកឧត្តម

សេនីយ៍ សេង សុគន្ធ ស្នងការ នគរបាលខេត្តប៉ៃលិន ហើយជំនាញបានកសាងសំណុំរឿងបញ្ជូនទៅអាយ្យការអមសាលាដំបូងខេត្តប៉ៃលិន ចាត់ការតាមនីតិវិធី ។

សូមរំលឹកថា ៖ ពលករខ្មែរចំនួន៤៧នាក់ បានចាញ់បោកមេខ្យល់ ហើយត្រូវទាហានឈុតខ្មៅថៃចាប់ខ្លួនក្រោយលួចឆ្លងដែនខុសច្បាប់ទៅធ្វើជាកម្មករបេះផ្លែមៀន ដោយម្នាក់ៗបង់ប្រាក់ឱ្យទៅគេអស់ជាច្រើន ទើបពលករខ្មែរចំនួន៤៧នាក់ ដែលហ៊ានឆ្លងដែនខុសច្បាប់ តាមច្រករបៀងខេត្តប៉ៃលិន ត្រូវបានក្រុមទាហានឈុតខ្មៅថៃធ្វើការចាប់ឃាត់ខ្លួន ខណៈពេលដែលពួកគេចូលទៅក្នុងទឹកដីថៃ ដើម្បីធ្វើជាកម្មករបេះផ្លែមៀន (ហៅតាង៉ែន) នៅក្នុងទឹកដីខេត្តចាន់បុរី ប្រទេសថៃ ។ សូមរំលឹកទៀតថា នៅមុនពេលកើតហេតុ មានពលករខ្មែរចំនួន៤៧នាក់ បានជឿតាមការឆបោករបស់មេខ្យល់ ក៏នាំគ្នាលួចឆ្លងព្រំដែនចូលទៅក្នុងទឹកដីប្រទេសថៃ ដោយបាននាំគ្នាដើរកាត់តាមចំការដំណាំ ស្របពេលដែលកម្លាំងទាហានឈុតខ្មៅថៃ កំពុងចុះល្បាត តាមព្រំដែនក៏ស្ទាក់ចាប់ឃាត់ខ្លួនតែម្តង៕

## ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២១

### កិច្ចប្រជុំពិគ្រោះយោបល់លើកទី៣ ស្តីពីការពង្រឹងសេវាសម្របសម្រួល ដើម្បីសុវត្ថិភាពពលករ និងសហគមន៍ !

https://www.information.gov.kh/ ចេញផ្សាយ ថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០២១

សៀមរាប៖ គណៈកម្មការជាតិប្រឆាំងអំពើជួញដូរមនុស្ស ហៅកាត់ គ.ជ.ប.ជ និងអង្គការការីតាសស្វីស បានបើកកិច្ចប្រជុំពិគ្រោះយោបល់លើកទី៣ ស្តីពីការពង្រឹងសេវាសម្របសម្រួល ដើម្បីសុវត្ថិភាពពលករ និងសហគមន៍ ដើម្បីរកភាពខ្លាំងនៅក្នុងការផ្តល់សេវាកម្ម ឬការឆ្លើយតបទៅនឹងតម្រូវការរបស់ជនងាយរងគ្រោះ។ កិច្ចប្រជុំនេះ បានធ្វើឡើងនៅសាលប្រជុំរបស់រដ្ឋបាលខេត្តសៀមរាប នាព្រឹកថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២១ ដោយមានការអញ្ជើញចូលរួមពីលោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ លោកស្រី យូ សុភា អភិបាលរងខេត្តសៀមរាប រួមជាមួយមន្ទីរ អង្គភាពពាក់ព័ន្ធ និងអង្គការសង្គមស៊ីវិលដៃគូមួយចំនួនទៀត។

លោកស្រី យូ សុភា បានមានប្រសាសន៍ថា ចាប់តាំងពីមានការឆ្លងរាលដាលមេរោគកូវីដ-១៩ រហូតមកដល់ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២១ មានពលករចំណាកស្រុកប្រមាណជាង ៣ម៉ឺននាក់ បានវិលត្រលប់ពីបរទេសមកកាន់ភូមិដ្ឋានរបស់ពួកគាត់នៅក្នុងខេត្តសៀមរាប។ ក្រៅពីពលករទាំងនេះ ខេត្តសៀមរាប ក៏បានក្លាយជាខ្សែត្រៀមទី២ ក្នុងការទទួលយកពលករពីខេត្តឧត្តរមានជ័យ និងខេត្តមួយចំនួនទៀត ដើម្បីព្យាបាល និងធ្វើចត្តាឡីស័កផងដែរ។ លោកស្រីបន្តថា បើគិតមកដល់ថ្ងៃទី០៨ ខែកញ្ញា ២០២១នេះ មានពលករប្រមាណជាង៥៣ពាន់នាក់ ដែលបញ្ជូនមកពីខេត្តឧត្តរមានជ័យ ចូលមកខេត្តសៀមរាប។ លោកស្រី យូ សុភា បន្ថែមថា នៅខេត្តឧត្តរមានជ័យ កន្លែងគាត់តូច ខេត្តតូច អញ្ចឹងពលករគាត់សម្រុកចេញតាមច្រកអូរស្មាច់ក៏ដូចជាច្រកជាំសាង៉ាំ ខេត្តឧត្តរមានជ័យ អត់កន្លែងដាក់ ត្រូវបានបញ្ជូនមកខេត្តសៀមរាប ដូចនេះខេត្តសៀមរាប ក៏ទទួលពលករ ដែលមកពីខេត្តជាប់ព្រំដែនផងដែរ។ ក្រៅពីកិច្ចការទទួលពលករដែលវិលត្រលប់មកវិញនេះ រដ្ឋបាលខេត្តក៏បានយកចិត្តទុកដាក់គិតគូរអំពីការប្រកបរបររបស់បងប្អូនទាំងនោះ បន្ទាប់ពីគាត់មករស់នៅក្នុងស្រុក ភូមិរបស់ពួកគាត់វិញផងដែរ។ នៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់នាពេលនេះ ក៏ក្លាយជាការស្វែងរកធាតុផ្សំចូលមួយចំនួនឲ្យចំគោលដៅ ដែលបងប្អូនពលករចង់បាន។

មានប្រសាសន៍បើកកិច្ចប្រជុំនេះដែរ លោកជំទាវ ជូ ប៊ុនអេង បានថ្លែងនូវការកោតសរសើរចំពោះរដ្ឋបាលខេត្តសៀមរាប ដែលបានយកចិត្តទុកដាក់ នៅក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក៏ដូចជាការគិតគូរខ្ពស់ដល់ប្រជាពលរដ្ឋ ជាពិសេសពលករដែលវិលត្រលប់ពីក្រៅប្រទេស។ ជាមួយគ្នានេះដែរលោកជំទាវ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ក៏បានជំរុញឲ្យសមាជិកនៃកិច្ចប្រជុំពិគ្រោះយោបល់នេះ ត្រូវស្វែងរកចំណុចសំខាន់ ដើម្បីពន្យល់ឲ្យបងប្អូនពលករផ្លាស់ប្តូរផ្នត់គំនិត ដែលតែងតែចង់ធ្វើការនៅក្រៅប្រទេស រហូតមករស់ប្រទេសដើមខ្លួនឯងលែងកើត។ រឿងពលករចំណាកស្រុកនេះ ជារឿងធំដែលយើងត្រូវយកចិត្តទុកដាក់ដោះស្រាយជូនពួកគាត់ ចាប់ពីពេលនេះទៅមុខ បង្កលក្ខណ:ងាយស្រួលសម្រាប់ពួកគាត់៕ មន្ទីរព័ត៌មានខេត្តសៀមរាប សម្រួលផ្សាយដោយ៖ ធូ កុសល

## មេបញ្ជាការកងពលតូចថ្មើរជើងលេខ៥៣ ដាក់បទបញ្ជាបន្តរឹតបណ្តឹងល្បាតខ្សែព្រំដែនកម្ពុជា ខណ:ពលករព្យាយាមលួចឆ្លងដែន

https://cen.com.kh/ Posted ByPen Srey NeatSeptember 11, 2021

បាត់ដំបង ៖ ឧត្តមសេនីយ៍ត្រី កែវ សេងលន មេបញ្ជាការកងពលតូចថ្មើរជើងលេខ៥៣ នៅព្រឹកថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២១ បានបញ្ជាយ៉ាងតឹងរឹងចំពោះមេបញ្ជាការរងកងពល ទទួលបន្ទុកទិសទាំងបី ទិសស្រុកកំរៀង ស្រុកភ្នំព្រឹក និងស្រុកសំពៅលូន ត្រូវបន្តពង្រឹងកងកម្លាំងល្បាតតាមចំណុចគោលដៅខ្សែបន្ទាត់ព្រំដែនម៉ឺងម៉ាត់ និងហ្មត់ចត់បំផុត។ លោកបន្តថា មេបញ្ជាការទិសស្រុកនិមួយៗ ត្រូវទទួលខុសត្រូវខ្ពស់ចំពោះភារកិច្ចរបស់ខ្លួន ដោយចុះធ្វើកិច្ចការផ្ទាល់ ព្រោះពេលនេះភ្លៀងកំពុងធ្លាក់ជោគជាំ ហើយទឹកអូរព្រំដែនក៏កាន់តែកើនឡើងខ្លាំង អាចជាឱកាសមេខ្យល់នាំពលករលួចឆ្លងដែន ប្រសិនបើយើងធ្វេសប្រហែស។ លោកមេបញ្ជាការបន្ថែមថា ស្ថិតនៅក្នុងកាល:ទេស:នេះ យើងត្រូវអនុវត្តបទបញ្ជាថ្នាក់លើឲ្យបាន ក្នុងការទប់ស្កាត់ពលករលួចឆ្លងដែនខុសច្បាប់ និងទប់ស្កាត់ការឆ្លងរាលដាល នៃជំងឺកូវីដ-១៩ មិនឲ្យចូលក្នុងប្រទេស។ លោកក៏បានបញ្ជាក់ផងដែរថា កងកម្លាំងមិនត្រូវគិតពីផលប្រយោជន៍ផ្ទាល់ខ្លួន និងមិនត្រូវជាប់ពាក់ព័ន្ធនឹងការស៊ីសំណូកសូកប៉ាន់ ឃុបឃិតជាមួយមេខ្យល់ដាច់ខាត ប្រសិនបើដឹងថាយោធិនណាម្នាក់ប្រព្រឹត្តបទល្មើសនេះនោះនឹងត្រូវទទួលទោសតាមច្បាប់កងយោធពលខេមរភូមិន្ទ៕ រក្សាសិទ្ធិដោយ ៖ បញ្ញាស័ក្តិ

## ឃាត់ខ្លួន ជនជាតិថៃ៥នាក់ ដែលបម្រុងលបឆ្លងដែន មករធ្វើការ នៅក្នុងប្រទេសកម្ពុជា

https://www.kampucheathmey.com/ ថ្ងៃសុក្រ ១០ កញ្ញា ២០២១ដោយ Sorn Phanith

ជនជាតិថៃ ចំនួន៥នាក់ ដែលក្នុងនោះសុទ្ធតែជាមនុស្សប្រុស ត្រូវបានតម្រួតការពារព្រំដែនថៃលេខ១២ ធ្វើការឃាត់ខ្លួន នៅក្បែខ្សែបន្ទាត់ព្រំដែន ខណៈដែលពួកគេបម្រុងលួចឆ្លងដែនចូលមកក្នុងប្រទេសកម្ពុជា ដើម្បីរកការងារធ្វើ។ ការឃាត់ខ្លួននេះ បានធ្វើឡើងកាលពីវេលាម៉ោង១ រំលងអធ្រាត្រថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២១ ត្រង់ចំណុច បានណងច័ន្ទ ក្នុងឃុំម៉ាកម៉ុន ស្រុកគោកខ្សូង ខេត្តស្រះកែវ ប្រទេសថៃ បន្ទាប់ពីពួកគេកំពុងធ្វើដំណើរ ជិតដល់ព្រំដែនកម្ពុជា ក្នុងពេលដែលប្រទេសមានការរឹតបន្តឹង ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ កាន់តែមានសភាពធ្ងន់ធ្ងរ ពិសេសគឺមេរោគបំប្លែងខ្លួន ដែលតា។ ពួកគេបានអះអាងថា ការលបឆ្លងដែននេះ គឺអាចធ្វើឲ្យពួកគេសល់កម្រៃច្រើន ដោយចូលទៅធ្វើការនៅក្នុងកាស៊ីណូអនឡាញ នាក្រុងប៉ោយប៉ែត ព្រោះឮអ្នកស្គាល់គ្នាប្រាប់ថាបើទៅដល់ទីនោះក្រុមហ៊ុននឹងជួយគ្រប់យ៉ាងទាំងការហូបចុកនិងការស្នាក់នៅហើយបានប្រាក់ខែ២០,០០០ បាត។ បច្ចុប្បន្នជនជាតិថៃទាំង៥នាក់ ត្រូវបានបញ្ជូនទៅកាន់អធិការដ្ឋានតម្រួតស្រុកគោកខ្សូង ដើម្បីចាត់ការតាមនីតិវិធី៕ **អត្ថបទ៖ សោ និយមរ័ត្ន**

## កងកំលាំងប៉ូវ៉ាផា និងអាជ្ញាធរស្រុកអារញ្ញប្រាថេត ខេត្តស្រះកែវ បានចាប់ឃាត់ខ្លួនពលរដ្ឋខ្មែរលួចឆ្លងដែនចូលប្រទេសថៃដោយខុសច្បាប់ចំនួន ៤នាក់

https://www.facebook.com/Khmer.Channel.kh/ ទឹកចិត្ត ពលករ ឆ្លងដែន កញ្ញា 10 ម៉ោង 4:50 PM

កាលពីថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២១ កងកំលាំងប៉ូវ៉ាផា និងអាជ្ញាធរស្រុកអារញ្ញប្រាថេត ខេត្តស្រះកែវ បានចាប់ឃាត់ខ្លួនពលរដ្ឋខ្មែរលួចឆ្លងដែនចូលប្រទេសថៃដោយខុសច្បាប់ចំនួន ៤នាក់ នៅបរិវេណភូមិផានសឹក ឃុំផានសឹក ស្រុកអារញ្ញប្រាថេត ខេត្តស្រះកែវ។ បន្ទាប់ពីធ្វើការសាកសួរ ពលរដ្ឋខ្មែរទាំងអស់សារភាពថា ត្រូវការធ្វើដំណើរទៅប្រទេសម៉ាលេស៊ី ដើម្បីធ្វើការពេងចក្រឈើ បន្ទាប់មកត្រូវអាជ្ញាធរបញ្ជូនទៅចាត់វិធានការបន្តតាមផ្លូវច្បាប់។

## ពលករខ្មែរប្រុស-ស្រីចំនួន០៩នាក់ លួចឆ្លងដែនត្រូវយោធាថៃឃាត់ខ្លួន

https://gdlf-kh.com/ 2021/09/10/ Noun Vanny បន្ទាយមានជ័យ

បន្ទាយមានជ័យៈ ពលករខ្មែរចំនួន៩នាក់ ចំណាយប្រាក់ក្នុងម្នាក់ពី៥,០០០ទៅ ៥,៥០០បាត ដើម្បីឆ្លងដែនទៅធ្វើការនៅប្រទេសថៃ ត្រូវបានយោធាថៃឃាត់ខ្លួនកាលពីវេលាម៉ោង៨និង២៥នាទីព្រឹក ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២១។ តាមការឲ្យដឹងពីសមត្ថកិច្ចថាៈ មេបញ្ជាការកងកម្លាំងបូរផា បានបញ្ជាឲ្យកម្លាំងការពារព្រំដែនរឹតបន្តឹង ការលួចឆ្លងដែនចូលក្នុងប្រទេសដោយខុសច្បាប់ អំឡុងស្ថានការណ៍កូវីដ-១៩ រាត្បាតជាបន្តបន្ទាប់ នៅក្នុងប្រទេសថៃ ។ ជាមួយគ្នានោះសមត្ថកិច្ចទាហានអង្គភាពចំពោះកិច្ចតាប្រាយ៉ា សហការជាមួយកងរយទី៣និងនគបាលការពារព្រំដែនទី១២ ស្ទាក់ចាប់ពលករខ្មែរ បានចំនួន០៩នាក់ ក្នុងនោះប្រុស០៥នឹងស្រី០៤នាក់ នៅបរិវេណព្រៃជំឡួងមី ស្ថិតក្នុងភូមិខៅលូកឆាង ឃុំ/ស្រុកតាប្រាយ៉ា ខេត្តស្រះកែវ ។ ប្រភពដដែលបន្ថែមថាៈពលករខ្មែរទាំងអស់បានប្រាប់ថា ពួកគេទៅធ្វើការនៅក្រុងបាងកក២នាក់គឺធ្វើការនៅហាងលក់អាហារ នឹង៧នាក់ទៀតទៅធ្វើការនៅខេត្តណៈខនប៉ះធុម គឺការងារសំណង់ តែពួកគេមិនស្គាល់កន្លែងធ្វើការ ដោយសារមេខ្យល់អ្នកចាត់បញ្ជូនទៅតាមកន្លែងធ្វើការផ្សេងៗ។ ក្រោយពីសមត្ថកិច្ចថៃសួរនាំ នឹងធ្វើកំណត់ហេតុចាប់ខ្លួន នៅទីបញ្ជាការកងរយទី៣ នឹងអនុវត្តតាមវិធានរបស់ផ្នែកសុខាភិបាលរួចមក ពលករខ្មែរទាំងនោះត្រូវបានបញ្ជូនឲ្យត្រឡប់ទៅប្រទេសកម្ពុជាវិញ តាមច្រកអូរបីជាន់ ក្នុងស្រុកអូជ្រៅ ខេត្តបន្ទាយមានជ័យ៕

## ស្ថានអគ្គកុងស៊ុល កម្ពុជាប្រចាំខេត្តសាកែវ អន្តរាគមន៍សម្របសម្រួល បញ្ជូនពលករខ្មែរ ចំនួន៨នាក់ វិលត្រឡប់ មកកម្ពុជា

https://dap-news.com/ BySSP108 Posted on September 11, 2021

ភ្នំពេញៈ នៅថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ ២០២១ ស្ថានអគ្គកុងស៊ុលកម្ពុជា ប្រចាំខេត្តសាកែវ បានអន្តរាគមន៍សម្របសម្រួលបញ្ជូន ពលករខ្មែរចំនួន៨នាក់ មកពីតំបន់នានា ក្នុងប្រទេសថៃឲ្យវិលត្រឡប់ មកកម្ពុជាវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិ ខ្លងលឹក-ប៉ោយប៉ែត ដោយប្រគល់ជូនអាជ្ញាធរកម្ពុជា ដើម្បីដំណើការ តាមនីតិវិធីសុខាភិបាល។ នេះបើតាម លោក កុយ គួង អ្នកនាំពាក្យក្រសួងការបរទេស នៅមុននេះបន្តិច។ ដោយ: សយ សុភា

## ក្រោយរត់គេចខ្លួនជិត៥ឆ្នាំ ទីបំផុតម្ចាស់កប៉ាល់ដឹកប្រេងថៃត្រូវបានចាប់ខ្លួនពីបទរំលោភបំពានលើពលករខ្មែរ

https://khmeread.com/ September 12, 2021 02:54AM

ម្ចាស់កប៉ាល់ដឹកប្រេងថៃម្នាក់ ដែលត្រូវបានចោទប្រកាន់ពីបទរំលោភបំពានលើពលករខ្មែរចំនួន៦នាក់ និងបោកប្រាស់ប្រាក់ឈ្នួលរបស់ពួកគេ ត្រូវបានចាប់ខ្លួននៅខេត្តសាមុតសាខន បន្ទាប់ពីរត់គេចខ្លួនជិត ៥ ឆ្នាំ។ មន្ត្រីប៉ូលិសមកពីនាយកដ្ឋានប្រឆាំងការជួញដូរមនុស្សបានចាប់ខ្លួនឈ្មោះ Somwang (នាមត្រកូលមិនត្រូវបានបញ្ចេញ) អាយុ ៥៩ ឆ្នាំនៅហាងលក់ទំនិញមួយកន្លែងក្នុងស្រុកមឿង។ គាត់ត្រូវបានចាប់ខ្លួនតាមដីកាចាប់ខ្លួនដែលចេញដោយតុលាការខេត្តនគរស៊ីថាំរ៉ាត់កាលពីថ្ងៃទី ២៦ ខែកញ្ញាឆ្នាំ ២០១៦ ពីបទឃុបឃិតគ្នាជួញដូរមនុស្សដោយបង្ខំឱ្យធ្វើការ។

លោកឧត្តមសេនីយ៍ Siam Boonsom មេបញ្ជាការកងអនុសេនាធំបាននិយាយថាគាត់ក៏ត្រូវបានគេតាមចាប់ពីបទរំលោភបំពានលើច្បាប់ពលករចំណាកស្រុក និងច្បាប់គយតាមដីកា ៤ ផ្សេងទៀតដែលចេញដោយតុលាការខេត្តផ្សេងទៀត។ បុរសជនជាតិខ្មែរម្នាក់ឈ្មោះ "ត" បានប្រាប់ក្រុមអ្នកស៊ើបអង្កេតថាលោក Somwang និងបុរសម្នាក់ឈ្មោះ Charnchai ជាម្ចាស់កប៉ាល់ដឹកប្រេងបានផ្តល់ប្រាក់ឈ្នួលឱ្យគាត់និងជនរួមជាតិខ្មែរ ៥ នាក់ទៀតក្នុងមួយខែចំនួន ៩.០០០ បាតដើម្បីធ្វើការលើកប៉ាល់នេះ។ បុរសទាំង៦ នាក់បានយល់ព្រមប៉ុន្តែបន្ទាប់ពីធ្វើការនៅសមុទ្រអស់មួយខែគ្មានប្រាក់ឈ្នួលបើកឱ្យទេ។ លោក Charnchai ត្រូវបានគេរាយការណ៍ថាបានប្រាប់ពួកគេថាពួកគេនឹងត្រូវធ្វើការរយៈពេលមួយឆ្នាំ និងបន្ទាប់មកទើបបង់ប្រាក់ឈ្នួលឱ្យ។ ខណៈពេលកំពុងធ្វើការលើកប៉ាល់នៅឯនាយសមុទ្រភាគខាងត្បូងប្រទេសថៃ បុរសទាំងនោះមិនអាចទាក់ទងក្រុមគ្រួសារឬសាច់ញាតិរបស់ពួកគេបានទេ ហើយពួកគេមិនដែលត្រូវបានអនុញ្ញាតឱ្យឡើងគោកឡើយ។ បន្ទាប់ពីបញ្ចប់ឆ្នាំការងារ ពួកគេបានមកដល់ឆ្នេរសមុទ្រ ប៉ុន្តែនៅតែមិនទទួលបានប្រាក់ខែ។ ពួកគេបានដាក់ញត្តិទៅទីភ្នាក់ងារពាក់ព័ន្ធព្រមទាំងបានដាក់ពាក្យបណ្តឹងទៅប៉ូលិសស្រុកខនណាំក្នុងខេត្តណានស៊ីថាំរ៉ាត់។ ក្រោយមកក្រុមអ្នកស៊ើបអង្កេតបានស្វែងរកការយល់ព្រមពីតុលាការខេត្តនគរស៊ីថាំរ៉ាត់ដើម្បីចេញដីកាចាប់ខ្លួនជនសង្ស័យទាំងពីរនាក់នេះ។

លោកឧត្តមសេនីយ៍ Siam បាននិយាយថាលោក Somwang បានគេចខ្លួនទៅខេត្តផ្សេងទៀតមុនពេលគាត់ត្រូវបានចាប់ខ្លួននៅខេត្តសាមុតសាខន។ រីឯ Charnchai ត្រូវបានចាប់ខ្លួនមុននិងត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារប៉ុន្តែព័ត៌មានលម្អិតបន្ថែមទៀតមិនមានទេ។ ជនសង្ស័យបានបដិសេធរាល់ការចោទប្រកាន់មុននឹងប្រគល់ទៅឱ្យនគរបាលខនណាំដើម្បីចាត់ការតាមច្បាប់៕ ប្រភព ៖ Bangkok Post

## កងកំលាំងប៉ូរ៉ាផាចាប់ខ្លួនពលរដ្ឋខ្មែរត្រៀមលួចឆ្លងដែនចូលទៅប្រទេសកម្ពុជាចំនួន 4នាក់

https://www.facebook.com/Khmer.Channel.kh/ ទឹកចិត្ត ពលករ ឆ្លងដែន 11/09/2021

ថ្ងៃទី09 ខែកញ្ញា ឆ្នាំ2021 កងកំលាំងប៉ូរ៉ាផាចាប់ខ្លួនពលរដ្ឋខ្មែរត្រៀមលួចឆ្លងដែនចូលទៅប្រទេសកម្ពុជាចំនួន 4នាក់(ប្រុស2នាក់-ស្រី2នាក់) បរិវេណភូមិដុងង្វ ឃុំប៉ារ៉ៃ ស្រុកអារញ្ញប្រាថេត ខេត្តស្រះកែវ។ បន្ទាប់ពីធ្វើការសាកសួរ ពលរដ្ឋទាំងអស់វិលត្រឡប់មកពីធ្វើការបោកគក់ស្បែកជើងនៅក្នុងផ្សាររោងក្លឿត្រូវការវិលត្រឡប់ទៅកម្ពុជាវិញ បន្ទាប់មកត្រូវអាជ្ញាធរបញ្ជូនទៅចាត់វិធានការបន្តតាមផ្លូវច្បាប់។

# ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២១

## ទាហានឈុតខ្មៅថៃចាប់ខ្លួន ពលករខ្មែរ ១៥ នាក់ ឆ្លងដែនខុសច្បាប់

https://www.kampucheathmey.com/ ថ្ងៃអាទិត្យ ១២ កញ្ញា ២០២១ដោយ Dy Bunnara

ខេត្តបាត់ដំបង៖ ពលករខ្មែរចំនួន ១៥ នាក់ ត្រូវបានក្រុមទាហានឈុតខ្មៅថៃចាប់ខ្លួន ខណៈលបឆ្លងដែនដោយខុសច្បាប់ ដើម្បីចូលទឹកដីថៃរកការងារធ្វើ។ ការឃាត់ខ្លួននេះបានធ្វើឡើងកាលពីព្រឹកថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ ២០២១ វេលាម៉ោង ៥ និង ៣០ នាទី ទៀបភ្លឺ ត្រង់ចំណុចភ្នំកូនដំរី ក្នុងភូមិ១៤ ឃុំតាប្រាក់យ៉ា ស្រុកតាប្រាក់យ៉ា ខេត្តស្រះកែវ ប្រទេសថៃ ។ នៅមុនពេលឃាត់ខ្លួនគឺមានពលករខ្មែរចំនួន១៥ នាក់ បានលបឆ្លងព្រំដែនចូលទៅក្នុងទឹកដីថៃ ដោយនាំគ្នាជិះតាមរថយន្តមួយគ្រឿង ដែលអ្នកបើកបរគឺជាជនជាតិថៃ និងជាមេខ្យល់នាំផ្លូវ ស្របពេលដែលកម្លាំងទាហានឈុតខ្មៅថៃ សហការជាមួយកម្លាំងតម្រួតព្រំដែនលេខ១២ កំពុងល្បាតក៏បានស្ទាក់ចាប់ ក្នុងនោះប្រុស ៦ និង ស្រី ៩ នាក់ ប៉ុន្តែនៅពេលឃើញសមត្ថកិច្ច អ្នកបើកបរបានរត់គេចខ្លួនបាត់ស្រមោល ដោយបន្សល់នូវរថយន្តមួយគ្រឿងជាវត្ថុតាងសម្រាប់អោយសមត្ថកិច្ចយកទៅស្រាវជ្រាវរកម្ចាស់ មកសួរនាំតាមផ្លូវច្បាប់ ។

ក្រោយការចាប់ខ្លួនពលករខ្មែរបានសារភាពថា ពួកគេត្រូវចំណាយលុយមួយចំនួនទៅអោយអ្នកនាំផ្លូវ នៅពេលដែលជូនដល់គោលដៅ ដោយពួកគេមានបំណងទៅធ្វើការនៅខេត្តខុសៗគ្នា ពិសេសគឺនៅទីក្រុងបាងកក ។ ក្រោយពេលឃាត់ខ្លួន ក្រុមយោធាថៃបានត្រួតពិនិត្យសុខភាពពួកគេទាំងអស់ និងបានបញ្ជូនទៅអោយអធិការដ្ឋានតម្រួត ស្រុកតាប្រាក់យ៉ា ដើម្បីអនុវត្តតាមនីតិវិធី ដោយពលករខ្មែរទាំងអស់សុទ្ធតែបានចាក់វ៉ាក់សាំងការពារកូវីដ-១៩ គ្រប់ៗគ្នា៕ អត្ថបទ : សោ និយមរ័ត្ន

## ឃាត់ខ្លួនជនជាតិថៃ និងចិនបម្រុងឆ្លងដែន មកធ្វើការនៅភ្នំពេញ

https://www.kampucheathmey.com/ ថ្ងៃអាទិត្យ ១២ កញ្ញា ២០២១ដោយ Dy Bunnara

ជនជាតិថៃ ៦ នាក់ និងចិន ២ នាក់ ត្រូវបានកម្លាំងទាហានថៃឃាត់ខ្លួនក្បែរខ្សែបន្ទាត់ព្រំដែនកម្ពុជា ខណៈពួកគេទាំង ៨ នាក់ ត្រៀមលបឆ្លងដែនចូលមកកម្ពុជា ដើម្បីទៅធ្វើការនៅក្នុងទីក្រុងភ្នំពេញ។ ការឃាត់ខ្លួននេះ គឺបានធ្វើឡើងកាលពីវេលាម៉ោង១ និង ៤៥ នាទីរំលងអធ្រាត្រ ឈានចូលថ្ងៃទី ១២ ខែកញ្ញា ឆ្នាំ២០២១ ដោយកម្លាំងទាហានឈុតខ្មៅថៃក្នុងកងវរយលេខ៤ និងកម្លាំងតម្រួតព្រំដែនថៃ លេខ១២ ឃាត់ត្រង់ចំណុចភូមិ១ ឃុំណូនម៉ាកមុ៉ន ស្រុកគោកខ្សូង ខេត្តស្រះកែវ។ ពួកគេទាំង៨នាក់ គឺមានថៃ៦នាក់ មកពីខេត្តមួយចំនួនដូចជា ខេត្តផ៍យណាត ខេត្តប៉ាធុំថានី ខេត្តស៊ីសាកេត និងខេត្តអ៊ុដនថានី ចំណែកជនជាតិចិន២នាក់ មកពីស្រុក ហ៊ីឡាន និងស្រុកហ្វូជៀន ។

ក្រោយការឃាត់ខ្លួនបានសារភាពថា បានជិះរថយន្តមកចុះនៅក្នុងស្រុកអារញ្ញប្រាថេត រួចមករថយន្តនីសាន់ចំនួន២គ្រឿងមកដឹកបន្តទៅទំលាក់នៅខាងក្រោយភូមិណូនម៉ាកមុ៉ន ដោយត្រូវរង់ចាំអោយជនជាតិខ្មែរមកទទួលយក ដើម្បីបន្តដំណើរឆ្លងដែនចូលទៅកម្ពុជា តែក៏ត្រូវឃាត់ខ្លួនតែម្តង។ ទិសដៅពួកគេទាំង៨នាក់ គឺទៅបម្រើការងារជាបុគ្គលិកក្រុមហ៊ុនល្បែងភ្នាល់តាមអនឡាញមួយកន្លែងក្នុងទីក្រុងភ្នំពេញ ដោយនៅទីនោះក្រុមហ៊ុនជានារ៉ាប់រងទាំងអស់ ទាំងការធ្វើដំណើរ ការស្នាក់នៅ និងការហូបចុកជាដើម ។ ក្រោយពីការឃាត់ខ្លួន ពួកគេទាំងអស់ត្រូវបានបញ្ជូនទៅកាន់ អធិការដ្ឋានតម្រួតស្រុកគោលខ្សូង ដើម្បីចាត់ការតាមនីតិវិធីច្បាប់៕អត្ថបទ : សោ និយមរ័ត្ន

## ស្ថានទូតកម្ពុជានៅ ថៃ នាំយកស្បៀងអាហារចែកជូនពលករខ្មែរ ៩៩ គ្រួសារ ដែលកំពុងជួបការលំបាក

https://www.kampucheathmey.com/ ថ្ងៃអាទិត្យ ១២ កញ្ញា ២០២១ដោយ Blue Sky

នៅព្រឹកថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០២១ នេះ ឯកអគ្គរាជទូតកម្ពុជា និងមន្ត្រីស្ថានទូតកម្ពុជា ប្រចាំប្រទេសថៃ បាននាំយក អង្ករ ត្រីខ បន្លែ និង ត្រីសាច់ ទៅចែកជូនបងប្អូនពលករខ្មែរ ចំនួន ៩៩ គ្រួសារ នៅផ្លូវពហុយោធិន ១ សង្កាត់ផៈយ៉ាថៃ ខ័ណ្ឌផៈយ៉ាថៃ រាជធានីបាងកក។

លោក កុយ គួង រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិកម្ពុជា បានឲ្យដឹងថា បងប្អូនទាំងនេះ សុទ្ធសឹងជាអ្នកដែលជួបការលំបាកខ្លាំង និងមួយភាគធំ ជាអ្នកដែលជាប់ធ្វើចត្តាឡីស័ក។ លោកថា ការចែកជូនគ្រឿងឧបភោគបរិភោគនេះ ត្រូវបានផ្តល់ជូនទៅតំណាងរបស់ពួកគាត់ដើម្បីយកទៅចែកជូនបន្តដល់ដៃគ្រួសារនីមួយៗ ដោយសារពួកគាត់ពុំអាចមកទទួលដោយផ្ទាល់បាន និងដើម្បីបង្ការការរាតត្បាតនៃជំងឺកូវីដ-១៩ ផង៕ **អត្ថបទ៖ កោះកែវ**

## ថៃថា ពលករកម្ពុជាវិលចូលប្រទេសខ្លួនជាបន្តបន្ទាប់ ក្រោយចាក់វ៉ាក់សាំងរួច

https://kohsantepheapdaily.com.kh/ បន្ទាយមានជ័យ ១២ ខែ កញ្ញា ឆ្នាំ ២០២១ ម៉ោង ១៣:៤៩

ខេត្តបន្ទាយមានជ័យ ៖ អាជ្ញាធរនិងសមត្ថកិច្ចថៃបានកត់សម្គាល់ថា មួយរយៈចុងក្រោយនេះ ពលករកម្ពុជាបានលួចឆ្លងដែន ដើម្បីទៅរកការងារធ្វើក្នុងប្រទេសរបស់ខ្លួនជាបន្តបន្ទាប់ ខណៈស្ថានការណ៍ជំងឺកូវីដ១៩ មានការថមថយចុះ និងក្រោយពេលកម្ពុជាចាក់វ៉ាក់សាំងដល់ពលរដ្ឋស្ទើរគ្រប់រូបនៅទូទាំងប្រទេស ។ នេះបើយោងតាមការចុះផ្សាយរបស់គេហទំព័រកាសែតថៃមួយ។ ការលើកឡើងបែបនេះ ខណៈដែលអាជ្ញាធរ និងសមត្ថកិច្ចចម្រុះថៃបានធ្វើការឃាត់ខ្លួនពលករខ្មែរ១៥នាក់ (ប្រុស៦នាក់ ស្រី៩នាក់) លើរថយន្តថៃ១គ្រឿង ក្នុងឃុំតាប្រាយ៉ា ស្រុកតាប្រាយ៉ា ខេត្តស្រះកែវ ឈមទឹកដីកម្ពុជា ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ កាលពីវេលាទៀបភ្លឺថ្ងៃទី១១ កញ្ញា ឆ្នាំ ២០២១ ។

តាមប្រភពព័ត៌មានបានឱ្យដឹងថា មុនឃាត់ខ្លួនពលករទាំងនេះ អាជ្ញាធរនិងសមត្ថកិច្ចថៃបានចុះទៅទីតាំងមួយកន្លែងក្នុងស្រុកកើតហេតុ ដើម្បីត្រួតពិនិត្យរថយន្តមួយគ្រឿង ក្រោយរាយការណ៍ថាមានកាសង្ស័យ។ រថយន្តមួយគ្រឿងខាងលើម៉ាកវីហ្គោ ពណ៌ស ពាក់ស្លាកលេខ ថៃ ដែលអ្នកបើកបរជាជនជាតិថៃ ហើយសង្ស័យជាមេខ្យល់ផងនោះបានព្យាយាមបើកគេច និងបុកម៉ូតូសមត្ថកិច្ចខូចខាត តែមិនបង្ករបួសទេ បន្ទាប់មកបានគេចខ្លួនបាត់បន្សល់ទុកពលករទាំងអស់ក្នុងរថយន្តត្រូវចាប់ខ្លួនតែម្តង។ ពលករទាំងនេះត្រូវបានត្រួតពិនិត្យសុខភាពតាមវិធានការរបស់ក្រសួងសុខាភិបាលថៃបន្ទាប់មកគេយកទៅសាកសួរលម្អិតមុនប្រគល់ទៅសមត្ថកិច្ចជំនាញដើម្បីចាត់វិធានការបន្ត ៕

## បញ្ជូនពលករខ្មែរនៅថៃ ១៣នាក់ ត្រឡប់មកមាតុប្រទេសវិញ

https://dap-news.com/ ByPH104 Posted on September 13, 2021

ភ្នំពេញ៖ លោក កុយ គួង អ្នកនាំពាក្យក្រសួងការបរទេសខ្មែរ បានឲ្យដឹងថា នៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ ២០២១នេះ ស្ថានអគ្គកុងស៊ុលកម្ពុជា ប្រចាំខេត្តសាកែវ បានអន្តរាគមន៍សម្របសម្រួល បញ្ជូនពលករខ្មែរចំនួន ១៣នាក់ ដែលមកពីតំបន់នានា ក្នុងប្រទេសថៃ ឲ្យវិលត្រឡប់មកកម្ពុជាវិញ តាមច្រកទ្វារព្រំដែន អន្តរជាតិខ្លងលឹក-ប៉ោយប៉ែត ដោយប្រគល់ជូនអាជ្ញាធរកម្ពុជា ដើម្បីដំណើការតាមនីតិវិធីសុខាភិបាល ។

## ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២១

## ពលករខ្មែរជាង ១០០គ្រួសារ ជួបការលំបាកខ្លាំងនៅថៃ ទទួលបានស្បៀងអាហារ ពីស្ថានទូតកម្ពុជានៅទីនោះ

https://dap-news.com/ ByPH104Posted on September 13, 2021

**ភ្នំពេញ៖** លោក កុយ គួង អ្នកនាំពាក្យក្រសួងការបរទេស បានឲ្យដឹងថា នៅព្រឹកថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ ២០២១ មន្ត្រីស្ថានទូតកម្ពុជា ប្រចាំប្រទេសថៃ បាននាំយក អង្ករ ត្រីខ បន្លែ ត្រី សាច់ ទៅប្រគល់ជូនតំណាង របស់បងប្អូនពលករខ្មែរចំនួន ៦ក្រុម នៅទីក្រុងបាងកក ដើម្បីនាំយកទៅចែកជូន បន្តដល់បងប្អូនពលករ សរុប ១១៣ គ្រួសារ ។ លោក កុយ គួង បានបញ្ជាក់ថា ពលករខ្មែរទាំង ១១៣គ្រួសារ ដែលកំពុងជួបការលំបាកខ្លាំងមាននៅខេត្តសមុទ្រ ប្រាកាន ចំនួន ២៤ គ្រួសារ, ខេត្តនុនថៈប៊ុរី ចំនួន ៥ គ្រួសារ, ទីក្រុងបាងកក ចំនួន ៤០ គ្រួសារ, ខេត្តឈុនប៊ុរី ចំនួន ២២ គ្រួសារ និងខេត្តប៉ះធុមថានី ២២ គ្រួសារ។ លោកបន្ថែមថា ពលរដ្ឋខ្មែរទាំងនេះ សុទ្ធសឹងជាអ្នកដែលជួបការលំបាកខ្លាំងខ្លះបាត់បង់ការងារនិងមួយភាគធំជាអ្នកដែលជាប់ធ្វើចត្តាឡីស័កមិនអាចទៅធ្វើការបាន ៕

## អាជ្ញាធរចាប់ខ្លួនអ្នកលួចឆ្លងដែនខុសច្បាប់នៅខេត្តបន្ទាយមានជ័យ

https://www.khmertimeskh.com/ September 13, 2021ខ្មែរថាមស៍

កម្លាំងល្បាតព្រំដែនបានចាប់បញ្ជូនពលករខ្មែរ ៥ នាក់ដែលបានចាកចេញពីប្រទេសថៃ ហើយបានលួចឆ្លងដែននៅភូមិចំបក់ ឃុំបឹងបេង ស្រុកម៉ាឡៃ ខណៈពួកគេប៉ុនប៉ងឆ្លងដែនខុសច្បាប់ដើម្បីគេចពីការធ្វើចត្តាឡីស័ក។ កងកម្លាំងប្រដាប់អាវុធម៉ាឡៃបានរាយការណ៍នៅថ្ងៃទី ១២ ខែកញ្ញានេះថា កម្លាំងដឹកនាំដោយមេបញ្ជាការកងពលតូចលេខ ២ នៃកងកម្លាំងប្រដាប់អាវុធ ក្រុងប៉ោយប៉ែត លោកវរសេនីយ៍ទោស្រ៊ីន លីហ៊ាង បានធ្វើការចាប់ខ្លួនពលករនៅទីតាំងដែលបានរៀបរាប់ខាងលើ ក្រោយមក ពលករទាំងនោះ ត្រូវបានធ្វើតេស្តសំណាក និងបញ្ជូនទៅធ្វើចត្តាឡីស័កនៅវិទ្យាល័យអូរសំព័រ៕

## ពលករខ្មែរ ២៣នាក់ លួចឆ្លងដែន ចូលក្នុងទឹកដីថៃ រកការងារធ្វើ ត្រូវបានឃាត់ នៅព្រំដែនខេត្តបន្ទាយមានជ័យ

https://kohsantepheapdaily.com.kh/ បន្ទាយមានជ័យ១៣ ខែ កញ្ញា ឆ្នាំ ២០២១ ម៉ោង ២៣:៤៨

បន្ទាយមានជ័យ៖ ពលករខ្មែរ ចំនួន ២៣នាក់ បានលួចឆ្លងដែន ចូលក្នុងទឹកដីថៃ រកការងារធ្វើ ហើយត្រូវបានកងកម្លាំងយោធា ឃាត់នៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២១។ ក្នុងនោះ ១៥នាក់ ឃាត់នៅព្រឹកថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២១ នៅចំណុចភ្នំកូនដំរី ក្នុងភូមិ១៤ ឃុំ.ស្រុកតាប្រាយ៉ា ខេត្តស្រះកែវ ប្រទេសថៃ។ រីឯ ៨នាក់ទៀត ត្រូវបានកងកម្លាំងកម្ពុជាយើង ឃាត់ខ្លួននៅអូរជ្រៅ ក្នុងសង្កាត់ប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។

មន្ត្រីទំនាក់ទំនងកម្ពុជា.ថៃ បានប្រាប់ថា មានប្រជាពលរដ្ឋខ្មែរ ជាពលករ បានលួចឆ្លងដែនទៅប្រទេសថៃ ដោយខុសច្បាប់ ដើម្បីរកការងារធ្វើ តាមរយៈមេខ្យល់ ត្រូវបានកម្លាំងយោធាថៃឃាត់ខ្លួនចំនួន ១៥នាក់។ ក្រោយឃាត់ខ្លួនប្រជាពលរដ្ឋខ្មែរ ជាពលករចំនួន ១៥នាក់នោះ ត្រូវបានបញ្ជូនទៅប៉ុស្តិ៍នគរបាលស្រុកតាប្រាយ៉ា ដើម្បីសាកសួរតាមចម្លើយ។ ពួកគាត់បានបញ្ជាក់ថា ពួកគេបានលួចឆ្លងទៅរកការងារធ្វើ តាមរយៈមេខ្យល់ ក្នុង ម្នាក់តំលៃ ៥.០០០បាត ជូនដល់កន្លែងធ្វើការ។ តែពេលដែលកំពុងឆ្លងដែន ចូលក្នុងទឹកដីថៃ ត្រូវបានសមត្ថកិច្ចថៃ ឃាត់ខ្លួន។ មន្ត្រីទំនាក់ទំនង បានបញ្ជាក់ថា ក្រោយពេលដែលតម្រួតយោធាថៃឃាត់ខ្លួនពលករខ្មែរ ហើយបញ្ជូនទៅសាកសួរ នៅប៉ុស្តិ៍នគរបាល។ ពលករទាំងនោះ ត្រូវបានចាត់ការ តាមផ្លូវច្បាប់។ ចំណែកពលករខ្មែរ ចំនួន ៨នាក់ ត្រូវបានកម្លាំងចម្រុះ ឈរជើងតាមបន្ទាត់ព្រំដែន ឃាត់ខ្លួន ពេលបម្រុងលួចឆ្លងដែន ទៅរកការងារធ្វើ នៅប្រទេស

ថៃ។ ពលករខ្មែរទាំងនោះ ត្រូវបានឃាត់ខ្លួន កាលពីយប់រំលងអាធ្រាត្រ ចូលថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២១ នៅភូមិអូរជ្រៅ សង្កាត់.ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។

កម្លាំងនគរបាលវរៈការពារព្រំដែនគោកលេខ៨៩១ បានប្រាប់ថា ដើម្បីអនុវត្តវិធានទប់ស្កាត់ពលករ ដែលឆ្លងដែន ដោយខុសច្បាប់ គេចវេះពីការធ្វើចត្តាឡីស័ក គឺកម្លាំងចម្រុះ បានចេញល្បាតតាមបន្ទាត់ព្រំដែន ក៏បានប្រទះឃើញពលករខ្មែរ ចំនួន ៨នាក់ (ស្រី ៣នាក់) ដែលកំពុងធ្វើសកម្មភាពលួចឆ្លងដោយខុសច្បាប់។ ក្នុងនោះមានអ្នកខេត្តបន្ទាយមានជ័យ ចំនួន ៣នាក់ ខេត្តបាត់ដំបង ចំនួន ៣នាក់ ខេត្តកំពង់ធំចំនួន ២នាក់។ កម្លាំងនគរបាលបានបញ្ជាក់ថា ក្រោយឃាត់ខ្លួន ពលករខ្មែរទាំងនោះ ត្រូវកម្លាំងនាំយកទៅសាកសួរ។ តាមចម្លើយ ពួកគាត់ មានបំណងឆ្លងដែនទៅរកការងារធ្វើ នៅប្រទេសថៃ តាមរយៈមេខ្យល់ខ្មែរ ដែលទទួលជូនទៅដល់កន្លែងការងារ នៅប្រទេសថៃ ក្នុងម្នាក់តំលៃ ៥.០០០បាត។ ពួកគេ បានអោយលុយមេខ្យល់ ហើយពេលឆ្លងដែន ត្រូវបានកម្លាំងសមត្ថកិច្ច ឃាត់។ កម្លាំងនគរបាល បានបញ្ជាក់ថា ចំពោះមេខ្យល់ ដែលបោកប្រាស់ពលករខ្មែរ កំពុងធ្វើការស្រាវជ្រាវ និងរកចាប់ខ្លួន ដើម្បីចាត់ការតាមច្បាប់ ហើយពលករខ្មែរ ចំនួន ៨នាក់នោះ ត្រូវបញ្ជូនមណ្ឌលធ្វើចត្តាឡីស័ក៕ ប៊ុន ធឿន

## លោកឧត្តមសេនីយ៍ទោ សិទ្ធិ ឡោះ ចាត់តាំងស្នងការរង៣រូប ចុះពិនិត្យបទល្មើសតាមព្រំដែន និងស្ថានភាពទឹកជំនន់

https://dap-news.com/ ByPH104Posted on September 14, 2021

ខេត្តបន្ទាយមានជ័យ ៖ លោកឧត្តមសេនីយ៍ទោ សិទ្ធិ ឡោះ ស្នងការនៃស្នងការដ្ឋាន នគរបាលខេត្តបន្ទាយមានជ័យ នៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២១នេះ បានចាត់តាំងស្នងការរងចំនួន៣រូប រួមមាន: លោក ឧត្តមសេនីយ៍ត្រី អ៊ុ សុផល ស្នងការរង នគរបាលខេត្តបន្ទាយមានជ័យ ទទួលផែនការងារព្រំដែនគោក លោកស្រីឧត្តមសេនីយ៍ត្រី ឌី សុជាតិ ស្នងការរង ទទួលផែនប្រឆាំងបទល្មើសជួញដូរមនុស្ស លោកវរសេនីយ៍ឯក ជុន លាង ស្នងការរង ទទួលទិស៨០៧ ចុះត្រួតពិនិត្យស្ថានភាពព្រំដែន បទល្មើសឆ្លងដែនខុសច្បាប់ និងស្ថានភាពទឹកជំនន់ ។

លោកឧត្តមសេនីយ៍ត្រី អ៊ុ សុផល ស្នងការរងនគរបាលខេត្តបន្ទាយមានជ័យ ទទួលផែនការងារ ព្រំដែនគោក បានមានប្រសាសន៍ថា គោលបំណង នៃការចុះបេសកកម្មតាមព្រំដែនថ្ងៃនេះគឺ ចុះត្រួតពិនិត្យកងកម្លាំង តាមគោលដៅ -ទប់ស្កាត់មេខ្យល់ បទល្មើសឆ្លងដែនខុសច្បាប់ និងការដាក់កម្លាំង ត្រៀមលក្ខណៈជាស្រេច ដើម្បីត្រៀមបង្ការ សង្គ្រោះ ពលរដ្ឋនៅតំបន់ រងគ្រោះដោយទឹកជំនន់ ការជម្លៀសពលរដ្ឋទៅកាន់ ទីទួលមានសុវត្ថិភាព ដែលរស់នៅតាមខ្សែបន្ទាត់ព្រំដែន ក្នុងភូមិសាស្ត្រ នៃវរសេនាតូចការពារព្រំដែនគោក លេខ៨០៧។ ឆ្លៀតក្នុងឱកាសនោះ លោកឧត្តមសេនីយ៍ត្រី អ៊ុ សុផល ស្នងការរងក៏បាននាំយកអំណោយ អាវយឺត ចែកជូនដល់កម្លាំង និងមានមតិផ្តាំផ្ញើ ដល់កងកម្លាំងទាំងអស់ អនុវត្តតួនាទី ភារកិច្ចបានល្អ រួមគ្នាទប់ស្កាត់រាល់បទល្មើសតាមព្រំដែន ត្រូវយកចិត្តទុកដាក់ថែរក្សាសុខភាព និងបន្តអនុវត្តការណែនាំ របស់ក្រសួងសុខាភិបាល ៣កុំ ៣ការពារ ៕

# ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២១

## សម្តេចតេជោ ៖ មណ្ឌលចត្តាឡីស័កតាមព្រំដែនពលករខ្មែរ នៅសល់តែជាង៧ពាន់នាក់ប៉ុណ្ណោះ

https://kohsantepheapdaily.com.kh/ ភ្នំពេញ១៧ ខែ កញ្ញា ឆ្នាំ ២០២១ ម៉ោង ០៩:២៨

រាជធានីភ្នំពេញ ៖ សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីបានបញ្ជាក់នៅតាមមណ្ឌលចត្តាឡីស័កនៅតាមព្រំដែនកម្ពុជាថៃមានពលករមកពីថៃកំ ពុងធ្វើចត្តាឡីស័កមានជាង៧ពាន់នាក់ប៉ុណ្ណោះ ដែលមានមួយចំនួនថយចុះបន្ទាប់មានពីការចាក់វ៉ាក់សាំង ។ ថ្លែងក្នុងពិធីប្រកាសបើកយុទ្ធនាការចាក់វ៉ាក់សាំងប្រឆាំងជំងឺកូវីដ១៩ជូនកុមារចាប់ពីអាយុ៦ដល់១២ឆ្នាំ នាព្រឹកថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២១បានសម្តេចតេជោហ៊ុន សែន នាយករដ្ឋមន្ត្រីបានគូសបញ្ជាក់មកដល់មកពេលនេះ ចំនួនពលកករខ្មែរមកពីថៃកំពុងធ្វើចត្តាឡីស័កនៅមណ្ឌលចត្តាឡីស័កតាមព្រំដែនកម្ពុជាមានការថយចុះជាងពេលកន្លងមក ។ សម្តេចគូសបញ្ជាក់ថា ៖«តាមរបាយការណ៍ដែលខ្ញុំទទួលបាននៅក្នុងមណ្ឌលចត្តឡីស័កនៅតាមព្រំដែននៅសល់ជាង៧ពាន់នាក់ ខណៈកន្លងមកមានជាង១ម៉ឺននាក់ ។ តួលេខនេះបង្ហាញអត្រាអ្នកព្យាបាលជា ហើយចេញពីមណ្ឌលចត្តាឡីស័ក» ។ ជាមួយគ្នានោះដែរ សម្តេចតេជោ ហ៊ុន សែន ក៏បានឲ្យដឹងពលករខ្មែរដែលវិលត្រឡប់មកពីប្រទេសថៃវិញភាគីច្រើនសុទ្ធតែឆ្លងជំងឺកូវីដ១៩ ក្នុងនោះភាគីច្រើនជំងឺកូវីដ១៩ បំប្លែងថ្មីប្រភេទដែលតាតែម្តង ។

សម្តេចក៏បានឲ្យដឹងថា ៖«មុននេះយើងព្រួយបារម្ភធំណាស់ គឺពលករមកពីថៃ ប៉ុន្តែដោយមានកិច្ចសហការនិងប្រតិបត្តិការល្អរវាងរដ្ឋបាលកម្ពុជា និងរដ្ឋបាលថៃធ្វើឲ្យការវិលត្រឡប់ដោយរបៀបរៀបរាយរបស់ពលករយើងនៅក្នុងប្រទេសថៃបូកជាមួយនឹងវិធានការប្រកាន់យកប្រទេសថៃតាមព័ត៌មានខ្ញុំទទួលបាន គឺពលករយើងបានចាក់វ៉ាក់សាំងបានប្រមាណ៥២០០០នាក់ នៅក្នុងប្រទេសថៃ» ។ សម្តេចតេជោ បានបន្ថែមថា មកដល់ពេលនេះមានពលករខ្មែរមកពីថៃ កំពុងធ្វើចត្តាឡីស័កតាមព្រំដែននៅសល់តែជាង៧ពាន់នាក់ប៉ុណ្ណោះ ។ ភាគច្រើនពលករមកពីថៃភាគច្រើនឆ្លងជំងឺកូវីដ-១៩ ប្រភេទដែលតា។ សម្តេចតេជោ បានបញ្ជាក់ថា «សល់ជាង៧ពាន់នាក់ទេ ពលករមកពីថៃកំ ពុងនៅក្នុងមណ្ឌលចត្តាឡីស័កតាមព្រំដែន ការទប់ស្កាត់ការនាំចូលការធ្វើចត្តាឡីស័ក និងការធ្វើតេស្តរហ័សជាការទប់ស្កាត់បានឆាប់រហ័ស» ។ សម្តេចតេជោ បានបន្ថែមថា កម្ពុជាបានខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងការ ទប់ស្កាត់ជំងឺកូវីដ-១៩ ដើម្បីដាក់ចេញនូវវិធានការយុទ្ធសាស្ត្រទាំង៦របស់រាជរដ្ឋាភិបាលជាពិសេសនោះ ធ្វើចត្តាឡីស័កតេស្តរហ័ស ៕

## លោកនាយករដ្ឋមន្ត្រី៖ ពលករខ្មែរប្រមាណជាង ៥ ម៉ឺននាក់ បានទទួលការចាក់វ៉ាក់សាំងរួចហើយ នៅប្រទេសថៃ

https://www.postkhmer.com/ ម៉ុំ គន្ធា | Publication date 17 September 2021 | 09:01 ICT

**ភ្នំពេញ៖** លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានលើកឡើង នាព្រឹកថ្ងៃទី ១៧ ខែកញ្ញានេះ ក្នុងយុទ្ធនាការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ ១៩ ជូនកុមារអាយុពី ៦ ឆ្នាំ ដល់អាយុក្រោម ១២ ឆ្នាំ នៅវិមានសន្តិភាពថា ពលករខ្មែរប្រមាណជាង ៥ ម៉ឺននាក់បានទទួលការចាក់វ៉ាក់សាំងរួចហើយ នៅប្រទេសថៃ។ លោកមានប្រសាសន៍ថា៖ « ជាមួយគ្នានេះដែរនៅក្នុងមណ្ឌលចត្តាឡីស័កតាមព្រំដែននៅសល់ប្រមាណជាជាង ៧ ពាន់នាក់។ ពលករដែលវិលត្រលប់មកពីថៃ ភាគច្រើនឆ្លងវីរុសកូវីដ ១៩ ហើយវាសុទ្ធតែជាប្រភេទដែលតា»។ ទន្ទឹមនឹងនេះដែរ លោកក៏បានលើកពីការថយចុះនៃការឆ្លងរាលដាលនៃវីរុសកូវីដក្នុងរាជធានីភ្នំពេញ និងខេត្តកណ្តាល បន្ទាប់ពីយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ ១៩ រួចហើយ។ លោកបានបញ្ជាក់ថា ភ្នំពេញ និងខេត្តកណ្តាលជាតំបន់ដែលឆ្លងខ្លាំងតែពេលនេះមានការធ្លាក់ចុះ បើប្រៀបធៀបជាមួយនឹងខែមេសានិងឧសភា ទាំងការឆ្លង ការវិវត្តទៅជាធ្ងន់ធ្ងរ និងការស្លាប់ផងដែរ។

លោក ហ៊ុន សែន បានថ្លែងថា៖ «នៅពេលរាំក់សាំងជ្រាបក្នុងខ្លួន ទោះបីជាឆ្លងក៏មិនវិវត្តទៅធ្ងន់ធ្ងរដែរ ប៉ុន្តែកុំអាងលើរាំក់សាំងនាំគ្នាភ្លេចការការពារនោះទេ។ វិធានការ ៣ ការពារ ៣ កុំ វិធានការរដ្ឋបាល និងវិធានការច្បាប់ ត្រូវតែបន្ត មិនមានការលើកលែងទេ»៕

## នគរបាលប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បញ្ជូនជនសង្ស័យម្នាក់ទៅសាលាដំបូងខេត្ត ពីបទប្រទូស្តកេរ្តិ៍ខ្មាស ទៅលើក្មេងស្រីអាយុ១១ឆ្នាំ

http://cambodiapolice.com/policekh/ 5:34 pm 15 កញ្ញា 2021

ខេត្តបន្ទាយមានជ័យ ៖ បុរសម្នាក់ស្រវឹងស្រាថ្នាំបានប្រព្រឹត្តអំពើល្មើស(ប្រទូស្តកេរ្តិ៍ខ្មាស) ទៅលើក្មេងស្រីម្នាក់អាយុ១១ឆ្នាំ ត្រូវបាននគរបាលឃាត់ខ្លួនបញ្ជូនទៅសាលាដំបូងខេត្តបន្ទាយមានជ័យ ដើម្បីចាត់ការតាមនិតិវិធីនៅថ្ងៃទី១៥ខែកញ្ញា ឆ្នាំ២០២១នេះហើយ ។

លោកវរសេនីយ៍ឯកឡាយ គឹមលួន នាយការិយាល័យ នរបាលប្រឆាំងការជួញដូរមនុស្សនិងការពារអមនីតិជន បានឲ្យដឹងថា៖ ដោយអនុវត្តតាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សិទ្ធិ ឡោះ ស្នងការនរបាលខេត្តបន្ទាយមានជ័យ និងដោយមានការសម្របសម្រួលពីឯកឧត្តម កើត សុណ្ណារ៉េត ព្រះរាជអាជ្ញាធរ អមសាលាដំបូងខេត្តបន្ទាយមានជ័យ ។ ជនសង្ស័យម្នាក់ត្រូវបាននគរបាលស្រុកអូរជ្រៅឃាត់ខ្លួន ឈ្មោះ សុខ វង្ស ភេទប្រុសអាយុ៣៦ឆ្នាំ មានស្រុកកំណើតនៅភូមិស្វាយលួង ឃុំស្វាយលួង ស្រុកកន្លៀង ខេត្តពោធិសាត់ ជាពលករមកពីប្រទេសថៃស្នាក់នៅធ្វើចត្តាឡីស័កមណ្ឌលនៅវិទ្យាល័យកូប ស្ថិតក្នុងភូមិណាកាឆាយ ឃុំកូប ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ។នៅថ្ងៃទី១២ខែកញ្ញា ឆ្នាំ២០២១ វេលាម៉ោង៤ទាបភ្លឺ ជននេះពាក់ព័ន្ធករណីប្រទូស្តកេរ្តិ៍ខ្មាសទៅលើក្មេងស្រីងអាយុ១១ឆ្នាំ នៅមណ្ឌលចត្តាឡីស័កបន្ទប់ដេកជាមួយគ្នា ត្រូវឃាត់ខ្លួន តាមបណ្តឹងបងស្រីក្មេងស្រីរងគ្រោះ ដែលបានភ្ញាក់ទាន់ឃើញពីសកម្មភាពរបស់ជនសង្ស័យបានប្រព្រឹត្តទៅលើប្អូនស្រីរបស់ខ្លួន ។

លោកស្រី ឧត្តមសេនីយ៍ត្រី ឌី សុជាតិ ស្នងការរង ទទួលផែនប្រឆាំងការជួញដូរនិងការពារអនីតិជន បានឲ្យដឹងថា៖ជនសង្ស័យ មកពីប្រទេសថៃតាមច្រកអូរបីជាន់ មកធ្វើចត្តាឡីស័កនៅមណ្ឌលវិទ្យាល័យកូប នៅថ្ងៃទី០៤ខែកញ្ញា ឆ្នាំ២០២១ ស្នាក់អគាបន្ទប់លេខ០៦ ដែលមានមនុស្សប្រុស ស្រីចំនួន២៥នាក់ រួបគេ រួមទាំងក្មេងស្រីរងគ្រោះនិងបងស្រីរបស់គេដេកទលក្បាលគ្នា ។ នៅមុនពេលកើតហេតុល្ងាចថ្ងៃទី១១ខែកញ្ញា ឆ្នាំ២០២១ រូបគេនិងអ្នកស្នាក់នៅអគារជាមួយគ្នាចំនួន០៨នាក់ (មិនស្គាល់ឈ្មោះ) បានផឹកស្រាថ្នាំដែលឲ្យគេទិញមកឲ្យទម្លាក់ទុកនៅរបងសាលា ដោយផឹកផងរាំលេងផង អស់ស្រាចំនួន០៦ដបទឹកសុទ្ធ រហូតដល់ម៉ោង១០យប់ទើបបែកទៅដេករៀងៗខ្លួន ។នៅវេលាម៉ោង០៣ទាបភ្លឺក៏បានយកដៃលូករាវលើខ្លួនប្រាណក្មេងស្រីនោះរយៈពេលប្រហែល០១ម៉ោងខណៈដែលក្មេងស្រីនោះដេកលក់ដោយពុំដឹងខ្លួន តែជាអុសលក៏ត្រូវបងស្រីនាងភ្ញាក់ទាន់ស្រែកឡូឡានិងប្តឹងគ្រូពេទ្យ និងសមត្ថកិច្ចឃាត់ខ្លួនតែម្តង ។ លោកស្រី ឧត្តមសេនីយ៍ស្នងការរង បានបញ្ជាក់ថា៖ផ្អែកតាមបណ្តឹងរបស់បងស្រីក្មេងស្រីរងគ្រោះ និងចម្លើយសារភាពរបស់ជនសង្ស័យ ។នគរបាលជំនាញការិយាល័យប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន បានកសាងសំណុំរឿងបញ្ជូនជនទៅសាលាដំបូងចាត់ការតាមនិតិវិធីហើយដែរ ៕

## លួចឆ្លងដែនចូលទឹកដីថៃ ត្រូវសមត្ថកិច្ចឃាត់ខ្លួនបាន៩នាក់ មានទាំងជនពិការផងដែរ

https://www.kampucheathmey.com/ ថ្ងៃព្រហស្បតិ៍ ១៦ កញ្ញា ២០២១ដោយ Sorn Phanith

ពលករខ្មែរប្រុសស្រីចំនួន៩នាក់ នៅពេលឆ្លងដែនចូលក្នុងទឹកដីថៃហើយ បានជាប់គាំងចេញមិនរួច ដោយសារទឹកអូរជន់ឡើងខ្លាំង នាំគ្នាត្រឡប់ថយក្រោយរង់ចាំទឹកស្រក ក៏ត្រូវសមត្ថកិច្ចប្រទះឃើញឃាត់ខ្លួនតែម្ដង។ សមត្ថកិច្ចបានឱ្យដឹងថា ការឃាត់ខ្លួនពលករប្រុសស្រីខាងលើនៅ ខណៈដែលសមត្ថកិច្ចចម្រុះការពារព្រំដែនគោក នៅវេលាទៀបភ្លឺថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២១ បានចុះល្បាតប្រទះឃើញនិងឃាត់ខ្លួនពលករប្រុសស្រីចំនួន៩នាក់ ខណៈពេលដែលក្រុមពលករទាំងអស់ប្រុងឆ្លងដែនចូលទៅក្នុងទឹកដីប្រទេសថៃ។

តាមចម្លើយសារភាពរបស់ពលករ ដែលបានប្រាប់ដល់សមត្ថកិច្ចថា ករណីដែលពួកគេលួចឆ្លងដែនទៅប្រទេសថៃនេះ ក្នុងគោលបំណងជ្រកកោន ដើម្បីស្វែងរកការងារធ្វើ ហើយក្រៅពីនេះពួកគេនិងដើរសុំទាននៅក្នុងប្រទេសថៃផងចំពោះអ្នកដែលពិការ។ ពលករខ្មែរ ដែលឃាត់ខ្លួនខាងលើសរុបចំនួន៩នាក់ ក្នុងនោះមានស្រីចំនួន៣នាក់ រួមទាំងជនពិការចំនួន៤នាក់ ត្រូវកម្លាំងល្បាតព្រំដែនឃាត់ខ្លួននៅវេលាម៉ោង៣:៣៥នាទី ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២១ ត្រង់ចំណុចព្រំដែនក្នុងភូមិអូរល្ងា ឃុំជ្រៃសីមា ស្រុកសំពៅលូន ខេត្តបាត់ដំបង។ ករណីពលករឆ្លងដែនខុសច្បាប់ខាងលើ ក្រោយសមត្ថកិច្ចធ្វើការសាកសួរ និងណែនាំអប់រំសមត្ថកិច្ចបានតម្រូវឲ្យធ្វើកិច្ចសន្យាឈប់ប្រព្រឹត្ត ហើយបានអនុញ្ញាតឲ្យពួកគេវិលត្រឡប់ទៅស្រុកកំណើតរៀងៗខ្លួនវិញផងដែរ៕ **អត្ថបទ៖ សៅ សារិទ្ធ**

## កុងស៊ុលខ្មែរប្រចាំខេត្តសាកែវ ប្រទេសថៃ ជួយសម្រួលពលករខ្មែរ ៥នាក់ មកមាតុភូមិវិញ

http://freshnewsasia.com/ 2021-09-16 06:14pm

**(ភ្នំពេញ)៖** ស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំខេត្តសាកែវ នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២១ បានបន្តអន្តរាគមន៍សម្របសម្រួលបញ្ជូនពលករខ្មែរចំនួន ៥នាក់ ដែលមកពីតំបន់នានាក្នុងប្រទេសថៃ ឲ្យវិលត្រឡប់មកកម្ពុជាវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិខ្លងលឹក-ប៉ោយប៉ែត។ បើតាមលោក កុង គួង អ្នកនាំពាក្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បញ្ជាក់ទៀតថា មនុស្សទាំងអស់ត្រូវបានប្រគល់ជូនអាជ្ញាធរកម្ពុជា ដើម្បីដំណើការតាមនីតិវិធីសុខាភិបាល៕

## ពលរដ្ឋខ្មែរប្រយ័ត្នចាញ់បោក! អូស្ត្រាលីមិនទាន់ឱ្យគម្រោងទិដ្ឋាការ "កសិកម្ម" ថ្មី នៅប្រទេសណាទេ

https://www.kampucheathmey.com/ ថ្ងៃព្រហស្បតិ៍ ១៦ កញ្ញា ២០២១ដោយ KC Virak

ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំនៅប្រទេសអូស្ត្រាលីបានអះអាងថា ថ្មីៗនេះមានសារព័ត៌មាន បណ្ដាញសង្គម ក្រុមហ៊ុនឯកជន និងបុគ្គលមួយចំនួន បានដើរបំផុសបំផុលផ្ដល់ពត៌មានពុំច្បាស់លាស់ និងបំភ្លៃការពិត ក្នុងចេតនាបោកប្រាស់ ក្នុងការជ្រើសរើសពលករខ្មែរមកធ្វើការនៅប្រទេសអូស្ត្រាលី (Australia) ក្រោមគម្រោងទិដ្ឋាការ "កសិកម្ម" ថ្មី (Australian Agriculture Visa) របស់ប្រទេសអូស្ត្រាលី។ ដើម្បីជៀសវាងការចាញ់បោកជនខិលខូចឆ្លៀតឱកាស ស្ថានទូតបញ្ជាក់ថា បច្ចុប្បន្នរដ្ឋាភិបាលអូស្ត្រាលី តាមរយៈក្រសួងការបរទេស ក្រសួងមហាផ្ទៃ និងក្រសួងកសិកម្មអូស្ត្រាលី កំពុងពិភាក្សានៅឡើយ លើការរៀបចំគម្រោងទិដ្ឋាការ "កសិកម្ម" ថ្មី ជាមួយនឹងការកំណត់លក្ខខ័ណ្ឌផ្សេងៗក្នុងការទទួលបានទិដ្ឋាការនេះ។ គម្រោងទិដ្ឋាការកសិកម្មថ្មីនេះ នឹងផ្ដល់ឱកាសដល់ពលរដ្ឋប្រទេសមួយចំនួននៅក្នុងតំបន់អាស៊ីអាចមកធ្វើការនៅប្រទេសអូស្ត្រាលី លើវិស័យមួយចំនួនរួមទាំង វិស័យឧស្សាកម្មកែច្នៃសាច់ (Agroature sector including meat processing) ជាមួយនឹងការផ្ដល់ឱកាសអាច

ស្នើសុំសិទ្ធរស់នៅអចិន្ត្រៃយ៍ ក្នុងករណីពលករនោះ បំពេញបានតាមលក្ខខ័ណ្ឌ និងមានតម្រូវការជាក់ស្ដែងពីរដ្ឋាភិបាលអូស្ត្រាលី។ តាមគម្រោងទិដ្ឋាការថ្មីនេះ នឹងពិភាក្សាចប់សព្វគ្រប់នៅចុងខែកញ្ញា ឆ្នាំ២០២១ ខាងមុខ។ ជាមួយគ្នានេះ រដ្ឋាភិបាលអូស្ត្រាលី នឹងធ្វើការពិភាក្សាចរចាទ្វេភាគី ជាមួយប្រទេសដៃគូរមួយចំនួននៅក្នុងតំបន់លើគម្រោងទិដ្ឋាការថ្មីនេះ។

ស្ថានទូតបានបញ្ជាក់ផងដែរថា ក្រោមគោលការណ៍របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការស្វែងរកទីផ្សារការងារជូនពលករខ្មែរកន្លងមក ស្ថានទូតបានខិតខំស្វះស្វែងរកទីផ្សារការងារជូនបងប្អូនខ្មែរទាំងនៅប្រទេសអូស្ត្រាលី ក៏ដូចជាប្រទេសនូវែលហ្សេឡង់ តាមរយៈការជួបពិភាក្សាជាមួយថ្នាក់ដឹកនាំរបស់រដ្ឋាភិបាល ប្រទេសនិមួយៗជាបន្តបន្ទាប់។ ចំពោះគម្រោងទិដ្ឋាការកសិកម្មថ្មីនេះ ក្រោមការណែនាំដ៏ខ្ពង់ខ្ពស់ពីថ្នាក់ដឹកនាំក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងកិច្ចសហការគាំទ្រពីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈកម្ពុជា ស្ថានទូតបានត្រៀមខ្លួនជាស្រេចក្នុងការបន្តជួបចរចារកទីផ្សារការងារជូនពលរដ្ឋខ្មែរជាមួយរដ្ឋាភិបាលអូស្ត្រាលី។ ស្ថានទូតបញ្ជាក់ជាថ្មីថា មកទល់ពេលនេះគម្រោងទិដ្ឋាការកសិកម្មនេះ កំពុងស្ថិតក្នុងដំណាក់កាលរៀបចំនៅឡើយ ហើយរដ្ឋាភិបាលអូស្ត្រាលីនៅពុំទាន់សម្រេចថា នឹងផ្ដល់ទិដ្ឋាការប្រភេទនេះជូនកម្ពុជា ឬប្រទេសណាមួយនៅឡើយទេ។ ហេតុនេះ ស្ថានទូតស្នើបងប្អូនប្រុងប្រយ័ត្នខ្ពស់ចំពោះរាល់ការផ្សព្វផ្សាយព័ត៌មានពីការជ្រើសរើស និងការបញ្ជូនពលករខ្មែរមកធ្វើការនៅប្រទេសអូស្ត្រាលី ដោយទីភ្នាក់ងារជ្រើសរើស បុគ្គល ឬអង្គភាពណាមួយ។ ជាមួយគ្នានោះ ស្ថានទូតបានប្រាប់ឱ្យប្រជាពលរដ្ឋ តាមដានព័ត៌មានផ្លូវការជុំវិញវឌ្ឍនភាពគម្រោងទិដ្ឋាការកសិកម្មថ្មីនេះ នៅលើគេហទំព័រផ្លូវការរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិកម្ពុជា ស្ថានទូតកម្ពុជាប្រចាំប្រទេសអូស្ត្រាលី (https:// www.embassyofcambodi.ogr) ឬក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈកម្ពុជា៕ កោះកែវ

## សង់ត្រាល់ស្នើរដ្ឋាភិបាលកែសម្រួលគោលនយោបាយ និងវិធានការ ដើម្បីឆ្លើយតបកង្វល់ពលករខ្មែរចំណាកស្រុក

https://www.rfi.fr/km/ ចុះផ្សាយនៅថ្ងៃ៖ 16/09/2021 - 13:33

អង្គការសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (សង់ត្រាល់) នៅថ្ងៃទី១៦ ខែកញ្ញានេះ បានចេញផ្សាយរបាយការណ៍មួយ ស្ដីពីបញ្ហាប្រឈមរបស់ពលករកម្ពុជា ក្នុងអំឡុងពេលនៃការផ្ទុះរាលដាលជំងឺកូវីដ-១៩។ នៅក្នុងរបាយការណ៍កំរាស់៤០ទំព័រនេះ សង់ត្រាល់បានរំលេចពីក្ដីកង្វល់ និងបញ្ហាប្រឈមជាក់ស្ដែង ដែលពលករកម្ពុជាកំពុងជួបប្រទះនៅក្នុងប្រទេសថៃ។ អង្គការសង់ត្រាល់ ក៏បានស្នើឲ្យភាគីពាក់ព័ន្ធ កែសម្រួលគោលនយោបាយ ច្បាប់ និងវិធានការនានា ដើម្បីធានាបាននូវដំណោះស្រាយ ដែលមានប្រសិទ្ធភាព ឆ្លើយតបនឹងកង្វល់របស់ពលករ។ នៅអំឡុងពេលនៃការផ្ទុះកូវីដ១៩ ពលករនិងសាច់ញាតិរបស់ពលករ ជួបបញ្ហាប្រឈមជាច្រើន ដូចជា ការបញ្ចប់កិច្ចសន្យាការងារដោយអយុត្តិធម៌ពីថៅកែថៃ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ការជួញដូរមនុស្ស ការប្រើប្រាស់អំពើហិង្សា កង្វះស្បៀងអាហារព្រោះគ្មានការងារធ្វើ និងផលប៉ះពាល់ពីការបិទខ្ទប់របស់រដ្ឋាភិបាលថៃជាដើម។ នេះបើតាមរបាយការណ៍របស់ អង្គការសង់ត្រាល់។

របាយការណ៍ដដែលក៏បានបង្ហាញផងដែរ អំពីភាពលំអៀងក្នុងកិច្ចគាំពារផ្សេងៗ រួមមាន ការមិនទទួលបានការគិតគូរពីរដ្ឋាភិបាលថៃលើការធ្វើតេស្តរកវីរុសកូវីដលើពលករជនជាតិខ្មែរ ដែលធ្វើឲ្យទំហំនៃការរីករាលដាលក្នុងតំបន់ពួកគេរស់នៅកាន់តែកើនឡើងៗ។ ឯយុទ្ធនាការចាក់វ៉ាក់សាំងលើក្រុមពលករចំណាកស្រុក ក៏មិនទាន់មានគោលការណ៍ជាក់លាក់ណាមួយនៅឡើយ។ បើទោះបីជា ភាគីថៃបានចេញនូវវិធានការបិទខ្ទប់ជាបន្តបន្ទាប់ដើម្បីទប់ស្កាត់ការឆ្លងរាលដាលទ្រង់ទ្រាយធំ រីឯភាគីកម្ពុជាឯណោះវិញក៏បានប្រកាសផ្ដល់ជំនួយដល់ពលករដែលខ្វះខាត

និងប្រកាសបើកព្រំដែនទទួលយកពលករឡើងវិញក៏ដោយ ក៏អង្គការសង់ត្រាលអះអាងថា ការឆ្លើយតបទាំងនេះនៅតែមិនទាន់គ្រប់ជ្រុងជ្រោយ និងបានស្នើឲ្យរដ្ឋាភិបាលនៃប្រទេសទាំងពីរ បន្ថែមនូវគោលនយោបាយក្នុងការដោះស្រាយបញ្ហាទាំងនេះ។ សំណើនោះរួមមានជាអាទិ៍ បន្ថែមកិច្ចសហការតាមរយៈស្ថានទូត ការណែនាំដល់និយោជកដើម្បីចៀសវាងការរំលោភសិទ្ធមនុស្ស ការសម្រួលលើភាពស្មើគ្នានៃការទទួលបានការគាំពាសុខភាព ពង្រឹងនូវផាសុកភាពក្នុងមណ្ឌលចត្តាឡីស័ក និងមធ្យោបាយធ្វើដំណើរវិលត្រឡប់ចូលស្រុករបស់ពលករ។ល។

គួរបញ្ជាក់ថា សព្វថ្ងៃនេះ ពលករខ្មែរដែលកំពុងធ្វើការនៅប្រទេសថៃ ទាំងមានឯកសារ និងមិនមានឯកសារ មានចំនួនចន្លោះពី ១,៨លាននាក់ ទៅ ២លាននាក់។ ពួកគេទាំងនោះ កំពុងបំរើការងារនៅក្នុងវិស័យផ្សេងៗនៅក្នុងប្រទេសថៃ មានជាអាទិ៍ វិស័យសំណង់ ឧស្សាហកម្មម្ហូបអាហារ គ្រឿងអេឡិចត្រូនិក ឧស្សាហកម្មនេសាទ កសិកម្ម សេវាកម្ម និងអ្នកធ្វើការតាមផ្ទះ៕

## ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២១

### ថៃចាប់ពលករខ្មែរ ៨ នាក់ ដែលព្យាយាមលួចឆ្លងព្រំដែន

https://www.kampucheathmey.com/ ថ្ងៃសុក្រ ១៧ កញ្ញា ២០២១ដោយ KC Virak

ពលករខ្មែរចំនួន ៨ នាក់ ដែលខ្លះបានព្យាយាមរត់គេចពីកម្លាំងទាហានថៃ ត្រូវបានឃាត់ខ្លួន ខណៈពួកគេលបឆ្លងដែនចូលទឹកដីថៃដោយគ្មានច្បាប់អនុញ្ញាត។ កម្លាំងយោធាព្រំដែនលេខ ១៣ និងកម្លាំងកងរយលេខ ១៣០២ បានស្ទាក់ចាប់ពលករខ្មែរបានចំនួន៦នាក់ នៅព្រឹកថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ២០២១។ ដោយឡែក ២ នាក់ទៀតបានរត់គេចខ្លួន ត្រង់ចំណុច ភូមិថាន់ថៃ ក្នុងឃុំថាប់ព្រិច ស្រុកអារញ្ញប្រាថេត ខេត្តស្រះកែវ ប៉ុន្តែនៅទីបំផុតកម្លាំងកងរយបានតាមចាប់ខ្លួនពលករដែលរត់គេចយកមកវិញដល់ត្រង់ចំណុវផ្លូវបំបែកថាន់ថៃ។ ពលករទាំងអស់បានសារភាពថា ពួកគេត្រូវបានមេខ្យល់ណាត់ឱ្យជួបជុំគ្នានៅក្នុង ឃុំបឹងបេង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ មុនពេលចេញដំណើរឆ្លងដែន ដោយបង់ប្រាក់ទៅឱ្យមេខ្យល់ក្នុងម្នាក់ៗចាប់ពី ៣,០០០ ទៅ ៤,០០០ បាត។ ក្រោយពីបានត្រួតពិនិត្យសុខភាពរួចមក ពលករទាំងអស់ ត្រូវបានទាហានឈុតខ្មៅថៃប្រគល់ទៅឱ្យកម្លាំងអធិការ ខ្លងណាំសៃ ដើម្បីអនុវត្តតាមនីតិវិធី៕ អត្ថបទ៖ សោ និយមរ័ត្ន

### ពលរដ្ឋខ្មែរ ៤ នាក់ដែលជាប់គាំងនៅប្រទេសម៉ាឡេស៊ី ដោយសារជំងឺកូវីដ ១៩ ត្រូវបានជួយអន្តរាគមន៍បញ្ជូនត្រឡប់មកកម្ពុជាវិញនៅថ្ងៃនេះ

https://www.postkhmer.com/ រី សុបាន់ | Publication date 17 September 2021 | 17:33 ICT

**ភ្នំពេញៈ** ស្ថានទូតកម្ពុជាប្រចាំប្រទេសម៉ាឡេស៊ីបានជួយអន្តរាគមន៍បញ្ជូនពលរដ្ឋកម្ពុជាចំនួន ៤ នាក់ដែលជាប់គាំងនៅប្រទេសម៉ាឡេស៊ី ដោយសារការរាតត្បាតជំងឺកូវីដ ១៩ ត្រឡប់មកកម្ពុជាវិញនៅថ្ងៃនេះ។

លោក កុយ គួង អ្នកនាំពាក្យក្រសួងការបរទេសបានឱ្យដឹងថា៖ «ស្ថានទូតកម្ពុជាប្រចាំប្រទេសម៉ាឡេស៊ីបានអន្តរាគមន៍ជួយបញ្ជូនពលរដ្ឋខ្មែរចំនួន៤ នាក់ត្រឡប់មកកម្ពុជាវិញ តាមរយៈជើងយន្តហោះអាកាសចរណ៍សិង្ហបុរីលេខ SQ158 ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ ២០២១ វេលា ម៉ោង ៥:៣០ នាទីល្ងាចនៅព្រលានយន្តហោះភ្នំពេញ»។ លោកថ្លែងថា ដោយសារមានជីវភាពក្រីក្រខ្លាំង ប្រជាពលរដ្ឋទាំង ៤ នាក់ពុំមានលទ្ធភាពទិញសំបុត្រយន្តហោះ ស្ថានទូតកម្ពុជាប្រចាំប្រទេសម៉ាឡេស៊ី បានសហការជាមួយអង្គការអន្តរជាតិ ទេសន្តរប្រវេសន៍ប្រចាំប្រទេសម៉ាឡេស៊ី ដើម្បីផ្តល់សំបុត្រយន្តហោះជូនពួកគាត់ត្រឡប់មកកម្ពុជាវិញ។ លោក កុយ គួង បន្តថា ស្ថានទូតកម្ពុជាប្រចាំ

ប្រទេសម៉ាឡេស៊ីបានជួយចេញលិខិតធ្វើដំណើរបណ្ដោះអាសន្ន និងសម្របសម្រួលជាមួយមន្ត្រីអន្តោប្រវេសន៍ម៉ាឡេស៊ី ព្រមទាំងបានចាត់មន្ត្រីជូនដំណើរពលរដ្ឋទាំង៤នាក់មកកាន់អាកាសយានដ្ឋានអន្តរជាតិគូឡាឡាំពួផងដែរ។ កាលពីថ្ងៃទី ១៦ ខែកញ្ញា ស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំខេត្តសាកែវ ប្រទេសថៃបានអន្តរាគមន៍សម្របសម្រួលបញ្ជូនពលករកម្ពុជាចំនួន ៥ នាក់ ដែលមកពីតំបន់នានាក្នុងប្រទេសថៃឱ្យវិលត្រឡប់មកកម្ពុជាវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិខ្លងលឹកប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ និងបានប្រគល់ជូនអាជ្ញាធរកម្ពុជា ដើម្បីដំណើរការតាមនីតិវិធីសុខាភិបាល៕

## ពលករឆ្លងដែនខុសច្បាប់ចំនួន ២៦នាក់ ត្រូវបានឃាត់ខ្លួនដោយកម្លាំងកងការពារព្រំដែនលេខ៥០៣

https://swiftnewsdaily.com/ SWIFT NEWS ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២១

(បន្ទាយមានជ័យ)៖ ពលករឆ្លងដែនខុសច្បាប់ ត្រូវបានកម្លាំងកងការពារព្រំដែនលេខ៥០៣ ឃាត់ខ្លួនបាននៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២១នេះ វេលាម៉ោង ១២:០៥នាទី រហូតដល់ ម៉ោង ១៦:០០នាទីល្ងាច ខណៈពេលដែលពួកគេកំពុងដឹកនាំពលករឆ្លងដែនទៅប្រទេសថៃ ឃាត់បាន ២ករណី ដោយករណីទី១ ឃាត់បានចំនួន ១៦នាក់ ក្នុងនោះស្រី ៩នាក់ ក្មេង ១នាក់ រថយន្ត ២គ្រឿង ១ម៉ាកកាម៉ារីពណ៌ខ្មៅ ពាក់ស្លាកលេខ ពោធិ៍សាត់ 2A 0206 ម្ចាស់រថយន្តគេចខ្លួនបាត់ ២ម៉ាកកាម៉ារីពណ៌ខៀវ ពាក់ស្លាកលេខ កំពង់ចាម 2A 0521 ម្ចាស់រថយន្តពីរនាក់ប្តីប្រពន្ធ ចំណែកម្ចាស់ និងរថយន្ត បានប្រគល់ជូនកងរាជអាវុធហត្ថខេត្តបន្ទាយមានជ័យ។ ករណីទី២ ឃាត់បានចំនួន ១០នាក់ ក្នុងនោះស្រី ២នាក់ ក្មេង ១នាក់ គោយន្តកន្ត្រៃ ១គ្រឿង និងម្ចាស់ប្រគល់ជូនកងរាជអាវុធហត្ថខេត្តបន្ទាយមានជ័យ ចំណែកគោយន្តរក្សាទុកនៅអង្គភាព។ ហើយឃាត់ខ្លួនបានត្រង់ភូមិសាស្ត្រភូមិចក់ពួក ឃុំស្លក្រាម ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ។

ក្រោមការយកចិត្តទុកដាក់ដឹកនាំបញ្ជាផ្ទាល់របស់លោកឧត្តមសេនីយ៍ត្រី យួន ជឿន មេបញ្ជាការកងការពារព្រំដែនលេខ៥០៣ ចាត់តាំង លោកវរសេនីយ៍ទោ លេ លឿត មេបញ្ជាការរងកងការពារព្រំដែនលេខ៥០៣ ដឹកនាំកម្លាំងចំនួន ២៥នាក់ ល្បាត និងពួនស្ទាក់ចាប់បានពលករលួចឆ្លងដែនខុសច្បាប់ លោកបានដឹកនាំកម្លាំងល្បាត ២៤ម៉ោងលើ២៤ម៉ោង ដោយប្តូរវេនគ្នា ដើម្បីទប់ស្កាត់ពលករលួចឆ្លងដែនខុសច្បាប់ និងទប់ស្កាត់ការឆ្លងរាលដាល នៃជំងឺកូវីដ-១៩ មិនឲ្យចូលទៅក្នុងសហគមន៍។ ចំណែកឯពលករទាំង ២៦នាក់ ត្រូវបានបញ្ជូនទៅក្រុមការងារនៅច្រកអូរបីជាន់៕

## បញ្ជូនមេខ្យល់ រត់ការឱ្យពលករខុសច្បាប់ ៦ នាក់ ទៅតុលាការ

https://www.kampucheathmey.com/ ថ្ងៃសៅរ៍ ១៨ កញ្ញា ២០២១ដោយ deth leng

មេខ្យល់ចំនួន ៦ នាក់ ពាក់ព័ន្ធនាំមនុស្សទៅរកការងាធ្វើនៅប្រទេសថៃ ដោយមិនស្របច្បាប់ ត្រូវបានកម្លាំងនគរបាលការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បញ្ជូនទៅសាលាដំបូងខេត្តបន្ទាយមានជ័យ ចាត់ការតាមនិតិវិធី នៅថ្ងៃទី១៧ខែកញ្ញា ឆ្នាំ២០២១។ បុរសមេខ្យល់ទាំង៦នាក់ មានឈ្មោះ ផុន សុហុង អាយុ ២៥ ឆ្នាំ ប្រាក់ វណ្ណៈ អាយុ ៣៦ ឆ្នាំ វេត សារុំ អាយុ ២៦ ឆ្នាំ កែវ សិរី អាយុ ៣១ ឆ្នាំ លី ប៊ុនថន អាយុ ៣៦ ឆ្នាំ ទាំង ៥ នាក់ស្នាក់នៅក្រុងប៉ោយប៉ែត ចំណែកម្នាក់ទៀត ឈ្មោះ ម៉ឺន រុន អាយុ ៣៦ ឆ្នាំ ស្នាក់នៅខេត្តស្រះកែវ ប្រទេសថៃ។

លោកវរសេនីយ៍ឯក សៅ សារឿន អធិការនគរបាលក្រុងប៉ោយប៉ែតបានឱ្យដឹងថា ទាំង ៦ នាក់ ក្នុងនោះ៥នាក់ ត្រូវបានកម្លាំងនគរបាលការពារព្រំដែនគោកលេខ៩១១ ក្នុងភូមិសាស្ត្រក្រុងប៉ោយប៉ែតឃាត់ខ្លួ ចំណែក១នាក់ទៀត ត្រូវបានសមត្ថកិច្ចថៃឃាត់ខ្លួនប្រគល់នគរបាលការពារព្រំដែនគោកលេខ ៩១១ រួចនគរបាលការពារព្រំដែនគោកលេខ៩១១ បានបញ្ជូនមេខ្យល់ទាំង៦នាក់ឲ្យកម្លាំងជំនាញអធិការដ្ឋាននគរបាលក្រុងប៉ោយប៉ែត ដើម្បីរៀបចំសំណុំរឿងតាមនិតិវិធីច្បាប់ ដោយពាក់ព័ន្ធក្នុងករណីនាំចេញដោយមិនស្របច្បាប់ សម្រាប់ឆ្លងដែន។ មេខ្យល់ទាំង៦នាក់ ត្រូវបាននគរបាលជំនាញ ការិយាល័យប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន បញ្ជូនខ្លួនទៅសាលាដំបូងខេត្ត ដើម្បីចាត់ការតាមនិតិវិធី ហើយនៅថ្ងៃទី១៧ខែកញ្ញា ឆ្នាំ២០២១នេះ៕ អត្ថបទ: វ៉ាន់ ណាង

## ថៃស្នើកម្ពុជា បញ្ជូនពលករខ្មែរចាក់វ៉ាក់សាំងរួច ទៅធ្វើការក្នុងប្រទេសខ្លួន ខណៈគេកំពុងខ្វះកម្លាំងពលកម្ម

https://news.btv.com.kh/ 09/17/2021 01:09 PM

ភ្នំពេញ៖ អាជ្ញាធរនៃប្រទេសថៃ បានស្នើដល់រាជរដ្ឋាភិបាលកម្ពុជា ជួយបញ្ជូនពលករខ្មែរ ដែលបានចាក់វ៉ាក់សាំងបង្ការមេរោគកូវីដ១៩ រួចរាល់ហើយនោះ ទៅធ្វើការនៅតាមរោងចក្រ ក្នុងប្រទេសរបស់ខ្លួន ខណៈប្រទេសគេបានកំពុងប្រឈមខ្លាំង ក្នុងការខ្វះកម្លាំងពលកម្មនោះ។

ក្នុងជំនួបជាមួយ សុខ សុក្រឹត្យា រដ្ឋលេខាធិការកក្រសួងទេសចរណ៍ កាលពីថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២១ ឯកឧត្តម Niphon BUNYAMANEE អនុរដ្ឋមន្ត្រីក្រសួងមហាផ្ទៃថៃ បានថ្លែងកោតសរសើរ ចំពោះវិធានការដោះស្រាយវិបត្តិកូវីដ-១៩ របស់រាជរដ្ឋាភិបាលកម្ពុជា ដែលមានសម្តេចតេជោ ជាប្រមុខដឹកនាំ ។ ជាមួយគ្នានោះអនុរដ្ឋមន្ត្រីក្រសួងមហាផ្ទៃថៃ បានស្នើដល់រាជរដ្ឋាភិបាលកម្ពុជា សហការរៀបចំលក្ខខណ្ឌពិសេសណាមួយ ក្នុងការបញ្ជូនពលករខ្មែរ ដែលបានចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ រួចរាល់ ដើម្បីទៅធ្វើការនៅប្រទេសថៃវិញ ព្រោះនៅតាមរោងចក្រឧស្សាហកម្ម និងរោងចក្រផលិតកម្មផ្សេងៗនៅប្រទេសថៃ កំពុងប្រឈមការខ្វះខាតកម្លាំងពលកម្ម ។

ក្នុងឱកាសនោះ ឯកឧត្តមបណ្ឌិត សុខ សុក្រឹត្យា បានស្នើភាគីថៃ កំណត់វិធានសុវត្ថិភាពលើការធ្វើពាណិជ្ជកម្មនៅតាមព្រំដែនកម្ពុជា-ថៃ និងពង្រឹងកិច្ចសហប្រតិបត្តិការ លើការផ្លាស់ប្តូរទំនិញតាមព្រំដែន សហការក្នុងការទប់ស្កាត់ការជួញដូរមនុស្សឆ្លងកាត់ព្រំដែននៃប្រទេសទាំងពីរ និងអាជ្ញាធរថៃ ជួយជំរុញយុទ្ធនាការចាក់វ៉ាក់សាំងជូនពលករខ្មែរ ដោយឥតគិតថ្លៃផង ។

កាលពីពេលថ្មីៗ រដ្ឋមន្ត្រីក្រសួងសុខាភិបាលថៃ ក៏បានកោតសរសើររាជរដ្ឋាភិបាលកម្ពុជា ពាក់ព័ន្ធវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ១៩ ហើយបានចាត់ទុកកម្ពុជា ជាប្រទេសមានសុវត្ថិភាពបំផុត នៅក្នុងតំបន់អាស៊ាន ក្នុងការទទួលភ្ញៀវទេសចរណ៍បរទេស ៕ អត្ថបទ បាន ចក់

## យោធាថៃឃាត់ខ្លួនពលករខ្មែរប្រុសស្រីចំនួន១០នាក់ លួចឆ្លងដែនខុសច្បាប់ទៅរកការងារធ្វើក្នុងប្រទេសថៃ

https://kohsantepheapdaily.com.kh/ បន្ទាយមានជ័យ ១៨ ខែ កញ្ញា ឆ្នាំ ២០២១ ម៉ោង ០៩:៥៣

បន្ទាយមានជ័យ ៖ អគ្គស្នងការដ្ឋាននគរបាលជាតិបានបញ្ជាក់ថា សមត្ថកិច្ចថៃនៅតែបន្តរឹតបន្តឹងតាមបន្ទាត់ព្រំដែនកម្ពុជា-ថៃ ដើម្បីទប់ស្កាត់ការលួចឆ្លងដែនចូលដោយខុសច្បាប់ របស់ពលករខ្មែរ និងដើម្បីការពារការរាលដាលជម្ងឺកូវីដ-១៩ កាលពីថ្ងៃទី១៦ កញ្ញា២០២១ អង្គភាពទាហានប្រាណទី១៣ ប្រចាំស្រុកខ្លងហាត សហការជាមួយទាហានកងរយទី១,៣០២ និងនគបាលខ្លង ណាំសៃ អង្គភាពពាក់ពន្ធ័ និងអាជ្ញាធរឃុំថាប់ព្រិច ស្រុក

អារញ្ញ ខេត្តស្រះកែវ បានពិនិត្យឃើញក្រុមបុគ្គលគួរឲ្យសង្ស័យ ។ ខណៈដើរមកតាមផ្លូវរបៀង តាមបន្ទាត់ព្រំដែនកម្ពុជា-ថៃ សំដៅចូលមកក្នុងប្រទេសថៃ បរិវេណភូមិថាន់ថៃ ឃុំថាប់ ព្រិច ស្រុកអារញ្ញ សមត្ថកិច្ចថៃចូលទៅត្រួតពិនិត្យមនុស្ស ទើបដឹងថា ជាជនជាតិខ្មែរចំនួន៦នាក់ ក្នុងនោះប្រុស៣ ស្រី២ និងក្មេងម្នាក់ទៀតត្រូវបានឃាត់ខ្លួនមកសួរនាំ។

ក្រោយពីសមត្ថកិច្ចថៃសួរនាំ បានឲ្យដឹងថា៖ ពលករខ្មែរទាំង៦នាក់ខាងលើ ធ្វើដំណើរមកពីខេត្តបន្ទាយមានជ័យ និងចង់ទៅធ្វើការនៅខេត្តឈុន បុរី ដោយមកប្រមូលផ្តុំគ្នានៅឃុំបឹង បេង ស្រុកម៉ាឡៃ និងបានចំណាយលុយក្នុកម្នាក់ ពី៣,០០០ ទៅ ៤,០០០បាត មានមេខ្យល់ជនជាតិខ្មែរជាអ្នកនាំលួចឆ្លងដែនឆ្លងកាត់អូរណាំសៃ ព្រំដែនកម្ពុជា-ថៃ រហូតត្រូវសមត្ថកិច្ចថៃចាប់បានមុន ក្រោយពីសមត្ថកិច្ចឆែកឆេរពួកគេ គឺពុំមានឯកសារធ្វើដំណើរទើបពិនិត្យកំដៅ តាមវិធានរបស់ផ្នែកសុខាភិបាល មុនហ្នឹងនាំខ្លួនទៅកាន់ទីបញ្ជាការកងរយទី១៣០២ ។ បន្ទាប់មកនៅវេលាម៉ោង០៨ និង០០នាទី សមត្ថកិច្ចថៃបានតាមប្រម៉ាញ់ រហូតបានជួបពលករខ្មែរដែលលួចរត់បាន២នាក់ទៀត ទើបសមត្ថកិច្ចបាននាំខ្លួនពលករដែលចាប់បាន៦នាក់ សរុបទាំងអស់៨នាក់ ប្រគល់ឲ្យនគបាលឃុំខ្លងណាំសៃ ដើម្បីមានវិធានការបន្ត ៕

## បញ្ជូនមេខ្យល់៣នាក់ ពាក់ព័ន្ធករណីនាំពលករឆ្លងដែនខុសច្បាប់ ទៅតុលាការខេត្តបន្ទាយមានជ័យ

http://freshnewsasia.com/ 2021-09-18 04:52pm

**(បន្ទាយមានជ័យ)៖** កម្លាំងកងរាជអាវុធហត្ថខេត្តបន្ទាយមានជ័យ នៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២១នេះ បានបញ្ជូនខ្លួនមេខ្យល់ចំនួន០៣នាក់ និងវត្ថុតាងពាក់ព័ន្ធករណីនាំពលករឆ្លងដែនទៅបរទេសដោយខុសច្បាប់ ទៅសាលាដំបូងខេត្តបបន្ទាយមានជ័យ។ កម្លាំងវរៈការពារព្រំដែនលេខ៥០៣ យោធភូមិភាគទី៥ បានចុះល្បាតតាមបន្ទាត់ព្រំដែន ដឹកនាំដោយលោកឧត្តមសេនីយ៍ត្រី យួន ជឿន មេបញ្ជាការវរៈកងការពារព្រំដែន ស្ថិតក្នុងភូមិសាស្ត្រភូមិចក់ពួក ឃុំស្លក្រាម ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ ហើយបានប្រទះឃើញរថយន្តចំនួន២គ្រឿង ដែលមានបំណងឆ្លងដែនទៅប្រទេសថៃ ដោយឃើញដូច្នេះ កម្លាំងក៏ឃាត់រថយន្តទាំ០២គ្រឿងនោះ ហើយធ្វើការត្រួតពិនិត្យឃើញថា មានមនុស្សជិះក្នុងរថយន្តទាំង០២គ្រឿង នោះចំនួន២៧នាក់ ក្នុងនោះមានស្ត្រីចំនួន១១នាក់ កុមារចំនួន០២នាក់ បន្ទាប់មកកម្លាំងកងការពារព្រំដែន៥០៣ បានរាយការណ៍ និងបញ្ជូនមកប្រគល់មកឱ្យបញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្ត ចាត់ការតាមនីតិវិធី។

**លោកវរសេនីយ៍ឯក ម៉ែន ភិរម្យ មេបញ្ជាការរងកងរាជអាវុធហត្ថខេត្ត ទទួលការងារស្រាវជ្រាវ និងបង្រ្កាបបទល្មើស បានឱ្យដឹងថា ក្នុងចំណោម២៧នាក់ និងមានមនុស្សចំនួន ៣នាក់ជាមេខ្យល់រួមមាន៖**

**ទី១៖** ឈ្មោះ គុង កុត ភេទប្រុស អាយុ៤៧ឆ្នាំ ជនជាតិខ្មែរ មុខរបររត់តាក់ស៊ី

**ទី២៖** ឈ្មោះ មឿយ ផល្លី ភេទស្រី អាយុ៤១ឆ្នាំ បច្ចុប្បន្ន អ្នកទាំង០២ រស់នៅភូមិត្រាំកង់ ឃុំជន្លាសដៃ ស្រុកក្រឡាញ់ ខេត្តសៀមរាប។

និងទី៣៖ ឈ្មោះ ស្មឿន លីហ៊ាង ភេទប្រុស អាយុ៣៧ឆ្នាំ បច្ចុប្បន្ន រស់នៅភូមិកំណប់ ឃុំស្លក្រាម ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ។

ចំណែកពលករបម្រុងចេញ ទៅប្រទេសថៃចំនួន២៤នាក់ រួមទាំងកុមារ០២នាក់ផងនោះត្រូវបានកម្លាំងវរៈការពារព្រំដែន៥០៣ បញ្ជូនទៅមណ្ឌលចត្តាឡីស័កនៅវិទ្យាល័យសម្តេចឪ ស្ថិតក្នុងក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ។ លោកវរសេនីយ៍ឯក ម៉ែន ភិរម្យ បានឱ្យដឹងទៀតថា ជនសង្ស័យទាំង០៣នាក់ ក្រោយកម្លាំងជំនាញធ្វើ

ការសួនាំរួចបានឆ្លើយសារភាពថា ពួកគេពិតជាបានដឹកពលករទាំងអស់នោះ ដើម្បីយកឱ្យមេខ្យល់ម្នាក់ទៀតពុំស្គាល់អត្តសញ្ញាណទេ គឺទាក់ទងគ្នាតាមទូរស័ព្ទ ពេលមកដល់មាត់ច្រកព្រំដែនទើបកម្លាំងកងទ័ពឃាត់ខ្លួនបានតែម្តង ចំពោះស្ត្រីឈ្មោះ មឿយ ផល្លី ត្រូវជាប្រពន្ធរបស់ឈ្មោះ តុង កុត មិនដឹងរឿងអ្វីនោះទេព្រោះថ្ងៃនោះប្តីរបស់គាត់ហៅមកជាមួយបានជាគ្នា ព្រោះប្តីរបស់គាត់មិនស្រួលខ្លួន៕

## ឃាត់ខ្លួនជនជាតិថៃ៥នាក់ ដែលបម្រុងលបឆ្លងដែនមកធ្វើការនៅក្នុងប្រទេសកម្ពុជា

https://www.kampucheathmey.com/ ថ្ងៃសៅរ៍ ១៨ កញ្ញា ២០២១ដោយ Kang Tola

ប្រទេសថៃ ៖ ជនជាតិថៃចំនួន ៥ នាក់ ត្រូវបានតម្រួតការពារព្រំដែនថៃលេខ ៣ សហការជាមួយកម្លាំងអធិការស្រុកគោកខ្សូង ធ្វើការឃាត់ខ្លួននៅក្បែរខ្សែបន្ទាត់ព្រំដែន ថៃ-កម្ពុជា ខណៈដែលពួកគេបម្រុងលួចឆ្លងដែនចូលមកក្នុងប្រទេសកម្ពុជាដើម្បីរកការងារធ្វើ។ ការឃាត់ខ្លួននេះបានធ្វើឡើងកាលពីវេលាម៉ោង ៥ ទៀបភ្លឺ ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២១ ត្រង់ចំណុច បានណងយ៉ាកែវ ក្នុងឃុំគោកខ្សូង ស្រុកគោកខ្សូង ខេត្តស្រះកែវ ប្រទេសថៃ បន្ទាប់ពីពួកគេកំពុងធ្វើដំណើរ ជិតដល់ព្រំដែនកម្ពុជា ក្នុងពេលដែលប្រទេសមានការរឹតបន្តឹង ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ កាន់តែមានសភាពធ្ងន់ធ្ងរ។ ក្រោយពេលឃាត់ខ្លួន ពួកគេ បានអះអាងថា ការលបឆ្លងដែននេះគឺពួកគេមានបំណងចូលទៅធ្វើការនៅក្នុងកាស៊ីណូអនឡាញ នាក្រុងប៉ោយប៉ែត ព្រោះឮអ្នកស្គាល់គ្នាប្រាប់ថា បើទៅដល់ទីនោះក្រុមហ៊ុននឹងជួយគ្រប់យ៉ាងទាំងការហូបចុក និងការស្នាក់នៅ។

ជនជាតិថៃទាំង៥នាក់ ដែលក្នុងនោះមានប្រុស៣ ស្រី២ បានបន្តថា ពួកគេជិះឡានក្រុងមកពីខេត្តកិចិត្រ ២ នាក់ មកពីខេត្តឈៀងម៉ៃ ១ នាក់ និងមកពីខេត្តស្រះកែវ ២ នាក់ ដោយមកជួបគ្នានៅស្រុកអារញ្ញប្រាថេត ហើយក៏មានរថយន្ត តូយូតា វីហ្គូ ពណ៌ខ្មៅមកដឹកទៅទម្លាក់នៅចំណុច ផ្លូវលូករុង ទើបមានមេខ្យល់ខ្មែរម្នាក់មកទទួល ដោយនាំដើរកាត់ស្រែចំការដើម្បីឆ្ពោះទៅខ្សែបន្ទាត់ព្រំដែន ប៉ុន្តែមុននឹងសមត្ថកិច្ចចាប់ខ្លួន មេខ្យល់នោះបានរត់គេចខ្លួនបាត់ស្រមោល ដោយសារតែគេស្គាល់ភូមិសាស្ត្រច្បាស់។ បច្ចុប្បន្នជនជាតិថៃទាំង៥នាក់ ត្រូវបានបញ្ជូនទៅកាន់អធិការដ្ឋានតម្រួតស្រុកគោកខ្សូង ដើម្បីចាត់ការតាមនីតិវិធី៕ *អត្ថបទ ៖ សោ និយមវុឌ្ឍ*

# ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២១

## រាជរដ្ឋាភិបាលកំពុងប្រឹងប្រែងជួយសង្គ្រោះពលរដ្ឋម្នាក់ដែលអះអាងថាប្តីវាយធ្វើបាបនៅចិន

http://www.freshnewsasia.com/ 2021-09-20 09:42am

**(ភ្នំពេញ)៖** រាជរដ្ឋាភិបាលកម្ពុជា កំពុងប្រឹងប្រែងជួយសង្គ្រោះប្រជាពលរដ្ឋម្នាក់ ដែលនាងអះអាងថា ត្រូវប្តីវាយធ្វើបាបនៅប្រទេសចិន។ នេះបើតាមលោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធាន អចិន្ត្រៃយ៍ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស ប្រាប់បណ្តាញព័ត៌មាន Fresh News នៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២១។ ការជុតដៃជុតជើងអន្តរាគមន៍ពីរាជរដ្ឋាភិបាល បានធ្វើឡើងបន្ទាប់ពីស្ត្រី ដែលអះអាងថា ខ្លួនជាជនរងគ្រោះផងនោះ អំពាវនាវទៅសម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា តាមរយៈបណ្តាញសង្គម Tik Tok ជួយសង្គ្រោះនាងឱ្យបានមាតុភូមិនិវត្តន៍វិញ ក្រោយប្តីវាយធ្វើបាបអស់រយៈពេល ៤ឆ្នាំ។

លោកស្រី ជូ ប៊ុនអេង បានថ្លែងថា គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស បានទាក់ទងទៅនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ហើយនាយកដ្ឋានបានធ្វើទំនាក់ទំនងទៅស្ថានទូតកម្ពុជានៅចិន តាមរយៈក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និង Focal Point នៅប្រទេសចិន ដើម្បី

រកអាសយដ្ឋាន ដែលស្ត្រីរងគ្រោះរស់នៅ។ លោកស្រី ជួ ប៊ុនអេង បានស្រង់របាយការណ៍ នាយកដ្ឋានមកបញ្ជាក់ថា ៖ «**រហូតដល់ពេលនេះនាយកដ្ឋានជំនាញ បានខិតខំស្រាវជ្រាវរកឃើញក្រុមគ្រួសារជនរងគ្រោះនៅខេត្តកំពង់ស្ពឺ លេខទំនាក់ទំនង និង Location របស់ជនរងគ្រោះនៅប្រទេសចិនហើយ និងបានផ្តល់ជូនព័ត៌មានទាំងនេះទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ស្ថានទូតកម្ពុជានៅចិន និងជនបង្គោលក្រុមការងារមេគង្គឡានធាន់រួចហើយ ដើម្បីមានមូលដ្ឋានអន្តរាគមន៍ជួយសង្គ្រោះជនរងគ្រោះនៅប្រទេសគោលដៅ។ នាយកដ្ឋានកំពុងបន្តមានចំណាត់ការស្រាវជ្រាវរកមេខ្យល់ចាត់ការតាមច្បាប់**»។

នៅក្នុង Tik Tok នារីរងគ្រោះរៀបរាប់ថា នាងមានឈ្មោះ អាត់ សុភក្រ្ត ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ មានម្តាយឈ្មោះ ភី និងឪពុកឈ្មោះ អុល។ សុភក្រ្ត បានអំពាវនាវ ទាំងទឹកមុខក្រៀមក្រំ ដោយបញ្ជាក់ទៀតថា «**សូមសម្តេច ហ៊ុន សែន ជួយនាងខ្ញុំផង ឱ្យបានទៅខ្មែរវិញ**»៕

## សង់ត្រាល់ថាមានពលករខ្មែរខុសច្បាប់ជាង៧០០នាក់ឆ្លងដែនចូលប្រទេសថៃនៅក្នុងពេលផ្ទុះកូវីដ-១៩

https://www.rfi.fr/km/ ចុះផ្សាយនៅថ្ងៃ៖ 19/09/2021 - 08:13

*មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស ហៅកាត់ថាសង់ត្រាល់ បានអះអាងថា មានពលករខ្មែរខុសច្បាប់ប្រមាណជាង៧០០នាក់បានធ្វើចំណាកស្រុកទៅកាន់ប្រទេសថៃ គិតត្រឹមរយៈពេល៧ខែឆ្នាំ២០២១នេះ។ ជាការកត់សម្គាល់ ការចំណាកស្រុកនេះ ធ្វើឡើងនៅក្នុងកាលៈទេសៈដែលប្រទេសទាំងពីរ ទាំងកម្ពុជា ទាំងថៃ កំពុងរងការវាយប្រហារដោយវិបត្តិកូវីដ-១៩ ជាពិសេសវីរុសកូវីដ-១៩ប្រភេទ«ដែលតា»។ តែយ៉ាងណាពីខាងអាជ្ញាធរព្រំដែនបញ្ជាក់ថា ពលករខ្មែរខុសច្បាប់ចំណាកស្រុកទៅកាន់ប្រទេសថៃពេលនេះ មានចំនួនតិចតួច និងត្រូវបានបង្ក្រាបជាញឹកញយ។* គឺនៅក្នុងរបាយការណ៍ស្តីពីបញ្ហាប្រឈមរបស់ពលករកម្ពុជាក្នុងអំឡុងពេលនៃការផ្ទុះមេរោគកូវីដ-១៩ ចេញផ្សាយកាលពីថ្ងៃព្រហស្បតិ៍ មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស បានរកឃើញថា មានពលករខ្មែរខុសច្បាប់ចំនួន៧៤១នាក់ បានធ្វើចំណាកស្រុកទៅក្នុងប្រទេសថៃ និងត្រូវបានអាជ្ញាធរប្រទេសទាំងពីរបង្ក្រាបបានហើយក្នុងនោះមានពលករចំនួន៣៦០នាក់ ត្រូវបានបញ្ជូនទៅដោះស្រាយតាមផ្លូវច្បាប់។

លោក មឿន តុលា នាយកប្រតិបត្តិមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស ហៅកាត់ថាសង់ត្រាល់ បានបញ្ជាក់ប្រាប់វិទ្យុបារាំងអន្តរជាតិនៅព្រឹកថ្ងៃអាទិត្យទី១៩កញ្ញាថា មូលហេតុដែលធ្វើឲ្យពលករខ្មែរនៅតែប្រថុយប្រថានឆ្លងដែនត្រលប់ទៅកាន់ប្រទេសថៃដោយខុសច្បាប់ ទាំងដែលស្ថានភាពប្រទេសទាំងពីរកំពុងជួបវិបត្តិកូវីដ-១៩នោះ គឺដោយសារតែការមិនមានមុខរបរ និងការងារជាក់លាក់ពេលពួកគេត្រលប់ចូលមកកម្ពុជាវិញ ជាហេតុឲ្យពួកគេមិនអាចទទួលបានចំណូលប្រចាំថ្ងៃ។ រីឯបញ្ហាមួយទៀតនោះ គឺជាបំណុល ដែលពួកគេមិនទាន់មានលទ្ធភាពសងទៅកាន់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងធនាគារ។ ទាំងនេះសុទ្ធតែជាមូលហេតុ ដែលលោកមឿន តុលា បានអះអាងថាជំរុញឲ្យពលករបង្ខំចិត្តត្រលប់ទៅកាន់ប្រទេសថៃ បើទោះបីប្រទេសថៃកំពុងស្ថិតក្នុងស្ថានភាពធ្ងន់ធ្ងរជំងឺកូវីដ-១៩ធ្ងន់ធ្ងរក្តី។ ជាការកត់សម្គាល់ លោកមឿន តុលា ថា ការធ្វើចំណាកស្រុកខុសច្បាប់ពេលនេះ គឺធ្វើឡើងនៅតាមច្រករបៀងតូចៗនៃព្រំដែនប្រទេសទាំងពីរ ហើយភាគច្រើនគឺពលករត្រូវបានមេខ្យល់បញ្ចុះបញ្ចូលឲ្យទៅរកការងារធ្វើវិញ។ បើតាមសង់ត្រាល់ ពលករទាំងនោះត្រូវចំណាយទឹកប្រាក់សរុបប្រមាណ២.៥លានបាត ឬ ៧៦០០០ដុល្លារអាមេរិក។

យ៉ាងណាមិញ លោក សឿម ប៊ុនរិទ្ធី អភិបាលរងខេត្តបាត់ដំបង បានកត់សម្គាល់ថា មួយរយៈចុងក្រោយពុំសូវមានពលករខ្មែរចំណាកស្រុកខុសច្បាប់ចេញទៅប្រទេសថៃនោះទេ ដោយលោកបញ្ជាក់ថា មានត្រឹម៣ទៅ៤

នាក់ក្នុងមួយថ្ងៃ និងត្រូវបានអាជ្ញាធរបង្ក្រាបនិងអប់រំជាប្រចាំ។ បើតាមអាជ្ញាធរខេត្តព្រំដែនជាប់ប្រទេសថៃរូបនេះ បើទោះបីជាពលករអាចឆ្លងដែនទៅដល់ទឹកដីប្រទេសថៃ ក៏ត្រូវបានអាជ្ញាធរថៃចាប់ខ្លួនបញ្ជូនមកកម្ពុជាវិញជាបន្តបន្ទាប់ដែរ។ បន្ថែមពីនេះដែរ អភិបាលរងខេត្តបាត់ដំបងរូបនេះ បានអះអាងប្រាប់វិទ្យុបារាំងអន្តរជាតិទៀតថា ប៉ុន្មានថ្ងៃចុងក្រោយនេះ ក៏ពុំសូវមានពលករខ្មែរត្រលប់មកពីប្រទេសថៃ តាមច្រកអន្តរជាតិខេត្តបាត់ដំបងដែរ។ ដោយបច្ចុប្បន្ន មានពលករចំនួន១៦៣១នាក់ប៉ុណ្ណោះកំពុងបន្តធ្វើចត្តាឡីស័កបន្ទាប់ពីត្រលប់មកពីប្រទេសថៃវិញ។

គួរបញ្ជាក់ថា តាមរបាយការណ៍ក្រសួងសុខាភិបាលថៃ គិតត្រឹមថ្ងៃទី២២កក្កដា មានពលករខ្មែរសរុបចំនួន ១០៤៥៥នាក់ បានធ្វើតេស្តរកមេរោគកូវីដ-១៩ ក្នុងនោះពលករចំនួន ១០២២៦នាក់ បានឆ្លងជំងឺកូវីដ១៩នៃរលកទី៣ ចាប់ពីថ្ងៃទី១មេសាមក។ នេះបើតាមរបាយការណ៍របស់សង់ត្រាល់៕

## តុលាការខេត្តបន្ទាយមានជ័យ សម្រេចឃុំខ្លួនមេខ្យល់ ៦ នាក់រឿងនាំពលករឆ្លងដែនទៅថៃ

https://www.postkhmer.com/ គីម សារុំ | Publication date 19 September 2021 | 17:13 ICT

**បន្ទាយមានជ័យ** តុលាការខេត្តបន្ទាយមានជ័យកាលពីថ្ងៃទី១៨ កញ្ញាបានសម្រេចបញ្ជូនបុរសជាមេខ្យល់៦នាក់ ឃុំខ្លួនជាបណ្តោះអាសន្ន ក្នុងពន្ធនាគារខេត្តបន្ទាប់ពីឃាត់ខ្លួនពួកគេ នៅក្រុងប៉ោយប៉ែតករណីលួចនាំពលករឆ្លងដែនទៅប្រថៃ។

លោកស្រី ឌី សុជាតិ ស្នងការរងទទួលផែនការងារនគរបាលប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនខេត្តបន្ទាយមានជ័យឱ្យដឹងនៅថ្ងៃទី១៩ ខែកញ្ញាថាជនទាំង៦នាក់នោះមាន ទី១-ឈ្មោះប្រាក់ វណ្ណៈ ភេទប្រុស អាយុ ៣៦ឆ្នាំ ,ទី២-ឈ្មោះផុន សុខហុង ភេទប្រុស អាយុ ២៥ឆ្នាំ,ទី៣-ឈ្មោះវេត សារុំ ភេទប្រុស អាយុ ២៦ឆ្នាំ,ទី៤-ឈ្មោះកែវ សិរី ភេទប្រុសអាយុ ៣១ឆ្នាំ,ទី៥-ឈ្មោះលី ប៊ុនថនភេទប្រុស អាយុ ៣៦ឆ្នាំ។ ពួកគេរស់នៅក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។ ចំណែកជនម្នាក់ទៀតឈ្មោះម៉ឺន រុន ភេទប្រុស អាយុ ៣៦ឆ្នាំជនជាតិខ្មែររស់នៅភូមិប៉ារ៉ៃ ឃុំប៉ារ៉ៃ ស្រុកស្រះកែវ ខេត្តស្រះកែវ ប្រទេសថៃ។ជនទាំង៦នាក់ត្រូវបានតុលាការឃុំក្នុងពន្ធនាគារហើយពីថ្ងៃទី១៨កញ្ញា។ លោកស្រី សុជាតិ បានប្រាប់ថា៖ «ពួកគេត្រូវចោទបទ ការនាំចេញដោយ មិនស្របច្បាប់ សម្រាប់នាំឆ្លងដែនតាមមាត្រា១១នៃច្បាប់ការបង្ក្រាបអំពើ ជួញដូរមនុស្ស និងអំពើធ្វើ អាជីវកម្មផ្លូវភេទ»។ ពាក់ព័ន្ធបទចោទតាមមាត្រា១១នៃច្បាប់ការបង្ក្រាប អំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ នេះជនត្រូវចោទត្រូវប្រឈមនឹងការផ្តន្ទាទោស ដាក់ពន្ធនាគារពី៧ទៅ១៥ឆ្នាំបើតុលាការរកឃើញ ថា ពួកគេពិតជាបានប្រព្រឹត្តមែននោះ ។

លោក ព្រំ ពិសិដ្ឋ អធិការរងក្រុងប៉ោយបានប្រាប់នៅរសៀលថ្ងៃទី១៩កញ្ញាថា បុរសជាមេខ្យល់ទាំង៦នាក់នោះត្រូវបានសមត្ថកិច្ចប្រចាំការនៅតាមព្រំដែនខេត្តបន្ទាយមានជ័យឃាត់ខ្លួនបានកាលពីថ្ងៃទី១៧ កញ្ញា ក្នុង២ករណីផ្សេងគ្នាប៉ុន្តែពួកគេសុទ្ធនាំពលករឆ្លងដែនចូលទៅប្រទេសថៃដូចគ្នា។ លោកបានបញ្ជាក់ថា ៖«ពលករប្រុសស្រីដែលទប់ស្កាត់បានគឺយកទៅមណ្ឌលចត្តាឡីស័កអស់ហើយ»។

លោក សំរិទ្ធ សុខុន អ្នកនាំពាក្យ សាលាដំបូងខេត្តបន្ទាយមានជ័យមិនអាចទាក់ទងសុំអត្ថាធិប្បាយបានទេនៅថ្ងៃទី១៩ ខែកញ្ញានេះ៕

## តុលាការអូស្ត្រាលីកាត់ទោសដាក់គុកបុរសអូស្ត្រាលីម្នាក់ជិត ១០ឆ្នាំ ពីបទរំលោភផ្លូវភេទកុមារនៅកម្ពុជា

https://www.rfa.org/ ដោយ ខែ សុណង2021-09-18

តុលាការនៅតំបន់ អាឌីឡែត ភាគខាងត្បូងនៃប្រទេសអូស្ត្រាលី (South Australian Adelaide District Court) កាលពីថ្ងៃទី១៧ ខែកញ្ញា បានកាត់ទោសបុរសអូស្ត្រាលីម្នាក់ ឈ្មោះ ហ្សេហ្វ្រី វីលៀម ម៉ូយល៍ (Geoffrey

William Moyle) អាយុ ៤៧ឆ្នាំ ឲ្យជាប់ពន្ធនាគារជិត ១០ឆ្នាំ ពីបទរំលោភផ្លូវភេទលើកុមារនៅកម្ពុជា។ ទណ្ឌិតរូបនេះ បានសារភាពកំហុសរបស់ខ្លួន កាលពីឆ្នាំ២០២០ ថា ខ្លួនពិតជាបានជាប់ពាក់ព័ន្ធបទល្មើសរំលោភផ្លូវភេទលើកុមារកម្ពុជា ចំនួន ១២ករណី ចន្លោះពីឆ្នាំ២០០២ ដល់ឆ្នាំ២០០៥ ខណៈដែលធ្វើការជាមន្ត្រីជំនួយការបរទេសរបស់ក្រសួងកិច្ចការបរទេស និងពាណិជ្ជកម្ម។

ឯកអគ្គរាជទូតអូស្ត្រាលីប្រចាំកម្ពុជា លោក ប៉ាប្លូ កង (Pablo Kang) បញ្ជាក់នៅថ្ងៃទី១៨ ខែកញ្ញា ឲ្យថា រដ្ឋាភិបាលអូស្ត្រាលី នឹងមិនអត់ឱនជាដាច់ខាត រាល់ការរំលោភបំពានលើកុមារគ្រប់ទម្រង់។ មន្ត្រីពាក់ព័ន្ធអនុវត្តច្បាប់ បន្តប្រឹងប្រែងស្រាវជ្រាវស៊ើបអង្កេតករណី រហូតដល់យកជនល្មើសមកផ្តន្ទាទោសតាមច្បាប់ ដើម្បីការពារសិទ្ធិរបស់កុមារ៕

## អាជ្ញាធរបញ្ជូនជនសង្ស័យជាមេខ្យល់ ៦នាក់ ទៅតុលាការ រឿងនាំពលករលួចឆ្លងដែនទៅធ្វើការនៅប្រទេសថៃ

https://www.rfa.org/khmer/ ដោយ ខែ សុណង2021-09-18

សមត្ថកិច្ចប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បញ្ជូនមនុស្ស ៦នាក់ ទៅសាលាដំបូងខេត្តបន្ទាយមានជ័យ សង្ស័យថា ជាមេខ្យល់នាំពលករលួចឆ្លងដែនទៅធ្វើការនៅប្រទេសថៃ។ មន្ត្រីសង្គមស៊ីវិលផ្នែកសិទ្ធិការងារពលករចំណាកស្រុក យល់ថា ពលករខ្មែរនៅតែបន្តចាញ់បោកមេខ្យល់ចេញទៅរកការងារធ្វើនៅប្រទេសជិតខាង ព្រោះពួកគាត់ខ្វះខាតជីវភាពចិញ្ចឹមជីវិត ជំពាក់បំណុលធនាគារនិងឯកជន។

មន្ត្រីជាន់ខ្ពស់រដ្ឋាភិបាលប្រឆាំងការជួញដូរមនុស្សអះអាងថា ការចាប់អ្នកពាក់ព័ន្ធការជួញដូរមនុស្សគឺជាវិធានការច្បាប់ ដែលមិនមានការលើកលែង និងស្នើឲ្យពលរដ្ឋអត់ធ្មត់ កុំបន្តឆ្លងដែនទៅធ្វើការខុសច្បាប់ដោយប្រថុយប្រថាន។ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស អ្នកស្រី ជូ ប៊ុនអេង អំពាវនាវឲ្យប្រជាពលរដ្ឋអត់ធ្មត់ រង់ចាំឲ្យស្ថានភាពនៃការរីករាលដាលជំងឺកូវីដ-១៩ បានធូរស្រាល និងមានការរៀបចំឡើងវិញសិន។ អ្នកស្រីថា រដ្ឋាភិបាលនឹងមិនបិទសិទ្ធិពលរដ្ឋមិនឲ្យចេញទៅស្វែងរកការងារនៅក្រៅស្រុកនោះទេ៖ «សម័យកាលកូវីដ ក៏ដូចជាំប្រទេសថៃ ក៏ដូចជាប្រទេសទូទាំងពិភពលោកគេកំពុងតែមានការព្រួយបារម្ភពីអត្រាឆ្លងដែលកំពុងតែរាតត្បាតខ្ពស់។ គេអត់ចង់ឲ្យមានការឆ្លងកាត់ទៅមកទេ តែយើងទោះបីថា យើងត្រូវការ ការងារ ប៉ុន្តែគេចង់ប្រាប់ថា គេក៏កំពុងតែមានការបិទរោងចក្រសហគ្រាសក៏ដូចជាកន្លែងការងារជាច្រើនដោយសារតែការរាតត្បាតនៃកូវីដ-១៩។ អ៊ីចឹងត្រូវអត់ធ្មត់សិនហើយកាន់ប្រទេសយើងក៏អ៊ីចឹងដែរយើងបានប្រាប់ប្រជាពលរដ្ឋយើងថា យើងរស់នៅកន្លែងណា នៅកន្លែងហ្នឹងសិនទៅ។ ប្រសិនបើគាត់ចូលមក កម្ពុជាហើយ ក៏មកនៅក្នុងស្រុកភូមិដូចពេលមុនគាត់ទៅប្រទេសក្រៅអ៊ីចឹង។ ការដែលផ្អាកមិនឲ្យឆ្លងកាត់នៅពេលនេះ ព្រោះតែចង់ការពារទាំងគាត់ខ្លួនឯង ក៏ដូចជាក្រុមគ្រួសារនៅសហគមន៍ ហើយខាងប្រទេសគេហ្នឹងក៏គេមានការប្រុងប្រយ័ត្ន»។

ការលើកឡើងនេះ បន្ទាប់ពីសមត្ថកិច្ចប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បញ្ជូនបុរស ៦នាក់ ទៅសាលាដំបូងខេត្តបន្ទាយមានជ័យ សង្ស័យថាជាមេខ្យល់ នាំពលករលួចឆ្លងដែនទៅធ្វើការនៅប្រទេសថៃ។ ក្នុងចំណោមជនសង្ស័យទាំង ៦នាក់ មាន ៥នាក់ស្នាក់នៅក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ និងម្នាក់ស្នាក់នៅភូមិប៉ារ៉ៃ ឃុំប៉ារ៉ៃ ស្រុកស្រះកែវ ខេត្តស្រះកែវ ប្រទេសថៃ។

ទាក់ទងរឿងនេះ មន្ត្រីកម្មវិធីផ្នែកទេសន្តរប្រវេសក៍នៃមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស ហៅកាត់ថា សង់ត្រាល (Central) កញ្ញា ទ្រី សុភា យល់ថា ពលរដ្ឋនៅតែប្រថុយលួចឆ្លងដែនត្រឡប់ចូលទៅប្រទេសថៃវិញ គឺដោយសារតែពួកគាត់មកដល់ស្រុកកំណើតហើយ មិនបានទទួលជំនួយគាំពារសង្គម ខ្វះខាតជីវភាព និង

គ្មានប្រាក់ដោះបំណុល ទើបជំរុញឲ្យពួកគាត់ចង់វិលទៅរកការងារវិញដោយមិនខ្លាចគ្រោះថ្នាក់ និងបារម្ភខ្លាចជំងឺឆ្លង៖ «អ្វីដែលជាចំណុចសំខាន់នោះគឺការផ្តល់ជំនួយសង្គមដែលមានការគិតបញ្ចូលអំពីផលលំបាកនៃពលករដែលគាត់វិលត្រឡប់មកវិញ។ អ៊ីចឹងយើងឃើញថា មានសកម្មភាពជំនួយសង្គមផ្សេងៗ ក៏ប៉ុន្តែពលករដែលគាត់វិលត្រឡប់ គឺគាត់ពុំទាន់បានទទួលជំនួយទាំងអស់ហ្នឹងទេ ដោយសារយើងដឹងស្រាប់ហើយថា ការដែលគាត់ទៅធ្វើការនៅប្រទេសថៃ យូរអង្វែង គឺគាត់ធ្វើឲ្យបាត់បង់ឱកាសនៅក្នុងការចុះឈ្មោះទទួលបាននូវប្រព័ន្ធគាំពារផ្សេងៗ។ យើងសំណូមពរនេះគឺធ្វើយ៉ាងណា ដើម្បីឲ្យយន្តការនៃការផ្តល់ជំនួយគាំទ្រ ទៅដល់ពលករដែលគាត់វិលត្រឡប់មកវិញ ហើយគាត់កំពុងជួបប្រទះនូវបញ្ហាបាត់បង់ការងារធ្វើគ្មានប្រាក់ចំណូល ហើយនិងកត្តាជីវភាពផ្សេងៗ ក៏ដូចជាក្តីបារម្ភនៃការជំពាក់បំណុលធនាគារ»។ មន្ត្រីអង្គការសង់ត្រាល់ ដដែលថា ការបង្កើតឱកាសការងារក្នុងស្រុកគឺជាកត្តាសំខាន់ ដែលអាចដោះស្រាយបញ្ហានេះជូនដល់ពលរដ្ឋបាន ពិសេសពលករដែលទើបវិលត្រឡប់ពីប្រទេសថៃអំឡុងវិបត្តិនៃការរាលដាលជំងឺកូវីដ-១៩។

អង្គការសង់ត្រាល់ ឲ្យដឹងថា ចាប់តាំងពីចាប់ពីខែមករា រហូតដល់ខែកក្កដា ឆ្នាំ២០២១ មានពលរដ្ឋខ្មែរប្រមាណ ៧៤១នាក់ ត្រូវបានឃាត់ខ្លួនដោយអាជ្ញាធរនៃប្រទេសកម្ពុជានិងថៃ ពាក់ព័ន្ធនិងការលួចឆ្លងដែនខុសច្បាប់ទៅរកការងារធ្វើនៅប្រទេសថៃ។ ក្នុងនោះមនុស្សចំនួន ៣៦០នាក់ត្រូវបានអាជ្ញាធរចាប់ខ្លួន និងបញ្ជូនទៅចាត់ការតាមច្បាប់។ ក្នុងចំណោមអ្នកដែលបានឃាត់ខ្លួនសរុប ៧៤១នាក់ មាន ៣៧៣នាក់ ជាស្ត្រីចាញ់បោកមេខ្យល់ដែលភាគច្រើនជាជនជាតិខ្មែរដូចគ្នា ដែលជាមេខ្យល់នាំពលករទាំងនោះ។ ជនរងគ្រោះបានខាតបង់ប្រាក់សរុបចំនួន ២លាន ៥សែនបាត ឬប្រមាណ ៧ម៉ឺន ៦ពាន់ដុល្លារ៕

## ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២១

### មុខសញ្ញាជាមេខ្យល់នាំមនុស្សឆ្លងដែនទៅប្រទេសថៃដោយខុសច្បាប់០១នាក់ ត្រូវបានសមត្ថកិច្ចឃាត់ខ្លួនអនុវត្តតាមច្បាប់

http://cambodiapolice.com/policekh/ 4:39 pm 20 កញ្ញា 2021

ខេត្តបាត់ដំបង ៖ នៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២១ វេលាម៉ោង០០និង១១នាទី អនុវត្តតាមយោបល់ដឹកនាំរបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនៃស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង និងដោយមានការសម្របសម្រួលនីតិវិធីពីឯកឧត្តម កែវ សុជាតិ ព្រះរាជអាជ្ញាអមសាលាដំបូងខេត្ត លោកវរសេនីយ៍ទោ វេ គឹមចត់ អធិការនគរបាលស្រុកកំរៀង ដឹកនាំកម្លាំងសហការណ៍ជាមួយកម្លាំងនគរបាលវរសេនាតូចការពារព្រំដែនគោកលេខ៨១៩ ដែលមានលោកវរសេនីយ៍ឯក ម៉ង់ ស៊ី ជាមេបញ្ជាការបង្ក្រាបករណីនាំមនុស្សយកចេញឆ្លងដែនដោយមិនស្របច្បាប់ទៅប្រទេសថៃ ១ករណី ក្នុងបទល្មើសជាក់ស្តែង។ ក្នុងនោះសមត្ថកិច្ចបានឃាត់ខ្លួនជនសង្ស័យបានចំនួន ០១នាក់ឈ្មោះ ថេត សុជា ភេទប្រុស អាយុ២១ឆ្នាំ រស់នៅភូមិកូនខ្លុង ឃុំព្រៃតូច ស្រុកមោងឫស្សី ខេត្តបាត់ដំបង និងទប់ស្កាត់ពលករប៉ុនប៉ងឆ្លងដែនចំនួន ០៥នាក់ ស្រីចំនួន ០២នាក់ អនីតិជន ០២នាក់ ស្រីចំនួន ០១នាក់។ ករណីនេះ មុខសញ្ញាជាមេខ្យល់ខាងលើសមត្ថកិច្ចនគរបាលស្រុកកំពុងកសាងសំណុំរឿងបញ្ជូនមកការិយាល័យជំនាញដើម្បីអនុវត្តតាមច្បាប់ រីឯប្រជាពលរដ្ឋរងគ្រោះបានអប់រំណែនាំឱ្យវិលទៅលំនៅដ្ឋានវិញ ៕

## អាជ្ញាធរខេត្តបន្ទាយមានជ័យបើកកិច្ចប្រជុំត្រួតពិនិត្យ និងដាក់ផែនការពង្រឹងការត្រួតពិនិត្យសន្តិសុខ បទល្មើស និងការទប់ស្កាត់ពលករឆ្លងដែនតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ

http://nokorwatnews.com/ 20 កញ្ញា 2021

ខេត្តបន្ទាយមានជ័យ៖ បើយោងតាមប្រភពព័ត៌មានពីរដ្ឋបាលខេត្តបន្ទាយមានជ័យ បានឱ្យដឹងថា លោក អ៊ុំ រាត្រី អភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ អញ្ជើញដឹកនាំកិច្ចប្រជុំត្រួតពិនិត្យ និងដាក់ផែនការ ពង្រឹងការត្រួតពិនិត្យសន្តិសុខ បទល្មើស និងការទប់ស្កាត់ពលករឆ្លងដែនតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ក្នុងភូមិសាស្ត្រខេត្តបន្ទាយមានជ័យ ជាមួយលោកមេបញ្ជាការ មេបញ្ជាការរងកងពល សឹករងខេត្ត ស្នងការ និងមេបញ្ជាការគ្រប់ផ្នែកឈរជើងតាមខ្សែបន្ទាត់ព្រំដែន និងអភិបាលក្រុង និងស្រុកទាំង៥ នៅសាលាខេត្តបន្ទាយមានជ័យ នៅព្រឹកថ្ងៃចន្ទទី២០ ខែកញ្ញា ឆ្នាំ២០២១នេះ។ នាឱកាសនោះ ក្នុងនាមគណៈបញ្ជាការឯកភាពរដ្ឋបាលខេត្ត លោក អ៊ុំ រាត្រី អភិបាលខេត្ត បានណែនាំដល់មេបញ្ជាការកងកម្លាំងចម្រុះមានកម្លាំងនគរបាលការពារព្រំដែន អាវុធហត្ថ កម្លាំងយោធាទាំងអស់ ត្រូវពង្រឹងការទប់ស្កាត់ការឆ្លងដែនខុសច្បាប់ក្នុងដំណាក់កាលនៃការរីករាលដាលជំងឺកូវីដ១៩ ឱ្យបានតឹងរឹង ជានាការពារការរីករាលដាលនៃជំងឺកូវីដ១៩។

ជាមួយគ្នានោះ លោកអភិបាលខេត្ត ក៏បានរំលឹកបន្ថែមដល់កងកម្លាំង មន្ត្រីសុខាភិបាលនៅតាមបន្ទាត់ព្រំដែនទាំងអស់ត្រូវបង្កើនការប្រុងប្រយ័ត្នឲ្យបានខ្ពស់បំផុតក្នុងការការពារ និងទប់ស្កាត់ឲ្យខានតែបាននូវរោគរាតត្បាតនៃជំងឺកូវីដ-១៩នេះ ហើយចូលរួមធ្វើអនាម័យឲ្យបានគ្រប់ៗគ្នា ត្រូវចូលរួមអនុវត្តឲ្យបាន៣ការពារ និង៣កុំ តាមអនុសាសន៍របស់ប្រមុខរាជរដ្ឋាភិបាល សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រ ក៏ដូចជាក្រសួងសុខាភិបាលបានដាក់ចេញ ក្នុងនោះមាន ៖ ៣ការពារ ៣កុំ គឺត្រូវឧស្សាហ៍លាងដៃនឹងសាប៊ូ អាល់កុល ឬជែល កុំទៅចូលក្នុងចំណោមច្រើនកកកុញ កុំចាប់ដៃគ្នា ឬឱបថើបគ្នា កុំចូលទីកន្លែងបិទ គ្មានខ្យល់ចេញចូល និងមិនត្រូវប្រើម៉ាស៊ីនត្រជាក់ច្រើនពេក៕ **ដោយ៖សហការី**

## ស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំខេត្តស្រះកែវ ជួយសម្រាលទុក្ខលំបាកពលករខ្មែរ ១២៨គ្រួសារ

https://swiftnewsdaily.com/ SWIFT NEWS ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២១

(ថៃ)៖ នៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២១ ក្រុមការងាររបស់ស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំខេត្តស្រះកែវ ប្រទេសថៃ បានសហការជាមួយមន្ទីរការងារខេត្តសាកែវ អាជ្ញាធរមូលដ្ឋានស្រុកតាប្រាយ៉ា និងស្រុកគោកឈ្យូង ខេត្តសាកែវ ចុះសួរសុខទុក្ខបងប្អូនកម្មករខ្មែរ ព្រមទាំងបាននាំយកអំណោយឧបត្ថម្ភមានដូចជា អង្ករ មីកញ្ចប់ ទឹកត្រី ទឹកស៊ីអ៊ីវ ត្រីខកំប៉ុង ត្រីប្រលាក់គ្រៀម ទឹកដោះគោ និងសម្ភារៈមួយចំនួនទៀត ចែកជូនពួកគាត់នៅស្រុកតាប្រាយ៉ា ចំនួន៥៥ គ្រួសារ និងនៅស្រុកគោកឈ្យូង ចំនួន៧៣ គ្រួសារផ្សេងទៀត ដើម្បីជួយសំរាលទុក្ខលំបាកដល់ពួកគាត់ ដែលកំពុងទទួលរងផលប៉ះពាល់ដោយសារការរីករាលដាលជម្ងឺកូវីដ-១៩៕

## ថៃចាប់ខ្លួនពលរដ្ឋខ្មែរ ២នាក់ ដែលលួចឆ្លងដែន និងកាប់ឈើក្នុងឧទ្យានជាតិ ខេត្តស៊ីសាកេត

https://www.kampucheathmey.com/ ថ្ងៃអង្គារ ២១ កញ្ញា ២០២១ដោយ sopheak khoun

ប្រជាពលរដ្ឋខ្មែរ ២នាក់ ត្រូវបានកម្លាំងអភិរក្សថៃចាប់ខ្លួន ខណៈដែលពួកគេបានលួចឆ្លងដែន ចូលទៅក្នុងទឹកដីថៃ ដោយគ្មានការអនុញ្ញាត និងពាក់ព័ន្ធករណីកាប់ឈើគ្រញូងផងដែរ។ ការចាប់ខ្លួននេះ បានធ្វើឡើងកាលពីវេលាម៉ោង ១រំលងអាធ្រាត្រ ឈានចូលយប់ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២១ ត្រង់ចំណុច ខាងលិចឃៀងខាងជើង

ភូមិសនថន ក្នុងឃុំសៅថុងឆៃ ស្រុកកាន់ថនឡាក់ ខេត្តស៊ីសាកេត ប្រទេសថៃ ដោយកម្លាំងអភិរក្ស ប្រចាំតំបន់នោះ។ ប្រជាពលរដ្ឋខ្មែរទាំង ២នាក់នេះ មានឈ្មោះ ព្រុំ ភេទប្រុស អាយុ ៤៤ឆ្នាំ និងឈ្មោះ រ៉ាន់ ភេទប្រុស អាយុ ១៩ឆ្នាំ។ ដោយឡែកវត្ថុតាងដកហូតបាន រួមមាន៖ ឈើគ្រញូងចំនួន ៣ដុំ ពិលសម្រាប់ពាក់ក្បាលចំនួន២ និងការ៉ុងកែច្នៃ ធ្វើជាសាក់កាដូ សម្រាប់ស្ពាយចំនួន១។ ក្រោយការឃាត់ខ្លួន គឺនៅវេលាម៉ោង៨ និង៣០នាទីព្រឹក ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២១ ពលរដ្ឋខ្មែរទាំង២នាក់ ត្រូវបានបញ្ជូនទៅខណ្ឌរដ្ឋបាលព្រៃឈើបឹងម្លូ ដើម្បីអនុវត្តតាមនីតិវិធី៕ អត្ថបទ៖ សោ និយមរ័ត្ន

## ករណីឆ្លងក្នុងសហគមន៍កើនឡើងនៅតាមបណ្តាខេត្តជាប់ព្រំដែនថៃ

https://www.khmertimeskh.com/ យឹម ស្រីលីន / ខ្មែរថាមស៍

បណ្តាខេត្តដែលមានព្រំដែនជាប់ប្រទេសថៃ កំពុងប្រឈមមុខនឹងការផ្ទុះឡើងនូវករណីឆ្លងក្នុងសហគមន៍ ដែលនេះជាការដាក់សម្ពាធលើអាជ្ញាធរដើម្បីដោះស្រាយស្ថានភាពនេះ។ ករណីទី ២ គឺករណីឆ្លងក្នុងសហគមន៍ ដែលបណ្តាលមកពីអ្នកដឹកទំនិញ និងជំនួយការរបស់ពួកគេ ដែលបានចម្លងមេរោគតាមរយៈការប៉ះពាល់ផ្ទាល់ជាមួយអ្នកលក់នៅតាមផ្សារ ហើយការចម្លងបន្តទៅសមាជិកគ្រួសារ ឬអ្នកលក់ និងអ្នកដើរទិញឥវ៉ាន់ផ្សេងទៀត។

លោក ងួន រតនៈ អភិបាលខេត្តបាត់ដំបងបានប្រាប់កាសែតខ្មែរថាមស៍កាលពីម្សិលមិញថា ក្នុងរយៈពេលប៉ុន្មានថ្ងៃកន្លងមកនេះ ខេត្តបានប្រឈមនឹងការកើនឡើងនូវករណីឆ្លងក្នុងសហគមន៍ និងឆ្លងករណីនាំចូលក្នុងចំណោមពលករចំណាកស្រុក។ លោកនិយាយថា៖ «ក្នុងរយៈពេលប៉ុន្មានថ្ងៃនេះដែរ ករណីឆ្លងក្នុងសហគមន៍បានកើនដល់ជាង ២០០ ករណីជារៀងរាល់ថ្ងៃ ខណៈករណីឆ្លងនាំចូលដោយពលករចំណាកស្រុកមានចំនួនជាង ៥០ ករណីក្នុងចំណោមពលករចំនួន ២០០ នាក់»។

លោក ទៀ សីហា អភិបាលខេត្តសៀមរាបបានប្រាប់កាសែតខ្មែរថាមស៍ថា ការកើនឡើងនូវករណីឆ្លងដោយសារការផ្ទុះឡើងក្នុងសហគមន៍ បានបង្កឲ្យមានវិបត្តិសេដ្ឋកិច្ចនៅក្នុងខេត្តហើយពួកគេកំពុងតស៊ូ ដើម្បីទប់ទល់នឹងស្ថានភាពនេះ។ លោកថានេះគឺដោយសារតែប្រជាជនភាគច្រើនមិនសហការតាមរយៈការផ្តល់ព័ត៌មានទាន់ពេលវេលាអំពីករណីឆ្លងថ្មីៗ។ លោកបានឲ្យដឹងថា៖ «នៅថ្ងៃសុក្រនេះយើងរកឃើញករណីឆ្លងចំនួន ៤៨៣ នាក់ខណៈករណីឆ្លងចំនួន ២២២ នាក់ផ្សេងទៀតត្រូវបានរកឃើញនៅថ្ងៃសៅរ៍។ ម្សិលមិញ (ថ្ងៃអាទិត្យ) មានករណីវិជ្ជមានចំនួន ២៤៨ នាក់ទៀតរួមជាមួយករណីជាសះស្បើយចំនួន ៧៧ នាក់និងករណីស្លាប់ចំនួន ២ នាក់ផងដែរ»។

ទន្ទឹមនឹងនេះនៅខេត្តឧត្តរមានជ័យលោក លឹម សុខតូ អភិបាលរងខេត្តបានប្រាប់ខ្មែរថាមស៍កាលពីម្សិលមិញថា ចំនួនពលករចំណាកស្រុកដែលឆ្លងដែន និងអ្នកដែលឆ្លងជំងឺកូវីដ ១៩ បាននិងកំពុងធ្លាក់ចុះ។ លោកនិយាយថា៖ «នៅថ្ងៃសៅរ៍នេះពលករចំណាកស្រុកចំនួន ៨៤ នាក់បានឆ្លងដែនពីប្រទេសថៃឆ្លងកាត់តាមច្រកអន្តរជាតិអូរស្មាច់ដោយមានតែករណីឆ្លង ៦ ប៉ុណ្ណោះត្រូវបានរកឃើញ។ ទោះយ៉ាងណា នៅពេលអ្នកលក់ប្រមាណចំនួន ៤៩១ នាក់ទទួលការតេស្ត ពេលនោះករណីឆ្លងបានកើនឡើងដល់ ៣៧ នាក់ដែលទាំងនេះត្រូវបានចាត់ថ្នាក់ជាករណីឆ្លងក្នុងសហគមន៍»។ លោកបន្តថា៖ «ម្សិលមិញ (ថ្ងៃអាទិត្យ) ពលករចំណាកស្រុកចំនួន ៨៤ នាក់បានឆ្លងដែនដោយមានតែ ពលករចំនួន ៣ នាក់ប៉ុណ្ណោះដែលរកឃើញថាវិជ្ជមានកូវីដ-១៩។ ទន្ទឹមនឹងនោះពលរដ្ឋចំនួន ១.៥៥២ នាក់ទៀតត្រូវបានធ្វើតេស្តទូទាំងខេត្ត លើកលែងតែពលករចំណាកស្រុក ហើយមានតែចំនួន ៣២ នាក់ប៉ុណ្ណោះដែលរកឃើញថាវិជ្ជមានកូវីដ-១៩»។

លោក ង៉ោ ម៉េងជ្រួន អភិបាលរងខេត្តបន្ទាយមានជ័យបានប្រាប់ខ្មែរថាមស៍កាលពីថ្ងៃសៅរ៍ថា ពលករចំណាកស្រុកចំនួន ១៥៤ នាក់បានឆ្លងដែនពីប្រទេសថៃ។ ក្នុងនោះមានករណីវិជ្ជមានចំនួន ៤ ត្រូវបានរកឃើញ។ ហើយពលករចំណាកស្រុកចំនួន ១៨៧ នាក់ផ្សេងទៀតបានឆ្លងកាត់ព្រំដែនកាលពីថ្ងៃអាទិត្យ ដែលមានករណីវិជ្ជមានចំនួន ១៣ នាក់ត្រូវបានរកឃើញ។ ចំណែកនៅក្រុងប៉ោយប៉ែតវិញលោក កែវ តារាវស្មី អភិបាលរងក្រុង និងជាអ្នកនាំពាក្យសាលាក្រុងបានឲ្យដឹងថា ករណីឆ្លងក្នុងសហគមន៍បានមានការកើនឡើងជារៀងរាល់ថ្ងៃ។ លោកនិយាយថា៖ «គិតត្រឹមថ្ងៃសុក្រ ពលរដ្ឋសរុបចំនួន ៣៩៩ នាក់ត្រូវបានធ្វើតេស្តនិងមានចំនួន ៨៣ នាក់វិជ្ជមានកូវីដ-១៩។ ហើយក្នុងចំណោមមនុស្ស ៣៩៦ នាក់ដែលត្រូវបានធ្វើតេស្តនៅថ្ងៃសៅរ៍មានចំនួន ៩០ នាក់បានរកឃើញថាវិជ្ជមានកូវីដ-១៩។ កាលម្សិលមិញ (ថ្ងៃអាទិត្យ) មនុស្សចំនួន ២៩០ នាក់ត្រូវបានធ្វើតេស្តក្នុងចំណោមនោះមានចំនយន ៣៣ នាក់វិជ្ជមានកូវីដ-១៩»៕

## ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២១

### ស្ត្រីខ្មែរដែលរងការធ្វើបាបពីប្តីជនជាតិចិន ល្បីពេញ Tik Tok ត្រូវរាជរដ្ឋាភិបាលកម្ពុជា-ចិន ជួយសង្គ្រោះបានហើយ

http://freshnewsasia.com/ 2021-09-21 07:36pm

**(ភ្នំពេញ)៖** ស្ត្រីជនជាតិខ្មែរ ដែលបានទៅតាមប្តីរស់នៅប្រទេសចិន និងត្រូវបានប្តីជនជាតិចិនធ្វើបាបយ៉ាងដំណំអស់រយៈពេល ៤ឆ្នាំ រហូតទ្រាំលែងបាន និងបានអំពាវនាវសុំការជួយអន្តរាគមន៍ពីសម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា ជួយឱ្យបានត្រឡប់មកស្រុកខ្មែរវិញនោះ ត្រូវបានក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ស្ថានទូតកម្ពុជា និងនគរបាលចិន ជួយអន្តរាគមន៍សង្គ្រោះបានហើយ។

នេះបើយោងតាមលោក ស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស ស្រង់ប្រភពព័ត៌មានដែលផ្តល់ដោយនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃក្រសួងមហាផ្ទៃ មកប្រាប់បណ្តាញព័ត៌មាន Fresh News នៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២១។ លោកស្រី ជូ ប៊ុនអេង បានបញ្ជាក់យ៉ាងដូច្នេះថា «ស្ត្រីជាជនរងគ្រោះ ឈ្មោះ អាត់ សុភ័ក្រ ភេទស្រី អាយុ២៥ឆ្នាំ រស់នៅទីក្រុង Nanchang ខេត្ត Jiangxi ប្រទេសចិន។ បច្ចុប្បន្ន ជនរងគ្រោះមានសុវត្ថិភាព ហើយ ដោយកំពុងស្ថិតនៅជាមួយ នគរបាលចិនដើម្បីអនុវត្តនីតិវិធីបន្ត។ មន្ត្រីជំនាញ និងស្វែងរកមេខ្យល់ដើម្បីចាត់ការតាមនីតិវិធី»។

សូមបញ្ជាក់ថា ស្ត្រីជាជនរងគ្រោះខាងលើ ត្រូវបានប្តីចាប់បង្ខំធ្វើបាបនៅប្រទេសចិនយ៉ាងដំណំ អស់រយៈពេល ៤ឆ្នាំមកហើយ ដោយបានបិទសិទ្ធមិនឱ្យមានការទំនាក់ទំនងជាមួយគ្រួសារនោះឡើយ ដោយឡែកជាសំណាងល្អមួយ បានអ្នកជិតខាងជួយតាមរយៈការថតបង្ហោះវីដេអូ តាមបណ្តាញសង្គម Tik Tok ស្នើសុំការជួយសង្គ្រោះពីសម្តេចតេជោ ហ៊ុន សែន។ ក្នុងវីដេអូនោះ ស្ត្រីរងគ្រោះបានអំពាវនាវ ទាំងទឹកមុខក្រៀមក្រំថា «សូមសម្តេចហ៊ុន សែន ជួយនាងខ្ញុំផង ឱ្យបានទៅខ្មែរវិញ»៕

## ពិធីបើកវគ្គផ្សព្វផ្សាយស្តីពីការទប់ស្កាត់ការជួញដូរមនុស្ស និងការធ្វើចំណាកស្រុក ប្រកបដោយសុវត្ថិភាព

https://grandnewsasia.com/detail/ 22-/09-2021

ក្រចេះ៖ នាថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២១ លោកស្រី ខាំ សុភាព អភិបាលរងខេត្តក្រចេះ បានអញ្ជើញជាអធិបតីក្នុងវគ្គផ្សព្វផ្សាយស្តីពីការទប់ស្កាត់ការជួញដូរមនុស្ស និងការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាពស្ថិតនៅឃុំសំបូរ ស្រុកសំបូរ ។ វគ្គផ្សព្វផ្សាយមានគោលបំណងដើម្បីកសាងសមត្ថភាពដល់អាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋនៅក្នុងភូមិ ឃុំគោលដៅឲ្យមានការយល់ដឹងក្នុងការទប់ស្កាត់អំពើជួញដូរមនុស្ស ការកេងប្រវ័ញ្ចនានាតាមគ្រប់រូបភាពនិងកាត់បន្ថយការធ្វើចំណាកស្រុកដោយប្រថុយប្រថាន៕

## នគរបាលការពារព្រំដែនគោកលេខ៨១៧ សហការជាមួយកម្លាំងយោធា ការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែន និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញ ចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ

http://cambodiapolice.com/policekh/ 10:04 am 21 កញ្ញា 2021

ខេត្តបាត់ដំបង ៖ នៅថ្ងៃចន្ទ ១៤កើត ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២១ ដោយអនុវត្តតាមបទបញ្ជារបស់ លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបងជាប់ជាប្រចាំ ស្តីពីការ ការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញ ចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា_ថៃ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ បានចាត់កម្លាំងប៉ុស្តិ៍ព្រំដែនទាំង៦ចំណុះឲ្យវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ សហការជាមួយកម្លាំងយោធា ចេញល្បាតតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា_ថៃ ក្នុងភូមិសាស្ត្រប៉ុស្តិ៍គ្រប់គ្រង និងដាក់ពង្រាយកម្លាំងប្រចាំការតាមគោលដៅតូចៗចំនួន៥០គោលដៅ ដើម្បីខ្ទប់ស្កាត់ប្រជាពលរដ្ឋចេញ_ចូលផងដែរ ៕

## ឃាត់ខ្លួនជនជាតិថៃ ៥នាក់ ដែលចាញ់បោកមេខ្យល់ នាំមកធ្វើការនៅក្នុងប្រទេសកម្ពុជា

https://www.kampucheathmey.com/ ថ្ងៃពុធ ២២ កញ្ញា ២០២១ដោយ Sorn Phanith

ជនជាតិថៃ ដែលសុទ្ធសឹងជាយុវវ័យ៥នាក់ ត្រូវតម្រួតការពារព្រំដែនថៃលេខ ១២ សហការជាមួយកម្លាំងទាហានឈុតខ្មៅការពារព្រំដែន ធ្វើការឃាត់ខ្លួននៅក្បែរខ្សែបន្ទាត់ព្រំដែន ថៃ-កម្ពុជា ខណៈដែលពួកគេកំពុងលួចឆ្លងដែន ត្រឡប់ចូលទៅក្នុងប្រទេសខ្លួនវិញ។ ការឃាត់ខ្លួននេះ បានធ្វើឡើងកាលពីវេលាម៉ោង៩ និង៣០ នាទីព្រឹកកាលពីថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២១ ត្រង់ចំណុចលើកំណាត់ផ្លូវសេរីភិន ក្នុងភូមិ១ ឃុំណូនម៉ាកម៉ុន ស្រុកគោកខ្សូង ខេត្តស្រះកែវ ប្រទេសថៃ ខណៈដែលពួកគេបានធ្វើដំណើរ ផុតពីខ្សែបន្ទាត់ព្រំដែនកម្ពុជា ទៅហើយ និង ស្របពេលដែលប្រទេសមានការរឹតបន្តឹង ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ផងនោះ ។

ក្រោយពេលឃាត់ខ្លួន ពួកគេបានអះអាងថា ការលបឆ្លងដែនត្រឡប់ចូលមកស្រុកកំណើតវិញនេះ គឺដោយសារពួកគេចាញ់បោកមេខ្យល់ ដែលបាននាំទៅធ្វើការនៅក្នុងវេបសាយល្បែងភ្នាល់ ក្នុងកាស៊ីណូអនឡាញ នាក្រុងប៉ោយប៉ែត ដោយគេប្រាប់ថា ពេលទៅដល់ទីនោះក្រុមហ៊ុននឹងជួយគ្រប់យ៉ាងទាំងការហូបចុក និងការស្នាក់នៅ ប៉ុន្តែពេលទៅផ្ទាល់វាមិនដូចពាក្យសន្យា ទើបពួកគេសម្រេចត្រឡប់ចូលទៅប្រទេសថៃវិញតាមច្រករបៀង ប៉ុន្តែមិនទាន់បានទៅដល់ផ្ទះផងក៏ត្រូវចាប់ខ្លួន។

ក្រុមយុវវ័យថៃទាំង៥នាក់ ដែលក្នុងនោះមានប្រុស២ ស្រី៣ បានបន្តថា ពួកគេរស់នៅក្នុងខេត្តស្រះកែវទាំងអស់គ្នា ដោយចង់រកការងារធ្វើ តែមិនបានដូចបំណង ត្រូវចាញ់បោកមេខ្យល់ទៀត ។ បើទោះបីជាមានការវិលត្រឡប់ចូលទឹកដីថៃវិញក៏ដោយ ក៏សមត្ថកិច្ចបានលើកឡើងថា ត្រូវតែខុសនឹងច្បាប់ ព្រោះពួកគេមិនបានចេញ-ចូលតាមច្រកត្រឹមត្រូវ ដើម្បីឲ្យសមត្ថកិច្ចត្រួតពិនិត្យ ដោយបច្ចុប្បន្នជនជាតិថៃទាំង៥នាក់ ត្រូវបានបញ្ជូនទៅកាន់អធិការដ្ឋានតម្រួតស្រុកគោកខ្យូង ដើម្បីចាត់ការតាមនីតិវិធី ៕ **អត្ថបទ៖ សោ និយមរ័ត្ន**

## កម្លាំងនគរបាលខេត្តកំពង់ស្ពឺ សហការជាមួយកម្លាំងជំនាញជួយអន្តរាគមន៍ស្ត្រីម្នាក់ នៅស្រុកសំរោងទង ត្រូវប្តី ជនជាតិចិន និងឪពុកម្តាយក្មេកធ្វើបាប នៅប្រទេសចិន

https://cen.com.kh/ Posted ByPen Srey NeatSeptember 22, 2021

កំពង់ស្ពឺ៖ ក្រោយទទួលបានព័ត៌មានតាមប្រព័ន្ធអ នឡាញ tik tok និងWechat ដែលមាន ស ម្លេងសន្ទនាគ្នារវាងស្ត្រីម្នាក់និងជនរងគ្រោះ ដែលបានអះអាងថា ជាជនជាតិខ្មែរមានឈ្មោះ ភក្រ មានទីលំនៅមុនទៅក្រៅប្រទេសនិងមានស្រុកកំណើត រស់នៅក្នុងស្រុកសំរោងទង ខេត្តកំពង់ស្ពឺ បច្ចុប្បន្ន ត្រូវបានបុរសជាប្តី ជនជាតិចិន និងឪពុកម្តាយក្មេកធ្វើបាប រហូតមានរូបរាងស្គមស្គាំង ភ្លេចភ្លាំង ស្មារតី និងធ្លាក់ខ្លួនស្គមរីងរៃ ដង្ហោយរកការជួយអន្តរាគមន៍បានវិលត្រឡប់មកស្រុកកំណើតវិញ។ ដោយបានការដឹកនាំផ្ទាល់ពីលោកឧត្តមសេនីយ៍ទោ សម សាមួនស្នងការនគរបាលខេត្តកំពង់ស្ពឺ បានចង្អុលការណ៍ឱ្យ ជំនាញប្រឆាំង ការជួញដូរមនុស្សនិងការពារអនីតិជនខេត្តសហការស្រាវជ្រាវ រកក្រុមគ្រួសារតាមការអះអាង របស់ស្ត្រីដែលអះអាងថាជាជនរងគ្រោះកាលពីថ្ងៃសៅរ៍ទី១៨ ខែកញ្ញា ឆ្នាំ២០២១ ជំនាញបានចុះសហការស្រាវជ្រាវរកឃើញម្តាយរបស់ជនរងគ្រោះឈ្មោះ សឿន ទីទី លំនៅភូមិដូនអាត់ ឃុំស្គុះ ស្រុកសំរោងទង ជំនាញបានសាកសួរព័ត៌មានពិនិត្យឯកសារសោវតារូបថត ភស្តុតាងជាច្រើន លទ្ធផល គឺពិតជាកូនរបស់គាត់ពិតប្រាកដមែន។

តាមដំណើរនៃរឿងហេតុ៖ ឈ្មោះ អាត់ សុភ័ក្រ ភេទស្រី អាយុ២៣ឆ្នាំ អំឡុងខែឧសភា ឆ្នាំ២០១៨ បានចាកចេញពីផ្ទះទៅរកការងារធ្វើនៅតាមខេត្ត រួចក៏បាត់ដំណឹងឈឹងរហូតមកដល់បច្ចុប្បន្ន ទើបតែទទួលបានថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២១ (ឈ្មោះ សឿន ទី )បានដំណឹងតាមប្រព័ន្ធ tik tok ថាកូនស្រីរបស់គាត់ត្រូវបានគេបង្ហោះថារស់នៅប្រទេសចិន ត្រូវប្តីនិងឪក្មេកម្តាយក្មេកធ្វើបាប គាត់បានស្វែង រកកិច្ចអន្តរាគមន៍ ដើម្បីឱ្យសមត្ថកិច្ចជួយបន្ទាប់មកជំនាញការិយាល័យប្រឆាំង ការជួញដូរ មនុស្ស និងការពារអនីតិជន បានជួបនិងចំណាត់ការនីតិវិធីទាក់ទងតាមរយៈAccount Facebook ឈ្មោះ Lin pei ដែលបាន Share Videoនិងបានសួរអំពីព័ត៌មានជនរងគ្រោះម្ចាស់ accou nt បានប្រាប់ថានារីរងគ្រោះកំពុងរស់ភូមិហ៊ូធៀន ស្រុកណានឆាង ក្រុងណានឆាង ខេត្តជាំងស៊ី (ប្រទេសចិន )ហើយខ្លួនមាន មិត្តភក្តិម្នាក់ នៅប្រទេសចិនរស់ នៅក្បែរផ្ទះជនរងគ្រោះ។

កាលពីថ្ងៃចន្ទទី២០ ខែកញ្ញា ឆ្នាំ២០២១ កម្លាំងការិយាល័យជំនាញបានជូនម្តាយជនរងគ្រោះ ទៅនាយកដ្ឋានប្រឆាំងការជួញដូរ ក្រសួងការបរទេស ដើម្បីបំពេ ញបែបសុំអន្តរាគមន៍ទៅប្រទេសចិន អគ្គកុងស៊ុលនៅខេត្តប្រទេសចិន ដើម្បីស្វែងរកជនរងគ្រោះ តាមព័ត៌មាន ចុងក្រោយ police ចិនបានរកឃើញ និងបញ្ជូនជនរងគ្រោះមកទីស្នាក់ការប៉ុស្ត៏សុវត្ថិភាពដើម្បីបន្តនីតិវិធីបំពេញបែបបទបញ្ជូនមកប្រទេសកម្ពុជា៕ រក្សាសិទ្ធិដោយ៖បញ្ញាស័ក្តិ

## បុរសជនជាតិ អាមេរិកម្នាក់ ត្រូវបានចោទ ប្រកាន់ពី បទរំលោភបំពានផ្លូវភេទ លើកុមារ នៅខេត្តក្រចេះ

https://dap-news.com/ BySSP108Posted on September 22, 2021

**ភ្នំពេញ៖** សាលាដំបូងខេត្តក្រចេះ នៅថ្ងៃទី ១៩ ខែកញ្ញាឆ្នាំ ២០២១បានចោទប្រកាន់ ជនជាតិអាមេរិក អាយុ ៧៤ ឆ្នាំម្នាក់ ពីបទទិញពេស្យាចារកុមារ តាមមាត្រា៣៤ នៃច្បាប់ស្ដីពីការបង្ក្រាប ការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ ដែលពាក់ព័ន្ធនឹងក្មេងប្រុស មិនទាន់គ្រប់អាយុ ២ នាក់។ នេះបើតាមសេចក្ដីប្រកាសព័ត៌មានរបស់ អង្គការ APLE Cambodia នៅមុននេះបន្តិច។ ប្រភពដដែល បន្តថា ជនសង្ស័យ ត្រូវបានបញ្ជូនទៅឃុំខ្លួននៅពន្ធនាគារខេត្តដើម្បីរង់ចាំការកាត់ក្ដី។ នគរបាលប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនខេត្តក្រចេះ បានចាប់ផ្ដើមស៊ើបអង្កេត លើករណីរំលោភបំពាន ដោយជនជាតិអាមេរិក ដែលជាពាណិជ្ជករនៅក្នុងខេត្តនេះបន្ទាប់ពីទទួលបានរបាយការណ៍ពីអ្នករាយការណ៍ព័ត៌មានស៊ីវិលដែលមានមូលដ្ឋាននៅសហគមន៍អេភីអេល។ ជនរងគ្រោះទាំងពីរ បានកំណត់អត្តសញ្ញាណជន សង្ស័យថា ជាអ្នករំលោភ ហើយបានបញ្ជាក់ពីសកម្មភាព ផ្លូវភេទលើពួកគេ ដែលបានកើតឡើងជាច្រើនដង ខណៈពួកគេកំពុងធ្វើការ នៅសណ្ឋាគាររបស់គាត់។

APLE សរសើរការខិតខំប្រឹងប្រែង របស់ប៉ូលីស និងកិច្ចសហប្រតិបត្តិការពេហុទីភ្នាក់ងារ ដើម្បីស៊ើបអង្កេតករណីនេះ និងផ្ដល់ការការពារចាំបាច់ដល់ជនរងគ្រោះ។ អេភេលបានផ្ដល់ ការគាំទ្រផ្នែកផ្លូវចិត្ត និងសុខុមាលភាពចាំបាច់ ដល់ជនរងគ្រោះ ហើយនឹងធ្វើការ ជាមួយដៃគូ ដើម្បីធានានូវការថែទាំ សមរម្យនិងសេវាកម្មយូរអង្វែង សម្រាប់ពួកគេ និងគ្រួសាររបស់ពួកគេ៕

## ស្ថានទូតកម្ពុជានៅថៃ នាំយកជំនួយ ជូនពលករខ្មែរ៦0គ្រួសារ កំពុងជួបការលំបាកខ្លាំង

https://www.kampucheathmey.com/ ថ្ងៃពុធ ២២ កញ្ញា ២០២១ដោយ KC Virak

នៅព្រឹកថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២១នេះ ស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ ដឹកនាំដោយ លោក អ៊ុក សោភ័ណ ឯកអគ្គរាជទូត និងមន្ត្រីការទូត បាននាំយកអំណោយជាគ្រឿងឧបភោគបរិភោគរួមមាន អង្ករ ត្រីខ បន្លែ និងសាច់ស្រស់ ចុះចែកដល់បងប្អូនពលករខ្មែរចំនួន៦០គ្រួសារ ដែលកំពុងជួបការលំបាកខ្លាំងដោយសារការរីករាតត្បាតជំងឺកូវីដ-១៩ នៅស្រុកប្លែងយ៉ាវ ខេត្តឆាក់ឈើងសៅ។ នេះបើតាមការផ្ដល់ព័ត៌មានពីលោក កុយ គួង អ្នកនាំពាក្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិកម្ពុជា។ សូមបញ្ជាក់ថា កាលពីថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ ២០២១ នេះ លោក អ៊ុក សោភ័ណ ឯកអគ្គរាជទូតកម្ពុជា ប្រចាំព្រះរាជាណាចក្រថៃឡង់ដ៍ បានចាត់ក្រុមការងារនាំយក អង្ករ ត្រីខ បន្លែ ត្រី សាច់ ទៅប្រគល់ជូនតំណាងរបស់បងប្អូនពលករខ្មែរចំនួន ៦ ក្រុម នៅផ្លូវពហុយោធិន១ សង្កាត់ផៈយ៉ាថៃ ខណ្ឌផៈយ៉ាថៃ រាជធានីបាងកក ដើម្បីនាំយកទៅចែកជូនបន្តដល់បងប្អូនពលករសរុប ១១៣ គ្រួសារផងដែរ។ ក្នុងនោះពួកគាត់រស់នៅ៖

ទី១.ផ្លូវសុខសៈវ៉ាត់ឌី១២ ឃុំប៉ាកខ្លងប្លាកាត់ ស្រុកផ្រៈសមុទ្រចេឌី ខេត្តសមុទ្រប្រាកានចំនួន២៤គ្រួសារ។

ទី២. តំបន់ ៩/១៥៥ អ៊ឹមភើរៀល ឃុំឡាកូណា ស្រុកបាងបួថង ខេត្តនុនថៈប៊ុរី ចំនួន ៥ គ្រួសារ។

ទី៣. ក្រុមទី ៥ ផ្លូវសុខសុវត្ថិ ២ សង្កាត់ចោមថង ខណ្ឌចោមថង ទីក្រុងបាងកក ចំនួន ២៣ គ្រួសារ។

ទី៤. គម្រោងការស៊ិនថានី ៨៨ ឃុំបានកៅ ស្រុកផានថង ខេត្តឈុនប៊ុរី ចំនួន ២២ គ្រួសារ។

ទី៥. តំបន់កៈសេតណៈវ៉ៈមីន ទីក្រុងបាងកក ចំនួន ១៧ គ្រួសារ។

ទី៦. តំបន់តៈឡាតថៃ ស្រុកខ្លងហ្លួង ខេត្តប៉ៈធុមថានី ២២ គ្រួសារ។

ប្រជាជនទាំងនេះ សុទ្ធសឹងជាអ្នកជួបការលំបាកខ្លាំង ខ្លះបាត់បង់ការងារ ខ្លះមានឆ្លងជំងឺកូវីដ-១៩ និងមួយភាគធំជាអ្នកដែលជាប់ធ្វើចត្តាឡីស័ក មិនអាចទៅធ្វើការបាន៕ អត្ថបទ៖ កោះកែវ

## នគរបាលការពារព្រំដែនគោកលេខ ៨១៧ សហការជាមួយកម្លាំងយោធា ទទួលប្រជាពលរដ្ឋដែលវិលត្រឡប់មកពីប្រទេសថៃ ចូលមកប្រទេសកម្ពុជាវិញ

http://cambodiapolice.com/policekh/ 11:08 am   22 កញ្ញា 2021

ខេត្តបាត់ដំបង ៖ នៅថ្ងៃអង្គារ ១៥កើត ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី ២១ ខែកញ្ញា ឆ្នាំ២០២១ ដោយអនុវត្តតាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបងជាប់ជាប្រចាំ ស្តីពីការ ការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញ ចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា_ថៃ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ ៨១៧ បានចាត់កម្លាំងប៉ុស្តិ៍ព្រំដែន សហការជាមួយកម្លាំងយោធា ចេញល្បាតតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា_ថៃ ក្នុងភូមិសាស្ត្រប៉ុស្តិ៍គ្រប់គ្រង និងទៅទទួលប្រជាពលរដ្ឋដែលវិលត្រឡប់មកពីប្រទេសថៃ ចូលមកប្រទេសកម្ពុជាវិញ ត្រង់ចំណុចនៃភូមិសាស្ត្រភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបងចំនួន០១នាក់,ស្រី០នាក់។ បន្ទាប់ពីសាកសួរ,កត់ឈ្មោះនិងអប់រំណែនាំរួច កម្លាំងយើងបានប្រគល់បងប្អូនឲ្យទៅក្រុមគ្រូពេទ្យ ប្រចាំការនៅចំណុចច្រកទ្វារព្រំដែនអន្តរជាតិ គីឡូ១៣ ៕

## ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២១

## មេខ្យល់ ម្នាក់នាំពលករ២នាក់បម្រុងទៅរកការងារធ្វើនៅស្រុកថៃ ដោយខុសច្បាប់ត្រូវកម្លាំងកងរាជអាវុធហត្ថឃាត់ខ្លួនបញ្ជូនទៅតុលា

https://www.kampucheathmey.com/ ថ្ងៃព្រហស្បតិ៍ ២៣ កញ្ញា ២០២១ដោយ Kang Tola

បន្ទាយមានជ័យ ៖ កម្លាំងកងការពារព្រំដែនលេខ៥០៣ យោធភូមិភាគទី៥ បានចុះល្បាតតាមបន្ទាត់ព្រំដែន ដឹកនាំដោយលោកឧត្តមសេនីយ៍ត្រី យួន ជឿន មេបញ្ជាការកងការពារព្រំដែនលេខ៥០៣ ដល់ចំណុចភូមិខ្វាវលិច ឃុំស្វាយចេក ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ បានឃាត់មនុស្សចំនួន៣នាក់ ក្នុងនោះស្ត្រីម្នាក់ ដែលមានបំណងឆ្លងដែនទៅធ្វើការងារនៅប្រទេសថៃ។ ក្នុងចំណោម៣នាក់នោះមានមេខ្យល់១នាក់ ឈ្មោះ ប៉ិ ម៉ៅ ភេទប្រុស អាយុ៤៧ឆ្នាំ មុខរបររត់ម៉ូតូឌុប រស់នៅភូមិកន្ទួត សង្កាត់ភ្នៀត ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ នៅវេលាម៉ោង៤ព្រឹក ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២១។ លោកឧត្តមសេនីយ៍ត្រី យួន ជឿន បានបញ្ជាក់ឲ្យដឹងបន្តទៀត មេខ្យល់ខាងបាន  កងកម្លាំងការពារព្រំដែនបានបញ្ជូនមកប្រគល់ឲ្យទីបញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តចាត់ការតាមនីតិវិធី។ ចំណែកពលករចំនួន២នាក់ត្រូវបានកម្លាំងកងការពារព្រំដែនបញ្ជូនទៅមណ្ឌលចត្តាឡីស័ក អូរបីជាន់ ស្ថិតក្នុងស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ។

លោកវរសេនីយ៍ឯក ម៉ែន ភិរម្យ មេបញ្ជាការរងកងរាជអាវុធហត្ថខេត្ត ទទួលការងារស្រាវជ្រាវ និងបង្ក្រាបបទល្មើសបានឱ្យដឹងថា មេខ្យល់ឈ្មោះ ប៉ិ ម៉ៅ ក្រោយពីកម្លាំងការិយាល័យជំនាញសាកសួរចម្លើយបានឆ្លើយសារភាពថា រូបគេពិតជាបានដឹកពលករប្រុស ស្រី ចំនួន២នាក់ ដោយម៉ូតូបម្រុងលួចឆ្លងដែនទៅប្រទេសថៃដោយខុសច្បាប់ពិតប្រាកដមែន។ លោកវរសេនីយ៍ឯក ម៉ែន ភិរម្យ បានឱ្យដឹងទៀតថាដោយអនុវត្តតាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ត្រី បោន ប៊ិន មេបញ្ជាការកងរាជអាវុធហត្ថខេត្ត ជនសង្ស័យនិងវត្ថុតាងម៉ូតូត្រូវបានកម្លាំង

ការិយាល័យប្រឆាំងការជួញដូរមនុស្ស បញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តបញ្ជូនទៅសាលាដំបូងខេត្តដើម្បីចាត់ការទៅតាមផ្លូវច្បាប់ហើយ៕

## មន្ត្រីអន្តោប្រវេសន៍ថៃនិយាយថាពលករមកពីកម្ពុជាមានបំណងវិលត្រឡប់មករកការងារធ្វើនៅប្រទេសថៃវិញ

https://www.khmertimeskh.com/ Khmer Times September 23, 2021

ប៉ូលីសអន្តោប្រវេសន៍រំពឹងថា ពលករខុសច្បាប់មកពីប្រទេសជិតខាង នឹងវិលត្រឡប់មកប្រទេសថៃវិញ ខណៈប្រទេសនេះនឹងចាប់ផ្តើមបើកអាជីវកម្មច្រើនឡើងវិញ។ លោកឧត្តមសេនីយ៍ទោ Archayon Kraithong អ្នកនាំពាក្យការិយាល័យអន្តោប្រវេសន៍ បាននិយាយកាលពីថ្ងៃពុធថា និន្នាការនៃការចូលមកប្រទេសថៃដោយខុសច្បាប់បានកើនឡើង ខណៈពួកគេត្រូវបានទាក់ទាញអោយត្រលប់ទៅវិញដោយសារអាជីវកម្មបានបើកឡើងវិញបន្ទាប់ពីរដ្ឋាភិបាលបានបន្ធូរបន្ថយវិធានការរឹតត្បិត។ លោកបាននិយាយនៅក្នុងបទសម្ភាសន៍ជាមួយវិទ្យុជូឡានៃសាកលវិទ្យាល័យជូឡាឡុងកនថា កម្មករមកពីប្រទេសជិតខាងជាពិសេសពលករមកពីប្រទេសកម្ពុជាមានបំណងវិលត្រឡប់មករកការងារធ្វើនៅប្រទេសថៃវិញ។ លោកបានបន្ថែមថា" មួយចំនួនធំនៃអ្នកដែលត្រូវចាប់ខ្លួននៅព្រំដែនមានប័ណ្ណការងារ។

ប្រទេសថៃបានបិទព្រំដែនគោកទាំងអស់ ហើយអនុញ្ញាតអោយតែជនជាតិថៃវិលត្រឡប់មកវិញនិងទំនិញពាណិជ្ជកម្មឆ្លងដែនចូលប៉ុណ្ណោះ។ ពលករបរទេសក៏មិនត្រូវបានអនុញ្ញាតអោយចាកចេញទៅប្រទេសកំណើតរបស់ពួកគេផងដែរ។"ថ្វីបើមានការបិទព្រំដែនក៏ដោយក៏ពលករចំណាកស្រុកជាច្រើនបានរត់ចេញពីប្រទេសកាលពីខែមុនដោយសារពួកគេគ្មានការងារធ្វើក្នុងកំឡុងពេលជាប់គាំងនៅក្នុងប្រទេសថៃឬពួកគេចង់វិលត្រឡប់ទៅប្រទេសរបស់ពួកគេវិញដើម្បីចាក់វ៉ាក់សាំង។

ឧត្តមសេនីយ៍ទោ Archayon បាននិយាយថានិន្នាការនេះត្រូវបានបញ្ច្រាស់វិញនៅខែនេះដោយសារមានមនុស្សជាច្រើនទៀតត្រូវបានចាប់ខ្លួនដោយព្យាយាមលួចចូលប្រទេស ដោយលោកមិនបានផ្តល់តួលេខទេ។ ប៉ុន្តែទិន្នន័យពីមជ្ឈមណ្ឌលគ្រប់គ្រងស្ថានភាពកូវីដ-១៩ មិនបានបង្ហាញពីការកើនឡើងគួរឱ្យកត់សម្គាល់នៃអ្នកចូលខុសច្បាប់ទេ។ ស្ថាប័ននេះបង្ហាញថាមានជនបរទេសចំនួន ៤,៦០០ នាក់មកពីប្រទេសជិតខាងទាំងបួនត្រូវបានចាប់ខ្លួនកាលពីខែមុនហើយមាន ៤,១០០ នាក់ត្រូវបានចាប់ខ្លួនក្នុងរយៈពេល ២១ ថ្ងៃដំបូងនៃខែនេះ។ ពលករចំណាកស្រុកភាគច្រើនមកពីប្រទេសកម្ពុជាដែលលួចចូលមកប្រទេសថៃវិញដើម្បីរកការងារត្រូវបានសម្របសម្រួលដោយមេខ្យល់ដែលមានការរៀបចំល្អទាំងការរត់ពន្ធកម្មករឆ្លងដែនក៏ដូចជាការស្វែងរកនិយោជក ដោយមេខ្យល់ទាំងនោះនិយាយថានៅទីនោះមានប្រាក់ឈ្នួលខ្ពស់ជាង។ អ្នកឆ្លងព្រំដែនភាគច្រើនគឺជាពលករខុសច្បាប់ ខណៈដែលអ្នកខ្លះមានទិដ្ឋាការត្រឹមត្រូវនិងលិខិតអនុញ្ញាតអោយធ្វើការងារ ទោះបីជាចំនួនពិតប្រាកដនៃប្រភេទពលករនីមួយៗមិនត្រូវបានបញ្ជាក់ក៏ដោយ៕ bangkokpost

## សង្គមស៊ីវិលជំរុញឲ្យរដ្ឋាភិបាលរកការងារក្នុងស្រុកឲ្យពលករត្រឡប់មកពីប្រទេសថៃធ្វើ

https://www.rfa.org/khmer/ ដោយ ជី វិតា2021-09-22

សង្គមស៊ីវិលជំរុញឲ្យរដ្ឋាភិបាលរកការងារក្នុងស្រុកឲ្យពលករដែលទើបត្រឡប់មកពីប្រទេសថៃធ្វើ ដើម្បីទប់ស្កាត់កុំឱ្យពួកគេឆ្លងដែនត្រឡប់ទៅប្រទេសថៃទាំងប្រថុយប្រថានអំឡុងពេលនេះវិញ។ ការលើកឡើងនេះក្រោយពេលពលករជាច្រើនកំពុងនាំគ្នាឆ្លងដែនត្រឡប់ទៅរកការងារធ្វើនៅក្នុងប្រទេសថៃវិញជាបន្តបន្ទាប់។ ក្រុមអ្នកឃ្លាំមើលសិទ្ធិពលករសង្កេតឃើញថា ការលបឆ្លងដែនត្រឡប់ចូលទៅប្រទេសថៃវិញ គឺដោយសារពលករគ្មានការងារធ្វើ

ត្រឹមត្រូវនៅក្នុងស្រុក ទើបពួកគាត់នាំគ្នាលួចឆ្លងដែនចូលប្រទេសជិតខាងនេះវិញ ដោយប្រឈមនឹងអាជ្ញាធរថៃចាប់បញ្ជូនត្រឡប់ទៅប្រទេសវិញ ឬចាប់ដាក់ពន្ធនាគារ និងប្រឈមការឆ្លងជំងឺកូវីដ១៩(Covid-19) ជាដើម។

មន្ត្រីកម្មវិធីផ្នែកទេសន្តរប្រវេសន៍នៃមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស ហៅកាត់ថា សង់ត្រាល់ (CENTRAL) លោក ឌី ថេហូយ៉ា ឲ្យដឹងថា ពលករភាគច្រើនចង់បានការងារធ្វើដែលមានប្រាក់ចំណូលសមរម្យនៅក្នុងស្រុក ជាជាងការប្រថុយឆ្លងដែនទៅរកការងារធ្វើនៅប្រទេសថៃ។ ប៉ុន្តែច្រើនខែមកនេះ ពលករជាច្រើនសុទ្ធតែគ្មានការងារធ្វើ។ ពួកគាត់ខ្លះបានធ្វើស្រែ ឬចិញ្ចឹមសត្វបន្តិចបន្តួចជាលក្ខណៈគ្រួសារ។ ប៉ុន្តែពួកគាត់គ្មានប្រាក់ចំណូលប្រចាំថ្ងៃទេ ស្របពេលដែលពលករជាច្រើនជំពាក់បំណុលធនាគារ។ លោក ឌី ថេហូយ៉ា ព្រួយបារម្ភថា ប្រសិនបើរដ្ឋាភិបាលមិនបង្កើនមុខរបរក្នុងស្រុកបន្ថែមដូចការប្រកាសកន្លងទៅទេ ពលករកាន់តែច្រើននឹងនាំគ្នាប្រថុយឆ្លងដែនត្រឡប់ទៅប្រទេសថៃបន្តទៀត៖ «*រដ្ឋាភិបាលគួរតែឆ្លៀតឱកាសហ្នឹងបង្កើនប្រសិទ្ធភាព ដូចថាក្រសួងការងារបង្កើតសាលាបណ្ដុះបណ្ដាលវិជ្ជាជីវៈ។ អ៊ីចឹងមិនដឹងថា មកដល់ពេលនេះមាន (ពលករ)រៀនប៉ុន្មាននាក់ អ្វីប៉ុន្មាននាក់ គួរតែជំរុញទៅដើម្បីអ្វី? ដើម្បីឲ្យអាកូវីដហ្នឹងចប់ទៅ គាត់មានជំនាញហើយគាត់អាចរកការងារល្អបានធ្វើ ឬមួយការងារនៅក្នុងស្រុក*»។ អាជ្ញាធរថៃមិនទាន់ប្រកាសពីការបើកប្រទេសឲ្យពលករត្រឡប់រកការងារធ្វើនៅឡើយទេ។ ប៉ុន្តែពលរដ្ឋខ្មែរបាននាំគ្នាប្រថុយលួចឆ្លងដែនចូលទៅប្រទេសថៃកាន់តែច្រើនឡើង ពិសេស គឺនៅពេលយប់ដើម្បីទៅស្វែងរកការងារធ្វើវិញ។

ពលករម្នាក់ដែលទើបឆ្លងដែនបានចូលមកដល់ប្រទេសថៃកាលពីថ្ងៃទី២១ ខែកញ្ញា គឺលោកស្រី ពែន វីន ឲ្យដឹងថា លោកស្រីមានគ្នា៣នាក់បានប្រើពេលពេញមួយថ្ងៃដើរកាត់ព្រៃលបឆ្លងដែន មកប្រកបរបររើសអេតចាយនៅប្រទេសថៃវិញ។ ការណ៍ដែលលោកស្រី និងប្ដី សុខចិត្តត្រឡប់មករើសអេតចាយនៅប្រទេសថៃវិញ ព្រោះពួកគាត់គ្មានមុខរបរ និងគ្មានការងារធ្វើនៅស្រុកកំណើត។ លោកស្រី ពែន វីន បញ្ជាក់ថា ច្រើនខែមកនេះ លោកស្រី និងប្ដី ខិតខំដើររកការងារធ្វើនៅស្រុកកំណើតដែរ តែរកមិនបានដោយសារពួកលោកស្រី គ្មានចំណេះដឹង គ្មានជំនាញច្បាស់លាស់ ទើបពួកគេសម្រេចចិត្តត្រឡប់មករពឹងមុខរបររើសអេតចាយនៅស្រុកថៃវិញ៖«ខ្ញុំលួចចូលមក។ ខ្ញុំវាគ្មានលុយ គ្មានកាក់រកបាយហូបមិនបានក៏មកវិញមក។ ដូចថានៅផ្ទះ វាគ្មានស្រែ គ្មានអ្វីធ្វើដល់អ៊ីចឹងខ្ញុំក៏ឡើងមកវិញមក។ គេគ្មានតែឲ្យយើងចូលទេ។ គេចាប់បានបញ្ជូនទៅវិញមួយសារហើយហ្នឹង ខ្មែរយើងអ្នកចាប់។ ថៃគេគ្មានចាប់ផង។ គេចាប់បានគេបញ្ជូនទៅផ្ទះវិញមួយសារដែរហ្នឹង។ ទ្រាំដែរហ្នឹង តែធ្វើម្ដេចស្រុកយើងវាអត់មានអ្វីធ្វើ។ ខ្ញុំចេះតែមកទៅ»។

ការប្រថុយលួចឆ្លងដែនខុសច្បាប់ ទៅរកការងារធ្វើក្នុងស្ថានភាពដែលថៃកំពុងបិទប្រទេសនេះ ប្រឈមនឹងគ្រោះថ្នាក់ហើយត្រូវចំណាយលុយច្រើនជាងការឆ្លងដែនស្របច្បាប់។ ពលករត្រូវពឹងពាក់អ្នកនាំផ្លូវ ឬហៅថាមេខ្យល់ឲ្យនាំដើរផ្លូវវៀងឆ្ងាយ ឬត្រូវដើរកាត់ព្រៃ ឆ្លងអូរ ឡើងភ្នំ ដើម្បីគេចពីប៉ូលិសតាមព្រំដែន។ ក្រោយពេលឆ្លងចូលដល់ដីថៃហើយ ពលករក៏នៅតែប្រឈមនឹងគ្រោះថ្នាក់ដែរ ដូចជា គ្រោះថ្នាក់ចរាចរណ៍ ប៉ូលិសថៃចាប់បញ្ជូនត្រឡប់ទៅវិញ ឬចាប់ឃុំក្នុងពន្ធនាគារ និងភាពគ្មានការងារធ្វើនៅក្នុងប្រទេសថៃ ជាដើម ខណៈរោងចក្រនៅប្រទេសថៃខ្លះ បានក្ស័យធន និងខ្លះទៀត មិនត្រូវការរើសកម្លាំងពលកម្មបន្ថែម ឬថៅកែមិនហ៊ានទទួលយកអ្នកឆ្លងដែនខុសច្បាប់ជាដើម។

យុវជនខេត្តកំពង់ធំម្នាក់ លោក អ៊ី ព្រីង និយាយថា លោកកំពុងពិចារណាទៅរកការងារធ្វើនៅប្រទេសថៃវិញ ព្រោះត្រឡប់មកដល់កម្ពុជាច្រើនខែហើយ តែលោកគ្មានមុខរបរ គ្មានប្រាក់ចំណូលនោះទេ។ យុវជនវ័យ ៣២ ឆ្នាំរូបនេះ ចង់បានការងារធ្វើសមរម្យនៅក្នុងស្រុកជាងចំណាកស្រុក។ ប៉ុន្តែលោកថា នៅក្នុងស្រុកមិនសម្បូរការងារធ្វើ និងប្រាក់ឈ្នួលទាប មិនគ្រប់សម្រាប់ផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃ និងសងបំណុលធនាគារ៖ «*ថាចង់ត្រឡប់ទៅ*

*(ថៃ)វិញបង។ នៅខ្មែរ ខ្ញុំអត់ទាន់មានមុខរបរខ្លួនឯង។ ខ្ញុំគិតថាទៅវិញ ទៅរកស៊ីពីឆ្នាំអ្វីទៀត ក្រែងរកលុយបាន មកបង្កើតមុខរបរខ្លួនឯងបាន»។*

ប្រធានមូលនិធិពលករខ្មែរប្រចាំប្រទេសថៃលោក ស៊ុន សីហា ឲ្យដឹងថា ពលករជាច្រើនកំពុងទាក់ទងគ្នីគ្នា ឲ្យជួយរកការងារនៅស្រុកថៃឲ្យធ្វើ អាលនឹងពួកគាត់លួចឆ្លងដែនចូលមកប្រទេសថៃបន្ត។ លោក ស៊ុន សីហា ជំរុញឲ្យរដ្ឋាភិបាលបង្កើតការងារក្នុងស្រុកឲ្យពលករធ្វើ ប្រសើរជាងការបិទខ្ទប់ព្រំដែន ឬការចាប់ឃាត់ពលរដ្ឋនៅព្រំដែន៖ *«រដ្ឋាភិបាលគួរតែពន្លឿនចាក់វ៉ាក់សាំង ហើយចរចាដើម្បីបើកព្រំដែនជាធម្មតាទៅ ហើយរៀបចំឯកសារស្របច្បាប់ឲ្យពលករជៀសវាងក្នុងការគាត់ចាញ់បោកមេខ្យល់ ឬក៏គាត់មកផ្លូវកាត់ខុសច្បាប់ ធ្វើឲ្យគាត់មានបញ្ហាប្រឈមជនអន្តោប្រវេសន៍ខុសច្បាប់ហ្នឹង។ ពិបាកការពារសិទ្ធិរបស់គាត់ផង ហើយនឹងគាត់ប្រឈមបញ្ហាផ្សេងៗពីខាងថៅកែ ឬក៏និយោជក»។*

ជុំវិញករណីនេះ វិទ្យុអាស៊ីសេរីមិនអាចសុំការបញ្ជាក់ពីអ្នកនាំពាក្យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ លោក ហេង សួរ និងអ្នកនាំពាក្យទីស្តីការគណៈរដ្ឋមន្ត្រី លោក ផៃ ស៊ីផាន បានទេ នៅថ្ងៃទី២២ ខែកញ្ញា។ កាលពីខែកក្កដា ឆ្នាំ២០២០ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានសន្យាផ្តល់ទុន និងបង្រៀនបច្ចេកទេសចិញ្ចឹមត្រីដល់ពលករបាត់បង់ការងារធ្វើ។

លោក ហ៊ុន សែន បានបញ្ជាឲ្យរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បន្ថែមថវិការដ្ឋប្រាំលាន(៥លាន) ដុល្លារសម្រាប់ជួយឲ្យកម្មករ និងពលករ ឱ្យងាកមកប្រកបមុខរបរចិញ្ចឹមត្រីវិញ ហើយរដ្ឋនឹងផ្តល់កូនត្រីសម្រាប់ចិញ្ចឹមត្រី និងការជួយបង្ហាត់បង្រៀនពីរបៀបចិញ្ចឹមត្រីដល់ពួកគេ។ ប៉ុន្តែក្រៅពីការបញ្ជាផ្ទាល់មាត់ហើយនោះ ប្រមុខរដ្ឋាភិបាលមិនបានដាក់ចេញផែនការសកម្មភាពអ្វីជាក់លាក់នោះទេ ក្រៅពីការស្នើសុំឲ្យថៃទទួលយកពលករខ្មែរឲ្យចូលទៅធ្វើការនៅប្រទេសថៃវិញនោះ។

កាលពីខែតុលា ឆ្នាំ២០២០ ក្រសួងការបរទេសខ្មែរ និងស្ថានទូតប្រចាំទីក្រុងបាងកក បានស្នើសុំឲ្យរដ្ឋាភិបាលថៃ ទទួលយកពលករកម្ពុជាកាន់ប័ណ្ណឆ្លងព្រំដែន(borderpasses)និងពលករចុះឈ្មោះធ្វើការតាមប្រព័ន្ធអនុស្សរណៈយោគយល់គ្នា (MOU) ដើម្បីអាចពួកគេវិលត្រឡប់ចូលទៅធ្វើការនៅប្រទេសថៃវិញ និងស្នើសុំឲ្យបញ្ចុះថ្លៃទិដ្ឋាការ និងថ្លៃធ្វើចត្តាឡីស័កជាដើម។

គិតចាប់តាំងពីខែមីនា រហូតដល់ខែកក្កដា ពលករខ្មែរជាងមួយសែននាក់ (១០៣.០០០ នាក់) បានវិលត្រឡប់ពីថៃមកកម្ពុជាវិញ។ ក្រុមអ្នកឃ្លាំមើលយល់ថា ក្នុងស្ថានភាពនេះ រដ្ឋាភិបាលគួរជួយផ្គត់ផ្គង់ផ្នែកជីវភាព និងត្រូវបង្កើនមុខរបរក្នុងវិស័យកសិកម្មក្នុងស្រុកឲ្យពលករធ្វើ ទើបអាចទប់ស្កាត់លំហូរពលរដ្ឋខ្មែរ ឆ្លងដែនទៅរកការងារធ្វើនៅប្រទេសថៃវិញ៕

## ឈប់បានឈប់ទៅ! ពលករនិងមេខ្យល់៤នាក់ បម្រុងឆ្លងដែនខុសច្បាប់ទៅថៃ ត្រូវកម្លាំងការពារព្រំដែនឃាត់ខ្លួន

https://kbn.news/ September 24, 2021

បន្ទាយមានជ័យ៖ កម្លាំងកងការពារព្រំដែនលេខ៥០៣ និងអង្គភាពចំណុះកងអនុសេនាធំល្បាតទី៤ បានធ្វើការឃាត់ចំនួនខ្លួន២ករណីក្នុងនោះពលករនិងមេខ្យល់ចំនួន៤នាក់បម្រុងលួចឆ្លងដែនខុសច្បាប់ទៅប្រទេសថៃ។ ករណីទី១នៅវេលាម៉ោង ៦:០០នាទី ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២១ ខណៈពេលដែលពួកពលករនិងមេខ្យល់បម្រុងលួចឆ្លងដែនដោយខុសច្បាប់ដោយ មានចំនួន ៣នាក់ ក្នុងនោះមានស្រីម្នាក់ មេខ្យល់ម្នាក់និងម៉ូតូ១គ្រឿងម៉ាកហុងដាឌ្រីម ស៊េរីឆ្នាំ២០១៤ ពាក់ស្លាកលេខ ប.មានជ័យ 1L-9370 ស្ថិតនៅក្នុងភូមិសាស្រ្ត ភូមិខ្វាវលិច ឃុំស្វាយចេក ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ។ ករណីទី២នៅវេលាម៉ោង១៥:១៥នាទី រសៀលថ្ងៃទី២២ ខែកញ្ញា ឆ្នាំ

២០២១ កម្លាំងបានពួនស្ទាក់ចាប់បានមេខ្យល់ដឹកអីវ៉ាន់ឲ្យពលករដែលលួចឆ្លង ដែនដោយខុសច្បាប់បានម្នាក់ទៀត និងរ៉ឺម៉កម៉ូតូ១គ្រឿងម៉ាកវ៉េវ ស៊េរីឆ្នាំ២០២០ ពណ៌ ក្រហមខ្មៅអត់មានស្លាកលេខ និងដកហូតបានវត្ថុតាង១ចំនួន ស្ថិតនៅក្នុងភូមិសាស្រ្តដដែល។

សូមបញ្ជាក់ថាខណៈកងកម្លាំងកំពុងល្បាតក៏បានជួបពលករបម្រុងលួចឆ្លងដែនដោយប្រើមធ្យោបាយជិះម៉ូតូឌុបគ្នាដល់ចំណុចខាងលើក៏ត្រូវបានកងកម្លាំងឃាត់ខ្លួនបានតែម្តង។ ក្រោយពីឃាត់ខ្លួន កងកម្លាំងក៏បានណែនាំដល់បងប្អូនប្រជាពលរដ្ឋកុំឲ្យបន្តចាញ់ បោកមេខ្យល់ដែលតែងតែបញ្ចុះបញ្ចូលនាំពលករ ឆ្លងដែនដោយខុសច្បាប់ដោយមិនគិតពីសុខសុវត្ថិភាព និងខាតបង់ប្រាក់កាសជាបន្តបន្ទាប់ ជាពិសេសសូមបន្តចូលរួមអនុវត្តវិធានការ ៣ការពារ ៣កុំ ឲ្យបានទាំងអស់គ្នាដើម្បីគ្រួសារ និងសង្គមជាតិ។ បច្ចុប្បន្នពកលករទាំង២នាក់ ត្រូវបានបញ្ជូនទៅឲ្យក្រុមការងារចម្រុះប្រកអូរបីជាន់ដើម្បីបញ្ជូនទៅមណ្ឌលចត្តាឡីស័ក។ ចំពោះមេខ្យល់២នាក់ ម៉ូតូ ចំនួន១គ្រឿង និងអីវ៉ាន់របស់ពលករ អង្គភាពបានប្រគល់ទៅឲ្យកម្លាំងកងរាជអាវុធហត្ថខេត្តបន្ទាយមានជ័យ បន្តស្រាវជ្រាវរកអ្នកពាក់ព័ន្ធដើម្បី ចាត់វិធានការតាមផ្លូវច្បាប់ ដោយឡែករ៉ឺម៉កម៉ូតូរក្សាទុកនៅអង្គភាព៕

## ទាហានឈុតខ្មៅថៃចាប់ខ្លួនពលករខ្មែរ១៤នាក់ បន្ទាប់ពីលួចឆ្លងដែនខុសច្បាប់

https://www.kampucheathmey.com/ ថ្ងៃសុក្រ ២៤ កញ្ញា ២០២១ដោយ Sokhom Khon

ពលករខ្មែរចំនួន១៤នាក់ ត្រូវបានក្រុមទាហានឈុតខ្មៅថៃ ក្នុងកងវរយលេខ១២ ចាប់ខ្លួន ខណៈដែលពួកគេលបឆ្លងដែនដោយខុសច្បាប់ ដើម្បីចូលទឹកដីថៃរកការងារធ្វើនៅក្នុងខេត្តចំនួនពីរនាទឹកដីថៃ។ ការឃាត់ខ្លួននេះបានធ្វើឡើងកាលពីព្រឹកថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២១ វេលាម៉ោង១រសៀល ត្រង់ចំណុចភូមិប៉ាវ៉ែម៉ េ ក្នុងឃុំប៉ាវ៉ែ ស្រុកអារញ្ញប្រាថេត ខេត្តស្រះកែវ ប្រទេសថៃ ។

នៅមុនពេលឃាត់ខ្លួនគឺមានពលករខ្មែរចំនួន១៤នាក់ បានលបឆ្លងព្រំដែនចូលទៅក្នុងទឹកដីថៃ ដោយនាំគ្នាដើរកាត់តាមចម្ការអំពៅ ស្របពេលដែលកម្លាំងទាហានឈុតខ្មៅថៃកំពុងល្បាតក៏បានស្ទាក់ចាប់ ក្នុងនោះប្រុស៤នាក់ ស្រី៥នាក់ ក្មេងប្រុស៣នាក់ និងក្មេងស្រី២នាក់ ។ ក្រោយការចាប់ខ្លួនពលករខ្មែរបានសារភាពថា ពួកគេទាំងអស់គ្នាមានបំណងចូលទៅរកការងារធ្វើ ជាកម្មករសំណង់ ដោយខ្លះចង់ទៅខេត្តឆៈឈើងសៅ និងខ្លះទៀត ចង់ទៅធ្វើនៅខេត្ត សមុទ្រប្រាកាន ។ ក្រោយពេលឃាត់ខ្លួន ក្រុមយោធាថៃបានត្រួតពិនិត្យសុខភាពពួកគេទាំងអស់ដើម្បីការពារនៅក្នុងដំណាក់កាលនៃជំងឺកូវីដ-១៩ ដែលកំពុងរាតត្បាត និងបានបញ្ជូនទៅអោយអធិការដ្ឋានតម្រួត ស្រុកអារញ្ញប្រាថេត ដើម្បីអនុវត្តតាមនីតិវិធី៕ អត្ថបទ៖ សោ និយមរ័ត្ន

## មន្រ្តីកម្ពុជាសង្រ្គោះស្រ្តីម្នាក់ ពីការធ្វើបាបរបស់គ្រួសារខាងប្តីនៅចិន

https://www.postkhmer.com/ ឡាយ សាមាន | Publication date 24 September 2021 | 11:10 ICT

**ភ្នំពេញៈ** ស្រ្តីជនជាតិខ្មែរ ១ រូប ដែលបានទៅរស់នៅតាមស្វាមីនៅប្រទេសចិន ប៉ុន្តែត្រូវរងការធ្វើបាបពីសំណាក់ក្រុមគ្រួសារនេះត្រូវបានមន្ត្រីជំនាញកម្ពុជាជួយសង្គ្រោះយកដាក់នៅកន្លែងមានសុវត្ថិភាព ហើយដើម្បីត្រៀមបញ្ជូនត្រឡប់មកស្រុកខ្មែរវិញ។ ស្ត្រីជាជនរងគ្រោះ ឈ្មោះ អាត់ សុភ័ក្រ អាយុ ២៥ ឆ្នាំ ដែលមានទីកំណើតនៅស្រុកសំរោងទង ខេត្តកំពង់ស្ពឺ កាលពីពេលថ្មីៗនេះបានខ្ចីទូរស័ព្ទពីអ្នកជិតខាងនៅចិន ដើម្បីបង្ហោះវីដេអូដង្ហោយរកការជួយសង្គ្រោះពីរាជរដ្ឋាភិបាលកម្ពុជា បន្ទាប់ពីគាត់ត្រូវបានខាងគ្រួសារខាងប្តីធ្វើបាបយ៉ាងដំណំ។ ក្នុងវីដេអូដែលបានបង្ហោះលើបណ្តាញសង្គម TikTok រយៈពេលជាង ២ នាទី បានរៀបរាប់ថា៖ «សូមបងប្អូនជួយសូមឱ្យសម្តេច [ហ៊ុន សែន] ជួយខ្ញុំឱ្យបានទៅខ្មែរវិញផង ខ្ញុំនៅទីនេះ (ទីក្រុង Nanchang ខេត្ត Jiangxi ប្រទេសចិន) ប្តីខ្ញុំធ្វើបាបខ្លាំងណាស់ ខ្ញុំអត់បានទាក់ទងទៅគ្រួសារ ៤ ឆ្នាំហើយ»។ តាមរយៈវីដេអូនេះនាងបានរៀបរាប់ទាំងទឹក

មុខក្រៀមក្រំថា នាងរស់នៅពុំមានក្ដីសុខនោះទេដោយក្រុមគ្រួសារទាំងម៉ែក្មេក ឪក្មេក និងប្ដីវាយធ្វើបាប ហើយបញ្ជូនឱ្យទៅធ្វើស្រែចម្ការ ហើយបានរលូតកូន ៣ ដងទៀតផង។

លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្សបានប្រាប់ភ្នំពេញប៉ុស្តិ៍ពីថ្ងៃទី ២២ ខែកញ្ញាថា ភាគីកម្ពុជានៅមិនបានជួយសង្គ្រោះស្ត្រីនោះទៅកន្លែងមានសុវត្ថិភាពហើយ បន្ទាប់ពីទទួលដំណឹងនេះភ្លាម។ លោកស្រីថា៖ «នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជននៃក្រសួងមហាផ្ទៃបានទាក់ទងទៅភាគីចិន និងបានស្វែងរកទីតាំងដែលស្ត្រីនោះរស់នៅតាមរយៈឪពុកម្ដាយដែលរស់នៅស្រុកខ្មែរ ឥឡូវនេះបានរកឃើញហើយ ចំណែកស្ត្រីនោះត្រូវបានយកទៅរក្សាទុកនៅប៉ុស្តិ៍ប៉ូលិសនៅក្រុងប៉េកាំង ដើម្បីសួរព័ត៌មាន និងធ្វើចត្តាឡីស័ក»។ លោកស្រីបន្តថា បន្ទាប់បញ្ចប់ធ្វើចត្តាឡីស័កនៅទីនោះ ភាគីប៉ូលិសចិននឹងជូនដំណឹងមកស្ថានទូតកម្ពុជាប្រចាំប្រទេសចិនដើម្បីត្រៀមបញ្ជូនស្ត្រីរងគ្រោះមកកម្ពុជាវិញឆាប់ៗនេះ។

ទន្ទឹមនេះដែរ លោកស្រី ជូ ប៊ុនអេង បានបន្តអំពាវនាវដល់ពលរដ្ឋខ្មែរមួយចំនួនឱ្យប្រុងប្រយ័ត្នខ្ពស់ចៀសវាងចាញ់បោកមេខ្យល់ដែលនាំឱ្យគ្រោះថ្នាក់ដល់ជីវិត។ លោកស្រីថា៖ «យើងបានផ្សព្វផ្សាយច្រើនហើយតាមរយៈការចុះអប់រំ ផ្សព្វផ្សាយតាមបណ្ដាញសារព័ត៌មានរឿងចាញ់បោកមេខ្យល់ យើងមិនចង់ឱ្យស្រីខ្មែរគិតថាមានភាពងាយស្រួលដែលទៅក្រៅប្រទេសនោះទេ»។ លោកស្រីបន្តថា៖ «គាត់តែងប្រើពាក្យថាគាត់ចាញ់បោកគេ ប៉ុន្តែអ្វីដែលគាត់និយាយវាហួសពេលហើយ ព្រោះគាត់បានរងគ្រោះរួចបាត់ទៅហើយ អ៊ីចឹងបទពិសោធទាំងនេះ យើងចង់ឱ្យអ្នកដទៃដែលមិនទាន់ចាញ់បោក ឱ្យគាត់រៀនសូត្រព្រោះដឹងហើយថាមានអ្នកដែលទៅក្រៅប្រទេស មិនមែនសុទ្ធតែបានសេចក្តីសុខទេ...»។ លោកស្រី ជូ ប៊ុនអេង បានផ្ដាំផ្ញើថា ការដែលធ្វើប្រថុយទៅធ្វើជាប្រពន្ធគេនៅបរទេស គឺគ្រាន់តែជាការចាញ់បោកមេខ្យល់ដែលបាន និងកំពុងកេងចំណេញប្រយោជន៍ពីពលរដ្ឋខ្មែរប៉ុណ្ណោះ។ លោកស្រីបញ្ជាក់ថា៖ «ពាក្យថាធ្វើជាប្រពន្ធគេ គឺជាអ្នកដែលត្រូវបានគេប្រើប្រាស់មួយជីវិតអត់មានប្រាក់បៀវត្សរ៍ទេ ហើយក៏គ្មានការធានាដែរពីព្រោះគេត្រូវអនុវត្តច្បាប់គ្រួសារដូចនៅប្រទេសចិនគេមានច្បាប់គ្រួសារ អ៊ីចឹងក្នុងគ្រួសារការស្តីប្រដៅដែរ វ៉ៃជារឿងធម្មតារបស់គេ»។

នាយកប្រតិបត្តិមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (Central) លោក មឿន តុលា បានថ្លែងថាមានកត្តា ២ ដែលធ្វើឱ្យពលរដ្ឋខ្មែរខ្លះនៅបន្តចាញ់បោកមេខ្យល់គឺកត្តាជំរុញ និងកត្តាទាក់ទាញ។ ក្នុងនោះកត្តាជំរុញដោយសារភាពក្រីក្រការងារមិនទៀងទាត់ ជំពាក់បំណុលមិនមានការងារធ្វើ ឬមិនមានមុខរបរគ្រប់គ្រាន់ជាដើម។ រីឯកត្តាទាក់ទាញគឺមេខ្យល់ដែលបោកស្ត្រីខ្មែរទៅធ្វើការ ឬការប្ដីនៅចិនពួកគេបានបញ្ចុះបញ្ចូលថាទៅប្រទេសចិននឹងមានលុយកាក់ច្រើន។ លោកថា៖ «តាមពិតទៅភាគច្រើនដែលយើងសម្ភាសស្ត្រីរងគ្រោះគឺគាត់មិនមែនទាក់ទងផ្ទាល់ទៅចិនទេគឺមានមេខ្យល់មកលួងលោមថាទៅរកការងារនៅចិន ហើយមេខ្យល់ទៀតសោតបានបង្ហាញភាពហ៊ឺហាថា មានស្ត្រីខ្មែរច្រើនទៅធ្វើការ ឬការប្ដីចិនសល់លុយពេលត្រឡប់មកស្រុកវិញ»។ លោកបន្តថាការជួយស្ត្រីរងគ្រោះពីភាគីកម្ពុជាជារឿងល្អ ប៉ុន្តែលោកជំរុញរាជរដ្ឋាភិបាលកម្ពុជាឱ្យបង្កើនការផ្សព្វផ្សាយ និងអប់រំបន្ថែមទៀតដើម្បីឱ្យពលរដ្ឋទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយ។ លោកថា៖ «ខ្ញុំមើលទៅរដ្ឋាភិបាលលោកបានព្យាយាមផ្សព្វផ្សាយខ្លះដែរ ប៉ុន្តែហាក់បីដូចជានៅមានកម្រិតនៅឡើយទេអ៊ីចឹងគួរតែផ្សព្វផ្សាយព័ត៌មានឱ្យដល់សហគមន៍ អ៊ីចឹងពេលគាត់ទទួលព័ត៌មានបានគាត់នឹងមានការប្រុងប្រយ័ត្នខ្ពស់»៕

## ឃាត់ខ្លួនពលករខ្មែរ ១៥នាក់ បម្រុងឆ្លងដែនខុសច្បាប់ទៅថៃ

https://kohsantepheapdaily.com.kh/ ២៤ ខែ កញ្ញា ឆ្នាំ ២០២១ ម៉ោង ១៤:៤០

ខេត្តបន្ទាយមានជ័យ ៖ ពលករខ្មែរឆ្លងដែនទៅប្រទេសថៃ ចំនួន១៥នាក់ ក្នុងនោះស្រី ៩នាក់ និងគោយន្តកន្ត្រៃ ១គ្រឿង បម្រុងឆ្លងដែនទៅធ្វើការនៅប្រទេសថៃ ត្រូវបានកម្លាំងតំបន់ប្រតិបត្តិការសឹករងបន្ទាយមានជ័យ ឃាត់ខ្លួន វេលាម៉ោង០៩យប់ ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២១ ត្រង់ភូមិសាស្រ្ត អូរព្រំដែន ភូមិប្រាសាទត្បែង ឃុំបន្ទាយឆ្មារ ស្រុកមថ្មពួក ខេត្តបន្ទាយមានជ័យ ។

ដោយអនុវត្តតាមបទបញ្ជារបស់មេបញ្ជាការ លោកវរសេនីយ៍ឯក កែវ ស៊ីថា មេបញ្ជាការរងតំបន់ប្រតិបត្តិការសឹករងបន្ទាយមានជ័យ ទទួលទិសថ្មពួក បានដឹកនាំកម្លាំងល្បាតជាប់ជាប្រចាំ ២៤ម៉ោង លើ២៤ម៉ោង ដោយប្តូរវេនគ្នា សហការជាមួយកម្លាំងនគរបាលការពារព្រំដែនគោកលេខ៨០៧ ដើម្បីទប់ស្កាត់ពលករលួចឆ្លងដែនខុសច្បាប់ និងទប់ស្កាត់ការឆ្លងរាលដាល នៃជំងឺកូវីដ-១៩ មិនឲ្យចូលទៅក្នុងសហគមន៍។ ជាក់ស្តែង នៅព្រឹកថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២១ លោកនាយចំណង់ ឆាត ឆាន់ មេក្រុមគោលដៅ ដឹកនាំកម្លាំងដើរល្បាតក៏ជួបពលករខ្មែរដែលបម្រុងឆ្លងដែនចេញទៅប្រទេសថៃ ត្រូវបានកម្លាំងតំបន់ប្រតិបត្តិការសឹករងខេត្ត បន្ទាយមានជ័យ ឃាត់ខ្លួនបានតែម្តង ។

សូមបញ្ជាក់ថា ចាប់តាំងពីកងកម្លាំងតំបន់ប្រតិបត្តិការសឹករងខេត្ត ត្រូវបានបញ្ជូនទៅបំពេញប្រតិបត្តិការសហការជាមួយកម្លាំងចម្រុះទប់ស្កាត់ពលករលួចឆ្លងដែន និងទប់ស្កាត់ការឆ្លងរីករាលដាល នៃជំងឺកូវីដ-១៩ បានឃាត់ខ្លួនពលករឆ្លងដែនបញ្ជូនទៅមណ្ឌលចត្តាឡីស័កជាបន្តបន្ទាប់ និងឃាត់ខ្លួនមេខ្យល់បានមួយចំនួន បញ្ជូនទៅសមត្ថកិច្ចជំនាញចាត់វិធានការតាមផ្លូវច្បាប់ ។ ចំណែកពលករទាំង ១៥នាក់ ក្រោយពីបានសួរនាំរួច ត្រូវបានប្រគល់អោយ ស្នាក់ការកងរាជអាវុធហត្ថ ចាត់ការតាមនីតិវិធីច្បាប់បន្ត ៕

## ស្នងការនគរបាលខេត្តព្រះសីហនុ
## បញ្ជាក់ពីប្រតិបត្តិការបង្ក្រាបករណីជួញដូរមនុស្សខុសច្បាប់ នៅក្នុងកាស៊ីណូហ្គោលដិនរើល៣, ឃាត់ជនជាតិចិន៣នាក់ ថៃម្នាក់ និងរកឃើញជនជាតិថៃខុសច្បាប់៣៦នាក់

http://freshnewsasia.com/ 2021-09-24 03:09pm

**(ព្រះសីហនុ)៖** លោកឧត្តមសេនីយ៍ទោ ជួន ណារិន្ទ ស្នងការនគរបាលខេត្តព្រះសីហនុ បានបញ្ជាក់ប្រាប់បណ្តាញព័ត៌មាន Fresh News នៅព្រឹកថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០២១នេះ កម្លាំងនគរបាលបានបើកប្រតិបត្តិការស្រាវជ្រាវ នៅកាស៊ីណូហ្គោលដិនរើល៣ ដោយរកឃើញជនជាតិថៃ ចំនួន៣៦នាក់ (ស្រី១០នាក់) ដែលមេខ្យល់នាំឆ្លងដែនដោយខុសច្បាប់ (ស្នាក់នៅកាស៊ីណូហ្គោលដិនរើល៣) ស្ថិតនៅភូមិ១ សង្កាត់៣ ក្រុង/ខេត្តព្រះសីហនុ។ លោកឧត្តមសេនីយ៍ទោ ជួន ណារិន្ទ បានបន្តថា កម្លាំងនគរបាលក៏បានចាប់ខ្លួនមេខ្យល់ចំនួន៤នាក់ ក្នុងនោះជនជាតិចិន ចំនួន៣នាក់ និងជនជាតិថៃម្នាក់ ដែលជាអ្នកនាំជនជាតិថៃទាំង៣៦នាក់ខាងលើនេះ ចូលមកប្រទេសកម្ពុជា ដោយខុសច្បាប់។

សូមបញ្ជាក់ថា ប្រតិបត្តិការចុះបង្ក្រាបនេះ បានធ្វើឡើងក្រោយពីមានព័ត៌មាន ចុះផ្សាយថាជនជាតិថៃទាំង៣៦នាក់ខាងលើនេះ ត្រូវបានគេចាប់បង្ខាំង និងធ្វើទារុណកម្មនៅក្នុងកាស៊ីណូគោលដិនរើល៣។ ភ្លាមៗក្រោយពីទទួលបានព័ត៌មាននេះ លោក គួច ចំរើន អភិបាលខេត្តព្រះសីហនុ បានចាត់ចែងក្រុមគ្រូពេទ្យចុះយកសំណាកធ្វើតេស្តទាំងអស់ជាបន្ទាន់ ក៏បានរកឃើញអ្នកវិជ្ជមានជំងឺកូវីដ១៩ ប្រភេទ Delta ចំនួន៥នាក់ ស្រី១នាក់ និងយកទៅ

ព្យាបាលនៅ សណ្ឋាគារសាកាណា៣។ ចំណែកជនជាតិថៃ ចំនួន៣១នាក់ ដែលមិនមានវិជ្ជជំងឺកូវីដ១៩ ត្រូវបានដាក់ឱ្យធ្វើចត្តាឡីស័ក នៅកន្លែងនោះដើម្បីតាមដានបន្ត។

បើតាមលោកស្នងការ កម្លាំងជំនាញបានបន្តស្រាវជ្រាវរកឃើញអ្នកពាក់ព័ន្ធដែលនាំជនជាតិថៃ ខាងលើចូលមកដោយខុសច្បាប់ចំនួន៤នាក់ (ចិន៣នាក់ និងថៃម្នាក់) ហើយបានកសាងសំណុំរឿងបញ្ជូនទៅសាលាដំបូងខេត្ត ដើម្បីអនុវត្តន៍តាមនីតិវិធីច្បាប់រួចរាល់ហើយ៕

## ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២១

## ទីប្រឹក្សាសម្តេចតេជោ ស្នើប្រធានរដ្ឋសភាថៃផ្តល់ការគាំពារសិទ្ធិ និងសុវត្ថិភាពជូនពលករខ្មែរ

http://freshnewsasia.com/ 2021-09-24 05:26pm

(បាងកក, ថៃ)៖ លោកបណ្ឌិត សុខ សុក្រឹត្យា ទីប្រឹក្សាផ្ទាល់សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្រ្តីកម្ពុជា បានស្នើប្រធានរដ្ឋសភាថៃ លោក ឈួន លីកផៃ ឱ្យផ្តល់ការគាំពារសិទ្ធិ និងសុវត្ថិភាពឱ្យបានខ្ពស់ជូនពលករខ្មែរ ដែលកំពុងបំពេញការងារនៅក្នុងប្រទេសថៃ។ សំណើរបស់លោក សុខ សុក្រឹត្យា បានធ្វើឡើងក្នុងពេលលោកចូលជួបសម្តែងការគួរសម និងសំណេះសំណាលការងារមួយចំនួនជាមួយលោក ឈួន លីកផៃ ដែលជាអ្នកនយោបាយជើងចាស់ និងជាអតីតនាយករដ្ឋមន្រ្តីថៃ។ ក្នុងជំនួបនោះ លោកបណ្ឌិត សុខ សុក្រឹត្យា បានពាំនាំនូវការផ្តាំផ្ញើសួរសុខទុក្ខ និងក្តីនឹករលឹករបស់សម្តេចតេជោ ហ៊ុន សែន ជូនចំពោះលោក ឈួន លីកផៃផងដែរ។ ដោយសារប្រទេសថៃប្រជាពលរដ្ឋខ្មែរជាច្រើនកំពុងបំពេញការងារនោះ លោកបណ្ឌិត សុខ សុក្រឹត្យា បានស្នើប្រធានរដ្ឋសភាថៃផ្តល់ការគាំពារ លើកម្ពស់សិទ្ធិ និងផ្តល់សុវត្ថិភាពឱ្យបានខ្ពស់ជូនពលករខ្មែរ និងបានស្នើឱ្យមានការចាក់វ៉ាក់សាំងជូនពលករខ្មែរផងដែរ។

ឆ្លើយតបសំណើនេះ លោក ឈួន លីកផៃ បានបញ្ជាក់ថា រាជរដ្ឋាភិបាលថៃ តែងតែយកចិត្តទុកដាក់រាល់ពលករកំពុងធ្វើការងារនៅក្នុងប្រទេសថៃ រួមទាំងពលករខ្មែរផងដែរ។ នាពេលកន្លងមក រដ្ឋសភាថៃ បានខិតខំលើកយករបៀបវារៈស្តីពីពលករចំណាកស្រុកមកពិភាក្សាក្នុងកិច្ចប្រជុំ និងបានជំរុញរាជរដ្ឋាភិបាលថៃ ឱ្យបន្តការយកចិត្តទុកដាក់ផ្តល់ការគាំពារ លើកកម្ពស់សិទ្ធិ និងផ្តល់សុវត្ថិភាពការងារ និងការរស់នៅជូនពលករចំណាកស្រុកជាប្រចាំ។ បន្ថែមពីលើនោះ រដ្ឋសភាថៃ តែងបានបានយកចិត្តទុកដាក់ជំរុញសកម្មភាពពាណិជ្ជកម្មកម្ពុជា-ថៃ ដែលមិនអាចខ្វះបានក្នុងនាមប្រទេសជិតខាង និងជាសមាជិកក្នុងសហគមន៍អាស៊ានតែមួយ។

លោកបណ្ឌិត សុខ សុក្រឹត្យា ក៏បានថ្លែងអំណរគុណជាអនេក ចំពោះប្រធានសភាថៃ ដែលបានបង្ហាញនូវការយកចិត្តទុកដាក់ខ្ពស់ទៅលើការគាំពារសិទ្ធិនិងសុវត្ថិភាពជូនពលករខ្មែរ។ ក្នុងជំនួបដ៏កម្រជាមួយអ្នកនយោបាយចាស់វស្សារបស់ថៃនេះ លោកបណ្ឌិត សុខ សុក្រឹត្យា ក៏បានជម្រាបអំពីភាពជោគជ័យក្នុងការដឹកនាំ និងកសាងប្រទេសរបស់សម្តេចតេជោ ហ៊ុន សែន ដែលបាន ដែលបានធ្វើឱ្យប្រទេសជាតិមានសុខសន្តិភាពពេញលេញ ស្ថិរភាពនយោបាយ និងសេដ្ឋកិច្ច-សង្គម។ លោកបណ្ឌិត ក៏បានជម្រាបពីភាពជោគជ័យលើការប្រយុទ្ធប្រឆាំងជំងឺកូវីដ១៩ ជាពិសេសការសម្រេចបាននូវការចាក់វ៉ាក់សាំងជូនប្រជាពលរដ្ឋបាន ៨០ភាគរយ ធៀបនឹងប្រជាពលរដ្ឋសរុប ដែលបង្កើតបាននូវខឿនការពារសុខភាពជូនប្រជាពលរដ្ឋកាន់តែប្រសើរពីការរាតត្បាតជំងឺកូវីដ១៩។

លោក ឈួន លីកផៃ បានសម្តែងការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះរាជរដ្ឋាភិបាលកម្ពុជា ដែលមានសម្តេចតេជោ ហ៊ុន សែន ជាប្រមុខដឹកនាំប្រកបដោយភាពឈ្លាសវៃ និងមានវិធានការច្បាស់លាស់ក្នុងការដោះស្រាយវិបត្តិកូវីដ-១៩ នៅកម្ពុជា។ ពាក់ព័ន្ធទំនាក់ទំនង និងចំណងមិត្តភាពកម្ពុជា-ថៃវិញ លោក ឈួន លីកផៃ បានបង្ហាញរូបថតអនុស្សាវរីយ៍ចំនួន ២សន្លឹករបស់លោកកាលនៅជានាយករដ្ឋមន្រ្តីថៃ ដែលបានថតជាមួយសម្តេចព្រះ

មហាវិរៈក្សត្រ នរោត្តម សីហនុ និងសម្តេចតេជោនាយករដ្ឋមន្ត្រី ក្នុងពេលលោកបំពេញបេសកកម្មផ្លូវការនៅកម្ពុជា។ លោកក៏បានរំលឹកពីចំណងទំនាក់ទំនងល្អប្រសើរមួយចំនួនរវាងលោក និងសម្តេចតេជោផងដែរ។

ក្នុងជំនួបនេះលោកប្រធានរដ្ឋសភាជាតិថៃ ក៏បានកោតស្ញប់ស្ញែងអំពីសក្តានុពលទេសចរណ៍ដែលមិនចេះរីងស្ងួតរបស់កម្ពុជា ដែលមានធនធានធម្មជាតិ និងបេតិកភណ្ឌវប្បធម៌ដ៏សម្បូរបែប និងបានជូនជាយោបល់ឱ្យលោកបណ្ឌិត សុខ សុក្រឹត្យា ចុះដកបទពិសោធន៍ជាក់ស្តែងបន្ថែមទៀតអំពីការរៀបចំ និងគ្រប់គ្រងតំបន់ទេសចរណ៍នានាក្នុងប្រទេសថៃ សម្រាប់យកទៅរៀបចំយុទ្ធសាស្ត្រកំណែទម្រង់វិស័យទេសចរណ៍នៅកម្ពុជានាពេលខាងមុខ។ លោក ឈួន លីកផៃ បានសន្យាបន្តរក្សា និងជំរុញទំនាក់ទំនងល្អរវាងកម្ពុជា-ថៃ ឱ្យកាន់តែរឹងមាំទាំងរវាងរដ្ឋ ប្រជាជន និងវិស័យឯកជន តាមរយៈការពង្រឹង និងការគោរពគោលការណ៍លទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋរវាងប្រទេសទាំងពីរ៕

## ស្ត្រីខ្មែរម្នាក់ ដែលបានចាញ់បោកមេខ្យល់ នាំទៅប្រទេសចិន ក្រោមរូបភាពរៀបការជាមួយជនជាតិចិន មានសុវត្ថិភាព ឯមេខ្យល់ត្រូវឃុំខ្លួន

https://cen.com.kh/ Posted ByPen Srey Neat September 25, 2021

ភ្នំពេញ ៖ កាលពីថ្ងៃទី ២១ ខែកញ្ញា ឆ្នាំ២០២១ ក្រុមការងារប្រតិកម្មរហ័សអគ្គស្នងការដ្ឋាននគរបាលជាតិ បានពិនិត្យឃើញព័ត៌មាន លើបណ្តាញទំនាក់ទំនងសង្គមបង្ហោះកាលពីថ្ងៃទី៤ ខែមីនា ឆ្នាំ២០២១ ដែលមានខ្លឹមសារថា ″ ក្មេងស្រីម្នាក់ឈ្មោះ អ៊ែន សុខជី អាយុ ១៥ ឆ្នាំ បានស្នើសុំសម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា ជួយសង្គ្រោះនាងពីប្រទេសចិនផង ដោយនាងបានចាញ់បោកមេខ្យល់ និងកំពុងរស់នៅយ៉ាងវេទនា ។ ព័ត៌មាននេះត្រូវបានគេបង្ហោះសារជាថ្មីម្តងទៀត និងចែកចាយលើបណ្តាញទំនាក់ទំនងសង្គម។

បន្ទាប់ពីទទួលបានព័ត៌មាននេះ មន្ត្រីជំនាញនៃនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានធ្វើការស្រាវជ្រាវផ្ទៀងផ្ទាត់ ទៅនឹងបណ្តឹងរបស់ឈ្មោះ ឌុច អ៊ីម ភេទស្រី អាយុ ៥២ ឆ្នាំស្នាក់នៅភូមិអូរខ្លែងព័រ សង្កាត់ប៉ាលហាល ក្រុងព្រះវិហារ ខេត្តព្រះវិហារ ត្រូវជាម្តាយជនរងគ្រោះខាងលើ។ ហើយករណីនេះត្រូវបានជំនាញនៃនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនសហការជាមួយ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រួមជាមួយអាជ្ញាធរចិនជួយសង្គ្រោះជនរងគ្រោះ អ៊ែន សុខជី កាលពីថ្ងៃទី១១ ខែមីនា ឆ្នាំ ២០២១ ដោយជោគជ័យ។ ក៏ប៉ុន្តែអំឡុងពេលជួយសង្គ្រោះ ក្មេងស្រីរងគ្រោះខាងលើកំពុងមានផ្ទៃពោះ៥ខែ ផ្អែកតាមនីតិវិធីនៃប្រទេសចិន ពុំអាចបញ្ជូនរូបនាងឲ្យត្រឡប់មកប្រទេសកម្ពុជាបាននោះទេ ដោយត្រូវរង់ចាំសម្រាលកូនរួចរាល់ ហើយអាជ្ញាធរចិន បានឱ្យរូបនាងត្រឡប់ទៅស្នាក់នៅ ជាមួយប្តីជាជនជាតិចិនវិញ ដោយនគរបាលចិនដោះស្រាយ បញ្ហាពាក់ព័ន្ធនឹងការស្នាក់នៅខុសច្បាប់របស់នារីរងគ្រោះខាងលើ និងបានរៀបចំទិដ្ឋាការជូនគាត់ស្នាក់នៅស្របច្បាប់។ បច្ចុប្បន្ន នារីរងគ្រោះខាងលើរស់នៅឯប្រទេសចិន ដោយសុវត្ថិភាព។

អនុវត្តគោលការណ៍ជំនាញ និងនីតិវិធី នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន សហការជាមួយស្នងការដ្ឋាននគរបាលខេត្តព្រះវិហារ បានស្រាវជ្រាវ ស៊ើបអង្កេត និងឈានដល់ការចាប់ខ្លួនមេខ្យល់ចំនួន ០២នាក់÷១.ឈ្មោះ ខេង ហុន ភេទស្រី អាយុ៥២ ឆ្នាំជនជាតិខ្មែរ មុខរបរកម្មករ ស្នាក់នៅភូមិក្រាំងដូង ឃុំព្រះឃ្លាំង ស្រុកត្រែងមានជ័យ ខេត្តព្រះវិហារ។ ២.ឈ្មោះ រឿង ភ័ណ្ឌ ភេទស្រី អាយុ៤១ ឆ្នាំ ជនជាតិខ្មែរ មុខរបរកម្មករ ស្នាក់នៅភូមិក្រាំងដូង ឃុំព្រះឃ្លាំង ស្រុកត្រែងមានជ័យ ខេត្តព្រះវិហារ។ ជនសង្ស័យជាមេខ្យល់ខាងលើ ត្រូវបានចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តចេញដីកាបង្គាប់ឲ្យឃុំខ្លួន បណ្តោះអាសន្ននៅពន្ធនាគារខេត្ត។

ឯកឧត្តម ឧត្តមសេនីយ៍ឯក ជីវ ផល្លី ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានថ្លែងឲ្យដឹងថា នាយកដ្ឋាននឹងបន្តសហការជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងអាជ្ញាធរចិន ដើម្បីសម្របសម្រួលឱ្យជនរងគ្រោះ ឈ្មោះ អ៊ាន សុខជី បានវិលត្រឡប់មកកម្ពុជាវិញ៕ ដោយ៖បញ្ញាស័ក្តិ

## ឃាត់ខ្លួនជនជាតិថៃ ៧នាក់ ដែលកំពុងលបឆ្លងដែនមកធ្វើការ នៅក្នុងប្រទេសកម្ពុជា

https://www.kampucheathmey.com/ ថ្ងៃសៅរ៍ ២៥ កញ្ញា ២០២១ដោយ Sorn Phanith

ជនជាតិថៃ ៧នាក់ ត្រូវបានតម្រួតការពារព្រំដែនថៃលេខ៤ សហការជាមួយកម្លាំងយោធា ក្នុងកងវរយលេខ ១២ ធ្វើការឃាត់ខ្លួននៅក្បែរខ្សែបន្ទាត់ព្រំដែនស្របពេល ដែលពួកគេកំពុងធ្វើដំណើរប្រុងលួចឆ្លងដែនចូលមកក្នុងប្រទេសកម្ពុជា ដើម្បីរកការងារធ្វើ។ ក្នុងកិច្ចប្រតិបត្តិការ នៃការឃាត់ខ្លួននេះបានធ្វើឡើងកាលពីវេលាម៉ោង៥ និង ៣០ នាទីល្ងាច ថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០២១ ត្រង់ចំណុច ភូមិ១ ក្នុងឃុំណូនម៉ាកមុ៉ន ស្រុកគោកខ្សូង ខេត្តស្រះកែវ ប្រទេសថៃ បន្ទាប់ពីពួកគេកំពុងធ្វើដំណើរ ជិតដល់ព្រំដែនកម្ពុជា ក្នុងពេលដែលប្រទេសថៃមានការរឹតបន្តឹងដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ កាន់តែមានសភាពធ្ងន់ធ្ងរ ពិសេស គឺមេរោគបំប្លែងខ្លួនដែលតា។

ពួកគេ បានអះអាងថា ការលបឆ្លងដែននេះ គឺចូលទៅធ្វើការនៅក្នុងកាស៊ីណូអនឡាញ នាក្រុងប៉ោយប៉ែត ដោយទៅដល់ទីនោះក្រុមហ៊ុននឹងជួយគ្រប់យ៉ាងទាំងការហូបចុក និងការស្នាក់នៅ ហើយពួកគេទាំង ៧ នាក់ គឺជាមិត្តរួមការងារនៅក្នុងទីក្រុងបាងកក ជាមួយគ្នា ទើបបបួលគ្នាមកទីនេះតែម្តង ដោយមានរថយន្តតួរីសទៅទទួលដល់ក្រុងបាងកក និង ដឹកយកមក ទម្លាក់នៅក្នុងរីសតមួយកន្លែង ក្នុងស្រុកអារញ្ញប្រាថេត ទើបមានរថយន្តនីសាន់ទៅដឹកបន្តឆ្ពោះទៅខ្សែបន្ទាត់ព្រំដែនកម្ពុជា ទើបមានមេខ្យល់មកយកបន្ត។ ក្រោយពេលសាកសួរទើបដឹងថា ពួកគេមកពីទីក្រុងបាងកក ៤ នាក់ ប៉ាធុំថានី ១ នាក់ ស៊ីសាកេត ១ នាក់ និង ណុនថៈបុរី ១ នាក់។ បច្ចុប្បន្នជនជាតិថៃទាំង ៧ នាក់ ត្រូវបានបញ្ជូនទៅកាន់អធិការដ្ឋានតម្រួតស្រុកគោកខ្សូង ដើម្បីចាត់ការតាមនីតិវិធី ៕ **សោ និយមរ័ត្ន**

## ឃាត់ខ្លួនជនជាតិថៃ៨នាក់ មកពីខេត្តឈុនបុរី និងក្រុងបាងកកប្រុងឆ្លងដែនមកធ្វើការនៅកម្ពុជា

https://www.kampucheathmey.com/ ថ្ងៃអាទិត្យ ២៦ កញ្ញា ២០២១ដោយ sopheak khoun

ជនជាតិថៃចំនួន ៨នាក់ ដែលធ្វើដំណើរមកពីទីក្រុងបាងកក និងខ្លះមកពីខេត្តឈុនបុរី ត្រូវបានកម្លាំងយោធាថៃ ក្នុងកងវរយលេខ៥៤៦ឃាត់ខ្លួន ខណៈដែលពួកគេបម្រុងឆ្លងដែន ចូលមកធ្វើការនៅក្នុងប្រទេសកម្ពុជា។ ការឃាត់ខ្លួនជនជាតិថៃទាំង ៨នាក់ ដែលសុទ្ធតែជាស្ត្រីនេះ គឺបានធ្វើឡើងនៅវេលាម៉ោង៨ និង៣០នាទីយប់ ថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០២១ ត្រង់ចំណុចក្បែរបន្ទាត់ព្រំដែន ក្នុងឃុំពោងណាំរ៉ន ស្រុកពោងណាំរ៉ន ខេត្តច័ន្ទបុរី។ ក្រោយពីបានសាកសួររួចមក ស្ត្រីទាំងអស់ដែលជាជនជាតិថៃ បានសារភាពថា ពួកគេទាំងអស់ខ្លះមកពីខេត្តឈុនបុរី និងខ្លះទៀតមកពីទីក្រុងបាងកក ដោយមានបំណងឆ្លងដែនទៅធ្វើការក្នុងកាស៊ីណូអនឡាញ នាក្រុងប៉ោយប៉ែត ដោយនៅទីនោះឮថា បានប្រាក់ខែខ្ពស់ តែក៏ត្រូវចាប់ខ្លួនតែម្តង។ បច្ចុប្បន្នក្រោយពេលឃាត់ខ្លួន និងក្រោយពេលដែលក្រុមគ្រូពេទ្យ បានពិនិត្យសុខភាពរួចមក ពួកគេទាំងអស់ត្រូវបានបញ្ជូនទៅកាន់អធិការដ្ឋានតម្រួត ស្រុកពោងណាំរ៉ន ដើម្បីអនុវត្តតាមវិធានការច្បាប់៕ អត្ថបទ៖ សោ និយមរ័ត្ន

## អាវុធហត្ថ បញ្ជូនជនសង្ស័យម្នាក់នាំមនុស្សឆ្លងដែន ខុសច្បាប់ទៅតុលាការ

http://ppt-news.net/ ចេញផ្សាយ ថ្ងៃទី 27/09/2021

ខេត្តបន្ទាយមានជ័យ៖ នៅវេលាម៉ោង២១និង០០នាទី ថ្ងៃទី២៣ ខែកញ្ញា កងអនុសេនាធំលេខ៣ កម្លាំងវរៈសេនាតូចលេខ១ តំបន់ប្រតិបត្តិការសឹករងបន្ទាយមានជ័យ ឈរជើងក្នុងភូមិប្រាសាទតៀង ឃុំបន្ទាយឆ្មារ ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ បានឃាត់គោយន្តកន្ត្រៃចំនួន១គ្រឿងដែលមានដឹកមនុស្សចំនួន១៥នាក់ ក្នុងនោះ មានស្ត្រីចំនួន៨នាក់ កុមារ១នាក់ ដែលមានបំណងលួចឆ្លងដែនដោយខុសច្បាប់ទៅប្រទេសថៃ ។ ក្នុងចំណោមមនុស្ស១៥នាក់នោះមានមេខ្យល់០១នាក់ ឈ្មោះ ឈុន ធីត ភេទប្រុស អាយុ៣៧ឆ្នាំ មុខរបរធ្វើស្រែ បច្ចុប្បន្ន រស់នៅភូមិថ្មពួក ឃុំថ្មពួក ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ។

មេខ្យល់ខាងលើ និងវត្ថុតាងគោយន្តកន្ត្រៃ ក្រោយពីកម្លាំងយោធាឃាត់បានប្រគល់មកឱ្យស្នាក់ការសន្តិសុខ៨៨៨ របស់មូលដ្ឋានកងរាជអាវុធហត្ថស្រុកថ្មពួកដើម្បីចាត់ការតាមនីតិវិធី ។ចំណែកពលករទាំង១៤នាក់ ត្រូវបានលោក យ៉ង់ យឺន អភិបាលរងស្រុកថ្មពួកធ្វើកិច្ចសន្យា ហើយអនុញ្ញាតឱ្យពួកគាត់វិលត្រឡប់ទៅលំនៅដ្ឋានវិញហើយ ។

លោកអនុសេនីយ៍ឯក អ៊ុក សូរផុន មេបញ្ជាការមូលដ្ឋានកងរាជអាវុធហត្ថស្រុកថ្មពួកបានឱ្យដឹងថា ជនសង្ស័យឈ្មោះ ឈុន ធីត ក្រោយពីកម្លាំងជំនាញសួរនាំរួចមកបានឆ្លើយសារភាពថា រូបគេពិតជាបានដឹកពលករតាមគោយន្តកន្ត្រៃបម្រុងលួចឆ្លងដែនដោយខុសច្បាប់ពិតប្រាកដមែន ដោយខ្លួនយកថ្លៃដឹកក្នុងម្នាក់១៣០០បាតលុយថៃ ។ ដោយផ្អែកលើចម្លើយសារភាពរបស់ជនសង្ស័យ និងការរៀបរាប់ពីពលករ ទើបកម្លាំងជំនាញមូលដ្ឋានកងរាជអាវុធហត្ថស្រុកថ្មពួកកសាងសំណុំរឿងបញ្ជូនបញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តចាត់ការបន្ត ។

លោកវរសេនីយ៍ឯក ម៉ែន ភិរម្យ មេបញ្ជាការរងកងរាជអាវុធហត្ថខេត្ត ទទួលការងារស្រាវជ្រាវ និងបង្ក្រាបបទល្មើសបានឱ្យដឹងថា មេខ្យល់ខាងលើមុនធ្វើការឃាត់ខ្លួនលោកក៏បានរាយការណ៍ជូនលោកឧត្តមសេនីយ៍ត្រី បោន ប៊ិន មេបញ្ជាការកងរាជអាវុធហត្ថខេត្ត និងមានការសម្របសម្រួលនីតិវិធីពី ឯកឧត្តម កើត វណ្ណារ៉េត ព្រះរាជអាជ្ញាអមសាលាដំបូងខេត្តបន្ទាយមានជ័យផងដែរ។ បច្ចុប្បន្ន ជនសង្ស័យនិងវត្ថុតាងគោយន្តកន្ត្រៃត្រូវបានកម្លាំងការិយាល័យប្រឆាំងការជួញដូរមនុស្ស បញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តបញ្ជូនទៅសាលាដំបូងខេត្តហើយ ៕

## ពលករ ២០៦នាក់ ត្រូវដឹកជញ្ជូនពីព្រំដែនកម្ពុជា-ថៃ នៅតាមបណ្តាគោលដៅក្នុងថ្ងៃនេះ

https://swiftnewsdaily.com/ SWIFT NEWS ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២១

(ភ្នំពេញ)៖រថយន្តកងទ័ព របស់កងពលតូចដឹកជញ្ជូនលេខ៩០ នៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២១នេះ បានដឹកជញ្ជូនពលករចំណាកស្រុកនៅតាមព្រំដែន កម្ពុជា-ថៃ មកដាក់នៅតាមបណ្តាខេត្តនានា បានចំនួន ២០៦ នាក់ ដែលស្មើនិង ៣៥ជើង។ កងពលតូចដឹកជញ្ជូនលេខ៩០ កងទ័ពជើងគោក ជាអង្គភាពជំនាញដឹកជញ្ជូនសម្ភារ កម្លាំងទ័ពជានាបម្រើប្រយុទ្ធ បច្ចុប្បន្នកំពុងទទួលបទបញ្ជាដឹកពលករចំណាកស្រុកនៅតាមព្រំដែន កម្ពុជា-ថៃ មកដាក់នៅតាមបណ្តាខេត្តនានា ដែលជាវិធានការមួយរបស់រដ្ឋាភិបាល ក្នុងការទប់ស្កាត់ការឆ្លងរីករាលដាលជំងឺកូវីដ-១៩ ចូលសហគមន៍ តាមរយៈពលករចំណាកស្រុកទាំងនោះ។

អនុវត្តតាមបទបញ្ជាដ៏ខ្ពង់ខ្ពស់ ឧត្តមសេនីយ៍ឯក ហ៊ុន ម៉ាណែត អគ្គមេបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ មេបញ្ជាការកងទ័ពជើងគោក ក្នុងនោះកងពលតូចដឹកជញ្ជូនលេខ៩០ ដែលដឹកនាំដោយ ឧត្តមសេនីយ៍ទោ ឈរ សុខ នាយសេនាធិការរងកងទ័ពជើងគោក មេបញ្ជាការ កងពលតូចដឹកជញ្ជូនលេខ៩០ និងកងកម្លាំងជំនាញដឹកជញ្ជូន ដែលបានចាត់តាំងក្នុងបេសកកម្មនេះ នៅបន្តអនុវត្តយ៉ាងយកចិត្តទុកដាក់ និងប្រកបដោយការទទួល

ខុសត្រូវខ្ពស់ ក្នុងការដឹកពលករខ្មែរ ទៅដាក់នៅតាមបណ្ដាគោលដៅដែលបានកំណត់ ទាន់ពេលវេលា និង ប្រកបដោយសុវត្ថិភាព៕

## ស្ត្រីដែលចាញ់បោកមេខ្យល់ នាំទៅរៀបការជាមួយជនជាតិចិន ត្រូវបានជួយសង្គ្រោះហើយ

https://www.kampucheathmey.com/ ថ្ងៃចន្ទ ២៧ កញ្ញា ២០២១ដោយ Sorn Phanith

ស្ត្រីវ័យក្មេងម្នាក់ឈ្មោះ សឿន បុប្ផា អាយុ២៣ឆ្នាំ មានស្រុកកំណើតភូមិកោះព្រះ ឃុំកោះព្រះ ស្រុកសៀមបូក ខេត្តស្ទឹងត្រែង ដែលចាញ់បោកមេខ្យល់ នាំទៅរៀបការជាមួយបុរសជនជាតិចិន នៅប្រទេសចិននោះ ត្រូវបានជួយសង្គ្រោះហើយ និងកំពុងធ្វើនីតិវិធីបញ្ជូន មកកម្ពុជាវិញ នាពេលឆាប់ៗខាងមុខ នេះបើតាមមន្ត្រីជាន់ខ្ពស់ក្រសួងការបរទេស។ លោក កុយ គួង រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងការបរទេស និងសហប្រតិបត្តិកាអន្តរជាតិបានថ្លែងប្រាប់កម្ពុជាថ្មី នាព្រឹកថ្ងៃ២៧ ខែកញ្ញា នេះថា មកដល់ពេលនេះ ស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំនៅទីនោះ កំពុងធ្វើការងារជាមួយអាជ្ញាធរចិន ហើយកំពុងពិនិត្យនីតិវិធី ដើម្បីបញ្ជូនគាត់មកវិញ។

សូមបញ្ជាក់ថា នារីរងគ្រោះខាងលើ បានចាញ់បោកមេខ្យល់ ទៅប្រទេសចិន កាលពីឆ្នាំ២០២០ និងបានរៀបការជាមួយបុរសជនជាតិ។ នាងបានរៀបរាប់ថា នាងឈ្មោះ សឿន បុប្ផា អាយុ២៣ ឆ្នាំ មានស្រុកកំណើតភូមិកោះព្រះ ឃុំកោះព្រះ ស្រុកសៀមបូក ខេត្តស្ទឹងត្រែង។ ដំបូងនាងត្រូវអ្នកស្គាល់គ្នា ដែលជួលផ្ទះនៅខេត្តជាមួយគ្នាលួងលោមនាងឲ្យមកធ្វើការនៅស្រុកចិន ដោយយកប្រាក់ (Comssion) ពីបុរសចិនចំនួន ២,០០០ ដុល្លារនៅខែធ្នូ ឆ្នាំ ២០២០ ប៉ុន្តែទៅដល់មិនបានធ្វើការអ្វីទេ ដោយមេខ្យល់យកនាងទៅឲ្យយកប្ដីចិន នៅផ្ទះលេខ ៣៥លីងជូភូមិជីនជូ ទីក្រុងដាលីងសាន (តុងកួន) ខេត្តក្វាងទុង ។ នាងថា ប្ដីចិនរបស់នាង និងម៉ែឪក្មេក ជាមនុស្សល្អតែមានជីវភាពមិនធូរធារ ដោយប្ដីរបស់នាងធ្វើការនៅរោងចក្រ និងបានផ្ញើប្រាក់មកផ្ទះបាន២ដងដែរ ។

## ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២១

## ករណីជួញដូរផ្លូវភេទ ក្មេងស្រីខ្មែរ អាយុ១៤ ឆ្នាំ នៅប្រទេសចិន ត្រូវបានមន្ត្រីទូតខ្មែរ និងប៉ូលិសចិន ជួយសង្គ្រោះហើយ

https://dap-news.com/ BySSP108 Posted on September 27, 2021

Breaking News: ករណីជួញដូរផ្លូវភេទ ក្មេងស្រីខ្មែរ អាយុ១៥ ឆ្នាំ នៅប្រទេសចិន ត្រូវបានមន្ត្រីទូតខ្មែរ និងប៉ូលិសចិន ជួយសង្គ្រោះហើយ, នេះបើតាមការបញ្ជាក់របស់អ្នកនាំពាក្យក្រសួងការបរទេស លោក កុយ គួង។ ថ្លែងប្រាប់មជ្ឈមណ្ឌលព័ត៌មាន ដើមអម្ពិល លោក កុយ គួង បញ្ជាក់ថា " ករណី នារី រ៉ន ស្រីពី ឬ Pin X You គាត់ត្រូវបានជួយសង្គ្រោះហើយ។ បច្ចុប្បន្ន ស្ថិតនៅចត្តាឡីស័កប៉ូលីសចិន មុនត្រូវបញ្ជូនមកកម្ពុជាវិញ"។ *មុនពេលត្រូវបានសង្គ្រោះ ក្មេងស្រីរងគ្រោះ បានព្យាយាមទាក់ទងមកខាងខ្មែរ ហើយក៏បានទាក់ទងជាមួយ លោក សយ សុភាព អគ្គនាយក មជ្ឈមណ្ឌលព័ត៌មានដើមអម្ពិល និងជាសហប្រធានសមាគមអ្នកសារព័ត៌មានកម្ពុជាចិន នៅថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ២០២១។* ហើយខាងមជ្ឈមណ្ឌលព័ត៌មានដើមអម្ពិល ក៏បានទាក់ទងទៅលោក កុយ គួង នាំពាក្យក្រសួងការបរទេសខ្មែរ ដើម្បីជួយអន្តរាគមន៍ រំដោះក្មេងស្រីរងគ្រោះនេះ។

*សូមស្ដាប់ការរៀបរាប់របស់ក្មេងស្រីរងគ្រោះ ប្រាប់មជ្ឈមណ្ឌលព័ត៌មាន ដើមអម្ពិល:* ខ្ញុំអត់ដឹងថា អាស័យដ្ឋានពិតប្រាកដនៅទីណាទេខ្ញុំគ្រាន់តែដឹងថានៅខេត្តជាំងស៊ី។ ខ្ញុំមកតាមផ្លូវវៀតណាម វាខុសច្បាប់អត់មានប៉ាស្ព័រ។ ទាំងអស់មានគ្នា៨នាក់ ហើយបួននាក់គេ ចាប់បានបញ្ជូនទៅខ្មែរវិញអស់ហើយ នៅសល់បួននាក់ទៀតមានទាំងខ្ញុំ។ ពេលមកហ្នឹង ថ្មើរជើងផង ម៉ូតូផង ឡានផង ឆ្លងកាត់ភ្នំ... អ្នកនាំមកហ្នឹង គឺមេខ្យល់និងមិត្តភក្ត័ខ្ញុំ គេបបួលខ្ញុំ បញ្ចុះ

បញ្ចូលខ្ញុំរហូលទាល់តែខ្ញុំមកទាល់តែបាន ដំបូងខ្ញុំមិនចង់មកទេ ខ្ញុំហ្នឹងនិងខែមីនា ឆ្នាំ២០២១។ គេឃុំខ្ញុំជាប់ ក្នុងបន្ទប់ អត់ដែលចេញទៅក្រៅណាទេ និយាយរួមខ្ញុំអត់ដឹងអីទាំងអស់៕

## បញ្ជូនពលករខ្មែរ ១១នាក់ ពីថៃមកដល់កម្ពុជា

https://swiftnewsdaily.com/ SWIFT NEWS ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២១

(ភ្នំពេញ)៖ ស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំ នៅខេត្តសាកែវ បានបញ្ជូនពលករខ្មែរ១១នាក់ ដែលមកពីតំបន់នានា ក្នុងប្រទេសថៃ វិលត្រឡប់មកកម្ពុជាវិញ។ នៅថ្ងៃទី ២៧ ខែកញ្ញា ឆ្នាំ ២០២១ ស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំខេត្តសាកែវ បានអន្តរាគមន៍សម្របសម្រួលបញ្ជូនពលករខ្មែរចំនួន១១នាក់ ដែលមកពីតំបន់នានាក្នុងប្រទេសថៃឲ្យវិលត្រឡប់មកកម្ពុជាវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិខ្លងលឹក-ប៉ោយប៉ែត ដោយប្រគល់ជូនអាជ្ញាធរកម្ពុជា ដើម្បីដំណើការតាមនីតិវិធីសុខាភិបាល៕

## រដ្ឋមន្ត្រីការងារ ស្នើអូស្ត្រាលីផ្តល់ឱកាសជូនពលករកម្ពុជា បានទៅធ្វើការឱ្យបានច្រើន

http://freshnewsasia.com/ 2021-09-27 03:25pm

**(ភ្នំពេញ)៖** លោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានស្នើដល់អគ្គរាជទូតអូស្ត្រាលីប្រចាំកម្ពុជា លោក Pablo Chiho Kang ពិចារណាផ្តល់ឱកាសជូនដល់ពលករកម្ពុជាបានចេញទៅធ្វើការនៅប្រទេសអូស្ត្រាលីឲ្យបានចំនួនច្រើន។ ការស្នើនេះធ្វើឡើងក្នុងជំនួបរវាងថ្នាក់ដឹកនាំទាំងពីរ នាព្រឹកថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២១ នៅទីស្តីការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីពិភាក្សាអំពីចំណាប់អារម្មណ៍របស់កម្ពុជាលើគម្រោងទិដ្ឋាការកសិកម្មអូស្ត្រាលី ដែលត្រូវបានផ្សព្វផ្សាយកាលពីពេលថ្មីៗនេះ។

អគ្គរាជទូត Pablo បានឱ្យដឹងថា រដ្ឋាភិបាលអូស្ត្រាលីគ្រោងផ្តល់ទិដ្ឋាការផ្នែកកសិកម្ម (Australian Agriculture Visa) សម្រាប់ប្រទេសដៃគូរបស់អូស្ត្រាលី និងប្រទេសមួយចំនួនក្នុងតំបន់អាស៊ាន ក្នុងនោះក៏មានកម្ពុជាផងដែរ។ សម្រាប់គម្រោងទិដ្ឋាការកសិកម្មអូស្ត្រាលី ដែលកំពុងត្រូវការពលករទៅបម្រើការងារផ្នែកប្រមូលផលកសិកម្ម ការនេសាទនិងជលផល និងឧស្សាហកម្មធនជានដើមនេះ។

នៅពេលទទួលបានព័ត៌មាននេះហើយ លោក អ៊ិត សំហេង បានបញ្ជាក់វិញថា ពលករកម្ពុជាពិតជាអាចបម្រើការងារនេះបានយ៉ាងល្អជូនដល់និយោជករបស់អូស្ត្រាលី។លោករដ្ឋមន្ត្រីបានស្នើឱ្យលោកអគ្គរាជទូតពិចារណាផ្តល់ឱកាសជូនដល់ពលករកម្ពុជាបានចេញទៅធ្វើការនៅប្រទេសអូស្ត្រាលីឲ្យបានចំនួនច្រើន ដូចកម្ពុជាបានបញ្ជូនទៅសាធារណរដ្ឋកូរ៉េដែរ ហើយបើអាចក្រៅពីផ្នែកកសិកម្ម ភាគីអូស្ត្រាលីអាចពិចារណាក្នុងការបើកឱកាសជូនដល់ពលករកម្ពុជាទៅធ្វើការផ្នែកសំណង់ សេវាកម្ម និងឧស្សាហកម្មផងដែរ ដើម្បីពួកគាត់ទទួលបាននូវប្រាក់ចំណូលខ្ពស់សម្រាប់ទ្រទ្រង់ជីវភាពគ្រួសារ ក៏ដូចជាទទួលបាននូវបទពិសោធន៍ថ្មីៗបន្ថែមទៀតពីអូស្ត្រាលី។

ភាគីទាំងពីរបានពិភាក្សាការងារ និងចែករំលែកព័ត៌មានពីនីតិវិធី យន្តការ និងប្រព័ន្ធគ្រប់គ្រងពលករ ទាំងក្នុងយន្តការជ្រើសរើស បញ្ជូន និងគ្រប់គ្រង ដែលអាចធានាបាននូវការបង្កជាហានិភ័យ ឬការបោកបញ្ឆោតកេងប្រវ័ញ្ចកម្លាំងពលកម្ម ការជួញដូរមនុស្សជាដើម។ ភាគីអូស្ត្រាលីបារម្ភខ្លាចក្រែងមានជនឱកាសនិយមយកព័ត៌មាននេះទៅបំភ្លៃការពិត ហើយបោកបញ្ឆោតពលករកម្ពុជា ក្នុងពេលដែលអូស្ត្រាលីមិនទាន់អនុញ្ញាតជាផ្លូវការឱ្យកម្ពុជាបញ្ជូនបាននៅឡើយ។

ស្ថានទូតក៏មានការពេញចិត្តណាស់ចំពោះក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលបានចេញសេចក្តីជូនដំណឹងដើម្បីទប់ស្កាត់មិនឱ្យមានការបោកប្រាស់ពលករកម្ពុជាដែលថា អូស្ត្រាលីបានផ្តល់ទិដ្ឋការការងារទៅធ្វើ

ការខាងផ្នែកកសិកម្ម ដោយភាគីទាំងពីរកំពុងស្ថិតក្នុងដំណាក់ការចរចា ដើម្បីបើកឱកាសការងារនេះ។ ខាងស្ថានទូតអូស្រ្តាលីប្រចាំនៅកម្ពុជានឹងបន្តការងារជាមួយអគ្គនាយកដ្ឋានការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយសម្រាប់ស្នើសុំទៅទីក្រុងកង់បេរ៉ា ធ្វើការពិនិត្យសម្រេច។

លោករដ្ឋមន្រ្តីមិនភ្លេចថ្លែងអំណរគុណជូនដល់រដ្ឋាភិបាលអូស្រ្តាលី ដែលតែងតែបានជួយឧបត្ថម្ភគាំទ្រ ទាំងជំនួយជាហិរញ្ញវត្ថុ ទាំងការបណ្តុះបណ្តាលធនធានមនុស្ស រួមនឹងកសាងនូវហេដ្ឋារចនាសម្ព័ន្ធរូបវន្តផងដែរ ជូនដល់ពលរដ្ឋ ក៏ដូចជារាជរដ្ឋាភិបាលកម្ពុជា ហើយរំពឹងថា ចំណងមិត្តភាពរវាងប្រទេសទាំងពីរ កម្ពុជា-អូស្រ្តាលី នៅតែបន្តកិច្ចសហប្រតិបត្តិការយ៉ាងរឹងមាំជាមួយគ្នាទៅមុខទៀតជានិរន្តរ៍។ ទន្ទឹមនេះ លោករដ្ឋមន្រ្តីបានសម្តែងនូវក្តីសង្ឃឹមយ៉ាងមុតមាំថា ភាគីអូស្រ្តាលីនឹងផ្តល់ឱកាសការងារនេះជូនដល់ប្រជាពលរដ្ឋកម្ពុជា ព្រោះថាកម្ពុជាបានរៀបចំបានយ៉ាងល្អនូវលិខិតបទដ្ឋាន គោលនយោបាយ និងយន្តការច្បាស់លាស់ ដែលជាប្រព័ន្ធគ្រប់គ្រងមួយយ៉ាងល្អក្នុងការធានាបាននូវការជ្រើសរើស បញ្ជូន និងគ្រប់គ្រងពលករ មិនឱ្យមានការរំលោភបំពានសិទ្ធិ និងអត្ថប្រយោជន៍ ហើយអាចទប់ស្កាត់បាននូវការកេងប្រវ័ញ្ចកម្លាំងពលកម្ម និងការជួញដូរមនុស្សជាដើម។

សូមបញ្ជាក់ថា គម្រោងទិដ្ឋាការកសិកម្មអូស្រ្តាលី (Australian Agriculture Visa) ត្រូវបានប្រកាសកាលពីថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២១ ក្នុងនោះអូស្រ្តាលីត្រូវការជ្រើសរើសពលករផ្នែកកសិកម្ម នេសាទនិងជលផល និងឧស្សាហកម្មធនធានដើម។ គម្រោងទិដ្ឋាការកសិកម្មអូស្រ្តាលីនេះ ស្រដៀងគ្នានឹងគម្រោងការងារប៉ាស៊ីហ្វិក (Pacific Labour Scheme) ដោយពលករក្រោមគម្រោងទិដ្ឋាការកសិកម្មអូស្រ្តាលី អាចធ្វើការបានរហូតដល់រយៈពេល ១-៣ឆ្នាំ ក្រោមការទទួលបន្ទុកដោយក្រសួងការបរទេស និងពាណិជ្ជកម្មអូស្រ្តាលី៕

## រដ្ឋបាលខេត្តព្រះសីហនុ នឹងចាត់វិធានការតាមច្បាប់ចំពោះម្ចាស់អគារ សណ្ឋាគារ និងកាស៊ីណូ ដែលប្រើប្រាស់បុគ្គលិកដោយបង្ខំ

http://freshnewsasia.com/ 2021-09-27 06:40pm

**(ព្រះសីហនុ)៖** លោក គួច ចំរើន អភិបាលខេត្តព្រះសីហនុ បានចេញសេចក្តីជូនដំណឹង ដោយបញ្ជាក់ថា អាជ្ញាធរខេត្ត នឹងចាត់វិធានការរដ្ឋបាល និងច្បាប់ចំពោះម្ចាស់អគារ សណ្ឋាគារ និងកាស៊ីណូដែលប្រើប្រាស់ ហត្ថពលករដោយបង្ខំ។ នេះបើតាមសេចក្តីណែនាំដែលបណ្តាញព័ត៌មាន Fresh News ទទួលបាននៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២១នេះ។ ការចេញមកសេចក្តីជូនដំណឹងបែបនេះរបស់លោក គួច ចំរើន បានធ្វើឡើងបន្ទាប់ពីក្នុងរយៈពេលកន្លងមករដ្ឋបាលខេត្តព្រះសីហនុបានសង្កេតឃើញថា ការជ្រើសរើស ការគ្រប់គ្រង ការចាត់ចែង ការអនុវត្តកិច្ចសន្យាការងារ រវាងនិយោជក និងបុគ្គលិក កម្មករ និយោជិតមួយចំនួននៅមិនទាន់ស្របតាមនីតិវិធីច្បាប់នៅឡើយ ដែលជាហេតុបណ្តាលឱ្យកើតមានវិវាទការងារ ហើយរដ្ឋបាលខេត្តក៏បានទទួលពាក្យបណ្តឹង និងដោះស្រាយវិវាទការងារ ជាបន្តបន្ទាប់ច្រើនករណីមកហើយ។

**លោកបានបញ្ជាក់ថា ដើម្បីដោះស្រាយ និងកាត់បន្ថយវិវាទការងារប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលា ជាពិសេសដើម្បីទប់ស្កាត់ការបំពេញការងារដោយបង្ខំ ឬជាកាតព្វកិច្ច ដែលអាចប្រឈមនឹងការជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទក្រោមរូបភាពរកការងារឱ្យធ្វើក្នុងទម្រង់កេងប្រវ័ញ្ចពលកម្ម រដ្ឋបាលខេត្តព្រះសីហនុ សូមដាក់ចេញនូវវិធានការម៉ឺងម៉ាត់ តាមច្បាប់ដូចខាងក្រោម៖**

***ទី១៖** ការងារដោយបង្ខំ ឬជាកាតព្វកិច្ច ត្រូវហាមឃាត់ដាច់ខាត (ដោយអនុលោមតាមអនុសញ្ញាលេខ ២៩ ស្តីពី ការងារដោយបង្ខំ ឬដោយកាតព្វកិច្ច អនុម័តនៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ១៩៣០ ដោយអង្គការការងារអន្តរជាតិ ហើយព្រះរាជាណាចក្រកម្ពុជា បានឱ្យសច្ចាប័ននៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៦៩ និងស្របតាមមាត្រា១៥ នៃច្បាប់ស្តីពីការងារ នៃព្រះរាជាណាចក្រកម្ពុជា)។

***ទី២៖** ការជួលមនុស្សឱ្យធ្វើការងារដើម្បីកាត់ជំពាក់ ត្រូវហាមឃាត់ (មាត្រា១៦ នៃច្បាប់ស្តីពីការងារ នៃព្រះរាជាណាចក្រកម្ពុជា)។

***ទី៣៖** ការកាត់ប្រាក់ឈ្នួលក្នុងគោលបំណងឱ្យអ្នកទទួលរកការឱ្យធ្វើ ទោះបីដោយចំពោះក្តី ឬមិនចំពោះក្តីឱ្យទៅនិយោជក អ្នកតំណាងនិយោជក ឬអន្តរការីណាម្នាក់ ដូចជាភ្នាក់ងារទទួលជ្រើសរើសហត្ថពលករជាដើមត្រូវហាមឃាត់ (មាត្រា១២៦ នៃច្បាប់ស្តីពីការងារ នៃព្រះរាជាណាចក្រកម្ពុជា)។

***ទី៤៖** ជនណាដែលនាំយកជនដទៃចេញដោយមិនស្របច្បាប់ ក្នុងគោលដៅស្វែងរកប្រយោជន៍ ឈ្លានពានខាងផ្លូវភេទ ផលិតរូបភាពអាសអាភាស រៀបអាពាហ៍ពិពាហ៍ផ្ទុយពីឆន្ទៈរបស់ជនរងគ្រោះ សុំកូន ឬទម្រង់ណាមួយនៃការកេងប្រវ័ញ្ចផ្សេងទៀតនឹងត្រូវផ្តន្ទាទោសតាមច្បាប់(មាត្រា១០ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ នៃព្រះរាជាណាចក្រកម្ពុជា)។

***ទី៥៖** បុគ្គលដែលចាប់ ឬឃុំឃាំង ឬដែលបង្ខាំងបុគ្គលផ្សេងទៀតដោយគ្មានបញ្ជាពីអាជ្ញាធរស្របច្បាប់ ឬក្រៅពីករណីដែលច្បាប់អនុញ្ញាតត្រូវផ្តន្ទាទោសតាមច្បាប់(មាត្រា២៥៣នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា)។

យោងតាមអនុសញ្ញាលេខ២៩ នៃអង្គការការងារអន្តរជាតិ និងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា សកម្មភាពដូចបានរៀបរាប់ខាងលើ គឺជាអំពើឧក្រិដ្ឋកម្មដែលត្រូវផ្តន្ទាទោស និងមានស្ថានទម្ងន់ទោសធ្ងន់ធ្ងរ ព្រោះជាអំពើប៉ះពាល់ដល់មនុស្សជាតិ។ ជាងនេះទៀតរដ្ឋបាលខេត្តនឹងចាត់វិធានការរដ្ឋបាល និងច្បាប់ចំពោះម្ចាស់អគារ សណ្ឋាគារ និងកាស៊ីណូ ដែលមានការពាក់ព័ន្ធទោះក្នុងរូបភាពដោយប្រយោល ឬដោយផ្ទាល់ក្តី ទៅលើការបង្ខាំងការបង្ខំឱ្យមនុស្សធ្វើការ ការជួញដូរតាមរូបភាពទទួលមនុស្សឆ្លងដែនដោយខុសច្បាប់ឱ្យធ្វើការ ដែលមានការចាត់តាំងជាដើម។ល។

ក្នុងករណីរកឃើញម្ចាស់អគារ សណ្ឋាគារ និងកាស៊ីណូប្រព្រឹត្តបទល្មើសដូចមានចែងខាងលើ រដ្ឋបាលខេត្តព្រះសីហនុនឹងចាត់វិធានការផ្អាកទីតាំងអាជីវកម្មជាបណ្តោះអាសន្ន និងកសាងសំណុំរឿងបញ្ជូនទៅតុលាការដើម្បីផ្តន្ទាទោសបុគ្គលដែលមានការពាក់ព័ន្ធស្របតាមច្បាប់ជាធរមាន ព្រមទាំងស្នើសុំរាជរដ្ឋាភិបាលដើម្បីលុបអាជ្ញាប័ណ្ណអាជីវកម្មជាស្ថាពរ៕

## គិតចាប់ពីដើមខែ រហូតដល់ថ្ងៃទី២៧ ខែកញ្ញា ពលករថៃប្រមាណ ៣៧៩នាក់ បានលួចឆ្លងដែនមកប្រទេសកម្ពុជា ដោយគ្មានច្បាប់អនុញ្ញាត

https://www.gntimes.com/ ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២១

ខេត្តបាត់ដំបង៖ បើយោងតាមប្រភពព័ត៌មានពីខេត្តស្រះកែវប្រទេសថៃបានឲ្យដឹងថា រយៈពេលចុងក្រោយនេះយោធា និងតម្រួតថៃបានចាត់វិធានការរឹតបន្តឹងលើប្រជាពលរដ្ឋរបស់ខ្លួន ដែលបានលួចឆ្លងដែនមកធ្វើការនៅក្នុងប្រទេសកម្ពុជាដោយគ្មានច្បាប់អនុញ្ញាត ទោះចេញឬចូលក៏ដោយចុះ ។ ហើយពលករថៃដែលល្មើសច្បាប់ខាងលើនេះត្រូវបានសមត្ថថៃចាត់វិធានការផាកពិន័យរដ្ឋបាល លើជនជាតិខ្លួនដែលល្មើសលួចឆ្លងដែនចេញចូលដោយខុសច្បាប់មកកម្ពុជាយ៉ាងចាស់ដៃមុននិងអនុវត្តន៍ចត្តាឡីស័ក១៤ថ្ងៃ ។

ប្រភពខាងលើបានបន្តថា ពាក់ព័ន្ធនឹងវិធានការរឹតបន្តឹងនេះស្របពេលកាលពីថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២១ កន្លងមកនេះ កម្លាំងសមត្ថកិច្ចកម្ពុជាបានឃាត់ខ្លួនជនជាតិថៃជាច្រើនបន្តបន្ទាប់ដែលពួកគេបានឆ្លងដែនចូលក្នុងទឹកដីកម្ពុជា ហើយបានប្រគល់ទៅឲ្យសមត្ថកិច្ចថៃវិញគ្រាដែលពួកគេឆ្លងដែនចូលមកទឹកដីកម្ពុជាតាមច្រករបៀងនានា ដើម្បីស្វែងរកធ្វើការនៅក្នុងកាស៊ីណូអនឡាញក្នុងក្រុងប៉ោយប៉ែតឬនៅក្នុងក្រុងភ្នំពេញ។

អាជ្ញាធរនិងសមត្ថកិច្ចថៃនៅក្នុងខេត្តស្រះកែវ ក៏បានបង្ហាញនូវចំនួនជនជាតិរបស់ខ្លួន ដែលល្មើសលួចឆ្លងដែនមកខាងទឹកដី ប្រទេសកម្ពុជា ដើម្បីរកការងារធ្វើដោយគ្មានច្បាប់អនុញ្ញាត ចាប់តាំងពីដើមខែកញ្ញាមកទល់នឹងថ្ងៃទី២៧ ខែកញ្ញា នេះ ពលករថៃដែលឆ្លងដែនចូលក្នុងប្រទេសកម្ពុជាសរុបចំនួន៣៧៩នាក់ ជាចំនួនដែលសមត្ថ

កិច្ចថៃចាប់បាននិងខាងភាគីកម្ពុជាចាប់បានរួចប្រគល់ឱ្យសមត្ថកិច្ចថៃ ហើយសមត្ថកិច្ចថៃនិយាយថាសម្រាប់ករណីលួចឆ្លងដែនតាមរយៈមេខ្យល់អាចនឹងមានច្រើនជាងចំនួនខាងលើ។ ប្រភពដដែលបានបញ្ជាក់ដែរថា ថ្មីៗនេះក្រោយពីភាគីកម្ពុជាបាននាំខ្លួនពលរដ្ឋថៃជាច្រើននាក់ទៅប្រគល់អោយតម្រួតថៃដែលឈរជើងនៅចំណុចច្រកអន្តរជាតិខ្លងលឹក ស្រុកអរញ្ញប្រាថេត ខេត្តស្រះកែវ សមត្ថកិច្ចថៃបានចាត់វិធានការសុខាភិបាលដោយពិន័យជាទឹកប្រាក់ក្នុង១នាក់ចំនួន៨០០បាត រួចបញ្ជូនទៅកាន់មណ្ឌលធ្វើចត្តាឡីស័ក១៤ថ្ងៃ ៕ សួន សុខហៃ

## សមត្ថកិច្ចចាប់ជនជាតិថៃលួចឆ្លងដែនខុសច្បាប់២៦នាក់ យកទៅអនុវត្តតាមនីតិវិធីច្បាប់

https://www.kampucheathmey.com/ ថ្ងៃអង្គារ ២៨ កញ្ញា ២០២១ដោយ Sokhom Khon

កម្លាំងចម្រុះការពារព្រំដែន បានចេញល្បាតនៅតាមបន្ទាត់ព្រំដែន បានប្រទះឃើញជនជាតិថៃចំនួន២៦នាក់ក្នុងនោះមានស្រី១២ នៅចំនុចភូមិព្រៃចាន់ ឃុំអូបីជាន់ ស្រុកអូជ្រៅ ខេត្តបន្ទាយមានជ័យ ឃាត់ខ្លួនបាននៅវេលាម៉ោង២យប់ចូលថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២១បម្រុងចូលមកក្រុងប៉ោយប៉ែតរកការងារធ្វើ ។

សមត្ថកិច្ចបាននិយាយថា ដោយអនុវត្តតាមបទបញ្ជាលោកឧត្តមសេនីយ៍មេបញ្ជាការកងពលតូចថ្មើរជើងលេខ៥១ កម្លាំងវរសេនាតូចថ្មើរជើងលេខ៥១៤ បានចេញទៅឈរជើងនៅតាមខ្សែបន្ទាត់ព្រំដែនខ្មែរ-ថៃ ចាប់ពីទិសបឹងត្រកួន ដល់អូរល្ហុងក្នុង ខេត្តបន្ទាយមានជ័យ ដើម្បីសហការជាមួយកម្លាំងតាមមូលដ្ឋាន ចូលរួមទប់ស្កាត់ពលករ ខ្មែរ – ថៃ ឆ្លងដែនខុសច្បាប់ ក្នុងការចូលរួមចំណែកជាមួយរាជរដ្ឋាភិបាល ដើម្បី ទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ១៩ កុំឲ្យឆ្លងចូលជាសហគមន៍ ។ សមត្ថកិច្ចបានបញ្ជាក់ឲ្យដឹងបន្តទៀតថា ជនជាតិថៃទាំង២៦នាក់នោះពេលសមត្ថកិច្ចខ្មែរសួរនាំបានប្រាប់ថា ពួកគេមកពីប្រទេសថៃ ដោយមានមេខ្យល់ជាជនជាតិខ្មែរជាអ្នកនាំផ្លូវនាំដើរកាត់តាមច្រករបៀងចូលមកប្រទេសខ្មែរដើម្បីមកធ្វើការងារធ្វើនៅក្រុងប៉ោយប៉ែត។ បន្ទាប់ពីសួរនាំរួចសមត្ថកិច្ចខ្មែរបាននាំខ្លួនពលករថៃទាំងអស់ទៅធ្វើកំណត់ហេតុឃាត់ខ្លួន និងអនុវត្តតាមវិធានរបស់សុខាភិបាល និងបញ្ជូនទៅចត្តាឡីស័កនៅមណ្ឌលស្រុកថ្មពួក ១៤ថ្ងៃទើបយកទៅអនុវត្តតាមនិតិវិធីច្បាប់របស់ស្រុកខ្មែរ៕ វ៉ាន់ ណាង

## ដោះលែងពលរដ្ឋខ្មែរ៣នាក់ឲ្យរួចពីការទោសវិញ ក្រោយជាប់ពន្ធនាគារលើទឹកដីថៃ

https://kohsantepheapdaily.com.kh/ ២៨ ខែ កញ្ញា ឆ្នាំ ២០២១ ម៉ោង ១៧:២០

ខេត្តឧត្តរមានជ័យ ៖ ប្រជាពលរដ្ឋខ្មែរ៣នាក់ត្រូវបានក្រុមអាជ្ញាធរថៃដោះលែងពីពន្ធធនាគារក្នុងខេត្តស៊ីសាកេត កាលពីព្រឹកថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២១ រួចក៏ត្រូវនាំខ្លួនប្រគល់ឲ្យក្រុមអាជ្ញាធរកម្ពុជាវិញតាមរយៈច្រកទ្វារអន្តរជាតិជាំ ស្ថិតនៅក្នុងភូមិជាំ ឃុំត្រពាំងប្រីយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ អ្នកទោសខ្មែរទាំង៣នាក់ដែលត្រូវក្រុមអាជ្ញាធរថៃដោះលែងឲ្យមានសេរីភាពវិញនោះ គឺ១- ឈ្មោះញ៉ែន ម៉ៅ ភេទប្រុស អាយុ៤០ឆ្នាំ រស់នៅភូមិកោះរាម ឃុំកោះរាម ស្រុកបវេល ខេត្តបាត់ដំបង ២- ឈ្មោះសេង យ៉ា ភេទប្រុស អាយុ៣៩ឆ្នាំ រស់នៅភូមិដីក្រហម ឃុំដីក្រហម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ និង៣- ឈ្មោះ ថេង ឡែន ភេទប្រុស អាយុ១៨ឆ្នាំ រស់នៅភូមិបីប៉ុយ ឃុំបីប៉ុយ ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម អ្នកទាំង៤នាក់ត្រូវចាប់ខ្លួនកាលពីថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៩ ពីបទឆ្លងដែនរកកាប់ឈើគ្រញូងខុសច្បាប់នៅប្រទេសថៃ ដោយចូលតាមច្រកអូក្រញូង ហើយក៏ត្រូវជាប់ពន្ធនាគារនៅខេត្តស៊ីសាកេត ប្រទេសថៃតែម្ដង។

ក្រុមអាជ្ញាធរកម្ពុជា បម្រើការងារនៅច្រកទ្វារអន្តរជាតិជាំ បានឲ្យដឹងថា ពលរដ្ឋខ្មែរចំនួន៣នាក់ខាងលើបន្ទាប់ពីបានធ្វើការសាកសួរ និងធ្វើកិច្ចសន្យា រួចក៏បានប្រគល់ទៅឲ្យគ្រូពេទ្យផ្នែកចត្តាឡីស័ក នាំយកសំណាកធ្វើតេស្តរកមើលមេរោគកូវីដ១៩ ជាលទ្ធផលគឺអវិជ្ជមាន ក្រោយមកក៏បានបញ្ជូនទៅធ្វើចិត្តាឡីស័ក នៅសាលាបឋមសិក្សាទួលថ្មីផងដែរ ៕

## ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១

## សម្ដេច ស ខេង ចូលរួមប្រជុំ ថ្នាក់រដ្ឋមន្ត្រី អាស៊ាន លើកទី១៥ ពីឧក្រិដ្ឋកម្មឆ្លងដែន ក្នុងក្របខណ្ឌអាស៊ាន

https://dap-news.com/ ByPH104Posted on September 29, 2021

ភ្នំពេញ ៖ សម្ដេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នាថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ ២០២១ បានអញ្ជើញចូលរួម កិច្ចប្រជុំ ថ្នាក់រដ្ឋមន្ត្រី អាស៊ាន (AMMTC) លើកទី១៥ ស្ដីពីឧក្រិដ្ឋកម្មឆ្លងដែន ក្នុងក្របខណ្ឌអាស៊ាន និងកិច្ចប្រជុំពិគ្រោះយោបល់នានា ជាមួយនឹងបណ្ដាប្រទេស ជាសមាជិកអាស៊ាន ផ្សេងទៀត តាមរយៈប្រព័ន្ធវីដេអូសន្និសីទZoom ។ កិច្ចប្រជុំនេះធ្វើឡើង រយៈពេលពីរថ្ងៃ ពីថ្ងៃទី២៩-៣០ ខែកញ្ញា ឆ្នាំ២០២១ ដែលមានប្រទេសព្រុយណេ ធ្វើជាប្រធានដឹកនាំ ៕

## ពលករខ្មែរ-ថៃ សរុប ៦៣នាក់ត្រូវបានឃាត់ខ្លួន ខណៈបម្រុងលួចឆ្លងដែនខុសច្បាប់

https://swiftnewsdaily.com/ SWIFT NEWS ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២១

(បន្ទាយមានជ័យ)៖ រយៈពេល ២ថ្ងៃ កម្លាំងចម្រុះដែលល្បាតតាមបណ្ដាយព្រំដែនកម្ពុជា-ថៃ បានពួនស្ទាក់ឃាត់ខ្លួនបានប្រជាពលរដ្ឋខ្មែរ និងថៃ ដែលលួចឆ្លងដែនសរុប ៦៣នាក់។ នេះបើយោងតាមការផ្សាយរបស់ផេកផ្លូវការកងទ័ពជើងគោក នារសៀលថ្ងៃអង្គារនេះ។ កម្លាំងកងការពារព្រំដែនលេខ៥០៣ និង កងពលតូចថ្មើរជើងលេខ៥១ បានសហការជាមួយនគរបាលព្រំដែនគោកលេខ៩១១ បានដើរល្បាត និងពួនស្ទាក់ចាប់បានពលករជនជាតិខ្មែរចំនួន ២៦នាក់ និងជនជាតិថៃ ចំនួន ១១នាក់ កាលពីថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២១ ខណៈពេលដែលពួកគេ បម្រុងលួចឆ្លងដែនដោយខុសច្បាប់៤គោលដៅផ្សេងគ្នា។ បន្ទាប់មក នៅម៉ោង ១:៤០នាទី រំលងអាធ្រាត ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២១ កម្លាំងកងអនុសេនាធំល្បាតទី២ ដឹកនាំដោយលោកវរសេនីយ៍ត្រី អ៊ិន ថុលបានសហការជាមួយកម្លាំងកងពលតូចថ្មើរជើងលេខ៥១ និងនគរបាលព្រំដែនគោកលេខ៩១១ បានឃាត់ខ្លួនជនជាតិថៃប្រុសស្រី ចំនួន២៦នាក់ទៀត ដែលបានលួចឆ្លងដែនពីប្រទេសថៃមកកម្ពុជា ស្ថិតក្នុងភូមិព្រៃចាន់ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ហើយជនជាតិថៃទាំងនេះត្រូវបានបញ្ជូនទៅឱ្យក្រុមការងារចម្រុះច្រកអូរបីជាន់ដើម្បីធ្វើកាតាមនីតិវិធី។

ឆ្លើយតបនឹងបញ្ហាលួចឆ្លងដែននេះ លោកឧត្ដមសេនីយ៍ត្រី យួន ជឿន មេបញ្ជាការកងការពារព្រំដែនលេខ ៥០៣ បានដាក់ចេញនូវបទបញ្ជាឱ្យពង្រឹងការល្បាត តាមបន្ទាត់ព្រំដែនកម្ពុជា-ថៃ ២៤ម៉ោងលើ២៤ម៉ោង ដោយប្ដូរវេនគ្នា សហការជាមួយកម្លាំងចម្រុះ ដើម្បីទប់ស្កាត់ពលករលួចឆ្លងដែនខុសច្បាប់ និងការឆ្លងរាលដាល នៃជំងឺកូវីដ-១៩ មិនឲ្យចូលទៅក្នុងសហគមន៍ និងតំបន់ផ្សេងទៀត។

សូមបញ្ជាក់ថា ខណៈកងកម្លាំងចម្រុះល្បាត ក៏បានជួបពលករបម្រុងលួចឆ្លងដែន ត្រូវបានកងកម្លាំង កងការពារព្រំដែនលេខ៥០៣ ឃាត់ខ្លួនបានតែម្ដង ក្រោយពីឃាត់ខ្លួន ក៏បានណែនាំដល់បងប្អូនប្រជាពលរដ្ឋ កុំឲ្យបន្ដចាញ់បោកមេខ្យល់ ដែលតែងតែបញ្ចុះបញ្ចូល នាំពលករឆ្លងដែនដោយខុសច្បាប់ ដោយមិនគិតពីសុខសុវត្ថិភាព និងខាតបង់ប្រាក់ជាបន្តបន្ទាប់ ជាពិសេសសូមបន្តចូលរួមអនុវត្តវិធានការ ៣ការពារ ៣កុំ អោយបានទាំងអស់គ្នា ដើម្បីគ្រួសារ និងសង្គមជាតិ៕

## ពលករខ្មែរវិលត្រឡប់មកពីថៃ ចូលតាមច្រកខេត្តបាត់ដំបងជាបន្តបន្ទាប់ ទោះបីករណីឆ្លងក្នុងសហគមន៍ខេត្តមិនទាន់ថមថយ

https://news.btv.com.kh/ 09/27/2021 01:09 PM

បាត់ដំបង ៖ ពលករខ្មែរបានវិលត្រឡប់មកពីប្រទេសថៃ ចូលតាមច្រកព្រំដែននានា ក្នុងភូមិសាស្ត្រខេត្តបាត់ដំបងជាបន្តបន្ទាប់ ទោះបីករណីឆ្លងជំងឺកូវីដ១៩ ក្នុងសហគមន៍ខេត្តមិនទាន់ថមថយនៅឡើយ។

លោក សៀម ប៊ុនរិទ្ធិ អភិបាលរងខេត្ត និងជាអ្នកនាំពាក្យរដ្ឋបាលខេត្តបាត់ដំបងបានថ្លែងថា ការវិលត្រឡប់របស់ពលករខ្មែរមកពីប្រទេសថៃចូលតាមច្រកខេត្តបាត់ដំបង មានជារឿយៗ ក្នុងចំនួនមិនទៀងទាត់នោះទេ ថ្ងៃខ្លះតិច ថ្ងៃខ្លះក៏ច្រើន។ លោក បានថ្លែងបន្ថែមថា ចំពោះពលករដែលវិលត្រឡប់មកពីប្រទេសថៃទាំងអស់ ត្រូវបានធ្វើតេស្តរហ័សនៅតាមច្រកព្រំដែន ក្នុងនោះក៏បានរកឃើញអ្នកឆ្លងកូវីដ១៩ មួយចំនួនផងដែរ ។ អ្នកនាំពាក្យរដ្ឋបាលខេត្តបានថ្លែងបន្តថា ថ្មីៗនេះចំនួនអ្នកឆ្លងជំងឺកូវីដ១៩ ក្នុងសហគមន៍ស្រុកជាប់ព្រំដែនថៃ មានការកើនឡើង ហើយមណ្ឌលព្យាបាលមានភាពចង្អៀតណែន អស់លទ្ធភាពដាក់អ្នកជំងឺ អាជ្ញាធរខេត្តបានផ្ទេរអ្នកជំងឺជាបន្តបន្ទាប់មកទទួលការព្យាបាលនៅក្នុងក្រុងបាត់ដំបង។

ដើម្បីឆ្លើយតបនឹងកំណើនអ្នកឆ្លងជំងឺកូវីដ១៩ ក្នុងសហគមន៍នេះ អាជ្ញាធរខេត្តបានសហការជាមួយភាគីពាក់ព័ន្ធរៀបចំមណ្ឌលព្យាបាលអ្នកជំងឺកូវីដ១៩ បន្ថែមទៀតជាបន្តបន្ទាប់ ទាំងនៅតាមបណ្តាស្រុកជាប់ព្រំដែន និងក្នុងក្រុងបាត់ដំបង។ គួរកត់សម្គាល់ថា ស្ថានភាពនៃការឆ្លងរីករាលដាលជំងឺកូវីដ១៩ ក្នុងសហគមន៍ខេត្តបាត់ដំបងមួយរយៈពេលចុងក្រោយនេះ មានការកើនឡើង រហូតដល់មានការបិទខ្ទប់វត្តអារាម ផ្សារ និងទីតាំងមួយចំនួន ខណៈរដ្ឋបាលខេត្តបានដាក់ចេញនូវវិធានការរដ្ឋបាល ដោយផ្អាកជាបណ្តោះអាសន្នចំពោះសកម្មភាពការងារ មុខរបរ ឬអាជីវកម្ម ដែលមានហានិភ័យខ្ពស់ នៃការឆ្លងរាលដាលជំងឺកូវីដ-១៩ និងការជួបជុំ ឬការប្រមូលផ្តុំមនុស្សជាលក្ខណៈឯកជន ៕

## ជនជាតិចិន ចំនួន ៤នាក់ និងអ្នកនាំផ្លូវម្នាក់ បម្រុងឆ្លងដែនខុសច្បាប់ ត្រូវបានឃាត់ខ្លួន ដោយកម្លាំងតំបន់ប្រតិបត្តិការបន្ទាយមានជ័យ

https://cen.com.kh/ Posted ByPen Srey Neat September 29, 2021

បន្ទាយមានជ័យ ៖ ជនជាតិចិន ចំនួន ៤នាក់ បម្រុងឆ្លងដែនទៅធ្វើការនៅប្រទេសថៃ ត្រូវបានឃាត់ខ្លួនដោយកម្លាំងតំបន់ប្រតិបត្តិការសឹករងបន្ទាយមានជ័យ វេលាម៉ោង ២០និង៣០នាទីយប់ ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២១ ត្រង់ភូមិសាស្ត្រ អូរព្រំដែន ភូមិកោះស្នួល ឃុំទួលពង្រ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ។

លោក ឧត្តមសេនីយ៍ត្រី ជឹម ប៊ុនអាន មេបញ្ជាការ តំបន់ប្រតិបត្តិការសឹករងបន្ទាយមានជ័យ ដាក់បទបញ្ជាយ៉ាងម៉ឺងម៉ាត់ ដល់កម្លាំង ទាំងអស់ល្បាតជាប់ជាប្រចាំ ២៤ម៉ោងលើ២៤ម៉ោង ដោយប្តូរវេនគ្នា សហការល្អ ជាមួយកងកម្លាំងចម្រុះ ដើម្បីទប់ស្កាត់ពលករ លួចឆ្លងដែនខុសច្បាប់ និងទប់ស្កាត់ការឆ្លងរាលដាល នៃជំងឺកូវីដ-១៩ មិនឲ្យចូលទៅក្នុងសហគមន៍។ ជាក់ស្តែង យប់ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២១ លោក អនុសេនីយ៍ទោ ហួត ប៊ុនធឿន មេក្រុមគោលដៅ ដឹកនាំកម្លាំងដើរល្បាតក៏ជួប ជនជាតិចិន ចំនួន ៤នាក់ អ្នកនាំផ្លូវម្នាក់ និងម៉ូតូ ចំនួន ១គ្រឿង បម្រុងឆ្លងដែនចេញទៅប្រទេសថៃ ត្រូវបានកម្លាំង តំបន់ប្រតិបត្តិការសឹករងបន្ទាយមានជ័យ ឃាត់ខ្លួនបានតែម្តង ។

សូមបញ្ជាក់ថា ចាប់តាំងពីកងកម្លាំងតំបន់ប្រតិបត្តិការសឹករងខេត្ត ត្រូវបានបញ្ជូនទៅបំពេញប្រតិបត្តិការសហការជាមួយកម្លាំងចម្រុះទប់ស្កាត់ពលករលួចឆ្លងដែន និងទប់ស្កាត់ការឆ្លងរីករាលដាល នៃជំងឺកូវីដ-១៩ បានឃាត់ខ្លួនពលករឆ្លងដែន បញ្ជូនទៅមណ្ឌលចត្តាឡីស័កជាបន្តបន្ទាប់ និងឃាត់ខ្លួនមេខ្យល់បានមួយចំនួន បញ្ជូន

ទៅសមត្ថកិច្ចជំនាញ ចាត់វិធានការតាមផ្លូវច្បាប់។ ចំណែកជនជាតិចិន ចំនួន ៤នាក់ អ្នកនាំផ្លូវ ក្រោយពីបានសួរនាំរួច ត្រូវបានប្រគល់អោយ ស្នាក់ការកងរាជអាវុធហត្ថ ចាត់ការតាមនីតិវិធីច្បាប់បន្ត៕ រក្សាសិទ្ធិដោយ ៖ បញ្ញាស័ក្តិ

## ឃាត់ខ្លួនពលករខ្មែរ និងថៃ៣៧នាក់ ដែលបម្រុងឆ្លងដែនពីថៃចូលកម្ពុជាខុសច្បាប់ នៅស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ

http://freshnewsasia.com/ 2021-09-28 04:30pm

**(បន្ទាយមានជ័យ)៖** កម្លាំងកងការពារព្រំដែនលេខ៥០៣ សហការជាមួយកងពលតូចថ្មើរជើងលេខ៥១ និងនគរបាលព្រំដែនគោកលេខ៩១១ បានឃាត់ខ្លួនពលករខ្មែរថៃចំនួន៣៧នាក់ ក្នុងនោះពលករខ្មែរ២៦នាក់ និងថៃ១១នាក់ ដែលបម្រុងលួចឆ្លងដែនខុសច្បាប់ពីប្រទេសថៃ ចូលមកកម្ពុជាខុសច្បាប់។ ពលករទាំង៣៧នាក់នេះ ត្រូវបានឃាត់ខ្លួននៅវេលាម៉ោង ១៖៤០នាទី រំលងអាធ្រាត្រថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២១ ស្ថិតក្នុងភូមិព្រៃចាន់ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ។ ក្រោយឃាត់ខ្លួន សមត្ថកិច្ចបានបញ្ជូនទៅឱ្យ ក្រុមការងារចម្រុះច្រកអូរបីជាន់ ដើម្បីធ្វើកាតាមនីតិវិធី។

ការបង្ក្រាប និងទប់ស្កាត់ការលួចឆ្លងដែនខុសច្បាប់ខាងលើនេះ បានធ្វើឡើងក្រោមបទបញ្ជាពីលោកឧត្តមសេនីយ៍ត្រី យួន ជឿន មេបញ្ជាការកងការពារព្រំដែនលេខ៥០៣។ លោកមេបញ្ជាការ បានដាក់បទបញ្ជាឲ្យកងកម្លាំងចុះពង្រឹង ការល្បាតតាមបន្ទាត់ព្រំដែនកម្ពុជា-ថៃ ២៤ម៉ោង លើ២៤ម៉ោង ដោយប្តូរវេនគ្នា សហការជាមួយកម្លាំងចម្រុះ ដើម្បីទប់ស្កាត់ពលករលួចឆ្លងដែនខុសច្បាប់ និងការឆ្លងរាលដាលនៃជំងឺកូវីដ១៩ មិនឱ្យចូលទៅក្នុងសហគមន៍ និងតំបន់ផ្សេងទៀត។ ក្រោយឃាត់ខ្លួនពលករទាំងនេះ សមត្ថកិច្ចក៏បានណែនាំកុំឱ្យបន្តចាញ់បោកមេខ្យល់ ដែលតែងតែបញ្ចុះបញ្ចូលនាំឆ្លងដែនខុសច្បាប់ ដោយមិនគិតពីសុខ សុវត្ថិភាព និងខាតបង់ប្រាក់ជាបន្តបន្ទាប់ ជាពិសេសសូមបន្តចូលរួម អនុវត្តវិធានការ «៣ការពារ និង៣កុំ» ឱ្យបានទាំងអស់គ្នា ដើម្បីគ្រួសារ និងសង្គមជាតិចៀសផុតពីជំងឺកូវីដ១៩៕

## ជនជាតិថៃ១១នាក់លួចឆ្លងដែនចូលមកប្រទេសកម្ពុជាត្រូវកងកម្លាំង វរសេនាតូចថ្មើរជើងលេខ៥១៤ សហការជាមួយកម្លាំងចម្រុះ ឃាត់ខ្លួន

http://nokorwatnews.com/ 28/09/2021

ខេត្តបន្ទាយមានជ័យ ៖ ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២១ លោកវរសេនីយ៍ទោ ប៉ែន សុគន្ធ មេបញ្ជាការវរសេនាតូចថ្មើរជើងលេខ៥១៤ ដឹកនាំកម្លាំងសហការជាមួយកម្លាំងចម្រុះ បានឃាត់ខ្លួនជនជាតិថៃ លួចឆ្លងដែនចូលមកប្រទេសកម្ពុជា បានចំនួន១១នាក់ ក្នុងនោះស្រី៥នាក់ និងកង់បីចំនួន១គ្រឿង នៅភូមិចំការគ ឃុំស្វាយចេក ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ។ លោក មេបញ្ជាការវរសេនាតូចថ្មើរជើងលេខ៥១៤ បានបញ្ជាក់ថា កងកម្លាំងល្បាតជាប់ជាប្រចាំ ២៤ម៉ោងលើ២៤ម៉ោង ដោយប្តូរវេនគ្នា សហការជាមួយកម្លាំងចម្រុះ ដើម្បីទប់ស្កាត់ពលករលួចឆ្លងដែនខុសច្បាប់ និងទប់ស្កាត់ការឆ្លងរាលដាល នៃជំងឺកូវីដ-១៩ មិនឲ្យចូលទៅក្នុងសហគមន៍។

ជាក់ស្តែង ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២១ ខណៈលោក វរសេនីយ៍ទោ ប៉ែន សុគន្ធ បានដឹកនាំកម្លាំងដើរល្បាតក៏ ជួបពលករថៃ បានលួចឆ្លងដែនចូលប្រទេសកម្ពុជា ត្រូវបានកម្លាំង វរសេនាតូចថ្មើរជើងលេខ៥១៤ កងពលតូចថ្មើរជើងលេខ៥១ ឃាត់ខ្លួនបានតែម្តង ។ លោកបន្តថា អនុវត្តតាមបទបញ្ជាថ្នាក់លើកម្លាំងគ្រប់គោលដៅបានល្បាតត្រួតពិនិត្យ២៤ម៉ោងលើ២៤ម៉ោង មិនឲ្យធ្វេសប្រហែសឡើយព្រោះខណៈពេលប្រទេសថៃនៅតែបន្តរកឃើញអ្នកឆ្លងកូវីដ-១៩ ជាបន្តបន្ទាប់៕

## ពលករខ្មែរ ៨នាក់ លួចឆ្លងដែនខុសច្បាប់ចូលទៅប្រទេសថៃ ត្រូវបានឃាត់ខ្លួន

https://dap-news.com/ BySKK106 Posted on September 29, 2021

**បន្ទាយមានជ័យ៖** ពលករខ្មែរចំនួន៨នាក់ បម្រុងនិងលួចឆ្លងដែនខុសច្បាប់ចូលទៅប្រទេសថៃ ត្រូវបានកម្លាំងវរសេនាតូចថ្មើរជើងលេខ៥១៣ សហការជាមួយកម្លាំងប៉ូលិស ៨១៥ ធ្វើការឃាត់ខ្លួន។ នៅយប់ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២១ លោកវរសេនីយ៍ទោ យូ សុគន្ធកក្តី មេបញ្ជាការ វរសេនាតូចថ្មើរជើងលេខ ៥១៣ បានចាត់តាំងកម្លាំងនៅជួរមុខតាមខ្សែបន្ទាត់ព្រំដែនខ្មែរ-ថៃ នៅទិសម៉ាឡៃ (ស្រុកម៉ាឡៃ) សហការជាមួយកម្លាំងប៉ូលិសព្រំដែន ៨១៥ និង កម្លាំងនៅតាមមូលដ្ឋាន ចេញល្បាតត្រួតពិនិត្យតាមព្រំដែនចាប់ពី ភូមិសន្តិភាព ឃុំទួលពង្រ ដល់ភូមិចំបក់ ឃុំបឹងបេង ក៏បានប្រទះឃើញ ហើយធ្វើការឃាត់ខ្លួនពលករខ្មែរបានចំនួន ៨នាក់ ស្រីចំនួន ៣នាក់ ប្រុសចំនួន ៥នាក់ នៅត្រង់ចំណុចភូមិបន្ទាយ២ ឃុំអូរសំព័រ ស្រុកម៉ាឡៃ ដែលបម្រុងនិងឆ្លងអូរលួចចូលទៅប្រទេសថៃ ក៏ត្រូវបានកម្លាំងសហការយើងធ្វើការឃាត់ខ្លួនរួចសាកសួរនាំ និង បានប្រគល់ជូនប៉ូលិសព្រំដែន៨១៥ ដើម្បីអនុវត្តទៅតាមច្បាប់។

សូមបញ្ជាក់ថា ដើម្បីចូលរួមចំណែកជាមួយរាជរដ្ឋាភិបាល ក្នុងការទប់ស្កាត់ការរីរាលដាលនៃជំងឺកូវីត១៩ កុំអោយឆ្លងចូលជាសហគមន៍ កម្លាំងវរសេនាតូចថ្មើរជើងលេខ៥១៣ តែងតែយកចិត្តទុកដាក់អនុវត្តតាមបទបញ្ជាថ្នាក់លើទាំង ៣ទិសក្នុងខេត្តបន្ទាយមានជ័យ ចាប់ពីទិសអូរនាង ប៉ោយប៉ែត និង ទិសម៉ាឡៃ សហការជាមួយកម្លាំងនៅតាមមូលដ្ឋានចេញល្បាតឆែកឆេរត្រួតពិនិត្យជាប្រចាំក្នុងការទប់ស្កាត់ពលករឆ្លងដែនខុសច្បាប់។

## សមត្ថកិច្ចណែនាំដល់ពលករខ្មែរ-ថៃចំនួន ៣៧នាក់ ឈប់ចាញ់បោកមេខ្យល់ទៀតទៅ ខណៈលួចឆ្លងដែនខុសច្បាប់

https://cen.com.kh/ Posted ByPen Srey NeatSeptember 29, 2021

បន្ទាយមានជ័យ ៖ ពលករខ្មែរ-ថៃ ចំនួន ៣៧នាក់ ដែលប៉ុនប៉ងលួចឆ្លងដែនខុសច្បាប់ ត្រូវបានសមត្ថកិច្ចឃាត់ខ្លួននៅវេលាម៉ោង ១និង៤០នាទី រំលងអាធ្រាត្រ ឈានថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២១ ស្ថិតក្នុងភូមិព្រៃចាន់ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ។ ពលករខ្មែរ-ថៃចំនួន ៣៧នាក់នេះ ក្នុងនោះ មានពលករខ្មែរ ២៦នាក់ និងពលករថៃ ១១នាក់, ពួកគេបម្រុងលួចឆ្លងដែនខុសច្បាប់ពីប្រទេសថៃ ចូលមកទឹកដីកម្ពុជាខុសច្បាប់។ ក្រោយឃាត់ខ្លួន សមត្ថកិច្ចបានបញ្ជូនទៅឱ្យ ក្រុមការងារចម្រុះច្រកអូរបីជាន់ ចាត់ការការតាមនីតិវិធី, ហើយសមត្ថកិច្ចបានណែនាំថា លើកក្រោយៗទៀត សូមកុំឱ្យបន្តចាញ់បោកមេខ្យល់ ព្រោះការលួចឆ្លងដែនបែបនេះ ជាទង្វើខុសច្បាប់ ប៉ះពាល់ដល់សេចក្តីសុខរបស់បងប្អូន និងខាតបង់ប្រាក់កាសជាបន្តបន្ទាប់។

លោកឧត្តមសេនីយ៍ត្រី យួន ជឿន មេបញ្ជាការវរការពារព្រំដែនលេខ៥០៣ ដែលបញ្ជាផ្ទាល់លើការងារល្បាតពួនស្ទាក់នេះបានឲ្យដឹងថា ប្រតិបត្តិការឃាត់ខ្លួនពលករខ្មែរ-ថៃទាំង ៣៧នាក់នេះ ធ្វើឡើងដោយកម្លាំងសហការរួមមាន កម្លាំងកងការពារព្រំដែនលេខ៥០៣ , កងពលតូចថ្មើរជើងលេខ៥១ និងនគរបាលព្រំដែនគោកលេខ៩១១៕ រក្សាសិទ្ធិដោយ ៖ ពិសិដ្ឋ CEN

# កម្ពុជា-ចិន បន្តទប់ស្កាត់បទល្មើសឆ្លងដែនគ្រប់ប្រភេទ ជាពិសេស ឧក្រិដ្ឋកម្ម និងល្បែងស៊ីសងអនឡាញ

https://dap-news.com/ BySKK106 Posted on September 29, 2021

**ភ្នំពេញ ៖** សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងលោក ចាវ យើជឺ សមាជិកក្រុមប្រឹក្សារដ្ឋ និងជារដ្ឋក្រសួងសន្តិសុខសាធារណៈ នៃសាធារណរដ្ឋប្រជាមានិតចិនរួមគ្នាបន្តទប់ស្កាត់បទល្មើសឆ្លងដែនគ្រប់ប្រភេទ ជាពិសេស ឧក្រិដ្ឋកម្មមានអង្គការចាត់តាំង ល្បែងស៊ីសងអនឡាញ អំពើឆបោកតាមប្រព័ន្ធទូរគមនាគមន៍ និងការជួញដូរគ្រឿងញៀនខុសច្បាប់ ជាដើម។

យោងតាមសេចក្តីប្រកាសព័ត៌មានរបស់ ក្រសួងមហាផ្ទៃ នាថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២១ បានឲ្យដឹងថា ដោយមើលឃើញពីសារៈសំខាន់ នៃកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់រវាងប្រទេសទាំងពីរ សម្តេច ស ខេង និងលោក ចាវ យើជឺ បានចុះហត្ថលេខាលើ ផែនការការងារ ស្តីពីការបន្តអនុវត្តឆ្នាំ នៃកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់ ដើម្បីបន្តពង្រឹង និងពង្រីកទំនាក់ទំនង និងកិច្ចសហការកាន់តែសកម្ម សំដៅសម្រេចបានសមិទ្ធផលថ្មីៗបន្ថែមទៀត បម្រើដល់ការអភិវឌ្ឍសង្គមជាតិ និងផលប្រយោជន៍ទៅវិញ ទៅមករបស់ប្រជាជននៃប្រទេសទាំងពីរ ។ ក្នុងនោះបានឯកភាពបន្តផ្តោតការយកចិត្តទុកដាក់លើការងារមួយចំនួន ៖

ទី១-បន្តពង្រឹងកិច្ចសហប្រតិបត្តិការទប់ស្កាត់បទល្មើសឆ្លងដែនគ្រប់ប្រភេទ ជាពិសេស ឧក្រិដ្ឋកម្ម មានអង្គការចាត់តាំងល្បែងស៊ីសងអនឡាញខុសច្បាប់ អំពើឆបោកតាមប្រព័ន្ធទូរគមនាគមន៍ និងការជួញដូរគ្រឿងញៀនខុសច្បាប់។ និងទី២-បន្តកិច្ចសហការជិតស្និទ្ធ និងគាំទ្រគ្នាទៅវិញទៅមក ដើម្បីបម្រើឲ្យការប្រារព្ធនូវព្រឹត្តិការណ៍ជាតិ និងអន្តរជាតិធំៗ ឲ្យប្រព្រឹត្តទៅដោយជោគជ័យតាមការគ្រោងទុក ក្នុងនោះរួមមាន ការទទួល តួនាទីជាប្រធានអាស៊ានឆ្នាំ២០២២ ការប្រកួតកីឡារដូវរងា ទីក្រុងប៉េកាំងឆ្នាំ២០២២ និងការរៀបចំព្រឹត្តិការណ៍កីឡា SEA Games លើកទី៣២ ឆ្នាំ២០២៣ ព្រមទាំងព្រឹត្តិការណ៍សំខាន់ៗ ដទៃទៀត ដែលប្រារព្ធធ្វើនៅកម្ពុជា និងចិន៕

# ស្គាល់ផ្ទះមេខ្យល់នៅតែចាប់អត់បាន បានតែពលករប្រុងលួចឆ្លងទៅថៃ

https://kohsantepheapdaily.com.kh/ បន្ទាយមានជ័យ២៩ ខែ កញ្ញា ឆ្នាំ ២០២១ ម៉ោង ១៣:៥៨

ខេត្តបន្ទាយមានជ័យ ៖ ប្រភពព័ត៌មានពីបន្ទាត់ព្រំដែនបានឲ្យដឹងថា កាលពីម៉ោងជិត៥ល្ងាច ថ្ងៃទី២៨ កញ្ញា ២០២១ កម្លាំងចម្រុះជួរមុខដែលឈរជើងនៅក្នុងភូមិសាស្រ្តឃុំ និងស្រុកស្វាយចេក និងស្រុកអូរជ្រៅ បានធ្វើការទប់ស្កាត់ឃាត់ពលករប្រុងលួចឆ្លងដែនទៅប្រទេសថៃចំនួន១៥នាក់ មានប្រុស៨នាក់ និងស្រី៧នាក់ ។ កម្លាំងជួរមុខរួមមាន យោធាកងពល៥១, យោធាការពារព្រំដែនលេខ៥០៣, នគរបាលការពារព្រំដែនគោកលេខ៩១១ និងមានកម្លាំងអាវុធហត្ថផងដែរ ។ ប្រភពបន្តថា ពលករ៤នាក់ត្រូវបានកម្លាំងល្បាត២ នៃយោធាការពារព្រំដែនលេខ៥០៣ ឃាត់ក្នុងភូមិព្រៃចាន់ ឃុំអូរបីជាន់ស្រុកអូរជ្រៅ ។ ចំណែកពលករ១១នាក់ទៀតឃាត់បានក្នុងដីឡូត៍របស់មេខ្យល់ក្នុងភូមិចំកាគរ ឃុំនិងស្រុកស្វាយចេក។ យ៉ាងណាក៏ដោយ ករណីនេះ មេខ្យល់ប្រហែលជាដឹងខ្លួនមុនបានគេចខ្លួនបាត់ស្រមោល ។ បច្ចុប្បន្ន ពលករទាំងអស់ ត្រូវបានដឹកតាមរថយន្តយោធាយកទៅប្រគល់ឲ្យគណៈកម្មការទទួលពលកររិលត្រឡប់ពីថៃនៅច្រករបៀងអូរបីជាន់ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ដើម្បីអនុវត្តន៍តាមវិធានការរបស់ក្រសួងសុខាភិបាល ៕

## កងកម្លាំង វរសេនាតូចថ្មើរជើងលេខ៥១៤ សហការជាមួយកម្លាំងចម្រុះ ឃាត់ខ្លួនពលករខ្មែរ ១១នាក់បម្រុងឆ្លងដែនចូលប្រទេសថៃ

https://cen.com.kh/ Posted ByPen Srey NeatSeptember 29, 2021

បន្ទាយមានជ័យ ៖ នៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២១ លោកវរសេនីយ៍ទោ ប៉ែន សុគន្ធ មេបញ្ជាការ វរសេនាតូចថ្មើរជើងលេខ៥១៤ ដឹកនាំកម្លាំងសហការជាមួយកម្លាំងចម្រុះ បានឃាត់ខ្លួនពលករខ្មែរបម្រុងឆ្លងដែនចូលប្រទេសថៃ បានចំនួន១១នាក់ ក្នុងនោះស្រី៥នាក់ និងកង់បីចំនួន១គ្រឿង នៅភូមិចំការគ ឃុំស្វាយចេក ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ។ លោក មេបញ្ជាការ វរសេនាតូចថ្មើរជើងលេខ៥១៤ បានបញ្ជាក់ថាកងកម្លាំងល្បាតជាប់ជាប្រចាំ ២៤ម៉ោងលើ២៤ម៉ោង ដោយប្តូរវេនគ្នា សហការជាមួយកម្លាំងចម្រុះ ដើម្បីទប់ស្កាត់ពលករលួចឆ្លងដែនខុសច្បាប់ និងទប់ស្កាត់ការឆ្លងរាលដាល នៃជំងឺកូវីដ-១៩ មិនឲ្យចូលទៅក្នុងសហគមន៍។ ជាក់ស្តែង ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២១ ខណៈលោក វរសេនីយ៍ទោ ប៉ែន សុគន្ធ បានដឹកនាំកម្លាំងដើរល្បាត បានជួបពលករខ្មែរបំរុងឆ្លងដែនចូលប្រទេសថៃ ត្រូវបានកម្លាំង វរសេនាតូចថ្មើរជើងលេខ៥១៤ កងពលតូចថ្មើរជើងលេខ៥១ ឃាត់ខ្លួនបានតែម្តង ។ លោកបន្តថា អនុវត្តតាមបទបញ្ជាថ្នាក់លើកម្លាំងគ្រប់គោលដៅ បានល្បាតត្រួតពិនិត្យ២៤ម៉ោងលើ២៤ម៉ោង មិនឲ្យធ្វេសប្រហែសឡើយ ព្រោះខណៈពេលប្រទេសថៃនៅតែបន្តរកឃើញអ្នកឆ្លងកូវីដ-១៩ ជាបន្តបន្ទាប់៕ រក្សាសិទ្ធិដោយ ៖ បញ្ញាស័ក្តិ

## ក្រសួងការងារថៃទុកឱសានវាទ ឱ្យនិយោជកចុះឈ្មោះពលករចំណាកស្រុកពីកម្ពុជានិងប្រទេសជិតខាង ដើម្បីឱ្យពួកគេធ្វើការដោយស្របច្បាប់

https://www.propertyarea.asia/ September 29, 2021 **ដោយៈសុខុម**

**បាងកក:** ក្រសួងការងារថៃ បានទុកឱសានវាទរយៈពេល៣០ថ្ងៃ ឱ្យនិយោជកចុះឈ្មោះពលករចំណាកស្រុករួមទាំងទៅពីកម្ពុជា ដែលគ្មានលិខិតស្នាមត្រឹមត្រូវ ដើម្បីឱ្យពួកគេធ្វើការនៅក្នុងប្រទេសថៃ ដោយស្របច្បាប់។ នេះបើយោងតាមកាសែត Bangkok Post ចុះផ្សាយនៅថ្ងៃពុធ ទី២៩ កញ្ញា នេះ។

លោក Suchart Chomklin រដ្ឋមន្ត្រីក្រសួងការងារថៃ បានប្រកាសឱសានវាទនេះកាលពីថ្ងៃអង្គារ ទី២៨ កញ្ញា បន្ទាប់ពីគណៈរដ្ឋមន្ត្រីបានយល់ព្រម តាមសំណើរបស់ក្រសួង ដើម្បីគ្រប់គ្រងលើពលករចំណាកស្រុកដែលទៅពីប្រទេសចំនួន៣ រួមមានមីយ៉ាន់ម៉ា ឡាវ និងកម្ពុជា ក្នុងគោលបំណងគ្រប់គ្រង និងទប់ស្កាត់ការរីករាលវីរុសកូវីដ-១៩។ លោករដ្ឋមន្ត្រីបានគូសបញ្ជាក់ថា នាយកដ្ឋានការងារត្រូវបានណែនាំ ឱ្យចុះត្រួតពិនិត្យដោយផ្ទាល់នៅតាមការដ្ឋានសំណង់ រោងចក្រ និងកន្លែងធ្វើការផ្សេងទៀត ដើម្បីផ្តល់ការណែនាំ អំពីការថែរក្សាសុខភាពដល់និយោជក និងពលករចំណាកស្រុករយៈពេល៣០ថ្ងៃ។ អំឡុងពេលនេះ ពលករចំណាកស្រុកខុសច្បាប់ នឹងត្រូវចុះឈ្មោះធ្វើលិខិតស្នាមត្រឹមត្រូវ ហើយនិយោជករបស់ពួកគេ ត្រូវដាក់ពាក្យស្នើសុំលិខិតការងារ រួមជាមួយឯកសារពាក់ព័ន្ធផ្សេងៗទៀតពីមន្ទីរការងារខេត្ត ឬការិយាល័យនានាក្នុងក្រុងបាងកក។

ពាក្យស្នើសុំធ្វើលិខិតការងារមានតម្លៃត្រឹមតែ១០០បាត (៣ដុល្លារ) ប៉ុណ្ណោះ។ បន្ទាប់មក និយោជកនឹងទទួលបានឯកសារមួយ ជួសមុខឱ្យពលករចំណាកស្រុក ដែលអាចប្រើប្រាស់បានជាបណ្តោះអាសន្ន ទម្រាំពួកគេទទួលបានលិខិតការងារ ដែលនឹងមានសុពលភាពរហូតដល់ថ្ងៃទី១៣ កុម្ភៈ ឆ្នាំ២០២៣។ លោកបានបន្ថែមទៀតថា គណៈរដ្ឋមន្ត្រីថៃ ក៏បានពិចារណាពន្យាឱសានវាទនេះសម្រាប់ពលករចំណាកស្រុក ដែលកំពុងត្រូវបានដំណើរការតាមសេចក្តីសម្រេចរបស់គណៈរដ្ឋមន្ត្រី ដែលមានរយៈពេលចាប់ពីថ្ងៃទី២៩ ធ្នូ ដល់ថ្ងៃទី៣១ មីនា ឆ្នាំក្រោយផងដែរ ដោយសារតែសេវាកម្មមួយចំនួន ត្រូវបានផ្អាកដោយសារស្ថានភាពវីរុសកូវីដ-១៩។ សេចក្តីសម្រេចនេះ

អនុញ្ញាតឱ្យនិយោជកដាក់ពាក្យស្នើសុំលិខិតការងារ ជួសមុខឱ្យពលករចំណាកស្រុកតាមប្រព័ន្ធអនឡាញ។ ប្រសិនបើថ្ងៃធ្វើលិខិតការងារត្រូវបានបង់រួចមុនថ្ងៃទី១៣ ខែកញ្ញា នាយកដ្ឋានការងារនឹងចេញលិខិតការងារ ដែលអាចប្រើបានរហូតដល់ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៣។

លោក Pairoj Chotikasathien អគ្គនាយកនៃអគ្គនាយកដ្ឋានការងារបានថ្លែងថា ពលករចំណាកស្រុកដែលទទួលបានលិខិតការងារ ត្រូវចុះឈ្មោះទិញធានារ៉ាប់រងសុខភាពពីក្រសួងសុខាភិបាល ឬក្រុមហ៊ុនធានារ៉ាប់រងនានា ខណៈពេលរង់ចាំទទួលយកអត្ថប្រយោជន៍នានាពីបេឡាជាតិសន្តិសុខសង្គម៕ Bangkok Post៕

## ក្រសួងមហាផ្ទៃ ចេញសេចក្តីប្រកាសព័ត៌មាន ស្តីពីលទ្ធផលនៃកិច្ចប្រជុំ និងចុះហត្ថលេខាលើផែនការការងារ ស្តីពីការបន្តអនុវត្តឆ្នាំ នៃកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់ រវាងក្រសួងមហាផ្ទៃកម្ពុជា និងក្រសួងសន្តិសុខសាធារណៈចិន

http://cambodiapolice.com/policekh/ 12:20 pm 29 កញ្ញា 2021

**រាជធានីភ្នំពេញ ៖** ដោយបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអញ្ជើញជាសហប្រធានដឹកនាំកិច្ចប្រជុំ និងចុះហត្ថលេខាលើ ផែនការការងារស្តីពីការបន្តអនុវត្តឆ្នាំនៃកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់ ជាមួយ ឯកឧត្តម ចាវ ឃើជី សមាជិកក្រុមប្រឹក្សារដ្ឋ និងជារដ្ឋមន្ត្រីក្រសួងសន្តិសុខសាធារណៈ នៃសាធារណរដ្ឋប្រជាមានិតចិន នាល្ងាចថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២១ តាមប្រព័ន្ធវីដេអូសន្និសីទ។

សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង ឯកឧត្តម ចាវ ឃើជី សមាជិកក្រុមប្រឹក្សារដ្ឋ និងជារដ្ឋមន្ត្រីក្រសួងសន្តិសុខសាធារណៈ បានសម្តែងការអបអរសាទរយ៉ាងក្រៃលែង ចំពោះទំនាក់ទំនងដ៏ល្អ រវាងថ្នាក់ដឹកនាំកំពូលនៃប្រទេសទាំងពីរ និងកិច្ចសហប្រតិបត្តិការជិតស្និទ្ធលើគ្រប់វិស័យក្នុងភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ ដែលបានរួមចំណែកនាំមកនូវវឌ្ឍនភាព និងការអភិវឌ្ឍរីកចម្រើនសម្រាប់ព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិន។

ក្នុងនេះផងដែរ សម្តេចក្រឡាហោម ស ខេង និងឯកឧត្តម ចាវ ឃើជី ក៏បានថ្លែងនូវការកោតសរសើរទៅវិញទៅមក ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់កង កម្លាំងអនុវត្តច្បាប់នៃភាគីទាំងពីរ ក្នុងការថែរក្សាបានយ៉ាងរឹងមាំនូវសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និង សុវត្ថិភាពសង្គម ទោះបីស្ថិតក្នុងស្ថានភាពប្រឈមដ៏ស្មុគស្មាញ ដែលបង្កឡើងដោយជំងឺកូវីដ-១៩។ ក្នុងក្របខណ្ឌនៃកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់ ភាគីទាំងពីរក៏បានកត់សម្គាល់នូវលទ្ធផល និង សមិទ្ធផលសំខាន់ៗ នារយៈពេលជាង២ឆ្នាំកន្លងមក បន្ទាប់ពីការចាប់ផ្តើមដំណើរការអនុវត្តឆ្នាំនៃកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់ រវាងក្រសួងទាំងពីរ កាលពីខែមីនា ឆ្នាំ២០១៩ ក្រោមគំនិតផ្តួចផ្តើមដ៏ឧត្តុង្គឧត្តមរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង ឯកឧត្តម ស៊ី ជីនពីង ប្រធានាធិបតី នៃសាធារណរដ្ឋប្រជាមានិតចិន។

ទន្ទឹមនេះ សម្តេចក្រឡាហោម ស ខេង និងឯកឧត្តម ចាវ ឃើជី ក៏បានចែករំលែក និងផ្លាស់ប្តូរទៅវិញទៅមក នូវសភាពការណ៍សន្តិសុខទូទៅ ព្រមទាំងបានកត់សម្គាល់នូវវឌ្ឍនភាព នៃកិច្ចប្រតិបត្តិការប្រកបដោយផ្លែផ្កា ការជួយគាំទ្រគ្នាទៅវិញទៅមកក្នុងការប្រយុទ្ធប្រឆាំងការរាតត្បាតនៃជំងឺកូវីដ-១៩ ការជួយឧបត្ថម្ភគាំទ្រផ្នែកសម្ភារបច្ចេកទេសការងារកសាងសមត្ថភាព ការផ្លាស់ប្តូរទស្សនកិច្ចប្រតិភូជំនាញ ជាពិសេសកិច្ចសហការទប់ស្កាត់ និងបង្ក្រាបបទល្មើសឆ្លងដែនគ្រប់ប្រភេទ។

ដោយមើលឃើញនូវសារៈសំខាន់ នៃកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់ រវាងប្រទេសទាំងពីរ សម្តេចក្រឡាហោម ស ខេង និងឯកឧត្តម ចាវ យើជឺ បានចុះហត្ថលេខាលើ **ផែនការការងារ ស្តីពីការបន្តអនុវត្តឆ្នាំ នៃកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់** ដើម្បីបន្តពង្រឹង និងពង្រីកទំនាក់ទំនង និងកិច្ចសហការកាន់តែសកម្មសំដៅសម្រេចបានសមិទ្ធផលថ្មីៗបន្ថែមទៀត បម្រើដល់ការអភិវឌ្ឍសង្គមជាតិ និងផលប្រយោជន៍ទៅវិញទៅមករបស់ប្រជាជននៃប្រទេសទាំងពីរ ដោយក្នុងនោះបានឯកភាពបន្តផ្តោតការយកចិត្តទុកដាក់លើការងារមួយចំនួន រួមមាន៖

-បន្តពង្រឹងកិច្ចសហប្រតិបត្តិការទប់ស្កាត់បទល្មើសឆ្លងដែនគ្រប់ប្រភេទ ជាពិសេសឧក្រិដ្ឋកម្មមានអង្គការចាត់តាំង ល្បែងស៊ីសងអនឡាញខុសច្បាប់ អពើធបោកតាមប្រព័ន្ធទូរគមនាគមន៍ និងការជួញដូរគ្រឿងញៀនខុសច្បាប់។

-បន្តកិច្ចសហការជិតស្និទ្ធ និងគាំទ្រគ្នាទៅវិញទៅមក ដើម្បីបម្រើឲ្យការប្រារព្ធនូវព្រឹត្តការណ៍ជាតិ និងអន្តរជាតិធំៗ ឲ្យប្រព្រឹត្តទៅដោយជោគជ័យតាមការគ្រោងទុក ក្នុងនោះរួមមាន ការទទួលតួនាទីជាប្រធានអាស៊ាន ឆ្នាំ ២០២២ ការប្រកួតកីឡារដូវរងារ ទីក្រុងប៉េកាំង ឆ្នាំ២០២២ និងការរៀបចំព្រឹត្តការណ៍កីឡា SEA Game ឆ្នាំ ២០២៣ ព្រមទាំងព្រឹត្តការណ៍សំខាន់ៗដទៃទៀត ដែលប្រារព្ធធ្វើនៅព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិន៕